# ជីវិតកថា



រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **ម៉ិញ សាវ៉ាន**

ព.ស. ២៥៥៤ - គ.ស.២០១០

**សម្រាប់ជាធម្មទាន**

# ជីវិតកថា

រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ

**ម៉ិញ សាវ៉ាន**

និង

វាយពុម្ពអក្សរដោយ

**វ៉ាត ភិរក្ស**

**ព.ស. ២៥៥៤ - គ.ស. ២០១០**

**ក្រុង ម៉ុងរេអាល**

**ខេត្ត កេបិក**

**កាណាដា**

## សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**

២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប ( ធំ, មធ្យម, តូច )

៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )

៤. ប្រជុំនានាធម៌សង្ខេគ ( ជ័យ ម៉ែ )

៥. អានាបានស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )

៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, សាន សុជា )

៧. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )

៨. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )

៩. រឿង នគរកាយ ( ចាប ពិន )

១០. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )

១១. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )

១២. ត្រៃកូដធម៌ ( សុង ស៊ីវ )



**ចិរំ តិដ្ឋតុ សទ្ធម្មោ**

**សូមព្រះសទ្ធម្មឋិតនៅអស់កាលយូរអង្វែង**

# មាតិកាធម៌


១. ពាក្យប្រារព្ធ..........................................................ទំព័រ

២. ជីវិតកថា...............................................................១៣

៣. សត្វលោកស្រឡាញ់ជីវិតខ្លួន......................................២១

៤. តម្លៃជីវិត..................................................................២៩

៥. ធម្មៈ និង វិទ្យាសាស្ត្រ...............................................៣៥

៦. លោកវិទូ..................................................................៤៦

៧. ជីវិតនេះតិចណាស់....................................................៥៣

៨. សត្វលោកវង្វេងនឹងជីវិត............................................៧០

៩. អន្លង់បួនប្រការ.........................................................៧៥

- រឿង ឯកបុត្តគហបតី...............................................៨១
- ទុក្ខ ១២ កង..........................................................៩៣
- កំណើតបួនយ៉ាង......................................................៩៤
- វណ្ណៈបួនយ៉ាង.....................................................១០០

១០. ការស្រឡាញ់ខ្លួនត្រូវធ្វើដូចម្តេច..............................១៣២

១១. ខ្លួនជាទីពឹងរបស់ខ្លួន...........................................១៣៥

១២. គុណធម៌បួនប្រការ..................................................១៣៨

- រឿង នាងថូនទាសី.................................................១៦០

១៣. សេចក្តីបញ្ចាក់.......................................................១៨៥

- តេមិយជាតក.........................................................១៩៥

១៤. សមាសភាពចូលរួម..............................................២១៤
១៥. ឯកសារពិគ្រោះ..................................................២១៥
១៦. នាមពុទ្ធបរិស័ទមានសទ្ធា......................................២១៦



# ពាក្យប្រារព្ធ

អត្តភាព គឺរូបរាងកាយរបស់សត្វទាំងឡាយ រមែងពុកផុយបែកធ្លាយ រលត់រលាយសូន្យសោះអស់ទៅ ឥតមានអ្វីសល់នៅសូម្បីតែបន្តិចបន្តួចឡើយ ។ ជីវិតមានមកក្នុងមួយជាតិៗ សុទ្ធតែជីវិតធន់ទ្រាំតស៊ូ សេចក្តីសុខសប្បាយលាយឡំ ផ្សំដោយសេចក្តីទុក្ខ ធ្វើឲ្យសត្វលោកមានការធន់ទ្រាំតស៊ូនឹងកម្លាច កំឡៅគម្លាន កង្វះខាត ចំណង់ ចំណូលគ្រប់បែបយ៉ាង ។

ការសាងកម្មទាំងឡាយ មានទាំងកម្មអាក្រក់និងកម្មល្អ គ្រាន់តែកំដរជីវិត ដែលកើតឡើងប្រាកដ និងរលត់ទៅវិញគ្រប់ខណៈប៉ុណ្ណោះ ។ នៅពេលជីវិតរលត់ រាងកាយក៏ត្រូវបែកធ្លាយខ្ចាត់ខ្ចាយទៅ បន្សល់នៅបានត្រឹមតែផលនៃអំពើអាក្រក់ និងល្អជាសំណាមគំនូស និងជាបច្ច័យសម្រាប់ជីវិតបុគ្គលម្នាក់ៗ ។ អំពើអាក្រក់ និងអំពើល្អទាំងឡាយ តាមទ្វារកាយវាចាចិត្ត តាមសេចក្តីពិតគេមិនពិបាកយល់នោះទេ ព្រោះថាក្នុងលោកនេះអ្វីក៏ដោយ ឲ្យតែឈ្មោះថា **អាក្រក់** ហើយ ទាំងមនុស្សទាំងសត្វប្រាកដជាមិនពេញចិត្តឡើយ សូម្បីតែអ្នកធ្វើអាក្រក់ដោយខ្លួនឯងហើយ បានទទួលផលជាទុក្ខទោសក្តី ឬជាអ្នកកំពុងតែមានជោគជ័យក្នុងអំពើអាក្រក់នោះ ដោយសេចក្តីសប្បាយរីករាយ និងទង្វើអាក្រក់នោះ ៗក្តី បើមានអ្នកដទៃគេមកថាស្តី តិះដៀលអំពីអំពើ

អាក្រក់នោះ ថាជាអំពើលាមកគួរឲ្យខ្ពើមរអើមណាស់ ដូច្នេះអ្នកដែលធ្វើអំពើអាក្រក់ទាំងឡាយ ក៏គង់មិនសប្បាយចិត្តទេ ។

អំពើល្អ **គុណធម៌** ជាគុណជាតិ ដែលមនុស្សសត្វស្រឡាញ់ត្រូវការ ពេញចិត្តព្រោះដ្បិតជាផលផ្តល់មកនូវសេចក្តីសុខ សេចក្តីត្រេកអររីករាយសប្បាយ សូម្បីតែពួកជនទាំងឡាយក៏រមែងពោលសរសើរដែរ ។

ក្នុងពេលធ្វើបុណ្យឈាបនកិច្ចម្តងៗ សូម្បីតែគ្រួសារសពមានសេចក្តីទុក្ខសោកសៅ ដែលកើតមកអំពីការនិរាសព្រាត់ប្រាសចាកគ្នាក៏ដោយ ក៏គេនាំគ្នាសូត្រជីវប្រវត្តិរបស់អ្នកស្លាប់ រៀបរាប់អំពីសេចក្តីល្អយ៉ាងនេះយ៉ាងនោះ ខុសអំពីសេចក្តីអាក្រក់ដែលគេមិនដែលលើកយកមកពោលថ្លែងសម្តែងទេ ព្រោះជាអំពើដែលគេមិនចូលចិត្តស្តាប់ ។

ដូច្នេះកាលបើជីវិតរស់នៅ ត្រូវព្យាយាមអប់រំសិក្សា ឲ្យយល់ស្គាល់ចូលចិត្តទៅតាមសេចក្តីពិត អំពីអំពើអាក្រក់និងអំពើល្អ ។ ព្យាយាមលះបង់អំពើអាក្រក់ ព្រោះផលនៃសេចក្តីអាក្រក់នាំមកនូវទុក្ខទោសទាំងពួងដល់ខ្លួនផង និងមិនជាទីពេញចិត្តនៃអ្នកដទៃផង ។ ត្រូវព្យាយាមខំសន្សំ **សេចក្តីល្អ , គុណធម៌** ដើម្បីជាបច្ច័យនាំមកនូវសេចក្តីសុខ សម្រាប់ជីវិតក្នុងបច្ចុប្បន្នផង និងសម្រាប់ជីវិតក្នុអនាគតជាតិផង ។

**សេចក្តីល្អ គុណធម៌** ដែលគេបានព្យាយាមបំពេញធ្វើហើយ តែងនាំមកនូវសេចក្តីសុខក្សេមក្សាន្តសម្រាន្តចិត្ត សម្រាប់ខ្លួនឯងផង និងអ្នកដទៃទៀតផង ព្រោះ **សេចក្តីល្អ , គុណធម៌** គេអាចរំលែកចែកជូនគ្នាក្នុងបច្ចុប្បន្នផង និងអាចឧទ្ទិសផ្សព្វផ្សាយផលដល់អ្នកមានគុណ ព្រមទាំងញាតិមិត្តសាច់សាលោហិត សព្វសត្វទាំងឡាយ ដែលបានចែកឋានទៅកាន់បរលោកនាយបានទៀតផង ។

អាស្រ័យហេតុដូចពោលរៀបរាប់មកនេះ ទើបធ្វើឲ្យយើងខ្ញុំព្រះករុណា ខ្ញុំបាទសង្វាតខិតខំរៀបរៀងសរសេរ វាយពុម្ពអក្សរចាត់ចែងឲ្យបានជាសៀវភៅ " **ជីវិតភថា** " នេះឡើង ដើម្បីប្រគេនចែកជូនជាធម្មទាន ។

ក្នុងសៀវភៅ " **ជីវិតភថា** " នេះមានចំណុចជាច្រើនដែលខ្ញុំព្រះករុណា ខ្ញុំបាទបានដកស្រង់ចម្លងចេញពីព្រះត្រៃបិដកដើម្បីជូនលោក-អ្នកអាន ដែលមិនធ្លាប់បានអានព្រះត្រៃបិដកសោះនោះ ឲ្យបានអានគ្រាន់នឹងបានជាឧបនិស្ស័យ ក្នុងការយល់ដឹងព្រះពុទ្ធដីកា របស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ជាព្រះបរមគ្រូនៃយើង ដែលមានចែងសម្តែងទុកក្នុងព្រះត្រៃបិដកស្រាប់ និងមានពាក្យពេចន៍ដែលប្រែជាភាសាខ្មែរ ចេញមកពីពាក្យបាលីសំស្ក្រឹត មាននៅក្នុងវចនានុក្រមខ្មែរ ( ២០០៨ ) ដែលជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ និង

លោកអ្នកប្រាជ្ញ ព្រឹទ្ធាចារ្យទាំងឡាយទៀតផង ។

ដូច្នេះយើងខ្ញុំព្រះករុណា ខ្ញុំបាទសូមលំឱនកាយថ្វាយបង្គំ សូមអភ័យខន្តីទោស អំពីសំណាក់ព្រះករុណាម្ចាស់ជាលោកអ្នកប្រាជ្ញ ព្រឹទ្ធាចារ្យ និងលោក-អ្នកអានទាំងឡាយ នូវរាល់កំហុសឆ្គងដោយអក្ខរាវិរុទ្ធ បទបាថវគ្គឃ្លាបាលី សេចក្តីមិនសមរម្យត្រង់ចំណុចណាមួយ សូមព្រះករុណាម្ចាស់ព្រមទាំងលោក-អ្នកអានទាំងឡាយ មេត្តាខន្តីអភ័យទោសនូវរាល់កំហុសឆ្គងនោះ ដល់យើងខ្ញុំ ព្រះករុណា ខ្ញុំបាទ ៗ សូមក្រាបអរព្រះគុណ និងសូមអរគុណ ។

*សរសេរចប់នៅ ក្រុងម៉ុងឫស្សី ខេត្តកេបិក កាណាដា

នៅថ្ងៃ ៧ ៣ ៦ ឆ្នាំខាល ទោស័ក ព.ស.២៥៥៤[១]
ត្រូវនឹងថ្ងៃ សៅរ៍ ទី ០១ ខែ ឧសភា គ.ស.២០១០

**ម៉ិញ សាវ៉ាន**

**វ៉ាត តិរត្ន**

(១) អានថា ថ្ងៃសៅរ៍ ៣រោច ខែពិសាខ ឆ្នាំខាលទោស័ក ព.ស. ២៥៥៤

# ឧទ្ទិសកថា

ដោយអំណាចកុសលចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានផ្តល់ជាពលានុភាព ឲ្យយើងខ្ញុំព្រះករុណា ខ្ញុំបាទស្រុះស្រួលមូលមតិគ្នា បរិច្ចាគបច្ច័យតាមកម្លាំងសទ្ធា សង្វាតខិតខំរៀបចំចាត់ចែង បោះពុម្ពជាសៀវភៅនេះឡើង ដើម្បីប្រគេន ចែកជូនជាធម្មទាន ។

សូមតេជៈផលានិសង្ស ដែលកើតបានមកពីការព្យាយាមផង អាមិសទានផង និងធម្មទានផង សូមឲ្យកុសលរាសីនេះ ចូរអណ្តែតត្រសែតទៅជួយទំនុកបម្រុងដល់អ្នកមានគុណទាំងឡាយមាន ៖ មាតាបិតា, គ្រូឧបជ្ឈាយាចារ្យ , លោកអ្នកប្រាជ្ញកវី , ញាតិមិត្តសាច់សាលោហិត ព្រមទាំងសត្វទាំងឡាយ ដែលបានបែកធ្លាយរំលាយខន្ធ ទៅកាន់បរលោកហើយ សូមឲ្យបានប្រកបដោយសេចក្តីសុខចម្រើនគ្រប់ប្រការ និងសូមឲ្យមានដំណើរជីវិតប្រព្រឹត្តទៅកាន់ទីបំផុតទុក្ខ សមតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ។

និងដោយអំណាចផលានិសង្ស នៃអាមិសទាន និងធម្មទាននេះ សូមជួយឧបត្ថម្ភដល់ពួកសត្វទាំងឡាយ ក្នុងចតុឱឃាជលាលោកទាំងអស់បានទទួលឥដ្ឋមនុញ្ញផលគ្រប់ ៗ គ្នា ព្រមទាំងមានប្រាជ្ញាថ្លាគំនិត បដិបត្តិព្រះធម៌បានសម្រេចមគ្គផល ដល់ទីបំផុតទុក្ខកុំបីខានឡើយ ។

**សូមអនុមោទនា** !!!

**ម៉ិញ សាវ៉ាន**

**វ៉ាត តិរត្ន**

**សតញ្ច ធម្មោ នជរំ ឧបេតិ**

**ធម៌របស់សប្បុរសទាំងឡាយ រមែងមិនចូលដល់ជរា**

អត្តភាពនៃសព្វសត្វទាំងឡាយ
តែងតែបែកធ្លាយជាធម្មតា
រីឯគុណធម៌នោះវិញណា
ឋិតនៅគ្រប់គ្រាមិនសូន្យឡើយ ។

# ជីវិតកថា

## ការពោលរៀបរាប់ អំពីជីវិត

ពាក្យថា **ជីវិត** នេះបើគេពុំបានគិតឬប្រើគំនិត ដើម្បីស្វែងយល់ឲ្យដល់ជម្រៅអំពីអត្ថន័យនៃពាក្យនេះទេ គេហាក់ដូចជាបានយល់ស្គាល់ ដឹងពាក្យនេះប្រាកដច្បាស់ណាស់ទៅហើយ គឺគេគ្រាន់តែឲ្យន័យទៅលើពាក្យថា " **ជីវិត** " នេះគឺត្រឹមតែការរស់នៅប៉ុណ្ណោះ ឃើញជាការស្រេច ដោយមិនចាំបាច់ទៅមានចម្ងល់និងធ្វើការស្រាវជ្រាវឲ្យបានដឹងយល់ស្គាល់អ្វីទៀតនោះទេ ។

ប៉ុន្តែបើគេបានសិក្សាស្វែងយល់អំពីពាក្យថា **ជីវិត** នេះទៅតាមអត្ថន័យនិងជម្រៅ គេរឹងរឹតតែមានចម្ងល់ច្រើនណាស់ទៅទៀតអំពីពាក្យថា **ជីវិត** ព្រមទាំងបញ្ហាដែលកើតមានជុំវិញជីវិតនេះជាអនេកប្បការទាំងផ្នែក **ទស្សនៈវិជ្ជា** និង **បរមត្ថវិជ្ជា** ។

❖ **ទស្សនៈវិជ្ជា** បានដល់ការសិក្សាស្វែងយល់ទៅតាមការឃើញឬការស្រាវជ្រាវខាងផ្នែកសម្ភារៈនិយមដោយផ្អែកទៅលើចំណេះដឹងនិងក្បួនវិជ្ជាសាស្ត្រផ្សេងៗ ដូចជាការសិក្សាឲ្យបានចេះដឹងយល់ស្គាល់ អំពីលក្ខណៈនិងការប្រែប្រួលផ្លាស់ប្តូរនៃជីវិតនេះទៅតាមកាលវេលា ដូចជាការរស់នៅឬការប្រព្រឹត្តទៅព្រមនៃរូបរាងកាយរបស់សត្វទាំងឡាយ ដោយមានការដកដង្ហើមចេញ-ចូលចេះស្រែកឃ្លាន ពោលពាក្យនិយាយស្តី សើចយំ ស្រឡាញ់ ស្អប់

ចេះប្រកបកិច្ចការអ្វីផ្សេងៗទៅតាមសញ្ញាតិញ្ញាណរបស់ខ្លួន ឬគេអាចសំគាល់បានដោយចលនាឥរិយាបថទាំងបួនមានការដេក ដើរ ឈរ អង្គុយ ដែលផុយអំពីសេចក្ដីស្លាប់ ហ្នឹងហើយហៅថា **ជីវិត** ដែលយើងហៅថាជីវិតមនុស្ស ជីវិតសត្វ មានចិត្តវិញ្ញាណ មានឥរិយាបថប្រព្រឹត្តទៅនោះឯង ។

តាមទស្សនៈ ការយល់ឃើញ របស់អ្នកស្រាវជ្រាវខ្លះគេតែងសម្គាល់ថារុក្ខជាតិ តិណជាតិ វល្លិជាតិ ជលជាតិទាំងនោះសុទ្ធសឹងតែមានវិញ្ញាណ មានជីវិតទៅតាមប្រភេទតូចធំ តិចច្រើន ដោយគេបានសម្គាល់ទៅតាមលក្ខណៈចលនា ការផ្លាស់ប្ដូរទៅតាមកាលវេលានៃរុក្ខាលតាជាតិនោះៗ ។ ដូចជាចេះបឺត ស្រូបយកទឹកជីរជាតិធាតុអាកាសកម្ដៅថ្ងៃ មកចិញ្ចឹមបណ្ដុះដើមមែកធាង ស្លឹកត្រួយ ផ្លែផ្កា ឲ្យលូតលាស់ដុះដាល បែកមែកសាខាត្រសាយត្រសុំធំខ្ពស់ទៅបាន ។

រុក្ខជាតិគ្រប់ចំពូក ហាក់បីដូចជាមានជីវិតវិញ្ញាណទទួលដឹងនូវកម្ដៅធាតុអាកាសនៅពេលណាមានកម្ដៅខ្លាំង ឬធាតុអាកាសក្ដៅខុសប្រក្រតីក៏សម្រេបស្លឹកស្វិតស្រពោន វេលាមានទឹកសន្សើម ឬមានភ្លៀងបង្អុរចុះមក ក៏ខំលូតលាស់បញ្ចេញសម្រស់ព្រមទាំងស្លឹក ផ្លែ ផ្កាស្រស់បំព្រងគួរឲ្យគយគន់ពិតពិលរមិលមើល ។

មានរុក្ខាលតាជាតិប្រភេទខ្លះទៀត ដូចជាបន្លាប្រខ្លប[១]

(១) តាមគ្រាមភាសា ខ្លះហៅថា បន្លាប្រក្រាប , ប្រខ្លប ឬមខ្លប ។

ជាដើមជារុក្ខជាតិមានដើមវៀវតូចឆ្មារ ស្រដៀងនឹងវល្លិមានបន្លាខ្លីទន់ មានពណ៌ស្វាយច្រើនដុះជាគុម្ពនៅលើដីទួលឬតាមភ្លឺស្រែ រុក្ខជាតិប្រភេទនេះ នៅពេលគេដើរទៅប៉ះ ឬពាល់ត្រូវក៏មានចលនាស្លឹក ក្តោបរមូរសម្រួបចូលគ្នាភ្លាម ហាក់បីដូចជាមានជីវិតវិញ្ញាណទទួល ដឹងសម្ផស្សដូច្នោះដែរ ។

មានរុក្ខជាតិច្រើនប្រភេទទៀត នៅពេលព្រលប់មានស្លឹកក្តោបសម្រួបចូលគ្នា ហាក់បីដូចជាត្រូវការសម្រាកសម្រាន្តក្នុងរាត្រីកាលដែរ ។ ឯរុក្ខាលតាជាតិខ្លះទៀតខំលូតលាស់បោះទងបញ្ចេញត្រួយថ្ពក់តោងវារឡើងទ្រើង ។

តាមទស្សនីយភាពដូចពោលរៀបរាប់មកនេះ ទើបធ្វើឲ្យលោក-អ្នកស្រាវជ្រាវខ្លះ បានពោលអាងសម្តែងបញ្ជាក់អំពីវិញ្ញាណជីវិតនិងការវិវដ្តន៍នៃជីវិតវិញ្ញាណទៅតាមកាលវេលា ។

ពួកគេបានពោលអះអាងថា រុក្ខាលតាជាតិគ្រប់ប្រភេទសុទ្ធសឹងតែមានជីវិតវិញ្ញាណ ប៉ុន្តែវិញ្ញាណ គឺការដឹងនោះជាវិញ្ញាណតូចល្អិត កើតមានតិចតួចស្តួចស្តើង ។ បានជាគេពោលដូច្នេះព្រោះ តាមការសង្កេតឃើញមានសត្វដង្កូវប្រភេទខ្លះកើតចេញពីសំបកឈើ ឬស្លឹកឈើ ។ សត្វអន្ទង់ក្លាយចេញពីដើមត្រស់ពាក់កណ្តាលមានក្បាលខ្លួនជាសត្វអន្ទង់ ពាក់កណ្តាលមានសភាពជាដើមត្រស់ ។ សត្វដង្កូវទឹកកើតចេញពីទឹកហើយដុះស្លាបប្រែក្លាយទៅជាមូស ។ សត្វដង្កូវដុះស្លាបប្រែរូបទៅជាមេអំបៅ ។ មិនតែប៉ុណ្ណោះគេថែមទាំងហ៊ាននិយាយថា កាលពីដើមសត្វស្វា

ក្លាយមកជាមនុស្ស ឬថាមនុស្សបានប្រែរូបរាងកាយក្លាយមកអំពីសត្វស្វា ។

ការពោលដូច្នេះ គឺចង់បញ្ជាក់អំពីលក្ខណៈនៃការឃើញ ដឹងយល់ស្គាល់អំពីចលនា ការប្រែប្រួល ផ្លាស់ប្តូរនៃរូបធាតុនិងវិញ្ញាណធាតុ តាំងតែពីតូចល្អិតដែលវិវដ្តន៍ទៅតាមកាលវេលាមានតំណតភ្ជាប់គ្នាមិនដាច់ អំពីសភាពមួយទៅកាន់សភាពមួយ រហូតឲ្យគេមានសេចក្តីយល់ឃើញថា រុក្ខាលតាជាតិប្រភេទទាំងអស់សុទ្ធសឹងតែមាន **ជីវិតវិញ្ញាណ** ទើបគេប្រើពាក្យថា ដើមឈើងាប់ ដើមឈើរស់ ដូច្នេះជាដើម ។

ការពោលរៀបរាប់ អំពីអត្ថន័យខ្លះនៃជីវិតមកប៉ុណ្ណោះនេះគ្រាន់តែបញ្ជាក់ទៅតាមផ្នែកម្យ៉ាងនៃ **ទស្សនវិជ្ជា** គឺការស្រាវជ្រាវនិងការពោលស្តីនិយាយទៅតាមលោកវោហារ ជាសាមញ្ញភាសា ឬជាគ្រាមភាសា ហាក់បីដូចជានិយមន័យត្រឹមតែប៉ុណ្ណោះឃើញថាជាការគ្រប់គ្រាន់ណាស់ទៅហើយ ។ ដូច្នេះសូមលោក-អ្នកអានទាំងឡាយងាកបែរមកសិក្សាពាក្យថា **ជីវិត** នេះតាមលំអាននៃព្រះពុទ្ធសាសនាម្តងវិញ ដែលចាត់ថាជាផ្នែក **បរមត្ថៈ**ៗនេះបានដល់អត្ថដ៏ឧត្តម ន័យដ៏ក្រៃលែង សេចក្តីពិត ។

❖ **បរមត្ថធម៌** តាមព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងក្នុង **គម្ពីរព្រះអភិធម្ម** ពាក្យថា **ជីវិត** នេះគឺជា **បរមត្ថធម៌** មានន័យសុខុមលំអិត ប្រណីត ពិតក្រៃលែងល្អិតល្អន់

ក្បោះក្បាយ ទូលំទូលាយ ជ្រាលជ្រៅជាទីបំផុត ។

ក្នុង **អភិធម្មសង្គណី** ពាក្យថា **ជីវិត** នេះសំដៅយកតែជីវិតមនុស្ស សត្វដែលមានចិត្តវិញ្ញាណ ជាសហជាតប្បច្ច័យពុំបានសម្ដែងរាប់បញ្ចូលដល់រុក្ខាលតាជាតិអ្វីនោះទេ ។

ព្រោះពាក្យថា **ជីវិត** នេះជាភាសាបាលី ឬសំស្រ្កឹត ប្រែជាភាសាខ្មែរបានដល់កិរិយារស់នៅ ដូចបទវិគ្គហថា ៖ **ជីវិយតេតិ** > **ជីវិតំ** > ធម្មជាតិជាគ្រឿងរស់នៅនៃសត្វ ធម្មជាតិជាទីប្រព្រឹត្តទៅនៃសម្បយុត្តធម្ម ហៅថា **ជីវិត** ។

ពោលតាមសេចក្ដី[១]ក្នុងបិដក សំណួរអំពីពាក្យថា ៖ **ជីវិតិន្ទ្រិយ** តើមានន័យដូចម្ដេចខ្លះ ? ចម្លើយ **ជីវិតិន្ទ្រិយ** មានពីរប្រការគឺ ៖ **រូបជីវិតិន្ទ្រិយ** មួយ(១) និង **អរូបជីវិតិន្ទ្រិយ** មួយ(១) ។

❖ **រូបជីវិតិន្ទ្រិយ** ពាក្យ **ជីវិតិន្ទ្រិយ** គឺជីវិតជាសភាវធំក្នុងការញុំាំងសហជាតធម្មឲ្យប្រព្រឹត្តទៅដូចជា រូបជីវិតិន្ទ្រិយបានដល់អាយុ ការឋិតនៅ ការតាំងនៅ ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការរក្សាការរស់នៅ ធម្មជាតិជាធំក្នុងការរស់នៅ

❖ ធម្មជាតិជាធំ ក្នុងការរស់នៅណានៃធម៌ដែលមានរូប

(១) ក្នុងបិដកលេខប៉ែតសិប ( ៨០ ) **អភិធម្មបិដក គម្ពីរវិភង្គ បឋមភាគ** ទំព័រពីររយសែសិបប្រាំបី ( ២៤៨ ) បន្ទាត់ដប់បី ( ១៣ ) ។

ទាំងនោះហៅថា **រូបជីវិតិន្ទ្រិយ** ។

❖ **អរូបជីវិតិន្ទ្រិយ** បានដល់អាយុ ការរស់នៅ ការតាំងនៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការរក្សាការរស់នៅ ធម្មជាតិជាធំក្នុងការរស់នៅ ធម្មជាតិជាធំក្នុងការរស់នៅណានៃធម៌ដែលមិនមានរូបទាំងនោះ ហៅថា **អរូបជីវិតិន្ទ្រិយ** ។

ដូច្នេះពាក្យថា **ជីវិត** ក្នុង **គម្ពីរទិភទ្ធ** ចាត់ថាជា រូបធម៌ផងចាត់ថាជា នាមធម៌ផង ។ ក្នុងចំណែកនៃរូបធម៌ទាំងម្ភៃប្រាំបី ( ២៨ ) ជីវិតចាត់ថាជាចំណែកនៃរូបមួយដែរ ព្រោះធម្មជាតិជាធំក្នុងការអនុបាលរក្សារូបដទៃ ឲ្យមានការតាំងនៅនិងប្រព្រឹត្តទៅបាន ។

ក្នុងចេតសិកហាសិបពីរដួង ( ៥២ ) **ជីវិត** ចាត់ថាជានាមធម៌ ត្រង់ខទីប្រាំមួយ ( ៦ ) ក្នុងសព្វចិត្តសាធារណចេតសិក ជីវិតជាធំ ក្នុងការរក្សាសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅក្នុងឱកាសដែលកើតឡើងតម្រង់នៅរហូតដល់ការរលត់ទៅវិញ ។

តាមសេចក្តីដូចបានរៀបរាប់មក បញ្ជាក់ឲ្យឃើញថា **ជីវិត** ពុំមែនកើតឡើងដោយឯកឯងនោះទេ ជីវិតជាសហជាតប្បច្ច័យ កើតឡើងបានដោយអាស្រ័យហេតុនិងបច្ច័យ ជីវិតជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ដែលកើតឡើងបានដោយអាស្រ័យហេតុមាន ៖ អវិជ្ជា, តណ្ហា, ឧបាទាន, កម្ម, អាហារជាដើម ។

**ជីវិត** កើតឡើង ដោយហេតុបច្ច័យណា រមែងរលត់ទៅវិញដោយហេតុបច្ច័យនោះ ជីវិតអតីតកើតឡើងហើយរលត់ ទៅវិញក៏ជាជីវិតអតីតដែរ មិនមែនជាជីវិតបច្ចុប្បន្ន ជីវិតបច្ចុប្បន្នកើតឡើងហើយ រលត់ទៅវិញក៏ជាជីវិតបច្ចុប្បន្នដែរ មិនមែនជាជីវិតអនាគត ជីវិតអនាគតកើតឡើងហើយ រលត់ទៅវិញក៏ជាជីវិតអនាគត មិនមែនជាជីវិតបច្ចុប្បន្ន ។

**ជីវិត** មិនទៀងទាត់ ផ្លាស់ប្តូរគ្នាទៅតាមហេតុបច្ច័យ ពេលខ្លះជីវិតជាហេតុ ពេលខ្លះជីវិតជាផល ជីវិតជារូប ជីវិតជានាមពោលទៅតាមបញ្ចក្ខន្ធទាំងប្រាំ ( ៥ ) មាន ៖ រូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ចាត់ជាចង្កោម ជាក្រុម គំនរនៃរូបធម៌និងនាមធម៌ ។ ក្នុង **គម្ពីរព្រះអភិធម្ម** រូបទាំងម្ភៃប្រាំបី ( ២៨ ) ចាត់ចូលក្នុងរូបក្ខន្ធ ចិត្តប៉ែតសិបប្រាំបួនដួង ( ៨៩ ) ចាត់ចូលក្នុងវិញ្ញាណក្ខន្ធ, ចេតសិកហាសិបពីរដួង ( ៥២ ) សញ្ញាចាត់ចូលក្នុងសញ្ញាខន្ធ, វេទនាចាត់ចូលក្នុងវេទនាខន្ធ នៅសល់ចេតសិកហាសិបដួង ( ៥០ ) ទៀតចាត់ចូលសង្ខារក្ខន្ធ ។

ដូច្នេះពាក្យថា **ជីវិត** ជា **បរមត្ថធម៌** ជាសភាវពិត ប្រព្រឹត្តទៅរួមដោយ រូបធម៌ នាមធម៌ មានមហាភូតរូបបួន ( ៤ ) រួមដោយចិត្តវិញ្ញាណ, ខន្ធ, ធាតុ, អាយតនៈឥន្ទ្រិយ ។ ជាសង្ខតបច្ច័យមានការកើតឡើងនិងរលត់ទៅវិញយ៉ាងឆាប់រហ័សជាទីបំផុត ។

ក្នុងរូបរាងកាយនៃសព្វសត្វទាំងឡាយ ដែលចាត់ថាមានជីវិតគឺសំដៅត្រង់កំពុងមានចលនាប្រព្រឹត្តទៅ ដូចជា ៖ ដេក ដើរ

ឈរ អង្គុយ និយាយស្តី សើចយំ ស្រេកឃ្លាន ប្រកបការងារ តាមនាទីខ្លួនទទួលដឹងអារម្មណ៍ដែលជាសុខ ជាទុក្ខ សោមនស្ស ទោមនស្ស ជាឧបេក្ខា នេះឯងហើយចាត់ថាមានជីវិត គឺការរស់នៅ ទើបតម្រូវឲ្យមានពាក្យសម្តីជាច្រើនសន្ធឹកសន្ធាប់រាប់មិនអស់ សំរាប់ប្រើជាមួយជីវិតនេះដូចជា ( **អត្ត** ជាភាសាបាលី ) , ( **អាត្មា អាត្ម័ន** ជាភាសាសំស្ក្រឹត ប្រែថា "**ខ្លួន**" សំដៅដល់ជីវិត ) ( **បាណ** ឬ **ប្រាណ** បានដល់ការរស់នៅ, ការប្រព្រឹត្តទៅនៃជីវិត )។

នៅមានពាក្យសំដីជាច្រើនទៀតជាលោកវោហារ ការសន្មតិជាអវិជ្ជមានបញ្ញតិ គឺគ្រាន់តែជាការកំណត់កត់ចំណាំចាំសម្គាល់ក្នុងការនិយាយពោលស្តី សំរាប់ជីវិតប្រចាំថ្ងៃ ដូចជា ៖ ភូមិ ឋាន ប្រទេសជាតិ ភាសា អក្ខរៈ ព្យញ្ជនៈ ។ ឈ្មោះប្រទេស ជាតិ មនុស្ស សត្វ បុគ្គល របស់សម្ភារៈនីមួយៗចាត់ថាជាបញ្ញត្តិ មិនជាសភាវធម៌ពិតគ្រាន់តែប្រឌិតកំណត់ឲ្យបានជានាម ជាពាក្យសម្តីកំណត់ចំណាំក្នុងការនិយាយពោលស្តី ប្រាស្រ័យហៅទាក់ទងទំនាក់ទំនងរវាងគ្នាទៅវិញទៅមក តាមសង្គមគ្រួសារ ភាសាជាតិប្រទេសតែរៀង ៗ ខ្លួន ។

បញ្ញតិទាំងឡាយ ទោះជាវិជ្ជមានបញ្ញត្តិក្តី អវិជ្ជមានបញ្ញត្តិក្តីដែលកើតមានឡើង ក៏ព្រោះតែមានមនុស្ស សត្វកើតឡើង មានជីវិតប្រព្រឹត្តទៅក្នុងលោក បើពុំនោះសោតក៏គ្មានបញ្ញត្តិសំរាប់ពោលស្តីឲ្យយល់ស្គាល់អ្វី ៗក្នុងលោកនេះដែរ ។

# សត្វលោកស្រឡាញ់ ជីវិតខ្លួន

ពាក្យថា **សត្វលោក** ចែកចេញជាពីរស័ព្ទគឺ ៖ **សត្វ** ជាស័ព្ទមួយ, **លោក** ជាស័ព្ទមួយ ។

❖ **សត្ត** ឬ **សត្វ** ( ជាភាសាបាលី ឬសំស្ក្រឹត ) ប្រែជាភាសាខ្មែរ បានដល់បុគ្គលអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ ក្នុងបំណងក្នុងជីវិតខ្លួនប្រាណ ។ បើយោលទៅតាមន័យសេចក្ដី ពាក្យថា **សត្វ** សំដៅដល់សត្វមានជីវិត ៖ ក្សត្រិយ៍ក្ដី , ព្រាហ្មណ៍ក្ដី , វេស្សក្ដី សុទ្ទៈក្ដី , គ្រហស្ថក្ដី , បព្វជិតក្ដី , ទេវតាក្ដី , មនុស្សក្ដី , តិរច្ឆានក្ដីរួមហៅថា **សត្វ** ។

❖ **លោក** ( ជាភាសាបាលី ឬសំស្ក្រឹត ) ប្រែជាភាសាខ្មែរ បានដល់សភាវធម៌ដែលកើតឡើងហើយ តែងវិនាសទៅវិញជារឿយៗ ឬដែលបាត់ៗ ឃើញៗ គឺកើតមានហើយវិនាសបាត់ទៅហើយក៏កើតឡើងតាមកាលសម័យ ។ បើយោលទៅតាមន័យសេចក្ដី ពាក្យថា **លោក** សំដៅដល់ ៖ អបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។

**លោក** ជាទីអាស្រ័យនៅ នៃសត្វតិរច្ឆានក្ដី អសុរកាយក្ដី ប្រេតក្ដី នរកក្ដី ចាត់ថាជាអបាយ ព្រោះជាភូមិឋាននៃសេចក្ដីវិនាស សូន្យចាកសេចក្ដីចម្រើន មិនអាចសាងបុណ្យ កុសល

បានរកសេចក្ដីសុខគ្មានមានតែទុក្ខទារុណកម្មដែលកើតពីអកុសលវិបាក ជាបច្ច័យ ។

**មនុស្សលោក** លោកជាទីអាស្រ័យនៃមនុស្ស ដែលចែកចេញទៅជាប្រទេស ជាតិ ភូមិឋាន ផ្សេងៗដោយឡែកពីគ្នា ។

**ទេវលោក** លោកជាទីអាស្រ័យនៅនៃពពួកទេវតា មានភូមិឋានប្រាំមួយជាន់មាន ៖ ចាតុម្មហារាជិកា , តាវតិង្សា , យាមា តុសិតា , និម្មានរតី , បរនិម្មិតវសវត្តី ។ ភូមិឋានជាទីអាស្រ័យនៅនៃរូបព្រហ្មដប់ប្រាំមួយជាន់មាន ៖ ព្រហ្មបារិសជ្ជា , ព្រហ្មបុរោ-ហិតា , មហាព្រហ្មា , បរិត្តាភា , អប្បមាណាភា , អភស្សរា , បរិត្តា-សុភា , អប្បមាណាសុភា , សុភកិណ្ហា , វេហប្ផលា ,អសញ្ញិសត្តា អវិហា , អតប្បា , សុទស្សា , សុទស្សី , អកនិដ្ឋកា ។

លោកជាទីអាស្រ័យនៅ នៃអរូបព្រហ្មបួនគឺ ៖ អាកាសន-ញ្ចាយតនៈ , វិញ្ញាណញ្ចាយតនៈ , អាកិញ្ចញ្ញាតនៈ , នេវសញ្ញានា-សញ្ញាយតនៈ ។

នរកប្រេត , តិរច្ឆាន , អសុរកាយក្ដី , មនុស្សក្ដី , ទេវតាក្ដី , ព្រហ្មមានរូប , ព្រហ្មឥតរូបក្ដី មានភូមិឋានជាទីកើតអាស្រ័យនៅខុសប្លែកពីគ្នា សូម្បីតែរូបរាងកាយក៏ផ្សេងៗគ្នាដែរ ។

ទាំងនេះអាស្រ័យកម្ម ជាកុសល ជាអកុសល ដែលសត្វលោកបានធ្វើ ហើយកម្មនោះបានវិចិត្រតាក់តែងមក ដូចជាសត្វកើតក្នុងអបាយលោក ឬយមលោក កើតបានដោយអកុសលវិបាក ជាផលនៃអកុសលចិត្តទាំងដប់ពីរ មានលោភមូលចិត្តប្រាំបី ទោសមូលចិត្តពីរ មោហមូលចិត្តពីរ ។ អកុសលមូលចិត្ត ទាំងដប់ពីរនេះ មានអកុសលចេតសិកកើតរួមជាមួយគ្នា ជួយជាកម្លាំងឲ្យប្រព្រឹត្តអកុសលកម្មបថទាំងដប់ប្រការ ប្រកបដោយកម្លាំងចិត្តខ្លាំងក្លា ត្រេកអរសប្បាយរីករាយខ្លះ មានកម្លាំងចិត្តខ្សោយស្មើៗ ធ្វើនូវបាបកម្ម ដោយចេតនាខ្លួនឯងខ្លះ ដោយតាមគេបបួលណែនាំខ្លះ ដូច្នេះទើបកើតក្នុងភពឋាន មានខ្លួនប្រាណខុសដោយឡែកពីគ្នា ទាំងបានទទួលទារុណកម្មផ្សេងៗគ្នាដូច្នោះដែរ ។

លោកជាទីអាស្រ័យនៅនៃមនុស្សក្តី ទេវតាក្តី ឬថាកំណើតមនុស្ស កំណើតទេវតា កើតបានដោយកាមាវចរកុសលចិត្តប្រាំបី ដែលមានកុសលចេតសិកកើតជាមួយ បំពេញនូវកុសលកម្មបថដប់ ទៅតាមកម្លាំងនិងចេតនាចិត្តរៀងៗខ្លួន ។

ពួកព្រហ្មមានរូប កើតបានដោយរូបាវចរកុសលឈានប្រាំ ព្រហ្មឥតរូប កើតបានដោយអរូបាវចរកុសលឈានបួន ។

សត្វក្នុងអបាយលោកក្តី មនុស្សលោកក្តី ទេវលោកក្តី ព្រហ្មលោកក្តីរួមមកហៅថា **សត្វលោក** ព្រោះជាអ្នកជាប់ជំពាក់

ក្នុងអារម្មណ៍ស្មើដូចគ្នា ។ បានដល់ចិត្តថ្លក់ជាប់ ប្រកាន់មាំប្រកាន់ខ្ជាប់ខ្ជួនទៅលើអារម្មណ៍មាន ៖ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ជាប់ជំពាក់ត្រេកត្រអាល ចំពោះភព ភូមិឋាន ទ្រព្យសម្បត្តិ យសសក្តិ អំណាចតំណែង នាទីជីវិតរបស់ខ្លួន ។ សូម្បីតែពពួកសត្វ ដែលកើតក្នុងអបាយភូមិ ក៏គង់មានការប្រកាន់សោកស្តាយ ចំពោះជីវិតរបស់ខ្លួន ដោយមានការខកខូចតូចចិត្ត ត្បិតជាអំពើអកុសលដែលខ្លួនបានធ្វើហើយ នាំឲ្យសោយទុក្ខវេទនាដូច្នេះ ។

**សត្វលោក** ស្រឡាញ់ ពេញចិត្ត ជាប់ចិត្តតែនឹងជីវិតខ្លួន ដូច្នេះទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ត្រាស់យ៉ាងនេះថា៖

**" នត្ថិ អត្ត សមំ បេមំ "**

**" សេចក្តីស្រឡាញ់អ្វី ស្មើនឹងខ្លួនមិនមាន "**

ពាក្យថា ស្រឡាញ់ខ្លួន ជាប់ចិត្តពេញចិត្តខ្លួន សំដៅដល់ជីវិតនេះឯង ។ សត្វលោកកើតមកហើយ សមប្រាថ្នាក្តី មិនសមប្រាថ្នាក្តី គ្រប់តែជីវិតមានចិត្តស្រឡាញ់ ប្រកាន់ខ្ជាប់ខ្ជួន មានទម្លាប់របស់ចិត្តមួយ គឺយកខ្លួនឯងជាធំ ដូច្នេះទើបធ្វើអ្វីៗដើម្បីខ្លួន ដោយការប្រោះព្រួយកខ្លួនជាធំ មានចិត្តគិតពីប្រយោជន៍របស់ខ្លួនមុនជាងប្រយោជន៍អ្នកដទៃទាំងអស់ ។

អំពើ ឬកិច្ចការងារគ្រប់បែបយ៉ាង ដែលគេបានសាងឡើង

ក្នុងអត្តភាពជាមនុស្សក្តី ជាសត្វក្តី មានការសិក្សា ប្រកបមុខរបរ ចិញ្ចឹមជីវិត បំពេញការងារ ទៅតាមនាទីតំណែងគ្រប់យ៉ាងនោះ ក៏ព្រោះខ្លួនគេនោះឯង ។

ជីវិតកើតមកហើយ ពុំមែនត្រូវនៅព្រងើយ សោះអង្គើយ ប្រាសចាកការងារនោះទេ ជីវិតបាននាំមកនូវទម្ងន់អំរែក ដ៏មហាសែនធ្ងន់ ផ្ទុកបន្ទុបមកលើម្ចាស់ជីវិត ជីវិតត្រូវការអាហារ ត្រូវការទីជម្រកជ្រកអាស្រ័យ ត្រូវការសំលៀកបំពាក់ ថ្នាំព្យាបាលរោគ ត្រូវការសេចក្តីសប្បាយរីករាយ ភាពស្និទ្ធស្នាល សេចក្តីស្រឡាញ់ និងភាពកក់ក្តៅ ។ តែអ្វីៗគ្រប់យ៉ាង មិនបានមកដោយឯងៗនោះទេ គឺត្រូវមានសេចក្តីព្យាយាម ធន់ទ្រាំ តស៊ូ ជួនកាលជីវិតបានសមស្របតាមសេចក្តីប្រាថ្នា ពេលខ្លះក៏ខុសខកបំណង ទាំងនេះជាចាំបាច់ណាស់ ដែលម្ចាស់ជីវិតត្រូវតែដឹងយល់ ស្គាល់នូវហេតុការណ៍និងព្យាយាមសម្របទៅតាមហេតុការណ៍នោះៗ បើមិនដូច្នោះទេនឹងជួបប្រទះនូវបញ្ហាដែលជាផលវិបាកសំរាប់ជីវិត ពិតមិនខាន ។

ព្រោះហេតុតែស្រឡាញ់ខ្លួន ទើបសត្វលោកធ្វើអ្វីៗទៅតាមចំណូលចំណង់របស់ខ្លួន បំពេញតែតាមតម្រូវការ បំរើសេចក្តីប្រាថ្នាខ្លួនជាធំ រហូតដល់ខ្លះច្រឡំវង្វេងលែងដឹងថាអ្វីជាកំហុស អ្វីជាតម្រូវ ជាបាបជាបុណ្យគុណទោស ក៏លែងទទួលស្គាល់ដឹង

យល់អស់ ។

ដើម្បីបំពេញសេចក្តីត្រូវការនិងបម្រើតណ្ហារបស់ខ្លួន ធ្វើឲ្យមនុស្សខ្លះវង្វេងងងឹត មិនអាចទទួលស្គាល់ថា សភាវៈពិតជាយ៉ាងណា ដូចជាបុរសម្នាក់មានចិត្តជាប់ជំពាក់ ដោយសេចក្តីស្នេហាទៅលើនារីដែលមានសម្រស់ដ៏ស្រស់បំព្រង ដូចបុប្ផាកំពុងតែរីកមួយទង បុរសខំព្យាយាមលួងលោម ដោយសំដីផ្អែមល្ហែមថ្នាក់ថ្នមលោមចិត្តឲ្យនារីនោះអាណិតបាក់ចិត្តស្រឡាញ់ខ្លួន ។

យើងធ្លាប់ឮ ពាក្យគេពោលជាប្រចាំថា " ខ្ញុំស្រឡាញ់នារីនោះខ្លាំងណាស់, ស្រឡាញ់អស់ពីដួងចិត្ត, សូម្បីប្តូជាកាយថ្វាយជីវិតក៏ព្រមដែរ " ។ តែដល់ដឹងថា នារីនោះគេមិនស្រឡាញ់ខ្លួន គេបានប្រគល់ក្តីស្នេហ៍ ឲ្យដល់អ្នកផ្សេងរួចទៅហើយ ស្រាប់តែបុរសកំសត់ ផ្ទុះកំហឹងយ៉ាងខ្លាំង រហូតតាមចងអាឃាតព្យាបាទនឹងនារីនោះដោយប្រការផ្សេងៗ ។

ភរិយាម្នាក់ បានពោលប្រាប់គេឯងថា " ខ្ញុំស្រឡាញ់ស្វាមីខ្ញុំណាស់, ស្រឡាញ់ដោយស្មោះអស់ពីដួងចិត្ត, ប្តូរកាយរំលាយជីវិតរួមរស់ជាមួយគ្នាលុះគ្រាអវសាន មិនតែប៉ុណ្ណោះ ព្រមទាំងបានសច្ចាប្រាថ្នាឲ្យបានជួបគ្នាគ្រប់ៗជាតិទៀតផង ។

ដល់ក្រោយមក ស្រាប់តែបុរសជាស្វាមី បែកបែរចិត្តថ្មីទៅយកស្ត្រីផ្សេងទៀតជាប្រពន្ធ ធ្វើឲ្យស្ត្រីដែលជាភរិយាដើមកើត

មានសេចក្ដីក្ដៅក្រហាយ ខ្វល់ខ្វាយអន្ទះអន្ទែង ដេកពួនលែងសុខ នៅមិនស្រណុក លំអុករករឿងបង្កើតឡើងជាបញ្ហា ផ្អើលគេឯង ពេញទាំងស្រុក ។

បើតាមសេចក្ដីដូចពោលរៀបរាប់នេះ យើងតាំងជាសំណួរ ថា ៖ តើបុរសដែលស្រឡាញ់នារី, ស្ត្រីជាភរិយាដែលពោលថា ខ្លួន ជាអ្នកស្រឡាញ់ប្ដីនោះ តើពិតជាមែនដូច្នោះមែនឬទេ ? ចម្លើយគឺ ពុំមែនដូច្នោះទេ ! ព្រោះអ្នកទាំងពីរមានសេចក្ដីស្រឡាញ់ក៏ពិតមែន ហើយ តែសេចក្ដីស្រឡាញ់នោះ គឺដើម្បីបម្រើគោលបំណងរបស់ គេតែប៉ុណ្ណោះ ដើម្បីខ្លួនគេតែម្យ៉ាង យកអ្នកដទៃមកអាង ប្រាស ចាកសេចក្ដីពិត ដោយភាពងងឹត វង្វេង មាយាមិនព្រមទទួល ស្គាល់នូវទោសកំហុសរបស់ខ្លួន ។

បុរសជាស្វាមីម្នាក់បានពោលឡើងថា " ខ្ញុំប្រច័ណ្ឌប្រពន្ធខ្ញុំ ណាស់ " ។ ហើយស្ត្រីជាភរិយាក៏ពោលពាក្យនេះដូចគ្នាដែរ ។ អ្នកទាំងពីរបានពោលពាក្យដូចគ្នាថា " ការប្រច័ណ្ឌព្រោះតែខ្ញុំស្រ - ឡាញ់គាត់ បាត់មុខមិនបាន " តើសម្ដីបែបនេះត្រឹមត្រូវដែរឬទេ ? ពិតជាមិនត្រឹមត្រូវទេ ត្បិតពាក្យថា " ប្រច័ណ្ឌ " បានដល់ការប្រ - កាន់ជាប់ជំពាក់ហួងហែង បើដូច្នោះយើងសួរទៀតថា ៖ តើការ ប្រច័ណ្ឌនោះដើម្បីអ្នកណា ? ពុំមែនតែដើម្បីខ្លួនឯងទេឬ ?

ឧទាហរណ៍ ដែលបុរសម្នាក់បានពោលអះអាងថា " ខ្លួន ស្នេហានារីម្នាក់នោះយ៉ាងអស់ពីចិត្តពីថ្លើម សូម្បីតែជីវិតក៏ហ៊ាន

លះបង់ដែរ បើដូច្នោះមែន ហេតុដូចម្ដេចក្រោយពេលដែលបានដឹងថា នារីនោះគេមិនស្រឡាញ់ខ្លួន គេបានទៅប្រគល់ក្ដីស្នេហ៍ឲ្យទៅបុរសផ្សេង ខ្លួនឯងបែរជាមានកំហឹង ឆាបឆេះក្ដៅក្រហាយនៅមិនបានទៅវិញ ។ បើដូច្នោះបញ្ជាក់បានថា " សម្ដីបុរសនោះ គឺគ្រាន់តែជាការបោកប្រាសប៉ុណ្ណោះ កុំថាឡើយដល់ជីវិតខ្លួននោះ សូម្បីតែសេចក្ដីស្នេហាខ្លួន ក៏មិនអាចលះបង់ ដើម្បីបំពេញបំណងឲ្យដល់មនុស្សម្នាក់ ដែលខ្លួនបានពោលថាស្រឡាញ់ស្មោះបានផង " ។

ដោយការជាប់ជំពាក់ ប្រកាន់ហួងហែង ស្រឡាញ់ពេញចិត្តចំពោះតែជីវិតខ្លួន ដូច្នេះហើយទើបធ្វើឲ្យសត្វលោកវង្វេងភ្លេចខ្លួន មិនបានព្យាយាមសម្រាលទម្ងន់ អម្រែកជីវិតខ្លួនឯងឲ្យបានធូរស្រាលទេ គឺបានខំព្យាយាមឆ្លៀតប្រមែប្រមូល ឱបក្រសោបស្រវារពីអ្នកដទៃ មកបន្ថែមពីលើខ្លួនឲ្យកាន់តែធ្ងន់ថែមទៀត ។

សត្វលោកស្រឡាញ់ខ្លួនជាជាងអ្វីៗពិតណាស់ ទោះបីជាខំស្រឡាញ់អ្នកដទៃ ឬខំប្រកបកិច្ចការអ្វីៗគ្រប់យ៉ាង ក៏ដើម្បីសាងលើកកម្ពស់ខ្លួនឲ្យបានថ្លៃថ្នូរ ។ ដោយការស្រឡាញ់ពេញចិត្តនឹងជីវិត ខំព្យាយាមរក្សាការពារ លើកកម្ពស់ឲ្យតម្លៃទៅលើជីវិត ថាមានតម្លៃពិតមិនអាចនឹងកាត់ថ្លៃឬប្រមាណប៉ុណ្ណោះប៉ុណ្ណោះបាន ។

# តម្លៃជីវិត

ការស្រឡាញ់ជាប់ចិត្តទៅលើជីវិតដូច្នេះហើយ ទើបឲ្យតម្លៃថាជីវិតថ្លៃជាងវត្ថុអ្វីៗទាំងអស់ក្នុងលោកនេះ ព្រោះយើងអាចសង្កេតឃើញថា មនុស្សក្តី សត្វក្តី តែងតែព្យាយាមខំប្រឹងរក្សាការពារជីវិត ទៅតាមសមត្ថភាពនិងសញ្ញាតិញ្ញាណរបស់ខ្លួន ។ ទោះបីជាដឹងថាជីវិតនេះ ត្រូវធន់ទ្រាំតស៊ូប្រឈមជាមួយនឹងច្បាប់ធម្មជាតិ គឺការស្រេកឃ្លាន កង្វះខាត ស្រឡាញ់ស្អប់ សើចយំទ្រាំនឹងសេចក្តីទុក្ខលំបាក ដែលជាបញ្ហាចោទឡើងនៅជុំវិញផងនិងចាស់ ឈឺ ស្លាប់ផងយ៉ាងណា ក៏មិនអាចនៅស្ងៀមព្រងើយបណ្តោយឲ្យជីវិតធ្លាក់ចុះ កាន់ភាពមហន្តរាយ បានដោយងាយនោះទេ ។

កុំថាឡើយចំពោះអ្នកដែលកើតមក មានកាយសម្បទាគ្រប់គ្រាន់ សូម្បីតែអ្នកពិកលពិការ ក៏ខំត្រដររដើរសុំទានគេ ដើម្បីរក្សាការពារជីវិតឲ្យបានរស់នៅ ទោះបីជាបានព្រឹកខ្វះល្ងាចក៏ដោយ ។

គ្រឿងសម្ភារៈទាំងឡាយ ដែលមនុស្សសាងសង់បង្កើតឡើង គឺសម្រាប់បម្រើសម្រួលដល់ជីវភាពរបស់មនុស្ស ។ គ្រឿង

ជំនិះមានយន្ត យាន ទីជម្រកជ្រកអាស្រ័យនៅគ្រឿងអលង្ការទាំងឡាយមានមាសពេជ្រកែវកងពិនទូរ្យស្វរិកានទាំងអម្បាលម៉ានដែលគេបានរចនាច្នៃ ឲ្យបានទៅជាខ្សែក ខ្សែដៃ ចិញ្ចៀន ទំហ៊ូមានពន្លឺឆ្លុះចាំងឡើងចិញ្ចាចចិញ្ចែង ។ គេបានឲ្យតម្លៃទៅលើវត្ថុទាំងអស់នោះ ទោះជាតម្លៃខ្ពស់ទាប តិចច្រើនយ៉ាងណា តែកុំភ្លេចថារបស់ទាំងនោះ គេអាចដាក់លក់នៅលើទីផ្សារ អាចកាត់ថ្លៃលក់ចេញទិញចូល ទៅតាមចំណូលចំណង់របស់មនុស្សនិងគ្រាន់តែជារបស់សម្រាប់បម្រើការ ឬសម្រាប់ជាលំអរតាក់តែងប្រដាប់រាងកាយរបស់បុរសស្ត្រីទាំងឡាយហ្នឹងឯង ឃើញថាមិនអាចយកមកប្រៀបផ្ទឹមនឹងជីវិតបានដែរ ព្រោះជីវិតនេះគេមិនអាចដាក់លក់តាមទីផ្សារ លក់ចេញទិញចូល ផ្លាស់ប្តូរគ្នាបានឡើយ ។

ទោះបីជាការរស់នៅដោយទ័លច្រកខកចិត្ត ដោយប្រការណាមួយក៏តាមចុះ ម្ចាស់ជីវិតនៅតែខំការពារ ព្យាយាមរហូតដល់អស់សមត្ថភាព ព្រោះហេតុដូច្នេះហើយ ទើបមនុស្សនាំគ្នាឲ្យតម្លៃទៅលើជីវិត ។

ការឲ្យតម្លៃទៅលើជីវិត ដោយការស្រឡាញ់ប្រកាន់ជាប់ជំពាក់យ៉ាងនេះ រមែងធ្លាក់ចុះក្នុងសេចក្តីវង្វេង ងងឹតរហូតធ្វើឲ្យចិត្តលែងដឹងយល់នៅអ្វីជាសភាវពិតរបស់ជីវិត ។

ទើបមានមនុស្សច្រើនណាស់ បានក្លាយទៅជាអាត្មានិយម

គិតតែពីរប្រយោជន៍ផ្ទាល់ខ្លួន ធ្វើអ្វីៗទៅតាមចំណូលចំណង់របស់ខ្លួន ដោយឥតបានគិតអំពីចិត្តអ្នកដទៃឡើយ សូម្បីតែទង្វើនៃខ្លួនប៉ះពាល់សង្កត់សង្កិន បៀតបៀន ធ្វើទុក្ខបុកម្នេញ ឲ្យដល់អ្នកដទៃសោកសៅ កន្ទក់កន្ទេញយ៉ាងណា ក៏មិនអើពើយកភ្នែកមើលដែរ ។

បើដូច្នេះ ពាក្យថាស្រឡាញ់ខ្លួន ការឲ្យតម្លៃទៅលើជីវិតតើត្រឹមត្រូវតាមផ្លូវព្រះពុទ្ធសាសនាដែរឬទេ ? គឺពិតជាមិនត្រឹមត្រូវទេ ព្រោះការស្រឡាញ់ខ្លួនក្តី ការឲ្យតម្លៃទៅលើជីវិតក្តី គឺត្រឹមតែជាការស្រឡាញ់ ប្រកាន់ជាប់ជំពាក់ហួងហែងការពារ ធ្វើអ្វីៗទៅតាមសេចក្តីប្រាថ្នា ឥតគិតពិចារណា ថាជាអំពើអាក្រក់ល្អ បាបបុណ្យគុណទោសខុសត្រូវទេនោះ ឃើញថាខុសផ្ទុយស្រឡះ ប្រាសចាកពីព្រះពុទ្ធដីការ ។

អ្នកដែលប្រព្រឹត្ត អំពើទុច្ចរិតតាមផ្លូវកាយ វាចា ចិត្តឈ្មោះថាជាអ្នកស្អប់ខ្លួន ដុតបំផ្លាញខ្លួន បន្ថោកតម្លៃជីវិតខ្លួន ។ ដូច្នេះ ដើម្បីឲ្យបានឈ្មោះថា ជាអ្នកស្រឡាញ់ខ្លួនពិតៗនិងបានលើកតម្កើងថាជីវិតនេះមានតម្លៃ ត្រូវព្យាយាមវៀរចាកនូវអំពើបាបកម្មទាំងឡាយ សមនឹងព្រះពុទ្ធដីកាព្រះអង្គទ្រង់ត្រាស់បញ្ជាក់យ៉ាងនេះថា ៖

**អត្តានញ្ចេ បិយំ ជញ្ញា នតំ បាបេន សំយុជេ**
**បើដឹងថាខ្លួន ជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន**
**មិនត្រូវប្រកបខ្លួនក្នុងអំពើអាក្រក់ឡើយ !**

ហេតុដូចម្តេច បានជាពោលថាជីវិតនេះមានតម្លៃ ? ពិតមែនហើយជីវិតនេះមានតម្លៃមិនអាចកាត់បាន ព្រោះជីវិតមនុស្សបានមកដោយកម្រពន់ពេកណាស់ លុះណាតែបំពេញកុសលឲ្យក្រាសក្រៃលគ្រប់ធួន ទើបបានកំណើតមកជាមនុស្ស បានកើតជាមនុស្សហើយ បានប្រកបដោយកាយសម្បទាបរិបូណ៌ជាការក្រ ការចិញ្ចឹមជីវិតរបស់មនុស្សជាការក្រ ព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្តែងថា ៖

**កិច្ឆោ មនុស្ស បដិលាភោ**
**ការបានកើតមកជាមនុស្ស ជាការក្រ**
**កិច្ឆំ មច្ចាន ជីវិតំ**
**ការរស់នៅរបស់សត្វទាំងឡាយ ជាការក្រ**

តាមន័យក្នុងព្រះពុទ្ធដីកា ជីវិតមនុស្សបានមកដោយការបំពេញកុសលជាកាមាវចរកុសល ប្រកបដោយញាណសម្បយុត្តក្តី ឬមិនប្រកបដោយញាណសម្បយុត្តក្តី ជាសង្ខារិកក្តី ជាអសង្ខារិកក្តី ប្រកបព្រមដោយសោមនស្សវេទនា ឬឧបេក្ខាវេទនាក្តី លុះត្រា

តែមានមហាកុសល គ្រប់ធួនល្មម ទើបកើតមកជាមនុស្សបាន ។ ដូច្នេះការបានកើតមកជាមនុស្ស ចាត់ថាជាលាភដ៏ប្រសើរ ធម្ម-ជាតិដែលក្រក្រៃលែងក្រគឺក្រនឹងបានកំណើតជាមនុស្ស ឯចំណែកធម្មជាតិដែលមានក្រៃលែងមាន ថ្លៃក្រៃលែងថ្លៃ ក៏ជាកំណើតមនុស្សនេះឯង ព្រោះជាតិជាមនុស្ស អាចបំពេញបុណ្យកុសលតម្កល់ទុកអបស្វបជីវិតឲ្យប្រព្រឹត្តទៅដោយភាពថ្លៃថ្នូរ អាចសាងសន្សំសេចក្តីសុខចម្រើន ឲ្យដល់ខ្លួន គ្រួសារ សង្គមជាតិ សង្គមលោកបាន ។ ជាតិជាមនុស្ស អាចសាងខ្លួនអំពីទាបឲ្យទៅខ្ពស់បាន គឺអាចសាងខ្លួនឲ្យទៅជាមនុស្សទេព មនុស្សព្រហ្ម មនុស្សពុទ្ធៈបានតាមសេចក្តីប្រាថ្នា ដល់ការកសាងនិងសេចក្តីព្យាយាមនោះ ។

សេចក្តីអធិប្បាយមកនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា តម្លៃជីវិតពិតបិតនៅលើគុណធម៌ វត្ថុដែលល្អពិតជាបិតនៅលើគុណភាព ។ ជីវិតបើប្រាសចាកគុណធម៌ហើយ នឹងប្រែទៅជាជីវិតថោកទាប វត្ថុដែលគ្មានគុណភាពនឹងចាត់ថាជាវត្ថុគ្មានតម្លៃ ដូច្នេះត្រូវខំព្យាយាមថ្នៃរចនា ជីវិតឲ្យប្រព្រឹត្តទៅព្រមជាមួយគុណធម៌គ្រប់ពេលវេលា ។

ចូរកុំធ្វើខ្លួនឲ្យជាបុគ្គលជ្រមុជឈ្លក់ទៅក្នុងទឹក ត្រូវជាបុគ្គលមានសេចក្តីព្យាយាមងើបឲ្យផុតពីទឹក បើបានជាងើបផុតពី

ទឹកហើយ ចូរកុំបណ្ដោយខ្លួនឲ្យលិចជ្រមុជឈ្លក់ទៅក្នុងទឹកវិញឡើយ ត្រូវព្យាយាមងើបឲ្យផុតពីទឹកហើយ ត្រូវសម្លឹងរកទិសដៅហែលទៅកាន់ទីត្រើយនៃច្រាំង ។

កើតមកជាមនុស្ស មិនត្រូវប្រមាទភ្លេចស្មារតី បណ្ដោយជីវិតឲ្យធ្លាក់ចុះ ឈ្លក់វង្វេងក្នុងអំពើអាក្រក់លាមក សាងសេចក្ដីទុក្ខសោកសៅ ក្ដៅក្រហាយដល់ខ្លួន គ្រួសារ សង្គមជាតិ សង្គមលោកសោះឡើយ ។

ត្រូវព្យាយាមលះបង់ អំពើទុច្ចរិតនិងអបាយមុខគ្រប់បែបយ៉ាង ព្យាយាមសាងកុសលធម៌ជាពូជបន្តសម្រាប់ជីវិត មិនត្រូវបណ្ដោយចិត្ត ទៅតាមចំណង់ចំណូលនៃបាបមិត្រនិងបាបធម៌ជារឿយៗឡើយ ត្រូវព្យាយាមសម្លឹងរកទិសដៅដែលជាផ្លូវជីវិត ព្យាយាមហែលឲ្យផុតពីទឹក គឺកិលេសដែលជាសភាវៈផ្សើមផ្អាប់ជីវិតឲ្យងឹតឈ្លក់ឆ្ពោះទៅកាន់ត្រើយ ដោយការប្រតិបត្តិនូវព្រះធម៌ ។



# ធម្មៈ និង វិទ្យាសាស្ត្រ

ពាក្យថាធម្មក្តី ធម៌ក្តី មានន័យទូលំទូលាយក្បោះក្បាយណាស់ បើសិនជាគេពុំបានពិចារណាឲ្យបានច្បាស់ទេ គេក៏ពុំអាចយល់ឲ្យដល់ ជម្រៅនៃពាក្យថាធម្មៈ ឬធម៌នេះឲ្យបានល្អិតល្អន់ឡើយ ។ ដូច្នោះហើយ ទើបមានពាក្យសម្តីនិយាយថា ធម៌ព្រះ ធម៌ព្រាហ្ម , ធម៌ចាស់ , ធម៌ថ្មី , ធម៌បុរាណ , ធម៌សម័យ ធម៌ហ្នឹងជាពាក្យពោលស្តីតែក្នុងព្រះពុទ្ធសាសនា ជាសម្តីចាស់គម្រឹលដើរមិនទាន់សម័យ មានគម្លាតឆ្ងាយអំពីវិទ្យាសាស្ត្រ ។

ដូច្នេះសូមលោក-អ្នកអាន ងាកមកពិចារណា ស្វែងយល់នូវពាក្យ ថា **ធម៌** ម្តងវិញ បើពុំនោះសោតទេ នឹងនៅតែមានចិត្តប្រកាន់ប្រកែកញែក ដាក់ព្រះធម៌ឲ្យនៅដោយឡែក ឆ្ងាយពីវិទ្យា - សាស្ត្រ មានខ្លះរហូតពោលថា ធម៌ជាពាក្យសម្តីនៃមនុស្សបុរាណចាស់ មិនទាន់សម័យ ព្រោះសម័យនេះជាសម័យវិទ្យាសាស្ត្រ គេកំពុងបោះជំហានឈានឆ្ពោះ ទៅរកសេចក្តីចម្រើនគ្រប់ស្រទាប់ ប្រកបដោយសម្ភារៈនិយមគ្រប់បែបយ៉ាង ។

គេអាចសាង ផលិត គ្រឿងប្រើប្រាស់សម្រាប់បម្រើតម្រូវការ ទៅតាមចិត្តប្រាថ្នារបស់សង្គមលោក ដោយឥតមានខ្វះកន្លះត្រង់កន្លែងណាឡើយ ។ ដូច្នេះទើបធ្វើឲ្យគេយល់ឃើញថា ព្រះ

ធម៌និងវិទ្យាសាស្ត្រ ផ្សេងស្រឡះឆ្ងាយដាច់ពីគ្នាទៅវិញ ។

ដើម្បីឲ្យបានយល់ ចូលចិត្តច្បាស់ថា តើធម៌ក្តី វិទ្យា-សាស្ត្រក្តី ខុសដាច់ដោយឡែកពីគ្នា ឬមានទំនាក់ទំនង ប្រស្រ័យគ្នាដោយប្រការយ៉ាងណានោះ ត្រូវធ្វើការស្វែងយល់ អំពីពាក្យថា **ធម៌** ឲ្យបានប្រាកដច្បាស់ក្នុងចិត្តជាមុនសិន ។

ពាក្យថា **ធម៌** (ជាភាសាសំស្រ្កឹត) **ធម្មៈ** (ជាភាសាបាលី) ប្រែសេចក្តីជាភាសាខ្មែរ[១] មានន័យច្រើនយ៉ាង ប្រកបដោយសេចក្តីពន្យល់យ៉ាងក្បោះក្បាយ ដែលខ្ញុំព្រះករុណា ខ្ញុំបាទ សូមដកស្រង់សេចក្តីប្រែត្រង់ចំណុចខ្លះៗ មកបំភ្លឺដូចតទៅ ។

ពាក្យថា **ធម្ម** ឬ **ធម៌** បានដល់សភាវៈ ទ្រទ្រង់សត្វលោក គឺបុណ្យ បាប សុច្ចរិត ទុច្ចរិត ហេតុ សភាព ធម្មតា ប្រក្រតី ធម្មជាតិ ។ ពាក្យថាសភាព ឬសភាវៈ បានដល់អ្វីដែលមានពិតប្រាកដ ទៅតាមលក្ខណៈប្រក្រតីយ៉ាងនោះ ។ ដូចជាថា សភាវៈទ្រទ្រង់សត្វលោក សំដៅយកគុណធម៌ គឺសុចរិតការប្រព្រឹត្តល្អដោយទ្វារកាយវាចាចិត្ត បានន័យថា ទង្វើដែលនៅក្នុងក្របខ័ណ្ឌនៃសីលធម៌ គឺជាបុណ្យ ជាគុណបញ្ជាក់នូវភាពថ្លៃថ្នូរ គួរជាទី

(១) តាមវចនានុក្រមភាគ ១ របស់សម្តេចព្រះសង្ឃរាជ ( **ជួន ណាត** ជោតញ្ញាណោ ) ទំព័របួនរយចិតសិបប្រាំ ( ៤៧៥ ) ។

គោរពបូជាកោតសរសើរ ។ ព្រោះមិនបានបៀតបៀន បំពាន បំពារប៉ះពាល់សិទ្ធសេរីភាព មិនបានធ្វើទុក្ខបុកម្នេញ ដល់សព្វសត្វទាំងឡាយ ទើបមានបរិយាយថា ជាគុណធម៌ទ្រទ្រង់សត្វលោក ឲ្យបានប្រកបដោយសុខមនោរម្យពិតៗ ។

ដែលថាជា **បាប** បានដល់ទុច្ចរិត ការប្រព្រឹត្តអាក្រក់តាមទ្វារកាយវាចាចិត្ត ដែលខុសផ្ទុយពីក្របខ័ណ្ឌនៃសីលធម៌ មានការបៀតបៀន ធ្វើទុក្ខបុកម្នេញ បំផ្លាញសេចក្ដីសុខ រំលោភសិទ្ធិបំបាត់សេរីភាព នៃសត្វទាំងឡាយ ជាទង្វើលាមកថោកទាប គួរឲ្យខ្ពើមរអើមខ្លាចរអា ទើបចាត់ថាជា **បាប** គឺជាទោសកំហុស ជាទោសដែលទ្រទ្រង់សត្វលោក ឲ្យប្រកបដោយទុក្ខទារុណ ។

ពាក្យថា **ហេតុ** បានដល់ ការឬដំណើរដែលប្រព្រឹត្តទៅ, ការណ៍, ដំណើរ, រឿង, ទំនាក់ទំនង, គន្លង, ផ្លូវ, ដើមចម, គោល, សេចក្ដី, វិធី, បំណង, ដើមទង ។

**ធម៌** គឺជាហេតុ បានដល់រឿងរ៉ាវទាំងអស់ក្នុងលោកនេះ ដែលមានទំនាក់ទំនងជាប់រដឹកមិនដាច់ ទោះបីជារូបធាតុ បានដល់វត្ថុធាតុក្ដី នាមធាតុក្ដី ដែលអាចកើតឡើងបាន សុទ្ធតែមានប្រព័ន្ធផ្សំគ្នា ជាកម្មជាកិរិយាការ ជាចលនាប្រព្រឹត្តទៅ ជាប្រក្រតីធម្មតា ។

ម្យ៉ាងទៀត ដែលហៅថាជាធម្មជាតិ ចែកចេញជាពីរពាក្យ គឺ៖ **ធម្មៈ** ដែលប្រែថា ប្រក្រតី, ធម្មតា ។ **ជាតិ** ប្រែថា កំណើត, ការកើត ។ កាលបើរួមពាក្យថា **ធម្មជាតិ** បានដល់អ្វីដែលកើតមានទៅតាមប្រក្រតីធម្មតា ប្រស្រ័យដោយហេតុបច្ច័យ ឥតមានជនណាឬព្រះជាម្ចាស់អង្គណាជាអ្នកបង្កើតទេ ។

ដូចពាក្យថា **សង្ខារធម៌** ឬ **សង្ខតបច្ច័យ** បានន័យថាអ្វីៗកើតមានឡើងដោយការផ្សំផ្គុំ ប្រជុំតាក់តែង រួមជាហេតុជាផលដូចជារូបធម៌រូបធាតុមានទឹក, ដី, ភ្លើង, ខ្យល់, អាកាស ដែលរួមផ្សំគ្នាជាវត្ថុធាតុដើម មានប្រចាំជាធម្មតាដូចជាបឹង , ស្ទឹង , ទន្លេ , សមុទ្រ, ភ្នំ, ព្រៃព្រឹក្សាលតាជាតិទាំងអស់ ចាត់ថាជា អនុបាទិនកសង្ខារ កើតឯងមានឯង ទៅតាមសភាវលក្ខណហេតុបច្ច័យ មានរូបសណ្ឋានរាងរៅ ឲ្យមើលទៅឃើញ មានទាំងពណ៌លឿង, ស, ក្រហម, ខៀវ មានរសជាតិល្វីង, ចត់, ជូរ, ផ្អែម, ប្រៃ, ហឹរ ប៉ុន្តែគ្មានចិត្តគ្មានវិញ្ញាណ កើតឯងមានឯង ។

ឧបាទិនកសង្ខារ បានដល់សង្ខារមានវិញ្ញាណ ដូចជាមនុស្ស, សត្វ មានចិត្តមានវិញ្ញាណ កើតឡើងដោយការប្រជុំតាក់តែង ផ្សំធាតុ មានរូបធាតុនិងនាមធាតុជាដើម ។

សូម្បីតែសម្ភារៈទាំងឡាយ ដែលមនុស្សបង្កើតឡើងសម្រាប់បម្រើតម្រូវការក្នុងជីវិតប្រចាំថ្ងៃ ដូចជាផ្ទះ, កុដិ, សាលា,

ព្រះវិហារ ។ល។ គ្រឿងអលង្ការជាប្រដាប់សម្រាប់តាក់តែងស្អិតស្អាងរាងកាយក្តី គ្រឿងប្រដាប់សម្រាប់តាំងលំអរគេហដ្ឋានក្តី គ្រឿងប្រើប្រាស់មានយន្ត , យាន , ឡាន , កប៉ាល់ទាំងក្នុងទឹកលើគោកលើអាកាស ។ល។ ទាំងអស់នេះក៏ចាត់ចូលក្នុងអនុបាទិនកសង្ខារដែរ ។

ឧបាទិនកសង្ខារក្តី, អនុបាទិនកសង្ខារក្តី រួមមកហៅថា **សង្ខារធម៌** បានដល់អ្វីៗទាំងអស់ក្នុងលោកនេះ កើតឡើងបានដោយអាស្រ័យ ការតាក់តែង ផ្សំផ្គុំ ប្រជុំសម្ព័ន្ធគ្នា ដោយហេតុបច្ច័យជាប្រក្រតីធម្មតា ។ មិនអាចវែកញែកចេញដាច់ដោយឡែកជាមួយផ្នែកបានទេ ។

ការអធិប្បាយរៀបរាប់មកប៉ុណ្ណោះ គ្រាន់តែបញ្ជាក់សេចក្តីយ៉ាងសង្ខេបខ្លី ពីអត្ថន័យព្រះធម៌ ឲ្យយល់ថាមានន័យទូលំទូ - លាយ គ្របដណ្តប់លើអ្វីៗ ទាំងអស់ក្នុងសកលចក្រវាឡនេះ ព្រោះវត្ថុធាតុក្តី នាមធាតុក្តី សុទ្ធតែនៅក្នុងក្របខ័ណ្ឌនៃពាក្យថា **ធម៌** ទាំងអស់ ។

ខ្ញុំសូមបញ្ជាក់សេចក្តីឲ្យខ្លី ឲ្យងាយយល់អំពីពាក្យថា **ធម៌** ដែលប្រែថាបុណ្យ ថាសុចរិត បានដល់សភាវៈជាគុណ រក្សាឃុំគ្រងអ្នកប្រតិបត្តិ ឲ្យបានប្រកបដោយសេចក្តីរីករាយ សប្បាយងាយសុខស្រួល ចម្រើន ។ ដែលប្រែថាជា បាប ទុច្ចរិត បាន

ដល់សភាវៈជាទោសកំហុស ជាវិបត្តិ នាំឲ្យដល់នូវសេចក្ដីទុក្ខសោកសៅ ក្ដៅក្រហាយ ខ្វល់ខ្វាយ វិនាស ខាតបង់ ។

ដែលប្រែថា **ហេតុ** បានដល់រឿងរ៉ាវ ដំណើរដើមទង បញ្ហាដែលកើតមានឡើងដោយប្រការផ្សេងៗក្នុងលោកនេះ ។ ព្រះធម៌ដែលប្រែថា ធម្មជាតិ បានដល់វត្ថុធាតុ មានរូបធាតុនិងអរូបធាតុដែលកើតមានក្នុងពិភពលោកនិងជាវត្ថុសភាវៈ ដែលមានមកជាធម្មតា ប្រក្រតី ដោយគ្មាននណាម្នាក់ប្រកាន់ហួងហែង ទាមទារថាមានសិទ្ធិ ជាម្ចាស់ក៏ទេដែរ ព្រោះជាធម្មជាតិកើតមានហើយ ក៏ផ្លាស់ប្ដូរប្រែប្រួលទៅ តាមកាលវេលាជាធម្មតា ។

**ព្រះធម៌** មាននៅប្រចាំលោក កើតមានតាំងនៅគ្រប់កាលសម័យ មិនមានចាស់ថ្មី ទោះបីក្នុងសម័យកាលមានព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រាស់ដឹងក្ដី ឬព្រះអង្គមិនត្រាស់ដឹងក្ដី ក៏ព្រះធម៌ឋិតនៅជាព្រះធម៌ដដែល មិនសាបសូន្យចាកលោកនេះឡើយ ។ ចុះត្រង់ពាក្យថា ជាធម៌របស់ព្រះសម្មាសម្ពុទ្ធ បានន័យថាព្រះអង្គជាម្ចាស់នៃធម៌ មិនខុសទៅហើយទេឬ ? ។

មិនខុសទេ ព្រោះព្រះអង្គជាអ្នកស្វែងយល់ ស្គាល់ ឃើញនូវព្រះធម៌ ដោយព្រះប្រាជ្ញាញាណ ជាអនន្តញ្ញាណ ហើយទើបលើកយកព្រះធម៌ មកសម្ដែងប្រោសសត្វលោក ទៅតាមចំណែក

នៃព្រះធម៌ ដែលព្រះអង្គបានវែកញែកបំបែកជាពួក ជាខន្ធ ដូចជា ព្រះវិន័យ ព្រះសូត្ត ព្រះអភិធម្មជាដើម ។

ដែលគេតែងនាំគ្នាពោលថា ធម៌បុរាណ ឬធម៌សម័យ ឬថាវិទ្យាសាស្ត្រនិងធម៌ ដោយឡែកចែកដាច់ពីគ្នា ក៏ដោយសារគេពុំបានសិក្សាឲ្យយល់ដល់ជម្រៅនៃពាក្យថាធម៌ហ្នឹងឯង ។ ដូច្នេះ សូមលោក-អ្នកអាន មេត្តាសាកល្បងពិចារណាតាមអត្ថាធិប្បាយដែលខ្ញុំព្រះករុណា ខ្ញុំបាទបានរៀបរាប់មកហើយ ប្រាកដជានឹងបានយល់ចូលចិត្តថា វិទ្យាសាស្ត្រនិងធម៌មិនមានគម្លាតពីគ្នាទេ ។ គឺឋិតនៅជាមួយគ្នាគ្រប់ពេលវេលា ។

ទោះជាគេចង់និយាយថា សម័យនេះជាសម័យចម្រើនដោយវិទ្យាសាស្ត្រយ៉ាងណាក៏ដោយ គង់ចេញទៅមិនផុតរត់ទៅមិនឆ្ងាយពីរូបធម៌នាមធម៌ ឬរូបធាតុនាមធាតុបានទេ ។ វិទ្យាសាស្ត្រដែលចម្រើន ទៅតាមកាលសម័យបាន ក៏ព្រោះមានទស្សនៈវិទូដែលជាអ្នកដឹងយល់ ស្រាវជ្រាវរកឃើញ បង្កើតជាក្បួនច្បាប់វិទ្យាសាស្ត្រ ចែងពីគោលការណ៍សំខាន់ៗនិងបុព្វហេតុផ្សេងៗអំពីជីវិតនៃមនុស្សនិងសត្វ ដែលហៅថាទស្សនវិជ្ជា ជាគុណវិសេសមួយចំណែកដែលអាចធ្វើឲ្យចិត្តគំនិតមនុស្ស មានដំណើរឆ្ពោះជឿនលឿន វិវឌ្ឍន៍ទៅតាមកាលសម័យបាន ។

ការដែលចម្រើនដោយសម្ភារៈនិយមក៏ដោយ លោក-អ្នក

ប្រាជ្ញខាងវិទ្យាសាស្ត្រមានច្រើន ទើបធ្វើឲ្យវិស្វករទាំងឡាយឆ្លាតវៃប៉ិនប្រសប់ ផ្សំផ្គុំវត្ថុធាតុ ដែលជាធម្មជាតិមានមកស្រាប់ហើយយកមកចម្រាញ់ប្រឌិតច្នៃឲ្យកើតបានជាគ្រឿងអលង្ការ យន្តយានសម្ភារៈប្រើប្រាស់ សម្រាប់បម្រើតម្រូវការ តាមចំណង់ឬចំណូលរបស់មនុស្ស ។

ក្នុងសម័យចម្រើនដោយសម្ភារៈនិយម ធ្វើឲ្យមនុស្សលោកវង្វេងលែងសូវបានគិត ដោះស្រាយស្វែងយល់ អំពីបញ្ហាជីវិត ។ ភាពងងឹតគ្របដណ្ដប់ដោយស្បៃអវិជ្ជា ទើបធ្វើឲ្យគេស្វែងរកការសប្បាយរីករាយ ភ្លើតភ្លើន ស្រើបស្រាល ត្រេកត្រអាលទៅតាមសម្ភារៈនិយម ។ សូម្បីជីវិតកំពុងរស់នៅជាមួយធម្មជាតិ ក៏លែងដឹងយល់ គេទទួលស្គាល់ឲ្យតម្លៃតែលើវិទ្យាសាស្ត្រប៉ុណ្ណោះ ។

ទាំងនេះមកពីគេពុំបានយល់ថា វិទ្យាសាស្ត្រដែលចម្រើនបាន ក៏ដោយសារការផ្សំបង្កើត នៃវត្ថុធាតុជាធម្មជាតិដែលមានជាប្រចាំនៅក្នុងលោកនេះឯង ។ ទន្ទឹមគ្នាជាមួយនឹងគ្រឿងសម្ភារៈកំពុងរីកចម្រើនដុះដាលស្អេកស្កះ ក៏ធ្វើឲ្យមនុស្សលោកមានការខ្វល់ព្រួយបារម្ភណាស់ទៅហើយ ពីព្រោះធម្មជាតិជាវត្ថុធាតុដើមចេះតែវិនាសបាត់បង់ថយចុះទៅ មិនអាចបំពេញតម្រូវការឲ្យមនុស្សលោកបានទាន់ពេល ។

តើគេធ្លាប់បានគិតដែរឬទេ ថាលោកអ្នកប្រាជ្ញខាងវិទ្យា-

សាស្ត្រអាចមានបច្ចេកទេសអ្វី ស្លចម្រាញ់បង្កើតប្រេងសាំង លោហធាតុ , មាស , ពេជ្រ , ត្បូង , ស្ពាន់ , សំណ , រ៉ែដែកជាដើម បានដោយបច្ចេកវិជ្ជាបែបណាដែរឬនៅ ក្រៅតែយកវត្ថុធាតុដើមមកស្លចម្រាញ់តែប៉ុណ្ណោះ ទាំងនេះអាចបញ្ជាក់បានថា វិទ្យាសាស្ត្រត្រូវរួមរស់ជាមួយធម្មជាតិ គឺឃ្លាតពីគ្នាមិនបាន ។

ជាពិសេស បើសិនជាលោក-អ្នកជាទស្សនវិទូ ឬតក្កវិទូប្រាកដមែន លោកពិតជាមិនបានចែកបុរាណកាល និងបច្ចុប្បន្នកាលឲ្យមានគម្លាតពីគ្នាទេ ព្រោះកាលបើវេលាជាអតីតរលត់ផុតទៅ ទើបជាសំណៅសំណាម បច្ចុប្បន្នកាលកើតមានទាំងផ្នែកខាងវត្ថុធាតុ សម្ភារៈទាំងឡាយក៏ដូចគ្នាដែរ មុននឹងប្រែរូបផ្លាស់ប្តូរអ្នកជំនាញការទាំងនោះ បានព្យាយាមស្រាវជ្រាវអស់រយៈកាលជាយូរអង្វែង ។ ដូច្នេះអ្វីៗនៅក្នុងលោកនេះ មានប្រព័ន្ធប្រទាក់គ្នាមិនដាច់ មានចាស់មានថ្មី និងត្រឡប់ពីថ្មីទៅរកចាស់វិញ ផ្លាស់ប្តូរគ្នាទៅតាមកាលវេលាជាដរាប ។

បើគេចង់ពោលថា វិទ្យាសាស្ត្រចម្រើន គេក៏មិនត្រូវភ្លេចពោលពាក្យសរសើរទស្សនវិទូ ដែលលោកបានស្រាវជ្រាវរកឃើញចងក្រងជាច្បាប់ក្បួន បង្កើតបានជាសម្ភារៈ បម្រើតម្រូវការគ្រប់បែបយ៉ាងដល់មនុស្សលោកឡើយ ។ ទស្សនវិទូសម័យបច្ចុប្បន្នអាចនឹងចេះដឹងយល់ស្គាល់ឃើញបាន ក៏ដោយមានលំនាំវិទ្យា-

សាស្ត្រ ជាតំណពីគ្រប់សម័យ គឺតាំងពីបុរាណសម័យ ដែលជាស្នាដៃរបស់លោក-អ្នកប្រាជ្ញជំនាន់មុនមកដែរ ។

ក្នុងចំណោមលោក-អ្នកប្រាជ្ញទាំងនោះ ភាគច្រើនលោកមានទស្សនៈខាងសម្ភារៈនិយម ស្វែងយល់ដឹងចំពោះតែវត្ថុធាតុដែលជារូបធាតុ ឬរូបធម៌រហូតដល់ស្ទាត់ជំនាញ ក្នុងការច្នៃផលិតចេញជាគ្រឿងប្រើប្រាស់គ្រប់ប្រភេទ សម្រាប់បម្រើភ្នែក , ត្រចៀក ច្រមុះ , អណ្ដាត , កាយ , ចិត្តរបស់មនុស្សលោក ធ្វើឲ្យវង្វេងភ្លើតភ្លើនកោតសរសើរមិនដាច់ពីមាត់ ។ មិនតែប៉ុណ្ណោះសោត ក្នុងបច្ចុប្បន្ននេះ ទន្ទឹមគ្នានឹងវិទ្យាសាស្ត្រកំពុងតែចម្រើនឡើង គួរឲ្យចាប់ចិត្តផ្ចិតអារម្មណ៍ មើលទៅត្រង់ណាគួរឲ្យត្រេកត្រអាលត្រកាលភ្នែកក៏ពិតមែនហើយ តែកុំភ្លេចថា ជីវិតរបស់សត្វលោកចេះតែថយទៅជាលំដាប់ ។ ទោះបីជាសម័យនេះរីកចម្រើនដោយវេជ្ជសាស្ត្រ មើលទៅឃើញមន្ទីរព្យាបាល ពេញពាសដេរដាស់ចម្រើនដោយថ្នាំព្យាបាលរោគ គ្រូពេទ្យទាន់សម័យ អាចកែច្នៃរូបរាងកាយ ដោយការកាត់វះដោះដូរ ថ្ពើម , ប្រមាត់ , បេះដូង , ភ្នែក, ត្រចៀក, ច្រមុះ តាក់តែងរូបសម្ផស្សឲ្យស្រស់ស្អាតយ៉ាងណា នៅតែបញ្ជាក់បានថា **អាយុសង្ខារសត្វលោក ចេះតែថយចុះទៅៗជាលំដាប់** ។

រោគាព្យាធិកាន់តែកើនឡើង សេចក្តីក្រវល់ក្រវាយ កង្វះខាតចេះតែមានថែមទៀត, បញ្ហាវិវាទ សង្គ្រាមផ្ទៃក្នុងឆាបឆេះរាលដាលចេញទៅខាងក្រៅ, វិបត្តិធម្មជាតិចេះតែកើតមានជាបន្តបន្ទាប់ បញ្ហាក្រីក្រកង្វះខាតសេដ្ឋកិច្ចធ្លាក់ចុះ គួរឲ្យបារម្ភតក់ស្លុតយ៉ាងក្រៃលែង ទាំងអស់នេះ គឺជាបញ្ហាសម្រាប់ជីវិត ដែលកើតមានក្នុងសកលពិភពនេះ ។

ទោះបីជាលោក-អ្នកប្រាជ្ញទាំងឡាយ បានរួមគ្នាព្យាយាមដោះស្រាយយ៉ាងណា ក៏ពុំមែនជាការងាយៗទេ ដោយការកង្វះខាតនិងកង្វល់នេះហើយ ទើបធ្វើឲ្យមនុស្សប្រឹងប្រែង ដោះស្រាយចំពោះបញ្ហានិងវិបត្តិខាងក្រៅ ដែលមើលឃើញបានត្រឹមតែផ្លូវភ្នែកប៉ុណ្ណោះ មិនបានយល់ស្គាល់ដល់ថា វិបត្តិខាងក្នុងនៃចិត្តសត្វលោកមានទំហំនិងថាមពលខ្លាំងដល់កម្រឹតណា គេពុំសូវជាចាប់អារម្មណ៍ និងស្វែងយល់ឲ្យបានច្បាស់លាស់ទេ ។

ត្រង់ចំណុចដែលខុសគ្នានេះហើយ ទើបគេអាចមើលឃើញថា សម័យនេះជាសម័យប្រកបដោយសម្ភារៈនិយម ជាសម័យទំនើបចម្រើនដោយវិទ្យាសាស្ត្រ ដែលនៅឆ្ងាយស្រឡះដាច់ពីធម៌ ។ តាមពិតវិទ្យាសាស្ត្រក្តី ធម៌ក្តី គ្រប់កាលសម័យមានប្រព័ន្ធជាប់គ្នាមិនដាច់ ដែលយើងហៅថា **វិទ្យាសាស្ត្រ** និង **ធម្មជាតិ** នោះឯង ។

# លោកវិទូ

ក្នុងចំណោមទស្សនវិទូទាំងអស់ មានតែព្រះសម្មាសម្ពុទ្ធមួយអង្គទេ ទើបចាត់ថាជាទស្សនវិទូឯក ជាលោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក ដោយព្រះញាណដ៏បរិសុទ្ធរបស់ព្រះអង្គជាអនន្តញ្ញាណ ។ ព្រះអង្គជ្រាបច្បាស់នូវសង្ខារលោក ឱកាសលោក សត្តលោក ។ ដោយព្រះញាណដ៏បរិសុទ្ធថ្លា ទើបព្រះអង្គជ្រាបច្បាស់ពីបុព្វហេតុនៃជីវិត ដំណើរជីវិត បញ្ហាព្រមទាំងធម្មជាតិ ដែលមានទំនាក់ទំនងជាប់ជាមួយនឹងជីវិតនេះ គ្រប់សម័យទាំងអស់ ។

មិនបាច់ពោលឡើយ ដល់កាលដែលព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយនោះ សូម្បីតាំងតែពីព្រះអង្គនៅមានអត្តភាពជាព្រះបរមពោធិសត្វបានតាំងអធិដ្ឋានចិត្ត បំពេញនូវបារមីធម៌ ។ កាលនោះព្រះអង្គក៏បានពិចារណាដឹងយល់ស្គាល់ពីបញ្ហាជីវិត ព្រមទាំងធម្មជាតិ ទៅតាមសភាវៈពិត លើសជាងទស្សនវិទូទាំងឡាយក្នុងលោកនេះជាស្រេចរួចទៅហើយ ។ ទាំងនេះព្រោះតែព្រះអង្គ ធ្លាប់មានព្រះជាតិជាសត្វលោក ធ្លាប់អន្ទោលទៅមកក្នុងសង្សារវដ្ដ ធ្លាប់រស់នៅក្រោមអំណាចច្បាប់ធម្មជាតិ ។

ជីវិតមានការធន់ទ្រាំ, កង្វះខាត, គម្លាន, កម្លាច, ចំណូល

ចំណង់, សំណើចសំណោក, ទំនាប, កម្ពស់ ជីវិតធន់ទ្រាំរស់ព្រោះកំណើត ដែលនាំជាប់ជាមួយនឹងជរាព្យាធិមរណៈ ជីវិតបរិបូរណ៍ដោយទ្រព្យសម្បត្តិ, លាភ, យស, សុខ, សរសើរ, សមបំណងឬមិនសមបំណងក្តី ក៏គង់ជីវិតនេះឋិតនៅក្រោមអំណាចច្បាប់ធម្មជាតិនោះឯង ។

មិនចាំបាច់ចែកបច្ចុប្បន្ននេះ ថាជាសម័យទំនើបចម្រើនជាងសម័យបុរាណនោះទេ តាមពិតគ្រប់សម័យ សេចក្តីល្ងូតលាស់ និងវិនាសចុះមានស្មើដូចគ្នា ព្រោះជាច្បាប់ធម្មជាតិ គ្រាន់តែការវិនាសនិងការចម្រើនទៅតាមប្រភេទកាលវេលាតែប៉ុណ្ណោះ។

ដូច្នេះហើយ បានជាព្រះមានព្រះភាគ ព្រះអង្គពុំបានឲ្យតម្លៃ ឬជាប់ចិត្តទៅលើសម្ភារៈនោះទេ ព្រះអង្គព្យាយាមបំពេញបារមីធម៌ ប្រកបដោយបញ្ញាស្វែងយល់ពីជីវិតឲ្យបានពិតប្រាកដ ព្រោះជីវិតនេះគឺជាធម្មតាធម៌ កើតចេញបានមករស់នៅអាស្រ័យទំនាក់ទំនងជាមួយនឹងច្បាប់ធម្មជាតិ ។ តែទស្សនវិទូតាំងពីសម័យបុរាណ រហូតមកដល់សម័យបច្ចុប្បន្ន ភាគច្រើនពុំទាន់បានស្រាវជ្រាវ ដឹងយល់ស្គាល់ពីពាក្យថាជីវិតនេះ ឲ្យបានដល់ទីជម្រៅនៅឡើយទេ លុះណាតែគេព្យាយាមសាងខ្លួនឲ្យខ្ពស់ដល់កម្រិតបាននាមពិតជា **ពុទ្ធៈ** សិនទើបមានពន្លឺយល់ស្គាល់នូវជីវិតតាមសភាវៈពិតទៅបាន ។

ដូច្នេះហើយ ព្រះសម្ពុទ្ធជាបរមគ្រូ កាលទ្រង់គង់នៅជាព្រះបរមពោធិសត្វ ព្រះអង្គព្យាយាមបំពេញបារមីធម៌ មានកំណត់បួនអសង្ខេយ្យកំរៃមួយសែនកប្ប ដោយអំណាចព្រះបញ្ញាធិក លុះត្រាបានសម្រេចព្រះសម្មាសម្ពោធិញ្ញាណ មានព្រះនាមថ្មីមួយថាជា **ព្រះសព្វញ្ញុពុទ្ធ** ប្រែថា ការត្រាស់ដឹងយល់សព្វប្រការ ដោយព្រះប្រាជ្ញាញាណ នូវអរិយសច្ចធម៌ ជាធម៌ពិតឆ្លុះបញ្ចាំងហេតុការណ៍នៃជីវិតដោយឥតមានទើសទាក់ ។

ក្នុងចំណោមទស្សនវិទូទាំងពួងនោះ មានតែព្រះបរមសា - ស្តាសម្មាសម្ពុទ្ធទេទើបចាត់ថា **ជាលោកវិទូ** ព្រះអង្គទ្រង់មានព្រះមហាករុណាធម៌ ក្នុងការពន្យល់ណែនាំចង្អុលបង្ហាញមាគ៌ាជីវិត និងដំណោះស្រាយបញ្ហា ដែលកើតមានជុំវិញជីវិតនៃសត្វក្នុងសង្សារវដ្ត ដោយពុំមានទឹកព្រះទ័យ សង្កត់ធ្ងន់ទៅលើការផលិតថ្មៃ បង្កើតសម្ភារៈទៅតាមចំណូលចំណង់របស់សត្វលោកនោះទេ តែព្រះអង្គមិនបានបន្ទុះបង្អាប់ នូវការរីកចម្រើន ដុះដាលដោយសម្ភារៈនិយម ដោយប្រការណានោះក៏ទេដែរ ។

ព្រះអង្គបានជ្រាបច្បាស់ ដោយព្រះប្រាជ្ញាញាណជាស្រេចហើយថា ទោះបីវិទ្យាសាស្ត្រចម្រើនដល់កំរិតណា ក៏វិទ្យាសាស្ត្រត្រូវនៅជាប់ជានិច្ចជាមួយធម្មជាតិ មិនអាចមានគម្លាតចេញពីគ្នាបានឡើយ ។

អ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ ទោះច្រើនស្អេកស្កះយ៉ាងណា ក៏មិនអាចដឹងយល់ដើមកំណើត និងចុងបញ្ចប់នៃធម្មជាតិបាន ដរាបណាគេនៅមិនទាន់បាន អប់រំឲ្យកើតប្រាជ្ញាញាណមានពន្លឺនៅឡើយទេ ដូច្នេះហើយទើបភាគច្រើន គេនាំគ្នាសិក្សាស្វែងយល់ តែរូបធាតុសម្ភារៈ ដែលមើលឃើញបានចំពោះ តែផ្លូវភ្នែក ឬដោយអតិសុខុមទស្សន៍ ម៉ាស៊ីនសម្រាប់មើលអតិសុខុមរូបខ្លះ ដែលមាននៅក្នុងរាងកាយ មនុស្សសត្វតែប៉ុណ្ណោះ ។

ម្ល៉ោះហើយទើបគេនាំគ្នា បែងចែករាងកាយមនុស្សសត្វ ទៅជាចំណែកៗបានត្រឹមតែស្រទាប់ជារូបធាតុ នៅពុំទាន់បាន យល់ថា នៅក្នុងរូបធាតុនោះ មាននាមធាតុអាស្រ័យនៅផងទេ ទើបគេយកចិត្តទុកដាក់ បង្កើតសម្ភារៈជារូបធាតុ និងវិធីសម្រាប់ព្យាបាល ជួសជុលកែកុន សម្របសម្រួលតែខាងសម្ភារៈរូបធាតុ ឲ្យបានល្អប្រសើរ ដោយភ្លេចគិតថា សម្ភារៈវត្ថុទំនើបនោះ អាចកើតចេញចម្រើនបាន ព្រោះតែមនុស្សជាអ្នកបង្កើត សម្រាប់បម្រើចំណូលចំណង់ តម្រូវការរបស់មនុស្សទូទៅនោះឯង ។ ដូច្នេះ មានតែមនុស្សទេ ដែលគួរឲ្យស្ងើចអស្ចារ្យ ក្នុងដំណើរជីវិតដែលប្រព្រឹត្តទៅ នៅក្នុងបច្ចុប្បន្ននេះ ។

ទន្ទឹមគ្នានឹងភាពរុងរឿង ឆើតឆាយត្រកាលភ្នែក ជក់ចិត្ត ផ្ចិតអារម្មណ៍អណ្តែតអណ្តូង ជាមួយសម្ភារៈនិយមនេះ គួរឲ្យ

សោកស្តាយណាស់ដែរ ដោយលោក-អ្នកប្រាជ្ញខាងវិទ្យាសាស្រ្ត ពុំអាចស្រាវជ្រាវរាវរកឃើញ ខាងចុងបញ្ចប់ឬអាចធ្វើដំណោះស្រាយបញ្ហាទុក្ខកង្វល់របស់ជីវិតឲ្យបានពិតប្រាកដទេ ។ ទោះបីជាវិទ្យាសាស្រ្តចម្រើនដល់កម្រិតណា សេចក្តីវិនាសនិងសេចក្តីទុក្ខសោក រមែងមានដល់កម្រិតនោះដែរ ។

សូម្បីតែគេចង់ពោលថា សត្វលោកក្តី ធម៌ក្តី ជាពាក្យសម្តីខាងព្រះពុទ្ធសាសនា ឬគេចង់ពោលពាក្យសម្តី តាមបច្ចេកវិជ្ជាសម័យ ថាជាមនុស្សវិទ្យាសាស្រ្តក្តី ក៏គង់ពាក្យសម្តីទាំងនេះ កើតមានបានចេញពីច្បាប់ធម៌ ហៅថាធម្មជាតិហ្នឹងឯងរមែងមានជម្រៅទៅតាមសភាវៈលក្ខណៈពិតជាយ៉ាងនោះ ។

មានតែព្រះសម្មាសម្ពុទ្ធទេ ទើបព្រះអង្គអាចពន្យល់បង្ហាញមាគ៌ាជីវិតឲ្យសត្វលោកបានយល់ ដូចជាព្រះពុទ្ធដីការ ព្រះអង្គត្រាស់សម្តែងថា " **ជីវិតជារូបធម៌ ជានាមធម៌ រួមអាស្រ័យគ្នាជាបញ្ចក្ខន្ធ** " ។ មានទាំងរូបរាងកាយ អាចមើលឃើញបានដោយភ្នែកខ្លះ ចាប់កាន់ប៉ះពាល់ត្រូវដោយដៃខ្លះ ដែលជាទីអាស្រ័យនៅនៃនាមធម៌ មាន ៖

❖ **វេទនា ៖** ការទទួលដឹងអារម្មណ៍, ជាសុខជាទុក្ខ, សោមនស្ស , ទោមនស្ស , ត្រេកអររីករាយសប្បាយ , ខឹងថ្នាំងថ្នាក់អាក់អន់ស្រពន់ចិត្ត នេះជានាទីរបស់វេទនា ។

❖ **សញ្ញា ៖** ការកំណត់កត់សម្គាល់ចងចាំនូវរូប, សម្លេង, ក្លិន, រស, សម្ផស្ស, ធម្មា រហូតដល់ ពណ៌សម្បុរ, សណ្ឋាន, បែបផែន, ទ្រង់ទ្រាយ, រាងរៅទាំងនេះជាកិច្ចរបស់សញ្ញា ។

❖ **សង្ខារ ៖** ចេតនាការផ្តងចិត្ត បង្អោនចិត្តប្រព្រឹត្តកិច្ចការងារជាកុសលក្តី, អកុសលក្តី, អាក្រក់ក្តី, កម្មសកម្មខ្មៅ ជានាទីរបស់សង្ខារ ។

❖ **វិញ្ញាណ ៖** មានសេចក្តីដឹងបាន ក្នុងខណៈមានអាយតនៈខាងក្រៅ[១] មកប៉ះត្រូវអាយតនៈខាងក្នុង[២] ឬថាអារម្មណ៍ខាងក្រៅមកប៉ះពាល់ត្រូវ ទ្វារខាងក្នុង ដូចជារូបកើតឡើងប្រាកដតាមទ្វារភ្នែក សម្លេងកើតឡើងប្រាកដតាមទ្វារត្រ - ចៀក ក្លិនកើតឡើងប្រាកដតាមទ្វារច្រមុះ រសកើតឡើងប្រាកដតាមទ្វារអណ្តាត ផោដ្ឋព្វៈកើតឡើងប្រាកដតាមទ្វារកាយ ធម្មៈកើតឡើងប្រាកដតាមទ្វារចិត្ត ។

សេចក្តីដឹងតាមទ្វារនីមួយៗ ក្នុងពេលមានអារម្មណ៍កើតឡើងប្រាកដ ដូចជាភ្នែកឃើញរូប កើតសេចក្តីដឹងភ្លាម ថានេះជារូប ជាឥត្ថីភាវរូប បុរិសភាវរូប ចាស់ក្មេង សណ្ឋានរាងរៅ ដឹងបានយ៉ាងនេះ ជាកិច្ចរបស់វិញ្ញាណ ។

---

(១) រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ, ធម៌ ទាំង ៦ នេះ ហៅថា អាយតនៈខាងក្រៅ ។

(២) ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, មនោ ទាំង ៦ នេះ ហៅថា អាយតនៈខាងក្នុង ។

រូបធាតុ រូបធម៌ ជាធម្មជាតិមិនដឹង កាលបើគ្មាននាមធម៌ គឺ **វេទនា , សញ្ញា , សង្ខារ , វិញ្ញាណ** ទេនោះ មិនខុសអ្វីអំពីរូបតុក្កតា , រូបគំនូរ, រូបចម្លាក់ ដែលគេធ្វើ ឬគូរបូកប៉ាន់ឆ្លាក់ឡើងភ្ជាប់នៅលើក្រដាស់ខ្លះ ធ្វើឡើងអំពីឈើ ថ្ម ស៊ីម៉ង់ត៍ ឬអំពីវត្ថុផ្សេងៗ តែប៉ុណ្ណោះ ។

ដូច្នេះពាក្យថា **បញ្ចក្ខន្ធ** មានទាំងរូបទាំងនាមជីវិតប្រព្រឹត្តរួម ទើបមានចលនា ឥរិយាបថនៃរូបរាងកាយ របស់មនុស្សសត្វ ដែលហៅថាជីវិត ពិតជាមានន័យល្អិតជាបរមត្ថៈ ជាធម្មៈ ឬជាធម្មជាតិហ្នឹងឯង ។

សេចក្តីអធិប្បាយមកនេះ គ្រាន់តែបញ្ជាក់ អំពីពាក្យថាធម៌ ឲ្យឃើញថាមានអត្ថន័យទូលំទូលាយ វែងឆ្ងាយគ្របដណ្តប់លើអ្វីៗ ដែលមាននៅក្នុងពិភពលោកនេះទាំងអស់ និងជាហេតុបញ្ជាក់ជូនលោក-អ្នកអានឲ្យបានយល់ បំបាត់ចម្ងល់អំពីពាក្យថាធម៌ចាស់ថ្មី ធម៌មានបុរាណមានសម័យ ធម៌និងវិទ្យាសាស្ត្រមានគម្លាតពីគ្នា ។

ចាំបាច់ពោលអ្វី ដល់ទៅសម្ភារៈនិយម វិទ្យាសាស្ត្រនិយម ភាពចម្រើនលូតលាស់ខុសសម័យកាលនោះ ទោះបីជាសម័យវិនាសក្តី សម័យដែលចម្រើនក្តី គឺកើតចេញមកពីមនុស្សទាំងអស់ បើជីវិតមនុស្សជាធម្មៈ ធម្មជាតិទៅហើយ តើវិទ្យាសាស្ត្រ និងធម៌ ញែកចេញពីគ្នាដូចម្តេចកើត ? ។

# ជីវិតនេះ តិចណាស់

ជីវិតមនុស្សនេះ ទោះបីបានមកដោយអំណាច កុសលាភិសង្ខារ គឺកុសលតាក់តែងមក ឲ្យបានកំណើតមកជាមនុស្ស ខុសប្លែកផ្សេងៗពីគ្នា ទៅតាមចេតនាបំពេញកុសលរៀងៗខ្លួន បុគ្គលខ្លះមានកាយសម្បទាបរិបូណ៌ ប្រកបដោយទ្រព្យសម្បត្តិ, លាភ, យស, សុខ, សរសើរ បុគ្គលខ្លះខ្វះខាតខាងរាងកាយ ក្លាយជាអ្នកពិកលពិការ បាត់បង់ទ្រព្យសម្បត្តិ, លាភ, យស, សុខ, សរសើរ ។ ទោះបីជីវិតប្រព្រឹត្តទៅមិនបានស្មើគ្នា ជាជីវិតសមប្រាថ្នាក្តី មិនសមប្រាថ្នាក្តី ជីវិតក្នុងលោកិយនេះខ្លីណាស់ តិចណាស់ បែកធ្លាយ ពុកផុយ វិនាសទៅឆាប់រហ័សណាស់[១] ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា **ជីវិតនេះ តិចណាស់ រមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស ( ពីមួយរយឆ្នាំ ) ទៅ បុគ្គលនោះ គង់ស្លាប់ព្រោះជរាពុំខាន** [២] ។

អធិប្បាយពាក្យថា **ជីវិតនេះ តិចណាស់** ត្រង់ពាក្យថា ជីវិត គឺអាយុ, ការតាំងនៅ, ការរស់នៅ, ការញុំាងអត្តភាពឲ្យរស់នៅ, ការ

---

(១) ព្រះពុទ្ធដីការ ក្នុងបិដកលេខហុកសិបបួន (៦៤) ។ **ខុទ្ទកនិកាយ មហានិទ្ទេស បឋមភាគ** ទំព័រពីររយម្ភៃមួយ (២២១) ។

(២) **ជរាសុត្តនិទ្ទេស** ទី ៦ ទំព័រមួយរយប៉ែតសិបមួយ (១៨១) ។

ដើរទៅ, ការប្រព្រឹត្តទៅ, ការរក្សាជីវិត, ជីវិតិន្ទ្រិយ ។ មួយទៀត ជីវិតតិច, ជីវិតស្តួចស្តើង ដោយហេតុពីរគឺ ៖ ជីវិតតិច ព្រោះជាធម្មជាតិតាំងនៅតិច ១ , ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិច ១ [១] ។

**ជីវិតតិច** ព្រោះជាធម្មជាតិតាំងនៅតិច តើមានន័យដូចម្តេច ? សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន នឹងមិនរស់នៅក្នុងអនាគតទេ ។ សត្វនឹងរស់នៅក្នុងខណៈចិត្ត ជាអនាគត មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន មិនរស់នៅហើយក្នុងអតីតទេ ។ សត្វដែលកំពុងរស់នៅ ក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយក្នុងអតីត នឹងមិនរស់នៅក្នុងអនាគតទេ ។

**ជីវិត** អត្តភាព សុខនិងទុក្ខទាំងអស់ ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈចិត្តប្រព្រឹត្តទៅរហ័ស ពួកទេវតាណា ឋិតនៅអស់ ៨៤ ពាន់កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្ត ២ ហើយរស់នៅទេ ខន្ធទាំងឡាយណារបស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន ។ ខន្ធទាំងឡាយណា ដែលកន្លងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនា-

---

(១) **ជរាសុត្តនិទ្ទេស** ទី ៦ ទំព័រមួយរយប៉ែតសិបពីរ (១៨២) ។

គត នឹងបែកធ្លាយផង សេចក្តីផ្សេងៗគ្នានៃខន្ធទាំងឡាយ ជាបច្ចុប្បន្នដែលរលត់ហើយ ក្នុងចន្លោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈសត្វលោក ដែលកើតហើយដោយអនាគតក្ខន្ធដែលមិនទាន់កើត មិនឈ្មោះថារស់នៅហើយ ទាំងមិនឈ្មោះថាកំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត ( នេះជា ) **បញ្ញត្តិនៃបរមត្ថ** ការប្រែប្រួលទៅដោយឆន្ទៈ ដូចជាទីទាប រមែងប្រព្រឹត្តទៅដូច្នោះ វេទនាទាំងឡាយមានសឡាយតនៈជាបច្ច័យ មានវារៈមិនដាច់ តែងប្រព្រឹត្តទៅខន្ធទាំងឡាយ ដែលបែកធ្លាយហើយ ក៏មិនដល់នូវការតម្កល់ទុកគំនរនៃខន្ធ ក្នុងអនាគតក៏មិនមាន ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងឋិតនៅដូចគ្រាប់ស្នៃ ដែលឋិតនៅលើចុងដែកស្រួចកាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះ ក៏ឋិតនៅក្នុងខាងមុខសភាវៈដែលត្រូវវិនាសទាំងឡាយ (ខន្ធ) កំពុងឋិតនៅមិនច្រឡូកច្រឡំដោយខន្ធចាស់ទេ រមែងមកអំពីទីមើលមិនឃើញលុះបែកធ្លាយហើយតែងទៅកាន់ទីមើលមិនឃើញវិញរមែងកើតឡើងផង រមែងវិនាសទៅផងដូចជាផ្លេកបន្ទោរព្ធដ៏អាកាស ។

**ជីវិតតិច** ព្រោះការឋិតនៅតិច យ៉ាងនេះ ។

**ជីវិតតិច** ព្រោះកិច្ចរបស់ខ្លួនតិច តើមានន័យដូចម្តេច ?

ជីវិតជាប់ទាក់ទងដោយដង្ហើមចូល, ជីវិតជាប់ទាក់ទងដោយដង្ហើមចេញ, ជីវិតជាប់ទាក់ទងដោយដង្ហើមចូលនិងដង្ហើមចេញ, ជីវិតជាប់ទាក់ទងដោយមហាភូតរូប, ជីវិតជាប់ទាក់ទងដោយភ្លើងធាតុ, ជីវិតជាប់ទាក់ទងដោយអាហារជាពំនូត, ជីវិតជាប់ទាក់ទងដោយវិញ្ញាណ ។ ឫសគល់របស់ធម៌ទាំងនេះ មានកម្លាំងថយ ។ សូម្បីពួកធម៌ណាជាបច្ច័យ ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណាជាប្រភព ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ ធម៌ណាដែលកើត ជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ពួកធម៌ប្រកបជាមួយគ្នា នឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ធម៌ដែលកើតឡើង ជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។

ធម្មជាតិណាជាគ្រឿងប្រកប ធម្មជាតិនោះ ក៏មានកម្លាំងថយ ។ ធម៌ទាំងនេះមានកម្លាំងថយជានិច្ចដល់គ្នានិងគ្នា ។ ធម៌ទាំងនេះ មិនឱនរកគ្នានិងគ្នា ។ ធម៌ទាំងនេះញុំាងគ្នានិងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះមិនជាទីពឹងដល់គ្នានិងគ្នា ។ មួយវិញទៀត ធម៌ទាំងនេះ មិនតម្កល់ទុក នូវគ្នានិងគ្នា ។ សូម្បីធម៌ណា ជាអ្នកបង្កើត ធម៌នោះ ក៏មិនមាន ។ ធម៌ណាមួយ មិនមែនវិនាសដោយធម៌ណាមួយទេ ។ ព្រោះថា ធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះ កើតហើយព្រោះហេតុនិងបច្ច័យអំពីមុន ។ ហេតុនិងបច្ច័យណា ដែលកើតមុន ហេតុនិងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ។ ធម៌ទាំងឡាយ ខាងដើម

និងខាងចុង មិនបានឃើញគ្នានិងគ្នា ក្នុងកាលណាមួយឡើយ ។ **ជីវិតតិច** ព្រោះកិច្ចរបស់ខ្លួនតិចយ៉ាងនេះ ។

មួយទៀត ពួកមនុស្សមានជីវិតតិច ជីវិតស្ដួចស្ដើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតឆាប់ ជីវិតមិនមាំមួន ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិត របស់ពួកទេវតាក្នុងជាន់ចាតុម្មហារាជិកា , របស់ពួកទេវតាជាន់តាវត្តិង្ស , របស់ទេវតាជាន់យាមៈ , របស់ទេវតាជាន់តុសិត , របស់ទេវតាជាន់និម្មានរតី , របស់ទេវតាជាន់បរនិម្មិតវសវត្តី ។ ពួកមនុស្ស មានជីវិតតិច , ជីវិតស្ដួចស្ដើង , ជីវិតថយថោក , ជីវិតមានក្នុងមួយខណៈ , ជីវិតរហ័ស , ជីវិតឆាប់ , ជីវិតមិនមាំមួន , ជីវិតមិនឋិតនៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ពួកទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះដ៏មានព្រះភាគត្រាស់ថា ៖ " *ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះតិច បរលោកពួកសត្វត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយៈ ( ព្រោះថា ) សត្វដែលកើតហើយ មិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅអស់កាលយូរ បុគ្គលនោះគប្បីរស់នៅ ១០០ ឆ្នាំ តិចពីមួយរយឆ្នាំឬច្រើនជាងមួយរយឆ្នាំ* " ។

អាយុរបស់ពួកមនុស្សតិច បុគ្គលល្អគប្បីនឿយណាយនឹងអាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គល ដែលភ្លើងឆេះក្បាល ដំណើរមិនមកនៃមច្ចុ មិនមានទេ ថ្ងៃនិងយប់តែងកន្លងទៅ ជីវិតក៏ស្រក

ស្រុតទៅដែរ អាយុរបស់ពួកសត្វ រមែងអស់ទៅ ដូចជាទឹកនៃស្ទឹងតូចទាំងឡាយ ។

ពាក្យថា សត្វរមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ[១] អធិប្បាយថា ៖

• សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាកលលៈ ក៏មាន ;

• សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាអម្ពុទៈ ក៏មាន ;

• សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបេសិ ក៏មាន ;

• សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាឃនៈ ក៏មាន ;

• សត្វរមែងច្យុត ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបញ្ចសាខា ក៏មាន ;

• សត្វគ្រាន់តែមានកំណើត ច្យុត ស្លាប់ បាត់បង់ វិនាស ក៏មាន ។

សេចក្ដីសង្ខេប សត្វកើតមកបានកន្លះខែក្ដី, មួយខែក្ដី, កន្លះឆ្នាំក្ដី, មួយឆ្នាំក្ដី, ប៉ែតសិបឆ្នាំក្ដី, កៅសិបឆ្នាំក្ដី, ច្យុត, ស្លាប់,

---

(១) **ជរាសុត្តនិទ្ទេស** ទី ៦ ទំព័រមួយរយប៉ែតសិបពីរ (១៨៣) ។

បាត់បង់, វិនាសទៅវិញ ក៏មាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលរមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ ។

ពាក្យថា បើបុគ្គលណា រស់នៅកន្លងហួសទៅ គឺបុគ្គលណារស់នៅកន្លងមួយរយឆ្នាំ បុគ្គលនោះ រស់នៅអស់មួយឆ្នាំក្តី ពីរឆ្នាំក្តី, រស់នៅរហូតអស់សាមសិបឆ្នាំក្តី, រស់នៅរហូតអស់សែសិបឆ្នាំក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើបុគ្គលណា រស់នៅកន្លងហួសទៅ[១] ។

ពាក្យថា បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន អធិប្បាយថាកាលណាបុគ្គលចាស់ ចម្រើនដោយវ័យ មានអាយុច្រើនកន្លងកាល ជ្រុលចូលក្នុងបច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលឆកស្បែកជ្រីវជ្រួញ ខ្នងកោងកាន់ឈើច្រត់ បុគ្គលនោះគង់ច្យុតស្លាប់ បាត់បង់ វិនាស ព្រោះជរា[២] ។

ការរួចចាកមរណៈមិនមានទេ សត្វទាំងឡាយដែលកើតហើយ តែងមានភ័យពីមរណៈជានិច្ច ដូចជាផ្លែឈើទុំទាំងឡាយតែងមានភ័យអំពីការជ្រុះចុះក្នុងវេលាព្រឹក, ភាជន៍ដី ដែលកុម្ភការធ្វើហើយទាំងអស់ មានការបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិត

(១) **ជរាសុត្តនិទ្ទេស** ទី ៦ ទំព័រមួយរយប៉ែតសិបបួន (១៨៤) ។

(២) **ជរាសុត្តនិទ្ទេស** ទី ៦ ទំព័រមួយរយប៉ែតសិបប្រាំ (១៨៥) ។

របស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ពួកជនណា ទាំងក្មេង, ទាំងចាស់, ទាំងពាល, ទាំងបណ្ឌិត ពួកជនទាំងនោះរមែងលុះអំ - ណាចនៃមច្ចុរាជ ។ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅខាងមុខ កាលពួកជនទាំងនោះ ដែលមច្ចុគ្របសង្កត់ ទៅកាន់បរលោក បិតាពឹងបុត្រមិនបាន ឬថាពួកញាតិពឹងពួកញាតិក៏មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសម្លឹងមើល កំពុងយំរៀបរាប់ច្រើន សត្វលោក ដែលត្រូវមច្ចុនិងជរាបំផ្លាញហើយ ដូចជាបណ្តាសត្វទាំងឡាយ គោមួយៗដែលត្រូវគេនាំទៅសម្លាប់ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន ។

ហេតុនោះ **ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖**

**" ជីវិតនេះ តិចណាស់ រមែងស្លាប់ខាងអាយ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស ( ពីមួយរយឆ្នាំ ) ទៅ បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន "** ។

ខ្ញុំព្រះករុណា ខ្ញុំបាទបានដកស្រង់យកព្រះពុទ្ធដីកា ដែលមានក្នុង **គម្ពីរសុត្តន្តបិដក** ដែលព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបានសម្តែងបញ្ជាក់ អំពីជីវិតនេះ ឲ្យឃើញថាតិចតួចណាស់ ខ្លីណាស់ ឆាប់រហ័សណាស់ ប្រកបដោយការប្រៀបធៀប មានអត្ថន័យពិរោះក្បោះក្បាយ សុខុមលំអិត និងគួរឲ្យមានចិត្តសង្វេគ តក់ស្លុត រន្ធត់ភ័យយ៉ាងក្រៃលែងណាស់ គ្រប់តែជីវិតនេះ ។

ខន្ធចាស់, ខន្ធថ្មី, ខន្ធជាអតីត, ខន្ធអនាគត, ខន្ធបច្ចុប្បន្ន ខន្ធទាំងអស់នេះ មិនបានពឹងពាក់ពំនាក់អាស្រ័យដល់គ្នានឹងគ្នា ជីវិតជាអតីត ដឹងបានតែក្នុងជីវិត ដែលកំពុងប្រព្រឹត្តទៅតែក្នុងអតីត, ជីវិតបច្ចុប្បន្ន ដឹងបានតែក្នុងជីវិត ដែលកំពុងប្រព្រឹត្តទៅតែក្នុងបច្ចុប្បន្ន, ជីវិតអនាគត ក៏ដូច្នោះដែរ ។ ជីវិតក្នុងកាលអតីតបែកធ្លាយរលត់រលាយទៅ ក៏ជាជីវិតអតីត ពុំមែនជាជីវិតក្នុងបច្ចុប្បន្ន ឬក៏ជាជីវិតក្នុងអនាគតទេ ជីវិតកើតបានក្នុងកាលណាជាបច្ចុប្បន្ន អតីត អនាគត ក៏រមែងរលត់ទៅក្នុងកាលនោះៗ ។

ព្រោះហេតុដូច្នោះហើយ ទើបសត្វលោករស់នៅដោយស្មានៗ ឥតបានដឹងថាខ្លួនមកអំពីទីណា មកកើតទីនេះ កាលពីអតីតជាតិមានភេទជាអ្វី ? ជាមនុស្សឬជាសត្វ សោយសុខទុក្ខដោយប្រការណាក៏ឥតបានដឹង លុះបែកធ្លាយរំលាយខន្ធអំពីលោកនេះទៅ នឹងទៅកើតក្នុងទីណា ? ក៏មិនដឹងថាប្រាប់បានក្នុងកាលជាអនាគត ។ ត្រង់ចំណុចនេះ ទើបបញ្ជាក់ឲ្យយល់បានថា ខន្ធចាស់ ខន្ធថ្មី មិនអាស្រ័យដល់គ្នា មិនជាទីពឹងពំនាក់ ឬជួយឧបត្ថម្ភរវាងគ្នាសោះឡើយ ។

**ជីវិត** ពុកផុយ បែកស្រាំទៅឆាប់រហ័ស បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គបានប្រៀបធៀប ជីវិតនេះថា ដូចជាផ្លេកបន្ទោរ ព្រោះផ្លេកបន្ទោរអាចបញ្ចាំងកាំរស្មីទៅបាន ត្រឹមតែមួយខណៈ មួយប៉ប្រិចភ្នែកប៉ុណ្ណោះ ចាំងហើយក៏រលត់ ហើយក៏ចាំង

ធ្លុះឡើងទៀត យ៉ាងណា ជីវិតក៏កើតរលត់ៗទៅតាមខណៈចិត្ត មួយខណៈៗដូច្នោះដែរ ។ ជីវិតប្រៀបបាននឹងគ្រាប់ស្លែ ដែលជាប់នៅលើចុងដែកដ៏ស្រួច បានន័យថា គ្រាប់ស្លែដ៏តូចតើនឹងអាចឋិតនៅលើចុងដែកដ៏ស្រួច បានត្រឹមរយៈកាលយូរប៉ុន្មាន ? រមែងត្រូវខ្យល់បោកបក់ រសាត់ធ្លាក់សូម្បីតែស្រមោលក៏មើលមិនឃើញផង យ៉ាងណាមិញ ជីវិតតែងជួបប្រទះនូវបញ្ហា ជាអនេកប្រការរាប់មិនអស់ ឧបសគ្គភយន្តរាយ រមែងធ្វើឲ្យជីវិតទទួលនូវភាពវិនាស បាត់បង់ទៅគ្រប់ខណៈទាំងអស់ ។

ផ្លែឈើទុំ នឹងត្រូវរោយរុះជ្រុះចាកទងធ្លាក់មកលើផែនដីស្អុយរលួយបានជាចំណីនៃសត្វដង្កូវយ៉ាងណា ជីវិតក៏យ៉ាងនោះដែរ ។ ពពុះទឹកក្តី ក្រពេញទឹកក្តី ប៉ោងឡើងហើយបែកទៅវិញ ក្រពេញទឹកមានចលនាព្រួចចុះព្រួចឡើង មិននឹងនរ មិនប្រាកដប្រជា ជីវិតនេះក៏ឋិតនៅក្នុងសភាពមិនទៀងទាត់ដូច្នោះដែរ ។

ខ្យល់បោកបក់ បង្កើតឲ្យបានជាបណ្តាញទឹករលកបណ្តោញគ្នាជាចង្វាក់មុនក្រោយ បោះពួយឆ្ពោះមករកច្រាំង ទឹករលកជាចង្វាក់មុន មកដល់បោកប៉ះផ្ទប់នឹងច្រាំងមុនក៏បែកមុន ទឹករលកជាចង្វាក់បន្ទាប់ ក៏បែកខ្ចាយជាបន្ទាប់ ទឹករលកដែលមកដល់ជាខាងក្រោយ ក៏បែកទៅជាខាងក្រោយយ៉ាងណា ធម៌ជាបច្ច័យដល់ជីវិត ធម៌ណាកើតមុន ក៏រលត់មុន ធម៌ណាកើតជាខាងក្រោយ ក៏រលត់ក្នុងកាលជាខាងក្រោយ ។ ខណៈចិត្តកើតឡើងជាខាង

ក្រោយបន្តមកទៀត ក៏រលត់ក្នុងពេលជាខាងក្រោយបន្តៗទៅ ។

**ជីវិត** ជាសហជាតប្បច្ច័យ អាស្រ័យដោយខ្យល់ដង្ហើមចេញ-ចូល ទាក់ទងដោយមហាភូតរូបបួន អាស្រ័យបានដោយភ្លើងធាតុ រស់បានដោយអាហារជាពំនូត ជីវិតពុកផុយ បែកស្រាំបាត់បង់ទៅឆាប់រហ័ស បច្ច័យជាទីអាស្រ័យរបស់ជីវិតសោតទៀតក៏ជារបស់ពុកផុយ ឆាប់វិនាស មានកម្លាំងថយ មិនអាចជួយឧបត្ថម្ភគ្នាបាន ។ ក្នុងបច្ច័យនីមួយៗ អាចប្រព្រឹត្តទៅបានតាមនាទីរបស់ខ្លួនតែប៉ុណ្ណោះ បើមានបច្ច័យណាមួយ ទ្រុឌទ្រោមខូចខាតដោយប្រការណាមួយហើយ បច្ច័យឯទៀតៗក៏វិនាសបាត់បង់ខូចខាតទៅជាមួយដែរ ។

ឧទាហរណ៍ ដូចជាឧបករណ៍ភ្លើង ឬគ្រឿងយន្តមានរថយន្តជាដើម ភ្លើងដែលមានពន្លឺទៅបាន ត្រូវមានម៉ាស៊ីនភ្លើងដែលជាប្រភព ជាមេភ្លើង មានខ្សែភ្លើង មានអំពូលភ្លើង ម៉ាស៊ីនភ្លើងមាននាទីខាងការបង្កើត បញ្ចេញភ្លើងឲ្យរត់ទៅតាមខ្សែភ្លើង ខ្សែភ្លើងមាននាទីទទួលភ្លើងឲ្យរត់ចូលទៅកាន់អំពូលភ្លើង អំពូលភ្លើងមាននាទីក្នុងការបញ្ចេញពន្លឺភ្លើង ឲ្យភ្លឺស្វាងបាន ។

ម៉ាស៊ីនភ្លើងក្តី, ខ្សែភ្លើងក្តី, អំពូលភ្លើងក្តី ទាំងបីយ៉ាងនេះសុទ្ធតែត្រូវការជាចាំបាច់ ប្រព្រឹត្តទៅតាមនាទីជាប្រក្រតី បើវត្ថុណាមួយខូចគាំងមិនដើរហើយ វត្ថុដទៃក៏ឥតបានការដែរ ដូចជា

ម៉ាស៊ីនភ្លើងគាំងមិនដើរ មិនអាចបង្កើតបញ្ចេញភ្លើងបាន ខ្សែភ្លើង អំពូលភ្លើង ក៏មិនអាចមានភ្លើងទទួលបញ្ចេញជាពន្លឺបាន ។ បើសិនជាអំពូលដាច់ ខ្សែភ្លើងខូច ក៏ដូចតែគ្នា គឺគ្មានប្រយោជន៍អ្វីដែលត្រូវបានអំពីភ្លើងនោះ ក៏ទេដែរ ។

ឯចំណែកគ្រឿងយន្តយាន មានរថយន្តជាដើម ក៏កាន់តែបញ្ជាក់ឲ្យយើងងាយយល់ចូលចិត្តណាស់ទៅទៀត ។ ម៉ាស៊ីនរថ-យន្តមានឧបករណ៍ ប្រព្រឹត្តទៅល្អគ្រប់គ្រាន់ មិនខូច នៅពេលគេបញ្ឆេះម៉ាស៊ីន ត្រូវមានភ្លើងចេញពីធុងអាគុយ (Batterie) តាមខ្សែទៅកម្ដៅគ្រឿងសម្ភារៈផ្សេងៗទៀត ឲ្យមានចលនាកម្រើកទៅបាន បន្ទាប់មកជានាទីរបស់ម៉ាស៊ីនភ្លើងបង្កើតភ្លើង (Alternateur) បញ្ចេញភ្លើង បញ្ចូលទៅបំពេញធុងអាគុយឲ្យពេញដូចដើមវិញ ។ បានន័យថាឧបករណ៍នីមួយៗ មានចលនាទៅតាមមុខនាទី ប៉ុន្តែបើមានឧបករណ៍ណាមួយខូចគាំងហើយ ឧបករណ៍ដទៃៗទៀតក៏មិនអាចមានចលនាបាន ដូចជាធុងអាគុយអស់ភ្លើងហើយ គ្រឿងម៉ាស៊ីនរថយន្តទាំងអស់ក៏ត្រូវគាំងលែងដើរដែរ ដែលគេហៅថាម៉ាស៊ីនខូចនោះឯង ។ បានន័យថា គ្រឿងម៉ាស៊ីនតែមួយផ្នែកៗធ្វើការទៅតាមនាទីរបស់ឧបករណ៍នោះៗ បើមានឧបករណ៍ណាមួយគាំងឬខូចហើយ ឧបករណ៍ឯទៀតៗរមែងគាំងលែងដើរដូចគ្នាឥតមានឧបករណ៍ណា មកជំនួសឧបករណ៍ណាបានឡើយ ។

យ៉ាងណាមិញ អត្តភាពគឺរាងកាយ មនុស្ស សត្វ ក៏ដូច

គ្នា ។ ជីវិតដែលប្រព្រឹត្តទៅបាន អាស្រ័យបច្ច័យ ដូចបានពោល រៀបរាប់រួចមកហើយ ដូចជាមហាភូតរូបបួន បានដល់ **ដី, ទឹក, ភ្លើង, ខ្យល់** ប្រជុំបានជារូបកន្ធ យើងអាចចាប់កាន់ពាល់ត្រូវបាន ចែកចេញទៅជាអាការៈលក្ខណៈ ត្រង់ណារឹងៗចាត់ថាជា **បឋវីរូប** , ត្រង់ណារាវជ្រួតជ្រាបចាត់ថា **អាបោរូប** , ត្រង់ណាក្តៅឧណ្ហៗចាត់ថាជា **តេជោរូប,** ត្រង់ណាកម្រើកញ័រល្ហើយៗចាត់ថាជា **វាយោរូប**។

ការពោលមកនេះ គ្រាន់តែជាលក្ខណៈ បើចែកទៅតាមអាការៈឲ្យឃើញទៅជាចំណែកនីមួយៗ **បឋវីដី** មាន **២០** ៖

| | |
|---|---|
| ១. **កេសា** : សក់ | ១១. **ហទយំ** : បេះដូង |
| ២. **លោមា** : រោម | ១២. **យកនំ** : ថ្លើម |
| ៣. **នខា** : ក្រចក | ១៣. **កិលោមកំ** : វាវ |
| ៤. **ទន្តា** : ធ្មេញ | ១៤. **បិហកំ** : ក្រពះ |
| ៥. **តចោ** : ស្បែក | ១៥. **បប្ផាសំ** : សួត |
| ៦. **មំសំ** : សាច់ | ១៦. **អន្តំ** : ពោះវៀនធំ |
| ៧. **ន្ហារូ** : សរសៃ | ១៧. **អន្តគុណំ** : ពោះវៀនតូច |
| ៨. **អដ្ឋី** : ឆ្អឹង | ១៨. **ឧទរិយំ** : អាហារថ្មី |
| ៩. **អដ្ឋិមញ្ជំ** : ខួរក្នុងឆ្អឹង | ១៩. **ករីសំ** : អាហារចាស់ |
| ១០. **វក្កំ** : ទាច | ២០. **មត្ថកេមត្ថលុង្គំ** : ខួរក្នុងក្បាល |

**អាបោ : ទឹក** មាន **១២ ៖**

១. **បិត្តំ :** ទឹកប្រមាត់
២. **សេម្ហំ :** ស្លេស្ម៍
៣. **បុព្វោ :** ខ្ទុះ
៤. **លោហិតំ :** ឈាម
៥. **សេទោ :** ញើស
៦. **មេទោ :** ខ្លាញ់ខាប់
៧. **អស្សុ :** ទឹកភ្នែក
៨. **វសា :** ខ្លាញ់រាវ
៩. **ខេឡោ :** ទឹកមាត់
១០. **សង្ឃាណិកា :** ទឹកសម្បោរ
១១. **លសិកា :** ទឹករំអិល
១២. **មុត្តំ :** ទឹកមូត្រ

**តេជោ : ភ្លើង** មាន **៤ ៖**

១. **សន្តប្បគ្គិ** : ភ្លើងដែលញុំាងកាយឲ្យក្តៅ ;
២. **ជិរណគ្គិ** : ភ្លើងដែលញុំាងកាយឲ្យទ្រុឌទ្រោម ;
៣. **បរិណាមគ្គិ** : ភ្លើងដែលញុំាងកាយឲ្យក្រហល់ក្រហាយ ;
៤. **បរិទយ្ហគ្គិ** : ភ្លើងដែលដុតអាហារឲ្យរលួយ ;

**វាយោ : ខ្យល់** មាន **៦ ៖**

១. **ឧទ្ធង្គមវាត** : ខ្យល់បក់ឡើងលើ ;
២. **អធោគមវាត** : ខ្យល់បក់ចុះក្រោម ;
៣. **កុច្ឆិសយវាត** : ខ្យល់បក់ក្នុងពោះ ;
៤. **កោដ្ឋាសយវាត** : ខ្យល់បក់ក្នុងពោះវៀន ;

៥. **អង្គមង្គានុសារីវាត** : ខ្យល់បក់តាមរាងកាយ ;

៦. **អស្សាសបស្សាសវាត** : ខ្យល់ដកដង្ហើមចេញចូល ;

ការបែងចែកអាការៈរូបធាតុ ឲ្យឃើញទៅជាមួយផ្នែកៗ ដែលមាននៅក្នុងអត្តភាពរូបរាងកាយ របស់មនុស្ស សត្វទាំង - ឡាយដែលជាសម្ភារៈឧបករណ៍និងជាបច្ច័យនៃជីវិត ពិតជាមិនខុសអំពីគ្រឿងយន្តយានប៉ុន្មានទេ ព្រោះមហាភូតរូប ប្រជុំបានជារាងកាយ មានចំណែកជាដី ទឹក ភ្លើង ខ្យល់ ចែកទៅជាអាការៈច្រើនផ្នែក មាននាទីប្រព្រឹត្តទៅផ្សេងៗពីគ្នា ជារបស់ពុកផុយប្រេះស្រាំ បាក់បែក ខូចខាត វិនាសទៅឆាប់រហ័សណាស់ មានកម្លាំងថយមិនអាចពឹងពាក់ ពំនាក់អាស្រ័យ ជួយជំនួសគ្នាបានទេ ។

ដូចជា ក្រពះ, សួត, ប្រមាត់, ថ្លើម, បេះដូង, ពោះវៀនតូច, ពោះវៀនធំជាដើម របស់ទាំងនេះធ្វើកិច្ចការដោយឡែកពីគ្នា បើសិនជាមានរបស់ណាមួយខូចខាត បាត់បង់មិនអាចកែកុនជំនួសបានទេ គេក៏មិនអាចយករបស់ផ្សេងមកជួស ឬជំនួសបានដែរ ។ ម្យ៉ាងវិញទៀត របស់ទាំងនេះ មានកិច្ចនាទីផ្សេងគ្នាមែន តែត្រូវមានចលនាប្រព្រឹត្តទៅព្រមគ្នា ជាសហជាតបច្ច័យ តែត្រង់ថាមិនអាចជាជំនួយគ្នាបាន ដូចជាក្រពះ មាននាទីខាងការរំលាយអាហារ កាលណាបើក្រពះត្រូវឈឺខូចខាតបាត់បង់ប្រព្រឹត្តទៅលែងបានហើយ ឧបករណ៍ដទៃទៀតក៏ត្រូវខូចខាតវិនាសទៅដូច

គ្នាដែរ ។ វាយោរូប ធាតុខ្យល់មាននាទីខាងដកដង្ហើមចេញ-ចូល ប៉ុន្តែបើខ្យល់គាំងស្ទះ មិនអាចមានខ្យល់ចេញ-ចូលបាន គឺដាច់ខ្យល់ អ្វីៗទាំងអស់ក្នុងសព៌ាង្គកាយ ក៏ត្រូវគាំងបាត់បង់អស់ដូចគ្នាដែរ ។ ភ្លើងធាតុជាកម្តៅត្រូវរលត់ ធាតុទឹកត្រូវកកខាប់ ធាតុដីត្រូវហើមប៉ោង ប្រេះបែកញែកចេញពីគ្នា រលេះរលួយទៅ ជីវិតត្រូវរលត់ ។

ព្រោះហេតុដូច្នេះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖ " **ជីវិតតិចដោយកិច្ចរបស់ខ្លួន ដ្បិតជីវិតក្តី សម្ភារៈជាគ្រឿងអាស្រ័យសម្រាប់ជីវិតក្តី សុទ្ធតែជាធម្មជាតិ ពុកផុយទៅឆាប់រហ័ស មិនអាចផ្លាស់ប្តូរ និងមិនអាចជាជំនួយដល់គ្នាបាន** " ។

ការពោលរៀបរាប់មកនេះ អាចបញ្ជាក់បានថា ជីវិតសព្វសត្វក្នុងលោក ទោះបីជាផ្សេងដោយឡែកពីគ្នា ក៏ជីវិតមានស្មើដូចគ្នា គឺកើតឡើងហើយ ក៏រលត់ទៅវិញ ទោះបីជាម្ចាស់ជីវិតខំស្រឡាញ់ការពារ ឲ្យតម្លៃយ៉ាងណាក៏ដោយ ។



# ជីវិតនេះតិចណាស់

## បទពាក្យប្រាំពីរ

*ជីវិតសត្វលោកមានតិចណាស់ បញ្ជាក់យ៉ាងច្បាស់ព្រះពុទ្ធដីកា*
*ដាស់តឿនទូន្មានរាល់រូបា ឲ្យកើតប្រាជ្ញាស្មារតី ។*
*កុំឲ្យប្រមាទក្នុងជីវិត ព្យាយាមតាំងចិត្តទាំងយប់ថ្ងៃ*
*ដុសខាត់សម្អាតកាយវចី លកលៃបំពេញបុណ្យកុសល ។*
*ធ្វើទុកឲ្យហើយសម្រាប់ជីវិត ឈ្មោះប្រសើរពិតមានភោគផល*
*នៅពេលស្លាប់ទៅមិនបាច់ឆ្ងល់ មានបុណ្យកុសលតម្កល់ទុក ។*

ដោយ ឧបាសក **មុិញ សាវ៉ាន**



# សត្វលោក វង្វេងនឹងជីវិត

ដោយភាពស្រឡាញ់ពេញចិត្ត ប្រកាន់ហួងហែង លើកកម្ពស់ ឲ្យតម្លៃដល់ជីវិតគ្រប់ៗគ្នា ទើបធ្វើឲ្យសត្វលោក ជាប់ជំពាក់ វង្វេងងងឹត ឥតបានយល់ស្គាល់ ពីហេតុបច្ច័យរបស់ជីវិតពិតប្រាកដ រហូតនាំគ្នាប្រមាទភ្លេចខ្លួន គិតថាបានកើតជាមនុស្សរស់នៅមួយរយឆ្នាំ វិសេសវិសាលយូរអង្វែងណាស់ទៅហើយ ។

តាមពិត ជីវិតក្នុងសង្សារវដ្តនេះ បាននាំមកជាមួយនូវការចាស់ ឈឺ ស្លាប់ ទុក្ខសោក ជាប់មកជាមិត្តតាំងពីកកាញ់មានកំណើតមកម្ល៉េះ ។ សត្វលោក រស់ក្រោមដង្កាប់ចង្កូមមច្ចុរាជរស់ប្រកបទៅដោយសេចក្ដីល្ងិតល្ងង់ ។ រស់ក្នុងរង្វង់សត្រូវ ពោលគឺជីវិតខ្លួនឯង ដែលជាខន្ធមារ សត្វលោកមានកង្វះខាត មិនចេះឆ្អែតឆ្អន់គ្រប់គ្រាន់ ដោយនុយគឺ **កាមគុណ** មាន **រូប, សម្លេង , ក្លិន , រស , ផោដ្ឋព្វៈ** ជាប់ដោយខ្សែអន្ទាក់គឺ **ឧបាទាន**(១) អណ្ដែតទៅតាមក្រសែទឹកគឺ **តណ្ហា** លិចក្នុងអន្លង់បួនប្រការគឺ **កាមោឃៈ , ភវោឃៈ , ទិដ្ឋោឃៈ** និង **អវិជ្ជោឃៈ** ប្រឡាក់ដោយ

---

(១) ឧបាទាន អ៊ុប៉ា- សំ. បា. ( ន. ) ការប្រកាន់មាំ, ការប្រគោងចិត្តគំនិត, សេចក្ដីប្រកាន់ជាប់ស្អិត, សេចក្ដីជំពាក់ចិត្ត; ... : តណ្ហាជាបច្ច័យនៃឧបាទាន ។ ជាបច្ច័យនៃភព... ។

គ្រឿងសៅហ្មង ៣ ប្រការគឺ **លោភៈ , ទោសៈ , មោហៈ** ចេញមិនផុត វត់មិនរួចអំពីទ្រុង គឺភពទាំងបីមាន **កាមភព , រូបភព , អរូបភព** វង្វេងងងុលងប់ ជាទាសៈនៃតណ្ហា ចាញ់ឧបាយកលសេនារបស់មច្ចុមារ គឺ **ជាតិកំណើត** ។

ចាប់តាំងពីបានកើតមក ឃើញពន្លឺព្រះអាទិត្យកាលណា សត្វលោកវង្វេងនាំគ្នាសប្បាយរីករាយត្រេកអរ ប្រឡែងជាមួយជីវិត ដោយឥតបានគិតថា ជីវិតខ្លួនបាននាំមកជាមួយដោយ **ជរា , ព្យាធិ , មរណៈ** ជាប់ជាគ្នា ជាមារជាសត្រូវ បន្លំខ្លួនពួនសម្ងំ ធ្វើទុក្ខបុកម្នេញបំផ្លាញ រាល់តែជីវិតសត្វលោក តាំងពីកជាកំណើតមកម្ល៉េះ ព្រមទាំងបានបន្តតាមបៀតបៀន យាយីជីវិតគ្រប់ខណៈនាទីឥតមានឲ្យលស់ចន្លោះឡើយ ។

រស្មីនៃដួងចន្ទ្រ រមែងអ័ព្ទឥតពន្លឺ នៅពេលដែលមានពពកមកបិទបាំង ។ ព្រះអាទិត្យរះឡើងពីទិសបូព៌ាក្នុងវេលាព្រឹក តែងមានដំណើរចរលើលាឆ្ពោះទៅកាន់ទិសបស្ចិម សន្សឹមៗបន្ទាបប្រាណ ឰដ៏ជើងមេឃអស្តង្គតរលត់អស់រស្មី ស្បែងងឹតបានលាតសន្ធឹងគ្របដណ្តប់មកលើពិភពផែនដីនេះឲ្យងងឹត ប្រៀបបាននឹងដំណើរជីវិត ដែលមានដំណើរមកហើយ ក៏ពិតជាមានដំណើរត្រឡប់ទៅវិញ ជីវិតធ្វើដំណើរមកអំពីទីដែលមិនដឹង រមែងត្រឡប់ទៅរកទីមិនដឹងវិញដូច្នោះឯង ។

ការសើចសប្បាយ ត្រេកអររីករាយ លាយដោយសំណោកសោកសៅ បានផ្លាស់ប្តូរវេនគ្នា ដូចជាទិវារាត្រី ទើបឲ្យសត្វលោកភ្លេចស្មារតី គិតថាជាធម្មតារបស់ជីវិត ពិតជាយ៉ាងហ្នឹងទៅហើយ ក៏តាំងនាំគ្នាធន់ទ្រាំ តស៊ូ ធ្វើសង្គ្រាមជាមួយមច្ចុរាជដែលជាស្តេចមានអំណាច មិនអាចមានព្រះរាជាអង្គណាយកជោគជ័យបាន ។ សង្គ្រាមពីប្រទេសមួយទៅប្រទេសមួយ រវាងជាតិមួយនិងជាតិមួយ គេអាចប្រព្រឹត្តទៅដោយការឈ្នះនិងចាញ់បាន តែមច្ចុរាជសង្គ្រាម គ្មានសត្វលោកណា អាចទាមទារយកជ័យជំនះបានឡើយ ព្រោះសង្គ្រាមនេះមានស្មើទូទៅសម្រាប់ជីវិតសត្វលោកទាំងអស់ ទោះបីជាសត្វលោកនោះមានជាតិកំណើតភូមិឋានខុសផ្លែកពីគ្នាយ៉ាងណាក៏ដោយ ឲ្យតែជាលោកិយភូមិត្រូវចុះចាញ់មច្ចុសង្គ្រាមស្មើដូចគ្នា ។

ជីវិតសត្វលោក ជាទាសកររបស់តណ្ហាតាំងពីកើតមកមានការខ្វះខាត មិនដែលបានគ្រប់គ្រាន់ ។ ធម្មតាភាពជាទាស-ករ តែងតែធន់ទ្រាំនឹងសេចក្តីទុក្ខលំបាក ក្នុងការបម្រើគេ ធ្វើការមួយថ្ងៃៗបានកម្រៃគ្រាន់តែចម្អែតក្រពះមួយថ្ងៃ ស្ទើរតែមិនគ្រប់គ្រាន់ កម្លាំងកាយចិត្តជីវិតខ្លួន មានសម្រាប់ធ្វើការយកកម្រៃផលផ្តល់ជូនឲ្យម្ចាស់យ៉ាងណា ជីវិតសត្វលោកនេះ ក៏ជាទាសករយ៉ាងនោះឯង ។

ដោយការស្រឡាញ់ ជាប់ជំពាក់ហួងហែង ធ្វើឲ្យមនុស្សខំប្រឹងលើកតម្កើង ឲ្យតម្លៃខ្លួនដោយសេចក្ដីវង្វេង ភ្លេចខ្លួនមិនបានដឹងយល់ហេតុផលពិតរបស់ជីវិត ហ៊ានប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ដោយសម្អាងយកខ្លួនជាធំ ។ ទោះបីជាអំពើអាក្រក់ដែលខ្លួនកំពុងប្រព្រឹត្តនោះនឹងផ្ដល់ផលជាទុក្ខ ជាទោស សុខចិត្តនៅពើធ្វើមិនដឹង ប្រឹងត្រេកអររីករាយសប្បាយដោយភាពវង្វេងដូចជាសត្វដង្កូវកើតនៅក្នុងបង្គន់ ។

សត្វដង្កូវ កើតចេញពីលាមក រមែងមានរសជាតិ ក្លិនលាមកដក់ជិតស្អិតជាប់ពេញខ្លួន តែសត្វដង្កូវនៅតែមិនដឹង ប្រឹងសប្បាយរីករាយដោយសាររាងកាយ បានធំធាត់ដោយការបរិភោគលាមកជាអាហារ យ៉ាងណាមិញ សត្វលោកកំពុងញៀនញ៉មទៅតាមចំណី គឺ **កាមគុណ** រមែងត្រេកអររំភើបញាប់ញ័រដោយ ទ្រព្យសម្បត្តិ លាភយស អំណាច តំណែងនាទី សរសើរ សុខ ភ្លេចលែងគិតដល់បញ្ហាទុក្ខ ដែលមានប្រចាំមកលើជីវិត ។

សេចក្ដីទុក្ខ ទៅតាមសាមញ្ញភាសា អ្នកក្រទុក្ខព្រោះសេចក្ដីអត់ឃ្លាន រីឯអ្នកមាន ទុក្ខព្រោះការហួងហែងរក្សាការពារ ខ្លាចបាត់បង់ទ្រព្យ ។ តាមពិត ជីវិតសព្វសត្វក្នុងសង្សារវដ្ដនេះ សុទ្ធតែជាជីវិតកំពុងហែលឆ្លង កំពុងលិចលង់ ឈ្លក់ជ្រមុជ នៅក្នុងអន្លង់នៃសេចក្ដីទុក្ខបួនប្រការ នឹងត្រូវជួបប្រទះបញ្ហា ជាអនេក

ប្រការ ដោយគ្មានសត្វណា អាចឆ្លងឲ្យបានដល់ត្រើយដោយងាយៗនោះទេ ។

*បុគ្គលមានចិត្តសង្វេគ*
*ឈ្មោះថាជាអ្នកមិនមានដំណោកលង់លក់ក្នុងភព*
*បុគ្គលមិនប្រមាទទាំងថ្ងៃយប់*
*ឈ្មោះថាមិនបានបណ្ដោយឲ្យកាលវេលាកន្លងទៅទទេ*
*បុគ្គលមានព្យាយាមឥតទំនេរ*
*ឈ្មោះថាមិនបានបាត់បង់នូវគុណប្រយោជន៍*
*បុគ្គលមានសទ្ធានិងបញ្ញា*
*ពិចារណាតាមកម្មផល*
*ឈ្មោះថាជាអ្នកបានយល់ច្បាស់ពីសុខទុក្ខក្នុងសង្សារវដ្ដ ។*

ដោយ ឧបាសក **ម៉ិញ សាវ៉ាន**



# អន្លង់បួនប្រការ

១. **កាមោឃៈ** អន្លង់គឺកាម ៣. **ទិដ្ឋោឃៈ** អន្លង់គឺទិដ្ឋិ
២. **ភវោឃៈ** អន្លង់គឺភព ៤. **អវិជ្ជោឃៈ** អន្លង់គឺអវិជ្ជា

ពាក្យថា **ឱឃៈ** (ជាភាសាសំស្រ្កឹត ឬជាភាសាបាលី) ប្រែជាភាសាខ្មែរបានន័យថា ៖ អន្លង់, ជំនន់, ទឹកដែលឡើងលិចជ្រៅ, កម្លាំងខ្សែទឹក , ទឹកដែលហូរសំយុងចុះខ្លាំង , កិលេសដែលធ្វើឲ្យសត្វលិចលង់ធ្លាក់ចុះក្នុងសេចក្តីវិនាសអន្ទោលកើតស្លាប់ក្នុងអន្លង់

## ❖ អន្លង់ទីមួយ កាមោឃៈ

អន្លង់គឺកាម ពាក្យថា **កាមៈ** (ជាភាសាបាលី) ជាភាសាខ្មែរប្រែថា សេចក្តីប្រាថ្នា, ចំណង់, ទ្រព្យសម្បត្តិនិងកិលេសដែលសត្វតែងប្រាថ្នា ។ ស័ព្ទនេះអាចប្រើភ្ជាប់ជាមួយ ស័ព្ទដទៃទៀតបានជាអនេក ដូចជា ៖ កាមគុណ, កាមតណ្ហា, កាមរាគ, កាមរោគ, កាមច្ឆន្ទៈ ដូច្នេះជាដើម ។

**កាមៈ** ចែកចេញជាពីរយ៉ាងគឺវត្ថុកាម ១, កិលេសកាម ១។

**១. វត្ថុកាម** តើដូចម្តេច ? រូបជាទីគាប់ចិត្ត, សម្លេងជាទីគាប់ចិត្ត, ក្លិនជាទីគាប់ចិត្ត, រសជាតិជាទីគាប់ចិត្ត, ផ្សព្វៈជាទីគាប់ចិត្ត, រហូតដល់ទៅទ្រព្យសម្បត្តិ, មាសប្រាក់កែវកង, គ្រឿងយន្តយាន, គេហដ្ឋាន, គោ, ក្របី, សេះ, ដំរី, ជ្រូកក្តាន់, មាន់ទា,

ដីស្រែ, ចំការ, ច្បារដំណាំ, លាភ, យស, សក្តិ, អំណាច, តំណែង, នាទី, ការងារ ទាំងអស់នេះចាត់ថា **វត្ថុកាម** ។ កាមទាំងឡាយជាអតីតក្តី អនាគតក្តី បច្ចុប្បន្នក្តី កាមទាំងឡាយជាខាងក្នុងក្តី ខាងក្រៅក្តី ថោក ទាប ខ្ពង់ខ្ពស់ កណ្តាលក្តី ចាត់ថាជា **វត្ថុកាម** ។

កាមទាំងឡាយ ដែលសត្វហួងហែងថាជារបស់អញ ភូមិឋានជាកាមាវចរក្តី រូបាវចរក្តី អរូបាវចរក្តី ដែលជាវត្ថុនៃតណ្ហាជាអារម្មណ៍នៃតណ្ហា ឈ្មោះថាកាមដោយអត្ថថា គួរប្រាថ្នា គួរត្រេកអរ គួរស្រើង ទាំងនេះក៏ជា **វត្ថុកាម** ។

**២. កិលេសកាម** តើដូចម្តេច ? សេចក្តីប្រាថ្នាឈ្មោះថាកាម សេចក្តីត្រេកអរឈ្មោះថាកាម តម្រេកដោយការត្រិះរិះឈ្មោះថាកាម សេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ សេចក្តីត្រេកអររីករាយសប្បាយក្នុងកាម តណ្ហាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីអន្ទះអន្ទែង ការងល់ងប់ជ្រប់ក្នុងកាម អន្លង់គឺកាម គ្រឿងប្រកបគឺកាម ការថ្កក់ជាប់គឺកាម ទាំងនេះហៅថា **កិលេសកាម** ។

បញ្ជាក់សេចក្តី ដើម្បីជូនលោក-អ្នកអាន ឲ្យបានងាយយល់ចូលចិត្តពាក្យថា **វត្ថុកាម** សំដៅយកវត្ថុ របស់ ដែលអាចមើលឃើញ ចាប់កាន់ប៉ះពាល់ត្រូវ ស្តាប់ឮ ដឹងក្លិន រសជាតិ ផោដ្ឋព្វៈ សម្ផស្សៈ ទន់ជ្រាយ ងាយស្រួល ក្តៅត្រជាក់ ព្រមទាំង

សវិញ្ញាណកសម្បត្តិៈ សម្បត្តិដែលមានវិញ្ញាណក្តី អវិញ្ញាណក-សម្បត្តិៈ សម្បត្តិដែលគ្មានវិញ្ញាណក្តី ។ ទាំងនេះជាវត្ថុដែលគួរបំណង ប៉ុនប៉ងប្រាថ្នា ចង់បានចង់មាន ។

**កិលេសកាម** បានដល់ចិត្តដែលប្រាថ្នា គួចចងបំណងថ្លក់តោង រន្ធត់ញាប់ញ័រ ចង់បានវត្ថុទាំងនោះ វត្ថុណាមួយដោយប្រការណាមួយ ទោះបីបានដូចបំណងក្តី មិនបានដូចបំណងក្តី តូចចិត្តថ្នាំងថ្នាក់នៅពេលមិនបានដូចបំណងក្តី បានមកហើយត្រេកអរ រីករាយសប្បាយ ហួងហែងជំពាក់ចិត្ត ដ្បិតការថែរក្សាការពារ ទាំងនេះចាត់ថាជា **កិលេសកាម** ។

**កាមៈ** ចាត់ថាជាអន្លង់ដ៏មហាសែនជ្រៅ ធ្វើឲ្យសត្វលោកជ្រមុជច្របូកច្របល់ឈ្លក់អណ្តែតទៅតាមទឹកជំនន់ ដោយភ័យស្លុតរន្ធត់ញ័រ អន្ទះអន្ទែងរមែងជួបប្រទះតែទុក្ខលំបាកឥតស្រាកស្រាន្ត ។

សត្វលោក មានកង្វះខាត មានគម្លានញ៉ាមញៀន ជាប់ជំពាក់ស្វែងរកឥតស្រាកស្រាន្តនូវកាមគុណ សុខចិត្តធន់ទ្រាំទទួលសេចក្តីទុក្ខលំបាក ដោយភាពវង្វេងងងឹត ដូចហ្វូងត្រីចោលភ្នែកក្រឡេកឃើញនុយ ដែលនាយព្រានបានដោតបង្កប់ជាប់នឹងផ្លែសន្ទូច ខំស្ទុះហែលទៅត្របាក់ចឹក ដោយនឹកស្មានថាខ្លួនមាន

ភ័ព្វវាសនាបានចំអែតអាត្មា ដោយសារចំណីឆ្ងាញ់នេះហើយ ។ នៅទីបំផុត ត្រីត្រូវជាប់មាត់ដោយផ្លែសន្ទូច ខំរើបម្រះរលាស់ខ្លួនមិនរួច ធ្លាក់ប្រាណក្លាយទៅជាចំណីនាយព្រានសន្ទូចយ៉ាងឆ្ងាញ់ពិសា ។ សេចក្ដីដូចពោលមកនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា ៖ ( ព្រោះតែក្រពះ និងក្រពះវាស្រេកឃ្លាន ) នុយដែលបិតដោតជាប់នឹងផ្លែសន្ទូច ប្រៀបដូចជាវត្ថុកាម សេចក្ដីខ្វះខាត ការស្រេកឃ្លាន សេចក្ដីត្រេកអរ សប្បាយរីករាយ ហែលស្ទុះទៅចឹកត្របាក់នុយ នុ៎ះគឺជាកិលេសកាម ។

ព្រោះតែក្រពះវាស្រេកឃ្លាន ព្រាននិងត្រីជាសត្វលោក ជាអ្នកមានកង្វះខាត មានគម្លាន មានចំណង់ដោយកាមដូចគ្នា ត្រីជាវត្ថុកាម ដែលព្រានប្រាថ្នាចង់បានមកជាចំណី សេចក្ដីត្រេកអររីករាយ សប្បាយរំភើបចិត្ត ព្រោះជ្សិតបានត្រីដូចបំណង នេះជាកិលេសកាមរបស់ព្រាន ។

**កាមោឃៈ** អន្លង់គឺកាម ជាអន្លង់ជ្រៅពោរពេញទៅដោយទឹកកួចហូរ ធ្វើឲ្យសត្តាជ្រមុជចុះមិនងាយងើបឲ្យរួចឡើងឲ្យផុតបាន សត្វលោកដែលត្រូវលិចចុះក្នុងអន្លង់ដរាបណា សេចក្ដីទុក្ខសោកសៅក្ដៅក្រហាយ អន្ទះអន្ទែង សេចក្ដីភ័យញាប់ញ័រ តក់ស្លុតរន្ធត់ខ្លាច រមែងនៅដរាបនោះ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្ដែងថា ៖

## កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ
## កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ

## សេចក្តីសោក កើតមកពីចំណង់ ភ័យល្ងង់ក៏កើតមានមកពីចំណង់
## បើបុគ្គលមានចិត្ត ស្រឡះផុតពីចំណង់ហើយ
## សេចក្តីសោក ការភិតភ័យរមែងមិនមាន ។

*នេះជាកំណាព្យរបស់លោក **ឱម ណារត្រី** ( សាស្ត្រាចារ្យភាសាខ្មែរ ) ៖

សេចក្តីសោក ឃោគឃោបំ ឃិតក់ស្លុត ភ័យរន្ធត់
រមែងកើត ពីចំណង់ ចិត្តរលត់ ផុតអស់ហើយ
អំពីចង់ សោកភ័យល្ងង់ នឹងមានមក ពីណាបាន ? ។

សេចក្តីទុក្ខសោក តក់ស្លុតរន្ធត់ភ័យជាផល កើតមានមកព្រោះសេចក្តីស្រឡាញ់ ព្រោះបំណង ព្រោះការហ្មងហែងជាប់ជំពាក់ជាហេតុ ។ សេចក្តីស្រឡាញ់កើតមានហើយ ធ្វើឲ្យសត្វលោកវង្វេង ងងឹតភ្លាំងភ្លេចស្មារតី លែងដឹងយល់ស្គាល់អ្វីជាខុសអ្វីជាត្រូវ នឹងជាផ្លូវនាំទៅកាន់សេចក្តីទុក្ខ កុំថាឡើយដល់បុគ្គលដែលហ៊ានប្រព្រឹត្តបទល្មើសគ្រប់បែបយ៉ាង ហ៊ានសាងបាបកម្មធ្វើចោរកម្ម លួចឆក់ឆ្មក់ប្រវ័ញ្ច បោកប្រាស ភូតភកុហាក រំលោភបំពានបំពារច្បាប់សង្គម រហូតដល់មានទោសទារុណកម្មប្រចាំដល់ខ្លួន ព្រោះហេតុអ្វី ? ក៏ព្រោះការធ្វើនោះ ទៅតាមចំណូល

ចំណង់ និងបម្រើតម្រូវការ កង្វះខាតគម្លានរបស់ខ្លួនតែម្យ៉ាង ។

សេចក្ដីបំណងប៉ុនប៉ង ចង់បានវត្ថុអ្វីមួយ ដូចជាចង់បានឲ្យរូបស្អាត សម្លេងពីរោះ កេរ្តិ៍ឈ្មោះល្បីល្បាញ អំណាចនាទីតំណែង ទ្រព្យសម្បត្តិឧត្ដមសមប្រសើរ ទន្ទឹមគ្នាក្នុងចិត្តចង់បានរមែងអន្ទះអន្ទែងញាប់ញ័រ ព្យាយាមឲ្យបានរបស់ទាំងនោះសមតាមបំណង ។ នៅពេលដែលមិនបាន សមស្របតាមគោលបំណង រមែងកើតសេចក្ដី ថ្នាំងថ្នាក់អាក់អន់ស្រពន់ចិត្ត សោក-សៅក្ដៅក្រហាយ ។ នៅពេលដែលបានមកសមស្របតាមគោលបំណងប៉ងប្រាថ្នា ក៏មានចិត្តត្រេកអរសប្បាយរីករាយ ជាប់ជំពាក់ហួងហែង ភ័យខ្លាចវត្ថុជាទីស្រឡាញ់ពេញចិត្តនោះ បាត់បង់ខូចខាតវិនាសទៅវិញ ដោយប្រការណាមួយ ។ លុះវត្ថុជាទីស្រ-ឡាញ់ពេញចិត្ត បាត់បង់ខូចខាតវិនាសទៅវិញ ដោយហេតុណាមួយក្ដី រមែងសោកស្ដាយ ក្ដៅក្រហាយក្រវល់ក្រវាយ សញ្ជប់សញ្ជឹង ខ្សឹកខ្សួលយំស្រែក ក្ដុកក្ដួលអួលណែន អណ្ដឺតអណ្ដកស្រក់ទឹកភ្នែក ហៀរទឹកសម្បោរ នេះពុំមែនជាសេចក្ដីទុក្ខសោក-សៅ ដែលកើតមកអំពីការព្រាត់ប្រាស វិនាសបាត់បង់ ខូចខាតចាករបស់ជាទីស្រឡាញ់ពេញចិត្ត ប្រកាន់ហួងហែងទេឬ ? ។

សត្វលោករមែងរសាត់អណ្ដែត ទៅតាមក្រសែទឹកគឺលិចចុះនៅក្នុងអន្លង់ជ្រៅគឺ **វណ្ណកាម** ទោះបីជាយ៉ាងដូច្នោះហើយក៏

ដោយ សត្វលោកនៅតែប្រកាន់ស្អិតជាប់ចិត្ត នឹងកាមដោយមាន គំហើញថា កាមទាំងឡាយពុំមែននាំមកនូវសេចក្តីទុក្ខតែម្យ៉ាងទេ កាមទាំងឡាយក៏អាចនាំមកនូវសេចក្តីរីករាយខ្លះផងដែរ ។

ដូចជារឿង **ឯកបុត្តគហបតី** ហ៊ានប្រកែកដោយសេចក្តីប្រកាន់ ជំទាស់នឹងព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទៀតផង ។ ខ្ញុំព្រះករុណា ខ្ញុំបាទសូមលើកយករឿងនេះ ដែលមាននៅក្នុងប្រជុំនិទានជាតក ទំព័រ ( ១១០១ ) មកដើម្បីបញ្ជាក់ជូនលោក-អ្នកអាន ឲ្យបានងាយយល់ចូលចិត្ត រឹងរិតតែច្បាស់ថែមទៀត ។

## រឿង ឯកបុត្តគហបតី

### " សេចក្តីទុក្ខសោក កើតអំពីសេចក្តីស្រឡាញ់ "

កាលនោះ ព្រះមានព្រះភាគគង់នៅវត្តជេតពន ជិតក្រុងសាវត្ថី ។ មានគហបតីម្នាក់ កើតទុក្ខក្រៀមក្រំ បានចូលទៅគាល់ព្រះអង្គ ក្រាបថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរមួយ ។

ព្រះសម្មាសម្ពុទ្ធត្រាស់សួរថា ៖

*" ម្នាលគហបតី ! អ្នកមានមុខក្រៀមស្រពាប់ស្រពោន តើមានហេតុអ្វី ? " ។*

គហបតីក្រាបបង្គំ ទូលថា ៖

" *បពិត្រព្រះអង្គដ៏ចម្រើន ទូលព្រះបង្គំមានបុត្រតូចតែមួយគត់ ឥឡូវវាធ្វើមរណកាលចោលខ្ញុំព្រះអង្គទៅ* " ។

និយាយដូច្នេះហើយ ក៏យំសោកចំពោះព្រះភក្ត្រ រៀបរាប់ថា ៖

" *ម្នាលកូនសម្លាញ់ ! ឪពុកស្រឡាញ់កូនណាស់ ស្រឡាញ់កូនស្មើជីវិត តាំងពីកូនស្លាប់ទៅ ឪពុកតែងនៅយំសោក ហៅកូននៅឈាបនដ្ឋានរាល់ថ្ងៃ កិច្ចការនិងចំណីអាហារ ឪពុកលះបង់អស់ហើយ ឥតចង់បានទ្រព្យ ឥតស្រេកឃ្លានឡើយ តើឥឡូវនេះកូននៅទីណា ឲ្យឪពុកឃើញមុខកូនផង ?* " ។

ព្រះសម្ពុទ្ធត្រាស់ថា ៖

" *ម្នាលគហបតី ! ដំណើរនេះពិតយ៉ាងហ្នឹងហើយ សេចក្ដីសោកស្ដាយ ខ្សឹកខ្សួល ទុក្ខតូចចិត្ត និងការចង្អៀតចង្អល់ចិត្ត តែងកើតមកពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត* " ។

គហបតី ឆ្លើយបដិសេធពុទ្ធភាសិតនេះថា ៖

" *ត្រូវដូច្នោះខ្លះដែរ ប៉ុន្តែបើតាមពិតនោះ សេចក្ដីត្រេកអរនិងសេចក្ដីរីករាយ តែងកើតមកពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើតវិញទេ* " ។

និយាយដូច្នេះហើយ ក៏ក្រោកចាកអាសនៈចេញទៅ ឥត

មានការគួរសមចំពោះព្រះសម្ពុទ្ធឡើយ ។ ទៅដល់ពាក់កណ្ដាលផ្លូវ បានជួបពួកអ្នកលេងល្បែងភ្នាល់ ក៏និយាយប្រាប់អ្នកទាំងនោះថា ៖

*" ព្រះពុទ្ធបានសម្ដែងខុសយ៉ាងនេះថា សេចក្ដីទុក្ខសោកកើតមកពីសេចក្ដីស្រឡាញ់ ។ ចំណែកខ្ញុំយល់ថា សេចក្ដីត្រេកអរនិងសេចក្ដីរីករាយសប្បាយកើតមកពីសេចក្ដីស្រឡាញ់វិញ " ។*

ពួកអ្នកលេងឆ្លើយអបជើងថា ៖

*" ប្របាទលោកម្ចាស់ មានប្រសាសន៍ពិតជាត្រឹមត្រូវ "* ។

គហបតីគិតថាវាទៈ[១] របស់អញ សមគ្នានឹងយោបល់របស់ពួកអ្នកលេងហើយ ក៏ដើរចេញអំពីទីនោះទៅ ។

ពាក្យនេះបានឮខ្ចរខ្ចាយទៅក្នុងព្រះរាជវាំង ព្រះបាទ **បសេនទិកោសល** ត្រាស់សួរនាង **មល្លិកាទេវី** ជាមហេសីថា ៖

*" ព្រះសមណគោតម ជាគ្រូរបស់នាងបានសម្ដែងថា សេចក្ដីទុក្ខសោក កើតអំពីសេចក្ដីស្រឡាញ់ ដូច្នោះមែនឬទេ ? "* ។

ព្រះនាងមល្លិកាទេវី ក្រាបបង្គំទូលថា ៖

*" បើព្រះសម្ពុទ្ធបរមគ្រូសម្ដែងយ៉ាងណាគឺ ពិតជាដូច្នោះមែនហើយ "* ។

វេលានោះព្រះបាទបសេនទិកោសល ទ្រង់ខ្ចាល់ចំពោះ

---

(១) វាទ សំ. បា. ( ន. ) (វាទ) ពាក្យ, ពាក្យពោល, ពំនោល ។ វាទៈ

នាងមល្លិកាទេវីថា ៖

*" នែ! មល្លិកា នាងចេះតែចាក់បណ្ដោយ ឲ្យតែគ្រូថាយ៉ាងណា សិស្សចេះតែគាំទ្រថាត្រូវយ៉ាងនោះ នាងចូរជៀសចេញអំពីមុខយើងទៅ នាងឯងនេះខិលខូចណាស់ ! "* ។

នាងក៏ចេញទៅរាជដំណាក់វិញ ។

លុះទៅដល់ហើយ បានហៅនាឡិជង្ឃព្រាហ្មណ៍ឲ្យចូលគាល់ , មានព្រះសវនីយ៍ថា ៖

*" នែព្រាហ្មណ៍ ! ចូរអ្នកទៅគាល់ព្រះបរមគ្រូ ថាខ្ញុំសូមថ្វាយបង្គំព្រះបាទា ដោយសិរសាហើយថា ខ្ញុំសូមថ្វាយបង្គំសួរអំពីព្រះវាចាថា សេចក្ដីទុក្ខសោកកើតអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត តើព្រះអង្គបានសម្ដែងដូច្នោះមែនឬទេ ? "* ។

កាលនាឡិជង្ឃព្រាហ្មណ៍ទៅដលថ្វាយបង្គំ តាមដំណើរការណ៍ ហើយព្រះសម្ពុទ្ធត្រាស់ថា ៖

*" ពិតដូច្នោះមែន រឿងធ្លាប់មានមកហើយ "* ។

*" ម្នាលព្រាហ្មណ៍ ! ក្នុងក្រុងសាវត្ថីនេះ មានស្ត្រីម្នាក់កើតទុក្ខសោក ព្រោះមាតាស្លាប់ នាងទៅជាឆ្កួត ដើរគ្រប់ច្រកល្ហកសួររកមាតាខ្លួន នេះហើយជាសេចក្ដីទុក្ខ កើតពីសេចក្ដីស្រឡាញ់ "* ។

*" ម្នាលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថីនេះឯង មានស្ត្រីម្នាក់ទើបនឹងមានស្វាមី ពួកញាតិរបស់នាងមិនពេញចិត្ត បាននិយាយ*

*បំបែកចេញអំពីស្វាមី បម្រុងលើកនាងឲ្យទៅបុរសដទៃទៀត ។ នាងមានសេចក្តីស្រឡាញ់ចំពោះស្វាមី ក៏ដំណាលរឿងនោះប្រាប់ ឯស្វាមីក៏មានសេចក្តីស្រឡាញ់ចំពោះនាងដែរ សុខចិត្តស្លាប់ទាំង-អស់គ្នា សុំឲ្យបានជួបគ្នាក្នុងបរលោក ។ គិតស្រុះគ្នាដូច្នេះហើយ ស្វាមីក៏កាប់ប្រពន្ធជាពីរកំណាត់ ហើយវះពោះខ្លួនឯងស្លាប់ជាមួយគ្នាទៅ ។ នេះឯងសេចក្តីទុក្ខ កើតអំពីសេចក្តីស្រឡាញ់ ” ។*

គ្រានោះ នាឡិជង្ឃព្រាហ្មណ៍ត្រេកអរអនុមោទនា ចំពោះព្រះពុទ្ធភាសិតនេះហើយថ្វាយបង្គំលាទៅព្រះបរមរាជវាំង នាំពុទ្ធភាសិតនោះទៅទូលនាងមល្លិកាទេវីតាមដំណើររឿង ។

ព្រះនាងមល្លិកាទេវី មានព្រះទ័យរីករាយ ចូលទៅគាល់ព្រះបាទបសេនទិកោសល ទូលសួរថា ៖

*- បពិត្រព្រះមហារាជ កុមារីព្រះនាមវជិរីជារាជធីតា តើព្រះអង្គសព្វព្រះទ័យស្រឡាញ់ទេ ?*

*- អើមល្លិកា យើងស្រឡាញ់ **វជិរីកុមារ** ណាស់ ។*

*- បើកុមារីនេះនិរាសព្រាត់ប្រាសទៅតើ ព្រះអង្គមានសេចក្តីទុក្ខសោក តូចព្រះទ័យឬទេ ? ។*

*- អើមល្លិកា! បើដូច្នេះមែន ជីវិតរបស់អញក៏មុខជានឹងប្រែប្រួលទៅដែរ ចំណង់បើសេចក្តីទុក្ខនោះនឹងខានកើតមានដល់អញឯណាបាន ។*

*- បពិត្រមហារាជ នាង* ***វាសភខត្តិយា*** *ព្រះអង្គសព្វព្រះទ័យស្រឡាញ់ឬទេ ? ។*

*- អើមល្លិកា! យើងស្រឡាញ់ វាសភខត្តិយា ណាស់ ។*

*- បើនាងព្រាត់ប្រាសនិរាសទៅ តើព្រះអង្គមានសេចក្តីទុក្ខសោក តូចព្រះទ័យឬទេ ? ។*

*- ពិតជាមានណាស់ហើយ ។*

*- បពិត្រមហារាជ វិឌូឌភសេនាបតី ព្រះអង្គសព្វព្រះទ័យស្រឡាញ់រាប់អានឬទេ ? ។*

*- អើមល្លិកា! យើងស្រឡាញ់សេនាបតីនេះណាស់ ។*

*- បើសេនាបតីនេះ ព្រាត់ប្រាសនិរាសទៅ តើព្រះអង្គមានសេចក្តីទុក្ខសោក តូចព្រះទ័យឬទេ ? ។*

*- ពិតជាមានណាស់ហើយ ។*

*- បពិត្រមហារាជ ចុះខ្លួនខ្ញុំម្ចាស់ តើព្រះអង្គសព្វព្រះទ័យស្រឡាញ់ដែរឬទេ ?*

*- អើមល្លិកា! ឯងជាទីស្រឡាញ់របស់អញណាស់ដែរ ។*

*- បើខ្ញុំម្ចាស់និរាសប្រាសចាកព្រះអង្គទៅ តើព្រះអង្គមានសេចក្តីទុក្ខសោក អាឡោះអាល័យតូចព្រះទ័យដែរឬទេ ? ។*

*- អើមល្លិកា! បើឯងព្រាត់ប្រាសពីអញទៅ សេចក្តីទុក្ខសោកនឹងកើតមានដល់អញជាប្រាកដហើយ សូម្បីជីវិតអញក៏នឹងប្រែប្រួលទៅដែរ ។*

*- បពិត្រមហារាជ ដែនកាសី និងកោសល តើព្រះអង្គសព្វព្រះទ័យឬទេ ? ។*

*- អើមល្លិកា! ដែនទាំងពីរនេះ ជាទីស្រឡាញ់របស់យើង ព្រោះយើងប្រើប្រាស់ខ្លឹមចន្ទន៍ដែលបានមកពីដែន ទ្រទ្រង់កម្រងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ដោយអានុភាពនៃដែនទាំងពីរនេះឯង ។*

*- បើដែនទាំងពីរនេះ មានវិបត្តិប្រែប្រួលទៅ តើព្រះអង្គមានសេចក្តីទុក្ខសោកតូចព្រះទ័យដែរឬទេ ? ។*

*- អើមល្លិកា! ពិតជាមានណាស់ហើយ ។*

កាលបើព្រះបាទបសេនទិកោសល បានយល់ហេតុនៃសេចក្តីស្រឡាញ់ និងសេចក្តីទុក្ខសោកដូច្នេះហើយ នាងមល្លិកាទេវីក្រាបទូលបង្គំថា ៖

*- បពិត្រមហារាជ ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូរបស់ខ្ញុំ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់តាមដំណើរនេះហើយ ទើបព្រះអង្គសម្តែងថា ៖*

**បិយជាតិកា សោកបរិទ្ទ ទោមនស្ស ឧបាយាសា បិយប្បភូតិកា**

**សោកខ្សឹកខ្សួល សេចក្តីទុក្ខតូចចិត្ត សេចក្តីចង្អៀតចិត្ត តែងកើតឡើងអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។**

ព្រះបាទបសេនទិកោសល ត្រាស់ថា ៖

*" អស្ចារ្យណាស់ មល្លិកា ! ព្រះសម្ពុទ្ធអង្គនោះប្រហែលជាត្រាស់ដឹង ឃើញច្បាស់ដោយបញ្ញាមែន នាងចូរឲ្យទឹកសម្រាប់ជម្រះកាយដល់អញ ! "* ។

លុះព្រះអង្គជម្រះព្រះកាយរួចហើយ ក៏ពានាសំពត់ប្រណម្យអញ្ជលីឆ្ពោះត្រង់ទីព្រះសម្ពុទ្ធ ទ្រង់គង់បន្លឺឧទានអស់វារៈបីដងថា ៖

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ដំណើររឿងមានមកប៉ុណ្ណេះនេះ បញ្ជាក់ឲ្យឃើញបានថា សេចក្តីទុក្ខសោកទាំងអម្បាលមាណ កើតមានព្រោះសេចក្តីស្រឡាញ់ជាហេតុ ។ សេចក្តីស្រឡាញ់ ចំណង់ចង់បានចង់មានជាយ៉ាងនេះយ៉ាងនោះ ជាហេតុនាំចិត្តឲ្យធ្លាក់ចុះ ក្នុងការជាប់ជំពាក់ប្រកាន់ហួងហែង ដូចជាស្រឡាញ់ មាតាបិតា ញាតិមិត្ត គ្រួសារ ស្វាមីភរិយា បុត្តធីតា គូសង្សារ ការងារ តំណែង អំណាច នាទី ទ្រព្យសម្បត្តិគ្រប់ប្រការ ធ្វើឲ្យចិត្តប្រកាន់ស្អិតជាប់ជំពាក់ហួងហែង ចង់ឲ្យវត្ថុទាំងនោះ គង់វង្សឋិតថេរទៅតាមចំណង់ចំណូលចិត្តនៃខ្លួន ។ តែអ្វីៗទាំងអស់ឋិតនៅក្រោម **អនិច្ចភាព** មានការប្រែប្រួលផ្លាស់ប្តូរទៅតាមធម្មតាធម៌ ដែលសត្វាមិនអាចប្រកែកប្រកាន់បាន ។

**កាមៈ** ជាអន្លង់ទីមួយធ្វើឲ្យសត្វលោក មានការច្រប្លូក ច្របល់ជ្រមុជចុះ លិចលង់ផុងប្រាណ មិនងាយឲ្យងើបរួចឡើង ផុតបានមកទេ ។

## ❖ អន្លង់ទីពីរ ភវោឃៈ

ពាក្យថា **ភពៈ** ( ជាភាសាបាលី ឬជាភាសាសំស្ក្រឹត ) ប្រែជាភាសាខ្មែរបានន័យថា សេចក្តីចម្រើន ដំណើរកើត ប្រទេសឬទីសម្រាប់សព្វសត្វ កើតស្លាប់ ( លោកៈ ) សត្វទាំងឡាយ តែងអន្ទោលកើតស្លាប់នៅក្នុងភព នៅក្នុងលោក ។ ភពឬលោក បានដល់ភូមិឋានជាទីកើត ជាទីអាស្រ័យនៅនៃសព្វសត្វមានបីយ៉ាង គឺ ៖ កាមភព រូបភព អរូបភព ឬកាមលោក រូបលោក អរូបលោក ។

ដូចខ្ញុំបានសរសេរបញ្ជាក់ពីខាងដើមរួចមកហើយ **កាមភព** បានដល់ភូមិឋានរបស់ នរក ប្រេត តិរច្ឆាន អសុរកាយបួនជាន់ មនុស្សមួយជាន់ ទេវតាប្រាំមួយជាន់ រួមជាដប់មួយ ។ **រូបភព** ភូមិឋានជាទីនៅរបស់ រូបព្រហ្មដប់ប្រាំមួយជាន់ ។ **អរូបភព** ភូមិឋានជាទីនៅរបស់ អរូបព្រហ្មបួនជាន់ ។

ហេតុអ្វីគ្រាន់តែភព ជាទីកើត ជាទីអាស្រ័យនៅរបស់សត្វទាំងឡាយ ក៏ចាត់ថាអន្លង់ដែរ ? បានជាចាត់ថាអន្លង់ដែរនោះ ព្រោះសព្វសត្វដែលកើត ក្នុងភពទាំងឡាយនោះ សុទ្ធតែប្រកប

ដោយតណ្ហា មានតណ្ហាជាប្រភពក្នុងភូមិឋាននីមួយៗ ទើបចាត់តណ្ហាទៅតាមប្រភេទមានបីដែរគឺ ៖ កាមតណ្ហា១, ភវតណ្ហា១, វិភវតណ្ហា១ ។

ពាក្យថា **តណ្ហា** ( ជាភាសាបាលី ឬសំស្រ្កឹត ) ប្រែជាភាសាខ្មែរមានន័យថា ចំណង់ សេចក្តីប្រាថ្នា តម្រេក សេចក្តីអន្ទះអន្ទែង តម្រេកមានកម្លាំងខ្លាំង សេចក្តីប្រកាន់ សេចក្តីត្រេកអរ សេចក្តីរីករាយក្នុងតម្រេក តម្រេកមានកម្លាំងរបស់ចិត្ត សេចក្តីជ្រប់ចុះ កិរិយាងប់ចុះ សេចក្តីជំពាក់មាំ កិលេសជាគ្រឿងជាប់ កិលេសដូចភក់ កិរិយាស្វែងរក ការលោក់ពុត កិលេសជាតិជាគ្រឿងញុាំងសត្វឲ្យកើតគ្រឿងចាក់ស្រែះ កិលេសជាតិដូចបណ្តាញ កិលេសហូរទៅ ផ្សាយទៅ ក្រសែគឺតណ្ហា កិលេសជាតិដ៏ទូលាយ គ្រឿងញុាំងអាយុឲ្យវិនាស គ្រឿងញុាំងសត្វទៅកាន់ភព កិលេសជាតិដូចព្រៃធំព្រៃតូច ការស្និទ្ធស្នាល សេចក្តីស្នេហា ការអាល័យ សេចក្តីជាប់ជំពាក់ សេចក្តីប៉ុនប៉ង សេចក្តីជញ្ជឹង ភាពនៃចិត្តនឹកជញ្ជឹង ការជាប់ទូទៅ ការជាប់ក្រៃលែង ភាពនៃចិត្តជាប់ ការជក់ស្អិត ភាពនៃចិត្តជក់ស្អិត ភាពនៃចិត្តរឡិបរឡប់ ភាពនៃចិត្តប្រាថ្នាក្រៃពេក តម្រេកខុសគន្លងធម៌ សេចក្តីលោភមិនស្មើ សេចក្តីអាល័យ កិលេសជាតិជាទីអាល័យ សេចក្តីប្រាថ្នាគ្រប់យ៉ាង សេចក្តីស្រឡាញ់ ។

ពាក្យថា **តណ្ហា** តែមួយម៉ាត់ ប្រែចេញបានជាច្រើនយ៉ាង បញ្ជាក់ឲ្យយល់ច្បាស់ថា តណ្ហានេះជាកិលេស ដែលមានបណ្ដាញស្មុគស្មាញ ចាក់ស្រែះព័ទ្ធព័ន្ធចងឆ្នាក់សត្វលោក ឲ្យទទឹកជោកធ្លាក់ចុះ ក្នុងអន្លង់គឺភព ។ ធ្វើឲ្យសព្វសត្វអន្ទោលទៅអន្ទោលមកវិលកើត ចាស់ ឈឺ ស្លាប់ មិនចេះចប់មិនចេះហើយ ជ្រមុជចុះឡើងទៅតាមខ្សែទឹក ហៅថា **សង្សារវដ្ដ** ក្ដី ភពទាំងបីមាន ៖ កាមភព, រូបភព, អរូបភពក្ដី សុទ្ធតែមានតណ្ហាជាហេតុជាបច្ច័យ ។

មហាសមុទ្រដ៏ធំ ដែលគេមិនអាចមើលពីត្រើយអាយ ឲ្យឃើញទៅត្រើយនាយបាន តែគេអាចធ្វើដំណើរដោយយាន មានកប៉ាល់ជាដើមបាន ឯ **សមុទ្ទតណ្ហា** គ្មានសត្វលោកជាបុថុជ្ជនណាអាចឆ្លងដោយទូកក្ដារច្រវាចែវ ឬដោយកប៉ាល់បានទេ ដូច្នេះទើបព្រះពុទ្ធទ្រង់មានតម្រាស់ថា ៖

## នត្ថិ តណ្ហា សមានទី

## ស្ទឹងស្មើដោយតណ្ហា មិនមាន ។

**តណ្ហា** ជាគ្រឿងចាក់ស្រែះ រារាំង ប្រកាន់ទុក ចងសត្វលោកទុកឲ្យនៅក្នុងភពធ្វើសត្វឲ្យងោកងុយ ដេកត្រាំនៅក្នុងភពឋាន ដោយមិនបានគិតរកផ្លូវ ដើម្បីទៅឲ្យផុតចាកភពឡើយ ។ តណ្ហាជាឫសគល់នៃសេចក្ដីទុក្ខ ជាហេតុនៃទុក្ខ ជាដែនកើតនៃ

ទុក្ខ ជាអន្ទាក់នៃមារ ជាសន្ទូចរបស់មារ ធ្វើសត្វលោកឲ្យវង្វេងស្រេកឃ្លាន ដោយអារម្មណ៍ទាំងឡាយមាន ៖ រូបតណ្ហា, សទ្ទ-តណ្ហា, គន្ធតណ្ហា, រសតណ្ហា, ផោដ្ឋព្វតណ្ហា, ធម្មតណ្ហា, កាម-តណ្ហា, ភវតណ្ហា, វិភវតណ្ហា ។ សេចក្ដីប្រាថ្នារបស់សត្វលោកទៅលើរូប សម្លេង ក្លិន រស សម្ផស្ស ធម្មា ព្រមទាំងរបស់ផ្សេងៗច្រើនប្រការទៀតក្ដី ការជាប់ជំពាក់នឹងភពឋានជាដែនរបស់ខ្លួន ដូចជាពពួកមនុស្ស ពួកទេវតា ពួកព្រហ្មមានរូបអរូបព្រហ្មក្ដី ទាំងនេះចាត់ថានៅជាប់ដោយចំណងតណ្ហា ។

ការប្រាថ្នាជាប់ជំពាក់ប្រកាន់ ស្រឡាញ់ពេញចិត្ត ស្និទ្ធស្នាលអាល័យនៅមានដរាបណា ឈ្មោះថានៅជាប់ជំពាក់ដោយអន្ទាក់ នៅស្រេកឃ្លានដោយនុយរបស់មារ ដរាបនោះនឹងជាអ្នកធ្លាក់ចុះហែលក្នុងអន្លង់ភពមិនអាចរើខ្លួនបាន ។ **តណ្ហា** ជាមេជាងសាងនូវផ្ទះគឺអត្តភាពនៃសត្វទាំងឡាយ **តណ្ហា** ជាមេជាងសាងនូវខន្ធទាំងពួង មានបញ្ចវោការខន្ធ ចតុវោការខន្ធ ឯកវោការខន្ធ ។

**បញ្ចវោការខន្ធ** បានដល់ខន្ធប្រាំរបស់ពួកសត្វ ក្នុងអបាយ-ភូមិបួន ខន្ធរបស់មនុស្សព្រមទាំងទេវតាប្រាំមួយជាន់ ព្រហ្មដប់ប្រាំជាន់ចំណែកព្រហ្មជាអសញ្ញីសត្តា ជាឯកវោការខន្ធ មានតែខន្ធមួយ ឥតមាននាមខន្ធទេ ចតុវោការខន្ធ មានខន្ធបួនបានដល់អរូបព្រហ្ម ឥតមានរូបខន្ធទេ មានតែនាមខន្ធបួន ។

នៅក្នុងអរិយសច្ចធម៌ទាំងបួនប្រការ **ទុក្ខៈ** ជាផល **សមុទ-យៈ** គឺតណ្ហា ជាហេតុបង្កើតសេចក្ដីទុក្ខទាំងពួង ។ ពាក្យថា **ទុក្ខៈ** បានដល់សេចក្ដីព្រួយ សេចក្ដីពិបាក គឺពិបាកធន់ ពិបាកទ្រាំ ដំណើរមិនសុខកាយ មិនសប្បាយចិត្ត ។

- **ទុក្ខមាន ១២ គឺ ៖**

**១. ជាតិទុក្ខ** ទុក្ខព្រោះការកើត ;

**២. ជរាទុក្ខ** ទុក្ខព្រោះការចាស់ទ្រុឌទ្រោមគ្រាំគ្រា ;

**៣. ព្យាធិទុក្ខ** ទុក្ខព្រោះការឈឺចុកចាប់ ;

**៤. មរណទុក្ខ** ទុក្ខព្រោះសេចក្ដីស្លាប់ ;

**៥. ទុក្ខទុក្ខ** ទុក្ខព្រោះប្រកបការងារនឿយហត់ខាងរាងកាយ

**៦. សោកទុក្ខ** ទុក្ខព្រោះសេចក្ដីសោកសៅ ខ្សឹកខ្សួល ស្រណោះស្រណោក អាឡោះអាល័យចំពោះសត្វ និង សង្ខារ ដែលនិរាសព្រាត់ទៅ ;

**៧. បរិទេវទុក្ខ** ទុក្ខព្រោះការយំសោក អណ្ដឺតអណ្ដក ស្រក់ទឹកភ្នែក ត្អូញត្អែរៀបរាប់ពីរឿងព្រាត់ប្រាសនិរាស ចាកសត្វសង្ខារ ;

**៨. ទោមនស្សទុក្ខ** ទុក្ខព្រោះការខឹងថ្នាំងថ្នាក់ ចំពោះអារម្មណ៍មិនជាទីពេញចិត្ត ;

**៩. ឧបាយាសទុក្ខ** ទុក្ខព្រោះការតានតឹង ទង្គឹះខ្សឹកខ្សួលអួលណែនក្នុងទ្រូង យំក៏មិនចេញ និយាយក៏មិនកើត ;

**១០. អប្បិយេហិសម្បយោគទុក្ខ** ទុក្ខព្រោះជួបសត្វសង្ខារ[១] មិនជាទីស្រឡាញ់ពេញចិត្ត ;

**១១. បិយេហិវិប្បយោគទុក្ខ** ទុក្ខព្រោះការព្រាត់ប្រាសចាក សត្វសង្ខារ ជាទីស្រឡាញ់ពេញចិត្ត ;

**១២. យម្បិច្ឆំនលបតិតម្បិទុក្ខ** ទុក្ខព្រោះប្រាថ្នារបស់ណាហើយ មិនបានរបស់នោះដូចបំណង ។

***ទុក្ខទាំង ១២ កង** នេះរួមចូលក្នុងបញ្ចក្ខន្ធ ហៅថា **បញ្ចក្ខន្ធាបិទុក្ខ** ទុក្ខព្រោះខន្ធប្រាំ ។

**ជាតិទុក្ខ** ទុក្ខព្រោះការកើត ទុក្ខព្រោះមានកំណើត ។

- **កំណើតមានបួនយ៉ាង ៖**

| | |
|---|---|
| **១. ឧបបាតិកៈ** | **៣ . អណ្ឌជៈ** |
| **២. ជលាពុជៈ** | **៤ . សំសេទជៈ** |

**១. ឧបបាតិកៈកំណើត** បានដល់កំណើតដែលឧប្បត្តិកកើតបានដោយអកុសលវិបាកជាបច្ច័យ និងកុសលវិបាកជាបច្ច័យ

(១) ពាក្យថា " **សត្វ** " សំដៅដល់ មាតាបិតា ស្វាមី ភរិយា បុត្រធីតា បងប្អូន ញាតិមិត្ត និង ទ្រព្យសម្បត្តិដែលមានវិញ្ញាណដូចជា គោ ក្របី សេះ...។ល។

ឯពាក្យថា " **សង្ខារ** " សំដៅដល់ទ្រព្យសម្បត្តិ វត្ថុដែលគ្មានវិញ្ញាណដូចជា ផ្ទះ ដីស្រែ ចម្ការ ចំការ យន្តយាន គ្រឿងអលង្ការ...។ល។

កំណើតនេះមិនបានអាស្រ័យ មេបា មាតាបិតាទេ ដូចជាពួកសត្វនរក ប្រេត អសុរកាយ ពួកសត្វទាំងនេះកើតឡើងបានអាស្រ័យ **អកុសលាភិសង្ខារ** គឺអកុសលកម្ម តាក់តែងបង្កើតឲ្យជាកំណើតយ៉ាងនោះ ។ បន្ទាប់អំពីចុតិចិត្ត អកុសលវិបាកបដិសន្ធិ តភពតកំណើតឲ្យបានជាបញ្ចក្ខន្ធ ទទួលទុក្ខទារុណកម្មក្នុងអបាយភូមិយ៉ាងឆាប់រហ័ស ។

កំណើតទេវតាទាំងឡាយក្តី កំណើតព្រហ្មទាំងឡាយក្តី ក៏ចាត់ថាជា ឧបបាតិកៈកំណើតដែរ តែកើតបានដោយ **កុសលា-ភិសង្ខារ** ដោយកុសលកម្ម បានតាក់តែងឲ្យកើតក្នុងភពឋាននោះៗ ពួកព្រហ្មកើតបានដោយឈានកុសល ។ ឧបបាតិកៈកំណើតកើតឡើងភ្លាម ពេញរូបរាង ទៅតាមសណ្ឋានប្រភេទនៃសត្វក្នុងភពឋាននោះៗដោយអំណាច **កុសលាភិសង្ខារ** បានវិចិត្រតាក់តែង, ពួកនរក ប្រេត អសុរកាយក្តី ពពួកទេវតាក្តី កើតឡើងភ្លាមអាចរំឭកជាតិកំណើត បាបកម្មបុញ្ញកម្ម ដែលបានសាងអំពីជាតិមុនដោយប្រការណាៗទើបធ្វើឲ្យខ្លួនកើតមក ទទួលសោយនូវផលនៃកម្មនោះៗ ។

**២. ជលាពុជៈកំណើត** បានដល់កំណើតក្នុងគភ៌ កំណើតបានមកដោយការសម្ព័ន្ធផ្សំធាតុ កើតមកអំពីជាតិទឹក ដូចជាកំណើតមនុស្ស ត្រូវអាស្រ័យនៅក្នុងផ្ទៃមាតាប្រាំបួនខែម្ភៃថ្ងៃទើប

កើតចេញមកបាន និងកំណើតតិរច្ឆានឯទៀតច្រើនប្រភេទ ដូចជាសត្វស្រុកសត្វព្រៃមានគោ ក្របី សេះ ដំរី ជ្រូក ក្តាន់ ឆ្កែ ឆ្មាស្វា រមាស រមាំង ជាដើមនេះ សុទ្ធតែកើតអាស្រ័យមេរបស់វា ។

**៣. អណ្ឌជៈកំណើត** កំណើតអំពីស៊ុត ( ពង ) ដូចជាពួកបក្សាបក្សីមាន មាន់ ទា ក្ងាន ក្ងោក ប៉ោលតោក តាវៅ ទីទុយសេក សារិកា ទទា ប្របឹក និងសត្វឯទៀតដូចជាសត្វអណ្តើកក្រពើ កន្ធាយ បង្កួយ តុកកែ ពីងពាង ពួកសត្វទាំងឡាយនោះមានកំណើតពីរដង គឺមេវាពងចេញមកម្តង ហើយទើបញាស់ចេញពីពងមកម្តងទៀត ។

**៤. សំសេទជៈកំណើត** បានដល់កំណើត កើតចេញពីញើសក្អែលដូចជាចៃ សង្កើច ស្រមោច ស្រមើ និងដង្កូវពួកខ្លះជាដើម ពួកសត្វដែលកើតចេញអំពីសម្រាមធូលីទីក្រខ្វក់ ។

កំណើតទាំងបួនប្រភេទ ផ្សេងដោយឡែកពីគ្នាក៏ពិតមែនហើយ ទាំងមានខន្ធមិនស្មើគ្នា សត្វខ្លះជា **ឯកវោការខន្ធ** សត្វខ្លះជា **ចតុវោការខន្ធ** សត្វខ្លះជា **បញ្ចវោការខន្ធ** ឲ្យតែនៅមានខន្ធដរាបណា សេចក្តីទុក្ខកង្វល់ក៏នៅមានដ៏រាបនោះ ព្រោះខន្ធនេះជាមារ ជាសត្រូវបាននាំមកនូវបច្ចាមិត្តគឺ សេចក្តីទុក្ខគ្រប់បែបយ៉ាងជាប់មកជាមួយ សេចក្តីទុក្ខគ្រប់បែបយ៉ាងប្រជុំចុះរួមចូលក្នុងបញ្ចក្ខន្ធនេះឯង សមដូចព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ថា៖

# នត្ថិ ខន្ធ សមា ទុក្ខា

## ទុក្ខទាំងឡាយ ស្មើដោយខន្ធមិនមាន ។

ខន្ធដែលកើតឡើងបាន ព្រោះមានតណ្ហាជាមេជាង សាងបង្កើតឲ្យមានកំណើតសត្វ លិចអណ្តែតនៅក្នុងភព ចេញមិនរួចរត់មិនផុត ដូចជាសត្វជ្រូកដែលគេដាក់ក្នុងទ្រុង បង្ខាំងទុកដូច្នោះឯង ។

សត្វលោកប្រកាន់ស្អិតជាប់ចិត្តនឹងជីវិត ព្រមទាំងភូមិឋានរបស់ខ្លួន ទាំងមនុស្ស ទេវតា ព្រហ្ម ។ ដោយអំណាចសេចក្តីប្រាថ្នា ការជាប់ចិត្តទើបធ្វើឲ្យសត្វវង្វេងងងឹត មើលបានត្រឹមតែខាងអាយ មិនអាចសម្លឹងមើលទៅត្រើយខាងនាយ ម្ល៉ោះហើយទើបនាំគ្នា ធន់ទ្រាំតស៊ូរស់នៅជាមួយនឹងកង្វះ កំហាត គម្លានសំណោក កម្លាច ចំណង់គ្រប់បែបយ៉ាង ដែលជាសំណាងសំណង់របស់តណ្ហា អន្លង់ភពដែលសត្វជ្រមុជធ្លាក់ចុះ ហើយខំត្រដរហែលទាំងយប់ថ្ងៃ ទៅតាមក្រសែទឹកនៃតណ្ហា មិនងាយសត្វណាហែលបានដល់ត្រើយ និងងើបឡើងមកខាងនៃច្រាំងនោះទេ ។

### ❖ អន្លង់ទីបី ទិដ្ឋោឃៈ

បានដល់ទិដ្ឋិជាអន្លង់ ពាក្យថា **ទិដ្ឋិ** ( ជាភាសាបាលី ឬសំ

ស្រ្តឹត) ប្រែជាភាសាខ្មែរ បានដល់ដំណើរយល់ឃើញ សេចក្ដីប្រកាន់តាមការយល់ឃើញ ការយល់ឃើញត្រូវទៅតាមហេតុផលពិត ហៅថា **សម្មាទិដ្ឋិ** ។ ការយល់ឃើញខុសប្រាសចាកអំពីហេតុផលពិត ហៅថា **មិច្ឆាទិដ្ឋិ** ។

**ទិដ្ឋិ** ដែលចាត់ថាជាអន្លង់ សំដៅ **មិច្ឆាទិដ្ឋិ** ការយល់ឃើញខុស ជាទិដ្ឋិវិបត្តិការខូចដំណើរយល់ឃើញ គឺការភ្លាត់គំនិតយល់ឆ្វេង ខុសពីផ្លូវត្រូវ មិនស្របទៅតាមព្រះធម៌វិន័យ យល់ឃើញខុសអំពីហេតុផល បាបបុណ្យគុណទោស ។

បុគ្គលកាលមានចិត្តចុះស៊ប់ ប្រកាន់ងុលងប់នឹងការយល់ឃើញខុសរបស់ខ្លួនហើយ មិនងាយទាញចិត្ត ឲ្យងាកចេញមកវិញបានទេ ។ ការជាប់ជំពាក់ជាមួយទិដ្ឋិ ការប្រកាន់តាមការយល់ឃើញ ដូចយល់ឃើញថា លោកទៀង លោកមិនទៀង លោកទៀងក៏មាន លោកមិនទៀងក៏មាន លោកទៀងក៏មិនមែន លោកមិនទៀងក៏មិនមែន លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះ សរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វស្លាប់ទៅកើតទៀតក៏មាន សត្វស្លាប់ទៅមិនកើតទៀតក៏មាន សត្វស្លាប់ទៅកើតទៀតផងក៏មាន មិនកើតទៀតផង សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ការប្រកាន់តាមការយល់ឃើញថា ហេតុមិនមាន កម្មមិនមាន ផលរបស់កម្មមិនមាន បូជាតូច បូជាធំ មាតាបិតា សមណ-ព្រាហ្ម អ្នកបដិបត្តិបានសម្រេចគុណធម៌មិនមាន ។ បាបបុណ្យ គុណទោសខុសត្រូវ អាក្រក់ល្អសខ្មៅ ខ្លៅប្រាជ្ញកាចស្លូត ឆោតល្ងង់ត្រង់វៀច កើតឯងមានឯងជាធម្មតា ការយល់ឃើញយ៉ាងនេះ ពិតជាត្រូវទៅតាមគំនិតរបស់ខ្លួន ឯការយល់ឃើញដទៃ ក្រៅពីគំនិតខ្លួនថាត់ថាមោឃៈ ។

សត្វលោកកាលបើធ្លាក់ចុះ ក្នុងអន្លង់ទិដ្ឋិហើយ រមែងជាចំណងចងឲ្យជំពាក់ជាប់មិនងាយប្រព្រឹត្តកន្លងបានទេ គឺប្រព្រឹត្តកន្លងដោយលំបាក ឆ្លងដោយក្រ ឆ្លងចេញបានដោយកម្រប្រព្រឹត្តកន្លងបានដោយតឹង ឈានកន្លងបានដោយលំបាក ។

ដូច្នេះដំណើរធ្វើឲ្យយឺតយូរគឺ **ទិដ្ឋិ** ការសាំញ៉ាំគឺ **ទិដ្ឋិ** ផ្លូវលំ-បាកគឺ **ទិដ្ឋិ** ចម្រូងគឺ **ទិដ្ឋិ** ការញាប់ញ័រគឺ **ទិដ្ឋិ** សញ្ញោជនៈគឺ **ទិដ្ឋិ** ការប្រកាន់ ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់ អណ្តូង ការកាន់ដោយការស្វែងរកខុស ប្រកាន់វិបរិតវិបល្លាស ការប្រកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិត ថាជាការពិត ។

ការយល់ឃើញខុស ជាហេតុនាំឲ្យមានជំនឿខុស ការមានជំនឿខុសជាហេតុឲ្យមានការប្រកាន់តាមខុស ប្រតិបត្តិខុស

បានទទួលផលខុស ជម្លោះការឈ្លោះទាស់ទែងខ្វែងគំនិតគ្នា ក៏មកអំពីចិត្ត យល់ឃើញខុសប្រកាន់តាមខុស ការវិវាទរហូតមានការប្រកែកប្រកាន់គ្នាដោយសារទិដ្ឋិ មានគំនិតយោបល់ផ្សេងៗពីគ្នា ហើយប្រកាន់ទៅតាមគំហើញតែរៀងៗខ្លួន ។

ការយល់ឃើញខុសថាជាត្រូវ ជាផ្លូវឆ្ងាយដើរមិនងាយផុត ជាអន្លង់ជ្រៅលោតឆ្លងកន្លងមិនបាន ជាអន្ទាក់ចងឆ្នាក់មិនឲ្យរើខ្លួនងាករួច ធ្វើឲ្យមានដំណើរយឺតយូរក្នុងសង្សារវដ្ត ធ្វើឲ្យមានការតម្លើងមានះ លើកដាក់ចែកវណ្ណៈគ្នា ធ្វើឲ្យវត្តបដិបត្តិផ្សេងដោយឡែកពីគ្នា ។

កាលពុទ្ធសម័យ មានពួកព្រាហ្មណ៍ច្រើនណាស់ បាននាំគ្នាជឿកាន់តាមសាសនាព្រះព្រហ្ម ព្រះឥសូរ ពួកព្រាហ្មណ៍ទាំងឡាយនោះ មានជំនឿថា ព្រះព្រហ្មជាអ្នកបង្កើតលោក គឺបង្កើតទឹក ដី ភ្លើង ខ្យល់ សមុទ្ទ ស្ទឹង បឹងបួ ព្រៃភ្នំ មនុស្សសត្វទាំងអស់នៅក្នុងភពផែនដីនេះ ។ មិនតែប៉ុណ្ណោះ ពួកព្រាហ្មណ៍ទាំងនោះបានខំតម្លើងទិដ្ឋិមានះរបស់ខ្លួន ប្រកាន់បែងចែកវណ្ណៈទៅជាបួនឲ្យដាច់ដោយឡែកពីគ្នាថែមទៀត ។

- **វណ្ណៈបួនយ៉ាង ៖**

ពាក្យថា វណ្ណៈ បានដល់ ពណ៌ សម្បុរ ពន្លឺ រស្មី ភេទថ្នាក់ វង្ស ពូជ ពូជពង្ស (របស់មនុស្ស) តាមលទ្ធិព្រាហ្មណ៍គេ

ចែកពូជរបស់មនុស្សជាបួនថ្នាក់គឺ ៖

**ទី១. ព្រាហ្មណ៍** : ថាជា ( ដើមកំណើតដំបូងបំផុត ) កើតពីព្រះឱស្ឋរបស់ព្រហ្ម ព្រហ្មតម្រូវឲ្យជាម្ចាស់សាសនា មានមុខការខាងបង្រៀនប្រៀនប្រដៅវេទមន្តវិជ្ជាផ្សេងៗ ។

**ទី២. ក្សត្រិយៈ ឬខត្តិយៈ** កើតអំពីពាហា ( កំភួនដៃ ) របស់ព្រហ្ម មានមុខការខាងគ្រប់គ្រងរក្សាប្រទេស ។

**ទី៣. វៃស្យៈ ឬវេស្សៈ** កើតអំពីព្រះឧរុ ( ទ្រូង ) របស់ ព្រហ្ម មានមុខការខាងធ្វើកិច្ចការ ខ្ពង់ខ្ពស់ចុះរងពីក្សត្រិយមក ឬកិច្ចការធម្មតា ។

**ទី៤. សូទ្រៈ ឬសុទ្ទៈ** កើតអំពីព្រះបាទរបស់ព្រហ្ម ( មានមុខការខាងស៊ីឈ្នួល ឬធ្វើការថយថោកផ្សេងៗ ។

វណ្ណៈទាំងបួននេះ មានបញ្ញត្តិឲ្យស្លៀកដណ្តប់សំពត់ផ្សេងៗគ្នាគឺ ៖ ព្រាហ្មណ៍ ត្រូវប្រើសំពត់ស , ក្សត្រិយៈ ប្រើសំពត់ពណ៌ក្រហម , វៃស្សៈ ប្រើសំពត់ពណ៌លឿង , សូទ្រៈ ប្រើសំពត់ពណ៌ខ្មៅ ។

មិនត្រឹមចែកវណ្ណៈទៅតាមពណ៌សម្បុរ សម្លៀកបំពាក់ប៉ុណ្ណោះទេ ពួកព្រាហ្មណ៍មានទិដ្ឋិមានៈ ប្រកាន់មាំថា ពូជពង្សវង្សត្រកូលខ្លួនប្រសើរជាងគេ ។ វណ្ណៈព្រាហ្មណ៍ជាវណ្ណៈស វណ្ណៈដទៃជាវណ្ណៈខ្មៅ វណ្ណៈព្រាហ្មណ៍ជាវណ្ណៈខ្ពង់ខ្ពស់ វណ្ណៈដទៃជា

វណ្ណៈថោកទាប ព្រាហ្មណ៍កើតចេញពីមាត់ព្រហ្ម ជាវណ្ណៈឧត្តម មិនត្រូវគោរពវណ្ណៈដទៃ វណ្ណៈដទៃត្រូវតែគោរពពួកព្រាហ្មណ៍ ។

ការបែងចែកវណ្ណៈឲ្យដាច់ស្រឡះពីគ្នា ធ្វើឲ្យមានការទើសទាស់ឈ្លោះគ្នានៅពេលធីតាព្រាហ្មណ៍ បានមកស្នេហាស្មោះស្ម័គ្រជាមួយព្រះរាជកុមារក្តី ឬធីតាត្រកូលវេស្សៈ មកស្រឡាញ់បុរសជាត្រកូលព្រាហ្មណ៍ក្តី ត្រូវមាតាបិតាគេមិនទទួលស្គាល់ កាត់កាល់ចោល បើអ្នកទាំងពីរនោះបានរួមរស់ជាមួយគ្នា ទោះបីមានកូនប្រុស ឬកូនស្រី កូនហ្នឹងគេឲ្យឈ្មោះថា **ចណ្ឌាល** គេចាត់ថាជាមនុស្សថោកទាប ចង្រៃឧត្បាត ត្រូវគេបណ្តេញចេញ ឲ្យទៅរស់នៅឆ្ងាយពីស្រុកភូមិ ។

ពួកព្រាហ្មណ៍បាននាំគ្នាប្រកាន់ថា ខ្លួនជាកូនទាយាទរបស់ព្រហ្ម ខំនាំគ្នាលើកតម្កើងកម្ពស់ខ្លួនដោយអំណាចមិច្ឆាទិដ្ឋិ តែព្រាហ្មណ៍ឥតបានយល់ស្គាល់ ធម៌ជារបស់ព្រហ្ម ច្បាប់របស់ព្រហ្មថាជាយ៉ាងណា ៗ ។ ដោយការយល់ខុស ប្រកាន់ខុសប្រាសចាកហេតុផល ទើបព្រាហ្មណ៍បង្កើតលទ្ធិជំនឿ ការយល់ឃើញទៅតាមគោលគំនិតតែរៀង ៗខ្លួន ។

ដូចជាជំនឿក្នុងការស្វែងរកមង្គល ជំនឿក្នុងការបតិបត្តិខុសដោយឡែកពីគ្នា ពួកព្រាហ្មណ៍ខ្លះក្រោកពីព្រលឹម ឃើញរូបទាំងឡាយដែលសន្មតថាជាមង្គល ដូចជាឃើញសត្វត្រចៀកកាំ

ឃើញដើមញ្ចៅដុះ ឃើញស្ត្រីមានគភ៌ ឃើញក្អមមានទឹកពេញ ឃើញសេះអាជានេយ្យ ឃើញគោឧសភៈជាដើម ក៏ប្រកាន់ជឿនូវរូបទាំងឡាយមានសភាពយ៉ាងនេះ ថាជាមង្គល ។

ព្រាហ្មណ៍ពួកខ្លះ ឃើញគំនរចំបើង ឃើញឆ្នាំងខ្លាញ់ ឃើញឆ្នាំងទទេ ឃើញមនុស្សខ្វាក់ខ្វិន ជរា ឈឺ ស្លាប់ ឃើញរូបមានសភាពយ៉ាងនេះ ក៏ថាមិនមែនជាមង្គល ។

ការឮសម្លេង ធំក្លិន ក្រេបរស ប៉ះពាល់ត្រូវសម្ផស្ស ពួកព្រាហ្មណ៍យល់ឃើញ ប្រកាន់ជឿថាជាមង្គល ឬមិនមែនជាមង្គល ដោយការសន្មតិ ដូចជាពួកខ្លះក្រោកពីព្រលឹម គោរពព្រះអាទិត្យ គោរពទិស យកដៃអង្អែលដី ស្ទាបស្មៅស្រស់ ស្ទាបអាចម៍គោ ជាដើម ទាំងនេះព្រោះប្រកាន់ដោយទិដ្ឋិ និងមានជំនឿថាជាមង្គល។ ចំណែកខាងប្រព្រឹត្តវិញ មានច្រើនផ្សេងៗពីគ្នា ដូចជារដូវរងារគេនាំគ្នាចុះទៅត្រាំទឹក រដូវក្តៅហាលថ្ងៃ បំពក់ភ្លើងឆ្អើរ អាក្រាតកាយ អត់អាហារ ធ្វើវត្តដូចជាគោ ឆ្កែ ដើរជើងបួន បរិភោគអាហារដោយសារមាត់តាមគំនរសំរាមជាដើម ។

មានលទ្ធិប្លែកៗជាច្រើន ដែលពួកព្រាហ្មណ៍បាននាំគ្នាបង្កើតឡើង តាមការយល់ឃើញតែរៀងៗខ្លួន ។

ការប្រកាន់ក្នុងវត្ថុមិនពិត ថាជាការពិត រមែងធ្វើឲ្យងងឹតវង្វេង ដូចជាមនុស្សដើរខុសទិសដៅព្រោះជាអ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាបុគ្គល អ្នកដើរក្នុងទីងងឹតពិតជាមិនអាចចោលភ្នែកក្រឡេកមើលឃើញអ្វី សូម្បីតែវត្ថុនៅជាប់នឹងខ្លួន ក៏មើលមិនឃើញផង ។ យ៉ាងណាមិច្ឆាទិដ្ឋិ ការយល់ឃើញខុស ធ្វើឲ្យធ្លាក់ចុះក្នុងអន្លង់ភយន្តរាយ ញ៉ាំងជាតិកំណើតឲ្យកាន់តែវែងអន្លាយពន្យាផ្លូវដែលត្រូវដើរឲ្យកាន់តែឆ្ងាយទៅៗ ។

អន្លង់ជ្រៅដ៏មហាសែនជ្រៅ គឺការយល់ឃើញខុសនេះឯងមនុស្សកើតមកជាអ្នកឆ្គួតលីលាវង្វេងស្មារតី នៅមិនទាន់ទទួលទុក្ខភ័យ ឲ្យដូចជាបុគ្គលយល់ខុសទេ ព្រោះកាលបើមានចិត្តងងឹតគំនិតបែកឆ្វេង វង្វេងលែងយល់ត្រូវហើយ ក៏ជាហេតុធ្វើឲ្យប្រកាន់ខុស មានជំនឿខុស ។ ការប្រកាន់និងជឿខុស មានគំនិតនិងគំហើញខុស តើនឹងអាចងាកមករកត្រូវម្តេចបាន ? ។

ដូចជាអ្នកប្រកាន់ថា ៖ សត្វលោកកើតមកទៀង ស្លាប់ទៅវិញក៏ទៀង ។ បានសេចក្តីថា ធ្លាប់កើតមកជាមនុស្ស ជាប្រុសជាស្រី ធ្លាប់កើតមកជាសត្វ មានប្រភេទបែបយ៉ាងណាៗក្តី លុះស្លាប់ទៅវិញកើតទៀត ជាកំណើតទៀងទៅតាមប្រភេទ បែបផែនសណ្ឋានរាងពៅ ជាយ៉ាងនោះដដែល ។

ការយល់ឃើញថាសូន្យ ទិដ្ឋិដែលប្រកាន់ថា សត្វលោក មានកំណើតត្រឹមតែមួយជាតិ នៅពេលស្លាប់ចាកលោកនេះទៅហើយ ក៏សូន្យសោះអស់ជាតិកំណើតអ្វីទៀតហើយ គ្មានអ្វីនឹងអាចទៅចាប់ជាតិ មានកំណើតជាថ្មីបានទៀតទេ ។

ការប្រកាន់ដូចពោលមកនេះ ជាហេតុធ្វើឲ្យមានសេចក្តីប្រមាទ សោះអង្គើយព្រងើយកន្តើយ មិនយកចិត្តទុកដាក់ ក្នុងការបំពេញគុណប្រយោជន៍ សម្រាប់ខ្លួន សម្រាប់សង្គមជាតិខ្លួន ផ្ទុយទៅវិញធ្វើឲ្យគេព្យាយាមធ្វើអ្វីៗដើម្បីបម្រើ ទៅតាមចំណូលចំណង់របស់គេ ទោះបីជាទង្វើនោះប្រាសចាកគុណធម៌ សីលធម៌ក៏ដោយ ព្រោះគេគិតថា កើតមកមួយជាតិធាតុមួយចាន មុននឹងក្ស័យប្រាណគួរតែសប្បាយឲ្យអស់ដៃ ។

ទាំងនេះធ្វើឲ្យគេវង្វេងស្មារតី ងងឹតមិនអាចគិតអ្វីឃើញថាជាគុណជាទោស ខុសឬត្រូវ ជាផ្លូវគួរដើរឬមិនគួរដើរ ដោយគេបានប្រកាន់ខ្ជាប់ថា ជីវិតរស់នៅប្រាកដជាយ៉ាងណា លុះដល់ស្លាប់ទៅវិញកើតថ្មីទៀត វាគង់ទៀងទាត់ប្រាកដជាយ៉ាងនោះ ។ អ្នកដែលប្រកាន់ថាជីវិតនេះមានត្រឹមតែមួយជាតិ ក៏មិនខុសគ្នាដែរ ព្រោះគេមិនចាំបាច់ខ្វល់ព្រួយទៅគិត ដល់ជាតិមុខជាតិក្រោយអ្វីទៀត ឆ្លៀតរកសេចក្តីសប្បាយរីករាយបម្រើគោលគំនិត ដែលខ្លួនប្រកាន់ថាត្រូវជាយ៉ាងនោះហើយ ឃើញថាជាការស្រេច ដោយ

មិនចាំបាច់អើពើរវល់ខ្វល់ខ្វាយអំពីអ្នកដទៃណាឡើយ ។

ទិដ្ឋិបីយ៉ាង មានការយល់ឃើញថា មិនមានហេតុ មិនមានកម្ម ផលនៃកម្មមិនមាន បានដល់ការប្រកាន់របស់បុគ្គលពួកខ្លះ ទៅតាមការយល់ឃើញរបស់ខ្លួនដោយទាត់ចោលហេតុផលអាក្រក់ល្អ កម្មជាកុសល ឬអកុសល ។ បុគ្គលពួកនេះមានគំហើញយ៉ាងដូច្នេះ សត្វកើតមកក្នុងលោកនេះ កើតឯងមានឯងសេចក្តីបរិសុទ្ធ ឬមិនបរិសុទ្ធ មង្គលអព្វមង្គល កើតឯងមានឯងគ្មានអ្នកណាចាត់ចែងបង្កើតទេ គ្មានហេតុ គ្មានបច្ច័យអ្វីសោះឡើយ ។

ដើម្បីបញ្ជាក់សេចក្តីនេះបន្ថែម ខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកយកសំណួរ និងចម្លើយរបស់ព្រះរាជាទ្រង់ព្រះនាម **អង្គតិ** និងអចេលិក:ឈ្មោះ **គុណៈ** ជាកស្សបគោត្រ ( ដែលមានចែងក្នុង **សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ** លេខ ៦៣ ទំព័រ ៦ ) ។

( ១១ ). លំដាប់នោះ ព្រះរាជាព្រះអង្គប្រសើរក្នុងរថ ទ្រង់ប្រាថ្នាធមិ ក៏រីករាយតបទើបសួរអត្ថផង ធមិផង ហេតុដែលគួរដឹងផង ថាបពិត្រកស្សបគោត្រ សត្វគប្បីប្រព្រឹត្តធមិក្នុងមាតាបិតា តើដូចម្តេច ? គប្បីប្រព្រឹត្តក្នុងអាចារ្យ តើដូចម្តេច ? គប្បីប្រព្រឹត្តក្នុងកូនប្រពន្ធតើដូចម្តេច ? គប្បីប្រព្រឹត្តក្នុងពួកមនុស្សចាស់ តើ

ដូចម្តេច ? គប្បីប្រព្រឹត្តក្នុងសមណៈព្រាហ្មណ៍ តើដូចម្តេច ? ក្នុងពួកពល តើដូចម្តេច ? គប្បីប្រព្រឹត្តក្នុងជនបទ តើដូចម្តេច ? ។

សត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្តេច ? លះលោកនេះហើយទៅកាន់សុគតិ សត្វពួកខ្លះឋិតនៅក្នុងអធម៌ មានក្បាលសំយុងចុះធ្លាក់ទៅកាន់នរក តើដូចម្តេច ? ។

( ១២ ). អចេលិកៈ ជាកស្សបគោត្រ បានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយ ក៏ទូលដូច្នេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ នូវបទដែលពិត មិនឃ្លៀងឃ្លាតរបស់អាត្មាភាពចុះ ។ ផលល្អនិងអាក្រក់ របស់បុគ្គលអ្នកប្រព្រឹត្តធម៌មិនមានទេ បពិត្រព្រះសម្មតិទេព បរលោកក៏មិនមានដែរ ព្រោះថាក្នុងលោកនេះ មាននរណាមកពីបរលោក ។

បពិត្រព្រះសម្មតិទេព មួយទៀតមាតាបិតាមិនមានទេ មាតានឹងមានពីណា បិតានឹងមានពីណា បុគ្គលដែលមានឈ្មោះថាអាចារ្យមិនមានទេ បុគ្គលណានឹងទូន្មានបុគ្គលដែលទូន្មានមិនបាន ។ សត្វទាំងឡាយមានតុល្យភាពស្មើៗគ្នា សត្វទាំងឡាយជាអ្នកគោរពបុគ្គលចាស់មិនមានទេ កម្លាំងក្តី ព្យាយាមក្តីក៏មិនមានដែរ បុរសអ្នកព្យាយាមនឹងមានពីណា ។ ព្រោះថាសត្វទាំងឡាយទៀង ដូចទូកតូចចងភ្ជាប់នឹងទូកធំ សត្វរមែងបានរបស់ដែលត្រូវបាន ផលទានក្នុងបរលោកនោះនឹងមានមកពីណា ។

បពិត្រព្រះសម្មតិទេព ផលទានមិនមានទេ បពិត្រព្រះសម្មតិទេព សេចក្តីព្យាយាមមិនមានអំណាចទេ ទានគឺពួកជនពាលទេតើបញ្ញត្តមក ពួកបណ្ឌិតចាំតែទទួលយកទាននោះ ពួកជនពាលមិនមានអំណាច សម្គាល់ខ្លួនថាជាបណ្ឌិត រមែងឲ្យទានដល់បណ្ឌិតទាំងឡាយ ។

(១៣). ភ្លើង ដី ទឹក ខ្យល់ សុខ ទុក្ខ និងជីវិត ទាំង ៧ នេះឈ្មោះថាពួកទៀង ជាសភាវៈឲ្យដាច់មិនបាន ឲ្យកម្រើកមិនបាន ។ ពួកទៀងទាំង ៧ នេះគប្បីរស់នៅជាដរាប ដែលបុគ្គលកាត់ហើយមិនឈ្មោះថាកាត់ បុគ្គលអ្នកសម្លាប់ក្តី បុគ្គលអ្នកកាត់ក្តីមិនមាន ។ អ្នកណាឈ្មោះថាសម្លាប់អ្នកណាបាន ។ គ្រឿងសស្ត្រាទាំងឡាយគ្រាន់តែចូលចន្លោះនៃពួកទៀងប៉ុណ្ណោះ បុគ្គលណាយកដាវដែលសំលៀងហើយកាត់ក្បាលជនដទៃ បុគ្គលនោះមិនឈ្មោះថាកាត់ពួក ( ទៀង ) ទាំងនោះទេ ផលនៃបាបនៃការកាត់នោះនឹងមានពីណា ។

សត្វទាំងអស់កាលអន្ទោលអស់មហាកប្ប ៨៤ ទើបបរិសុទ្ធឯង កាលបើមិនទាន់ដល់កាលនោះ បុគ្គលសូម្បីសង្រួមក៏មិនបរិសុទ្ធ ។ កាលបើមិនទាន់ដល់កំណត់នោះ ពួកសត្វសូម្បីប្រព្រឹត្តសេចក្តីល្អច្រើន ក៏មិនបរិសុទ្ធ ទុកជាធ្វើបាបច្រើន ក៏មិនកន្លងហួសខណៈនោះដែរ ។ សេចក្តីបរិសុទ្ធនៃយើងទាំងឡាយ តាម

លំដាប់នៃកប្ប ៨៤ យើងទាំងឡាយមិនកន្លងហួស ( កម្រិត ) ដ៏ទៀងនោះទេ ដូចសាគរមិនកន្លងហួសច្រាំង ។

សេចក្តីដូចដែលពោលរៀបរាប់មកប៉ុណ្ណេះ គ្រាន់តែដើម្បីបញ្ជាក់ឲ្យឃើញថា ការជឿនិងការប្រកាន់តាមគំហើញខុស ចាត់ជាទោសយ៉ាងក្រៃលែង ដូចជាការយល់ចូលចិត្តរបស់អចេលកៈឈ្មោះ គុណៈកស្សបគោត្រ បានទាត់ចោលកម្មផល ហេតុបច្ច័យបាបបុណ្យគុណទោសទាំងអស់ មាតាបិតា គ្រូអាចារ្យ ការព្យាយាម សុទ្ធតែគ្មានផល សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធ មានឯងកើតឯង ទៅតាមកាលវេលា ។ បើសិនជាមនុស្សម្នាក់ៗ ដាក់ជំនឿទៅតាមការយល់ឃើញខុសដូច្នោះមែន ធ្វើឲ្យលោកនេះសោះសូន្យ ចាកគុណចាកប្រយោជន៍ទាំងអស់ ព្រោះមិនចាំបាច់ធ្វើអ្វីដែលជាសេចក្តីល្អ ដេកចាំកាលចាំវេលាឲ្យបាននូវសេចក្តីបរិសុទ្ធឯង ។ មិនតែប៉ុណ្ណោះ មនុស្សដែលជឿខុសរមែងប្រកាន់តាមការខុស កាលបើប្រកាន់តាមការខុសហើយ លែងអីនឹងធ្វើខុស កាលបើធ្វើខុសហើយ លែងអីនឹងបានទទួលផលខុស ។ ផលខុសនេះឯង តែងផ្តល់មកនូវទុក្ខក្នុងបច្ចុប្បន្ន ព្រមទាំងបរលោក ។ ឧទាហរណ៍ដូចបុគ្គលម្នាក់ប្រព្រឹត្តចោរកម្ម ត្រូវគេចាប់បាន តាំងឆ្លើយប្រាប់គេថា ការធ្វើនេះដោយសេចក្តីវង្វេងដោយការយល់ខុស ដោយការមិនដឹង ខំប្រឹងនិយាយដោះសារដោយប្រការផ្សេងៗយ៉ាងណា ក៏គេមិនអាចអត់ទោសឲ្យដែរ ។

នេះគឺជាច្បាប់របស់កម្មផល ដែលតែងផ្តល់ឲ្យបុគ្គលអ្នកធ្វើ ទាំងក្នុងលោកនេះនិងលោកខាងមុខ ដោយមិនអាចប្រកែកបាន ។ **មិច្ឆាទិដ្ឋិ** ការយល់ឃើញខុស ចាត់ថាជាទោសកំហុសយ៉ាងក្រៃលែងបំផុតក្នុងព្រះពុទ្ធសាសនា និងជាអន្លង់មួយដ៏សែនជ្រៅ ឲ្យសត្វលិចលង់ទៅ មិនងាយងើបឡើងមកបាន ។ សត្វលោកហ៊ានធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង ក៏ដោយសារជឿខុសប្រកាន់ខុស តណ្ហាចាត់ថាជាអន្លង់មួយទៅហើយ តែបើមានទិដ្ឋិកើតរួមជាមួយហើយ រមែងមានកម្លាំងខ្លាំងក្នុងការញ៉ាំងកិលេសឯទៀតកើតជាបន្តដូចជា មានៈ ការប្រកាន់ លើកតម្កើងខ្លួន ចចេសរឹងត្អឹង មិនព្រមទទួលត្រង់ត្រាប់ស្តាប់យកហេតុផលអំពីអ្នកដទៃជាដើម ក៏មកអំពីការប្រកាន់តាមការយល់ឃើញខុសមានបំណងប្រាថ្នាខុសនេះឯង ។

បុគ្គលវង្វេង ពុំមែនវង្វេងត្រឹមខ្លួនឯងតែម្នាក់ទេ រមែងដឹកនាំគេឲ្យវង្វេងទៀតផង ដូចជាពួកព្រាហ្មណ៍ខ្លះ ឥតរៀនខ្មាសហ៊ានប្រកាសថាខ្លួនឯងជាកូនព្រហ្ម ទាំងដែលខ្លួនមិនបានដឹងយល់ស្គាល់ធម៌ ដែលជាបញ្ញត្តិរបស់ព្រហ្មយ៉ាងណាផង ម្ល៉ោះហើយក៏តាំងលើកតម្កើងខ្លួនជាគណាចារ្យ បង្កើតលទ្ធិទៅតាមការងងឹតវង្វេងផ្សេងៗដឹកនាំសិស្សទាំងឡាយ ឲ្យប្រព្រឹត្តវង្វេងតាមដូចជាសម្លាប់សត្វបូជាយញ្ញ ។ល។ និង ។ល។

ព្រះបាទបសេនទិកោសល ក្រោយពីបានឮសម្លេងសត្វនរកស្រែកកណ្ដាលរាត្រីថា ៖ **ទុ. ស. ន. សោ** ទ្រង់មានសេចក្ដីតក់ស្លុតយ៉ាងខ្លាំង បានជឿតាមពួកព្រាហ្មណ៍បុរោហិត ឲ្យយកសត្វគ្រប់មុខ មួយមុខមួយរយៗ និងក្មេងប្រុសមួយរយ ក្មេងស្រីមួយរយ ដើម្បីធ្វើការបូជាយញ្ញ ។ ក្នុងពេលនោះ បានព្រះនាង **មល្លិកាទេវី** ជាអ្នកជួយព្រះអង្គឲ្យរួចចាកអំពីអកុសល ដោយបាននាំព្រះរាជាទៅគាល់ព្រះសម្ពុទ្ធ សួរអំពីហេតុដែលបានឮសម្លេងសត្វនរកនោះ ។

ចំណែកពួកសត្វនរកនោះ កាលខ្លួនមានកំណើតជាមនុស្ស ក៏ជាមនុស្សមានមិច្ឆាទិដ្ឋិ យល់ឃើញខុសប្រព្រឹត្តខុស ទើបបានទទួលទោសយ៉ាងដូច្នោះ ។ ខ្ញុំសូមលើករឿងនេះ មកសរសេរសង្ខេបខ្លីៗ ដើម្បីឲ្យស្របទៅតាមន័យ ក្នុងការយល់ខុសធ្វើខុសឲ្យបានកាន់តែច្បាស់ណាស់ទៅទៀត ។

ក្នុងសាសនាព្រះសម្ពុទ្ធកស្សបៈ កាលនោះមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ព្រះពុទ្ធកស្សបៈមានភិក្ខុសង្ឃ ៣ ម៉ឺនអង្គចោមរោមជាបរិវារ ព្រះអង្គយាងទៅប្រោសសត្វក្នុងក្រុងពារាណសី អ្នកក្រុងបានបបួលគ្នាធ្វើអាគន្តុកទាន [១] គ្រប់ៗគ្នា ។ ឯសេដ្ឋីបុត្របួន

---

(១) អាគន្តុ --គ័ន-តុ សំ. ( ន. ) អ្នកដែលទើបមកដល់ថ្មី, ភ្ញៀវ, ភ្ញៀវដែលមករក ។ វេវ. អាគន្តុក ។

នាក់ជាសម្លាញ់នឹងគ្នា ក្នុងម្នាក់ៗមានទ្រព្យ ៥០ កោដិ នៅក្នុងពារាណសីនោះដែរ ឥតមានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាឡើយ ។ បានជំនុំគ្នាថាយើងនឹងផឹកសុរាឲ្យស្រវឹង ហើយស៊ីសាច់ដែលមានរសឆ្ងាញ់ ទើបពិតជារបស់មានប្រយោជន៍ ។ ម្នាក់ទៀតនិយាយថា យើងគួរតែបរិភោគបាយស្រូវសាលី ដែលមានក្លិនក្រអូប និងវត្ថុមានរសផ្សេងៗ ។ ម្នាក់ទៀតនិយាយថា យើងត្រូវចំណាយប្រាក់ច្រើនឲ្យពួកស្រីៗប្រពន្ធ និងកូនក្រមុំអ្នកដទៃ នឹងស្ម័គ្រស្នេហាពួកយើងមិនខាន ។

សេដ្ឋីបុត្រទាំងបួន បានយល់ព្រមស្ម័គ្រចិត្តរួមគ្នាយ៉ាងនេះ ហើយក៏ចំណាយទ្រព្យប្រព្រឹត្តអបាយមុខ ស៊ីផឹកល្បែងពួកស្រីៗដែលមានរូបល្អ ដោយទ្រព្យ នាំគ្នាយកមកប្រព្រឹត្តបរទារកកម្ម [១] ចំពោះប្រពន្ធគេក៏មាន កូនក្រមុំគេក៏មាន រហូតអស់ពីរម៉ឺនឆ្នាំ ។ ទើបធ្វើមរណកាលទៅកើតក្នុងអវិចីនរក អស់ចន្លោះព្រះពុទ្ធមួយព្រះអង្គ រួចពីនរកអវិចីបានមកកើតក្នុងនរកលោហកុម្ភី ( ឆ្នាំងខ្ទះទង់ដែងយ៉ាងធំ ) មានជម្រៅ ៦០ យោជន៍ ។

ពួកសត្វនរកទាំងបួននោះ ចង់ស្រែកថ្លែងសេចក្ដីទុក្ខវេទនារបស់ខ្លួនប្រាប់គ្នីគ្នា ប៉ុន្តែដោយអំណាចកំសួលទឹកពុះខ្លាំង

---

(១) បរទារកម្ម ប៉ៈរ៉ៈទារ៉ៈក័ម ឬ -កៈក័ម បា. ( ន. ) អំពើដែលបុរសប្រព្រឹត្តខុសចំពោះភរិយារបស់អ្នកដទៃ គឺអំពើលួចប្រពន្ធគេ ។ បរទារកកម្ម

ពេក ខំស្រែកបានតែមួយម៉ាត់ ក៏លិចទៅក្នុងខ្ទះវិញ អាស្រ័យហេតុនេះទើបមហារាជស្តាប់ឮតែបួនម៉ាត់ថា **ទុ.ស.ន.សោ** ដូច្នេះ។

បញ្ជាក់សេចក្តីបានន័យថា សេដ្ឋីបុត្រទាំងបួននាក់ បានធ្លាក់ចុះទៅកាន់នរកទទួលបាបកម្មអស់កាលជាអង្វែងឆ្នាំ ក៏ព្រោះតែមានគំនិតយល់ឃើញខុស ប្រព្រឹត្តខុស សូម្បីតែកើតទាន់ ជួបព្រះសម្មាសម្ពុទ្ធហើយ ក៏មិនអាចមានជំនឿមកយល់ឃើញត្រូវបាន ។

ការយល់ឃើញខុស ជាចំណងជាបណ្តាញ ធ្វើឲ្យប្រទាក់ស្មុគស្មាញចេញទៅមិនបានឆ្ងាយ ឲ្យយឺតយ៉ាវក្នុងដំណើរដែលត្រូវទៅកាត់បង់ប្រយោជន៍ផលដែលត្រូវបាន ធ្វើឲ្យរំខានឲ្យស្មុះប្រយោជន៍ដល់ជនច្រើនគ្នាដែលគេជឿកាន់ តាមការយល់ខុសរបស់ខ្លួន ដូចជាអគ្គិទត្តបុរោហិត ដែលបានចេញបួសតាមសាសនាខាងក្រៅ ថែមទាំងមានសិស្សដប់ពាន់នាក់ នៅក្នុងសំណាក់ស្តាប់ការទូន្មានរបស់គាត់ ។

អគ្គិទត្តព្រាហ្មណ៍ មានការយល់ឃើញ ប្រាសចាកហេតុផល ឥតបានស្គាល់មាគ៌ាប្រតិបត្តិប្រាកដ គាត់បានឲ្យឱវាទដល់សិស្សរបស់គាត់យ៉ាងដូច្នេះថា ៖

" កិលេសទាំងឡាយ មានកាមវិត្តក [១] ជាដើម របស់យើង រាល់គ្នាកាលបើកើតមានចំពោះនរណា នរនោះគួរបន្ទោរចេញ ដោយរើសយកពំនូកនៃដុំខ្សាច់មួយដុំ រោយចុះមកក្នុងទីនេះ ។" សិស្សទាំងអស់ទទួលយល់ព្រមធ្វើតាម កតិកាសញ្ញា [២] ។

នៅពេលមានកិលេសកើតឡើង ម្នាក់ៗក៏យកដុំខ្សាច់ទៅដាក់ រហូតដល់កើតជាភ្នំខ្សាច់មួយ មិនតែប៉ុណ្ណោះអគ្គិទត្តៈ បានឲ្យឱវាទដល់សិស្សគ្រប់គ្នា ឲ្យយកព្រៃភ្នំក្រមថ្ម សមុទ្រ ស្ទឹង បឹងបួរ អារាមជាទីពឹង កាលបើអ្នកប្រព្រឹត្តយ៉ាងនេះ អ្នកនឹងបានរួចរំដោះចាកទុក្ខគ្រប់យ៉ាងបាន ។

ការប្រតិបត្តិរបស់អគ្គិទត្តៈព្រមទាំងពួកសិស្សទាំងនោះ គឺដើម្បីកំចាត់នូវកិលេស មានកាមកិលេសជាដើមដែរ ទាំងជាអ្នកប្រាថ្នាដើម្បីរំដោះទុក្ខទាំងពួង ។ ប៉ុន្តែការបដិបត្តិ ទៅតាមការយល់ខុស ជឿខុស ប្រកាន់ខុសជាហេតុធ្វើឲ្យយឺតយូរ ធ្វើឲ្យខាតបង់ពេលវេលា មិនខុសគ្នាអំពីអ្នកដែលមានខ្លួនប្រឡាក់ ដោយសារជាតិស្អុយ មិនគិតរកទឹកមកលាង ឬយកក្រណាត់មកជូតឲ្យស្អាតទេ គិតតែទៅរករបស់អ្វីដែលផ្សេងពីនោះទៅវិញ ។ អ្នកមានសេចក្តីទុក្ខគ្របសង្កត់ ព្រោះសេចក្តីស្រេកឃ្លានកើតមានឡើង

---

(១) កាមវិតក្ក (--វិ-តាក់-កៈ) សេចក្តីត្រិះរិះក្នុងកាម ។

(២) កតិកាសញ្ញា ការសន្មតិគ្នា, ការមត់គ្នាទុកជាគ្រឿងសំគាល់, ខសន្យា ។

មិនខំរកអាហារមកបរិភោគទេ បែរជាអង្គុយបន់ស្រន់ អង្វរករសុំវត្ថុស័ក្តិសិទ្ធយ៉ាងនេះយ៉ាងនោះឲ្យបានឆ្អែតទៅវិញ តើទាំងនេះសមស្របទៅតាមហេតុផលដែរឬ ? ។

**មិច្ឆាទិដ្ឋិ** ធ្វើឲ្យបាត់បង់គុណប្រយោជន៍ដែលត្រូវបាន ព្រោះតណ្ហា សេចក្តីប្រាថ្នាទៅតាមការយល់ឃើញខុសរបស់ខ្លួន ។ **មានះ** លើកតម្កើងប្រកាន់ **អតិមានះ** មើលងាយអ្នកដទៃ ។ **ថម្ភះ** ចចេសរឹងរូសប្រកាន់ទៅតាមការខុស មិនព្រមស្តាប់គ្រាប់តាម ឬទទួលយកគោលគំនិតពីអ្នកដទៃណាឡើយ ។

**ភិក្ខុទេវទត្ត** ជាសក្យត្រកូល បានចេញសាងផ្នួស ក្នុងសំណាក់ព្រះសាស្តាសម្មាសម្ពុទ្ធសក្យវង្សទាំងឡាយបានចូលបួសហើយ ព្យាយាមបតិបត្តិតាមឱវាទព្រះដ៏មានព្រះភាគ បានសម្រេចជាព្រះអរហន្តគ្រប់ព្រះអង្គ ។ ភិក្ខុទេវទត្ត បតិបត្តិបានសម្រេចឈានជាលោកិយ អាចសម្តែងឫទ្ធិហោះហើរដើរលើអាកាសបាន តែដោយអំណាចអកុសលចិត្តកើតឡើង មានគំនិតយល់ខុស ប្រទូស្តជាមួយព្រះពុទ្ធអង្គ ចង់លើកខ្លួនឯងឲ្យខ្ពស់ហួសព្រះអង្គ ព្យាយាមញុះញង់បំបែកសង្ឃ ឲ្យបែកបាក់ជាពីរក្រុម ព្រមទាំងបានបំភ័យបន្លាចព្រះបាទអជាតសត្រូវ ឲ្យភ័យខ្លាចដោយអំណាចឫទ្ធិខ្លួន ។ ដោយភាពចចេសរឹងរូសនិងការប្រកាន់ខុស ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះមេត្តាករុណាទិគុណ បានព្យា-

យាមឃាត់ ទេវទត្តឥតស្តាប់ ទៅញុះញង់ **អជាតសត្តុ** ឲ្យធ្វើឃាតព្រះបាទ **ពិម្ពិសារ** ជាព្រះបិតាយករាជសម្បត្តិ ខ្លួនឯងនឹងធ្វើឃាតព្រះបរមសាស្តា តាំងអាត្មាឯងឲ្យទៅជាព្រះពុទ្ធ ។ ផលដែលទេវទត្តត្រូវបាន លោកិយឈានវិនាសបាត់បង់អស់ ទាំងពីររូបត្រូវព្រះធរណីស្រូបធ្លាក់ទៅសោយបាបកម្មក្នុងនិរយលោក នៅរហូតសព្វថ្ងៃនេះ ។

បើសិនជា **ភិក្ខុទេវទត្ត** ព្យាយាមប្រតិបត្តិ តាមឱវាទព្រះសម្មាសម្ពុទ្ធដោយគ្មានទិដ្ឋិមានៈទេនោះ ម្ល៉ោះគង់នឹងបានឆ្លងផុតទុក្ខទោសក្នុងសង្សារវដ្តនេះទៅហើយ ។ ចំណែកឯអជាតសត្តុរាជាក៏ដូចគ្នា ដោយការយល់ខុសជឿតាមទេវទត្តព្រោះឃើញលោកិយឫទ្ធិតែប៉ុណ្ណោះ ហ៊ានធ្វើគុតព្រះបិតា ទើបបាត់បង់គុណគឺសោតា ក្រោយពេលបានស្តាប់ ព្រះធម៌ទេសនារបស់ព្រះសាស្តាចប់ ។

ដូច្នេះ **អន្លង់គឺទិដ្ឋិ** នេះ ជាអន្លង់ដ៏ជ្រៅធ្វើឲ្យសត្វលោកលិចលង់ទៅមិនងាយហែលឆ្លងផុត ងើបឡើងរត់ឲ្យរួចទៅបាន ។

## ❖ អន្លង់ទីបួន អវិជ្ជោឃៈ អន្លង់គឺអវិជ្ជា

អវិជ្ជា ឬអវិទ្យា ( ជាភាសាបាលី ឬសំស្ក្រឹត ) ជាភាសាខ្មែរប្រែថាការមិនដឹងច្បាស់ សេចក្តីល្ងង់ មោហៈ (វង្វេង ) សត្វលោកត្រូវអវិជ្ជារួបរិតបិទបាំង ព័ន្ធព័ទ្ធ ធ្វើឲ្យងងឹតសូន្យឈឹង ត្រង់ពាក្យ

ថាអវិជ្ជា បានន័យថាមិនដឹង បានសេចក្ដីថាមិនដឹងក្នុងកងទុក្ខ សេចក្ដីមិនដឹងក្នុងតណ្ហាជាហេតុនាំឲ្យកើតទុក្ខ សេចក្ដីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្ដីមិនដឹងក្នុងបដិបទា ( ប្រតិបត្តិ ) ជាដំណើរទៅកាន់ទីរលត់ទុក្ខ សេចក្ដីមិនដឹងក្នុងទីបំផុតខាងដើម សេចក្ដីមិនដឹងក្នុងទីបំផុតខាងចុង ទាំងសេចក្ដីមិនដឹងក្នុងទីបំផុតខាងដើមនិងបំផុតខាងចុងផង សេចក្ដីមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌នេះជាបច្ច័យ កិរិយាមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនចាក់ធ្លុះ ការមិនចុះចិត្ត ការមិនចុះចិត្តស៊ប់ ការមិនមានការរំពៃ ការមិនមានការពិចារណា ការមិនមានការយល់ច្បាស់ ការយល់បានក្រ ភាពជាពាល ភាពមិនមានសម្បជញ្ញៈ សេចក្ដីវង្វេងទូទៅ សេចក្ដីវង្វេងព្រម **ឱឃៈ** គឺអវិជ្ជា **យោគៈ** គឺអវិជ្ជា **អនុស័យ** គឺអវិជ្ជា ការស្ទាក់ដំណើរ គឺអវិជ្ជា បណ្ដាញ គឺអវិជ្ជា ។

**អវិជ្ជា** ជាសភាវហ៊ុមព័ទ្ធបិទបាំងប្រកត្និត ធ្វើឲ្យលោកងងឹតអ័ព្ទឥតពន្លឺ ។ **លោក** បានដល់លោកគឺ ៖ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត កាលបើត្រូវសេចក្ដីល្ងង់បាំងបិទហើយ ក៏ធ្វើឲ្យងងឹត មិនអាចយល់សេចក្ដីពិតបាន ។ **យោគៈ** គឺអវិជ្ជា ជាកិលេសជាតិប្រព្រឹត្តទៅត្រាំនៅជាមួយសត្វលោក សត្វលោកដែលមានគំនិតយល់ខុស មានសេចក្ដីប្រាថ្នាខុស មានចំណង់

ចំណូលចូលចិត្តខុស ព្រោះមានអវិជ្ជាជាបច្ច័យ អវិជ្ជាជាប្រភពដើមហេតុ ជាមេក្លោងក្នុងការបង្កើតកសាងអ្វីៗឲ្យមានក្នុងលោកទាំងអស់ ។ ដូចពាក្យថា ៖ **ត្រៃលោកគោកត្រៃលក្ខណ៍ សំសារចក្ករិលមិនដល់ អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ ។**

ពាក្យថា **ត្រៃលោក** សំដៅដល់លោកបីមាន ៖ **កាមលោក , រូបលោក , អរូបលោក** ជាភូមិឋានអាស្រ័យនៅ នៃសព្វសត្វទាំងឡាយ ដូចខ្ញុំបានសរសេររៀបរាប់ពីខាងដើមរួចមកហើយ ។ ពាក្យថា **ត្រៃលក្ខណ៍** បានដល់ធម៌ជាគ្រឿងសម្គាល់បីប្រការគឺ ៖
**១. អនិច្ចំ** សភាពមិនទៀង ប្រែប្រួល ផ្លាស់ប្តូរជារឿយៗទៅ ;
**២. ទុក្ខំ** សភាពជាទុក្ខ តានតឹងពិបាកធន់ ពិបាកទ្រាំ ;
**៣. អនត្តា** សភាពមិនមែនជាខ្លួនប្រាណ ជាសត្វជាបុគ្គល មិនឋិតនៅក្រោមអំណាច មិនអាចហាមប្រាមបាន ។

ដូច្នេះពាក្យថា **ត្រៃលោកគោកត្រៃលក្ខណ៍** ៖ បានដល់សត្វលោកដែលអាស្រ័យនៅក្នុងភពភូមិឋានទាំងបី ទោះជាមានប្រ - ភេទដោយឡែកពីគ្នាក៏ពិតមែនហើយ តែជាអ្នកប្រព្រឹត្តទៅស្មើគ្នាដោយធម៌បីប្រការ ព្រោះសត្វលោកឋិតនៅក្នុងលោកិយភូមិ បានឈ្មោះថាជាអ្នកកំពុងហែលឆ្លងក្នុងអន្លង់ រមែងមកទើរទាក់ទើសត្រឹមច្រាំងគឺ ៖ **អនិច្ចំ , ទុក្ខំ , អនត្តា** ។ ន័យមួយទៀត ធម៌បីប្រការនេះចាត់ថាជាកោះ ជាទីគោក បើសត្វលោកណាបានពិចារណា

យល់ច្បាស់ដោយបញ្ញា នូវធម៌បីប្រការនេះហើយ មានចិត្តសង្វេគភ័យតក់ស្លុត រន្ធត់ញាប់ញ័រចំពោះលោក ដែលមានទុក្ខទោសច្រើនប្រការ ឈ្មោះថាជាអ្នកបានកោះជាទីពឹងអាស្រ័យ ដើម្បីសម្លឹងមើលទិស ដែលគួរនឹងត្រាច់ចេញឲ្យផុត ។

ពាក្យថា **សំសារចក្កវិលមិនដល់** ៖ **សំសារចក្ក** លោកទុកដូចជាគ្រឿងយន្តយាន សម្រាប់ផ្ទុកពពួកសត្វ ។ **សំសារៈ** ប្រែថាអន្ទោលទៅអន្ទោលមក ។ **ចក្កៈ** ប្រែថាកង់ បានន័យថាភពលោក **លោក** ទុកដូចជារថ ដែលប្រកបដោយសម្ភារៈ មានកង់ មានកាំ មានដុំជាច្រើន ដូចជា អាសវៈ អវិជ្ជា ។ សង្ខារបីមាន ៖ **បុញ្ញាភិសង្ខារ , អបុញ្ញាភិសង្ខារ , អនេញ្ជាភិសង្ខារ** ។ **ជរាមរណៈ** ប្រកបផ្សំបានជារថមួយ ដឹកនាំពួកសត្វឲ្យអន្ទោលទៅអន្ទោលមក ចេញមិនផុតរត់ចុះមិនបានអំពីភពបី ៖ វិលកើតចាស់ឈឺស្លាប់រកចុងបញ្ចប់មិនឃើញ ។

**អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ** ៖ រុក្ខជាតិទាំងពួងមានឫសកែវ ជាប្រភពក្នុងការបឺតទឹកជីរជាតិ មកចិញ្ចឹមបណ្តុះដើម មែក ធាង ស្លឹក ផ្លែ ផ្កាឲ្យលូតលាស់ ដុះដាលទៅបានយ៉ាងណាមិញ អវិជ្ជាលោកចាត់ថា ជាឫសគល់ក្នុងការបណ្តុះធម៌ដទៃឲ្យកើតបានជាបន្តបន្ទាប់ដូច្នោះដែរ ។

ក្នុង **បដិច្ចសមុប្បាទធម៌** ធម៌ដែលមានទំនងទំនាក់ ប្រទាក់គ្នាដូចជាកាំច្រវាក់បានដល់ អវិជ្ជាជាបច្ច័យនៃសង្ខារ ពាក្យថាសង្ខារក្នុងបដិច្ចសមុប្បាទ បានដល់សង្ខារបីយ៉ាង ៖

- **បុញ្ញាភិសង្ខារ,**
- **អបុញ្ញាភិសង្ខារ ,**
- **អនេញ្ជាភិសង្ខារ** ។

○ **បុញ្ញាភិសង្ខារ** បានដល់កុសលាកុសលកម្ម តាក់តែងមនុស្សព្រមទាំងទេវតា ព្រហ្មមានរូបឲ្យកើតក្នុងភពភូមិឋានរបស់ខ្លួន ;

○ **អបុញ្ញាភិសង្ខារ** បានដល់អកុសលកម្ម តាក់តែងពួកសត្វនរក , ប្រេត , តិរច្ឆាន , អសុរកាយ ឲ្យកើតក្នុងអបាយភូមិ ;

○ **អនេញ្ជាភិសង្ខារ** បានដល់អរូបាវចរកុសលឈានជាឈានមិនញាប់ញ័រដោយអារម្មណ៍បាន តាក់តែងសត្វឲ្យកើតក្នុងភពភូមិឋាន ព្រហ្មគ្មានរូប ។

សត្វដែលកើតនៅក្នុងភព ដូចពោលមកហើយនេះឯងឈ្មោះថាមានអវិជ្ជាជាឫសគល់ជាបច្ច័យ ទើបចាត់ថាអវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ ។

ព្រះពុទ្ធដីកាក្នុង បដិច្ចសមុប្បាទធម៌ ព្រះអង្គបានត្រាស់សម្ដែងបញ្ជាក់អំពីធម៌ទាំងឡាយទាំងពួងដែលកើតឡើងបានព្រោះ

អាស្រ័យដោយហេតុដោយបច្ច័យ ធម៌ទាំងឡាយទាំងពួងនោះ មានអវិជ្ជាជាបច្ច័យ ដូចបទថា ៖

" **អវិជ្ជា បច្ចយា សង្ខារា សង្ខារប្បច្ចយា** " ដូច្នេះជាដើម។

**សង្ខារ** កើតមាន ព្រោះអវិជ្ជាជាបច្ច័យ , **វិញ្ញាណ** កើតមាន ព្រោះសង្ខារជាបច្ច័យ , **នាមរូប** កើតមានព្រោះវិញ្ញាណជាបច្ច័យ , **សឡាយតនៈ** កើតមានព្រោះនាមរូបជាបច្ច័យ , **ផស្សៈ** កើតមាន ព្រោះសឡាយតនៈជាបច្ច័យ , **វេទនា** កើតមានព្រោះផស្សៈជាបច្ច័យ , **តណ្ហា** កើតមានព្រោះវេទនាជាបច្ច័យ , **ឧបាទាន** កើតមានព្រោះតណ្ហាជាបច្ច័យ , **ភព** កើតមានព្រោះឧបាទានជាបច្ច័យ, **ជាតិ** កើតមានព្រោះភពជាបច្ច័យ , **ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ** កើតមានព្រោះមានជាតិជាបច្ច័យ , **ធម៌** ដែលមានបច្ច័យអាស្រ័យគ្នា ព្រោះមានអវិជ្ជាជាខាងដើម បង្កើតឲ្យមានទុក្ខសោករោគភ័យទាំងឡាយ ។

ដូច្នេះទុក្ខសោករោគភ័យ សេចក្ដីក្រវល់ក្រវាយដែលនឹងរលត់អស់ទៅបាន លុះណាតែរលត់អស់នូវអវិជ្ជា ដែលជាបច្ច័យនៃធម៌នោះៗដែរ ដូចបទថា **សេចក្ដីទុក្ខសោក** នឹងរលត់ទៅបាន លុះណាតែមិនមានជាតិ , **ជាតិ** មិនមានព្រោះរលត់ភព , **ភព** មិនមានព្រោះរលត់ឧបាទាន , **ឧបាទាន** មិនមានព្រោះរលត់តណ្ហា

**តណ្ហា** មិនមានព្រោះរលត់វេទនា , **វេទនា** មិនមានព្រោះរលត់ផស្សៈ , **ផស្សៈ** មិនមានព្រោះរលត់សឡាយតនៈ , **សឡាយតនៈ** មិនមានព្រោះរលត់នាមរូប , **នាមរូប** មិនមានព្រោះរលត់វិញ្ញាណ , **វិញ្ញាណ** មិនមានព្រោះរលត់សង្ខារ , **សង្ខារ** មិនមានព្រោះរលត់អវិជ្ជា ។

**អជិតមាណព** (១) ជាសិស្ស **ពាវរីព្រាហ្មណ៍** បានសួរព្រះដ៏មាន ព្រះភាគថា ៖

. " *បពិត្រព្រះមានព្រះភាគ ពាវរីព្រាហ្មណ៍សួរនូវក្បាលនិងធម៌ធ្វើឲ្យក្បាលឲ្យធ្លាក់ចុះ សូមព្រះអង្គព្យាករណ៍ប្រស្នានោះ បពិត្រព្រះអង្គជាឥសី សូមព្រះអង្គកំចាត់បង់នូវកង្ខាររបស់យើងទាំងឡាយ* " ។

ក្នុងពេលនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖

. " *អ្នកចូរដឹងថា* ***អវិជ្ជា*** *ជាក្បាល , វិជ្ជាដែលប្រកបដោយ* ***សទ្ធា , សតិ , សមាធិ , ឆន្ទៈ , វិរិយៈ*** *ជាធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ* " ។

**អវិជ្ជា** ទុកដូចជាក្បាល ព្រោះជាទីប្រជុំនៃធម៌ទាំងពួង ប្រៀបដូចជាខ្លួនមនុស្ស បើខូចបាត់បង់ត្រឹមតែអវៈយវៈណាមួយខាងក្រៅ នៅមិនមានជាអ្វីទេ តែបើគេកាត់ក្បាលបាត់បង់ទៅ

(១) ក្នុងគម្ពីរ **សុត្តន្តបិដក ខុទ្ទកនិកាយ ចុឡនិទ្ទេស បឋមភាគ** លេខ ៦៧ ទំព័រ ៩ ។

ហើយ ក៏ឃើញថាអវៈយវៈឯទៀតក៏ត្រូវខូចបាត់បង់ដែរ ។ ធម៌ទាំងឡាយមានអវិជ្ជាជាបច្ច័យ ជាទីប្រជុំឲ្យកើតបើសិនជាអវិជ្ជារលត់ហើយ ធម៌ទាំងឡាយក៏ត្រូវរលាយទៅតាមគ្នា ។

**អវិជ្ជា** ជាគ្រឿងប្រក់ ជាដំបូលបិទបាំងភ្និត ហ៊ុមព័ទ្ធមិនឲ្យឃើញពន្លឺ ក្នុងបណ្ដាធម៌ទាំងបួនប្រការមានៈ **កាម , តណ្ហា , ទិដ្ឋិ , អវិជ្ជា** ។ **អវិជ្ជា** ជាមេជាងបង្កើតសាង កុសលាភិសង្ខារ , អកុសលាភិសង្ខារ និងអនេញ្ជាភិសង្ខារ ។

សត្វទាំងឡាយណា កើតបានដោយកុសលាភិសង្ខារប្រជុំតាក់តែងឲ្យបានកើតមកជាមនុស្ស ជាទេវតា សត្វទាំងឡាយនោះរមែងលុះទៅដោយអំណាចតណ្ហា មានសេចក្ដីប្រាថ្នារឿយៗ មិនចេះគ្រប់គ្រាន់ មិនឆ្អែតឆ្អន់ដោយ **រូប , សម្លេង , ក្លិន , រស , ផោដ្ឋព្វៈ** ដែលហៅថា ៖ រូបតណ្ហា , សទ្ទតណ្ហា , គន្ធតណ្ហា , រសតណ្ហា , ផោដ្ឋព្វៈតណ្ហា ព្រមទាំងភោគសម្បត្តិ ចំណេះដឹង លាភយសសក្តិតំណែង អំណាច បរិវារ សុខ សរសើរ ។

តណ្ហានេះហើយធ្វើឲ្យសត្វលោក ស្វះស្វែងអន្ទះអន្ទែងញាប់ញ័រ ព្យាយាមរិះរកប្រកបធ្វើ ដើម្បីឲ្យបានរបស់ដែលខ្លួនប្រាថ្នានោះ ។ សេចក្ដីប្រាថ្នារបស់សត្វលោកមានក្រាស់ច្រើន មានកម្លាំងដរាបណា សេចក្ដីអន្ទះអន្ទែង រមែងមានកម្លាំងខ្លាំងដរាប

នោះ ព្រោះអវិជ្ជា សេចក្តីល្ងង់ខ្លៅ ភាពងងឹតវង្វេង មិច្ឆាទិដ្ឋិ សេចក្តីយល់ឃើញខុស ឃើញទោសជាគុណ ធ្វើឲ្យសត្វលោកធន់ទ្រាំ ជាប់ជំពាក់ធ្លាក់ចូលក្នុងអន្ទាក់ច្រវាក់កាម ឆ្ងាញ់ញៀនញ៉ាម សប្បាយរីករាយ ដោយទិដ្ឋិ អវិជ្ជា បិទបាំង ធ្វើឲ្យមើលឃើញត្រឹមតែជ្រុងម្ខាង គឺតម្រេកត្រេកត្រអាល ស្រើបស្រាលរីករាយ ។ ទន្ទឹមគ្នាជាមួយនឹងសេចក្តីសប្បាយភ្លើតភ្លើនភ្លេចខ្លួននោះ សត្វលោកភាំងភ្លេចស្មារតី ពុំបាននឹកឃើញដល់សេចក្តីទុក្ខសោះឡើយ ។

ពិតមែនហើយកាលសត្វលោក បានសម្រេចទៅតាមគោលបំណងប៉ងប្រាថ្នា ក៏នាំគ្នាគិតថា ខ្លួនមានបុណ្យវាសនាជោគសំណាងល្អ ។ ឧទាហរណ៍ដូចជាអ្នកលេងល្បែងភ្នាល់ ឬកីឡា ឈ្នះក៏នាំគ្នាលោតកញ្ឆេងស្រែកហ៊ោរគឹកកង បញ្ចេញសម្លេងឮរំពង សើចសប្បាយ មានទឹកមុខស្រស់ស្រាយឥតឧបមាដោយភ្លេចគិតថាទន្ទឹមគ្នានោះ អ្នកដែលចាញ់កំពុងតែខកខូចតូចចិត្ត សញ្ជប់សញ្ជឹងបង្ហូរទឹកភ្នែកនោះទេ ។ ល្បែងភ្នាល់ ម្តងគេម្តងឯង តែងប្តូរគ្នាសើចយំយ៉ាងដូច្នោះឯង ។

អ្នកផឹកទឹកឃ្មុំដែលគេបន្លំលាយដោយថ្នាំពិស ពេលដែលពិសពុលមិនទាន់ឲ្យផល ក៏រមែងជាប់ចិត្តលិទ្ធហើយលិទ្ធទៀតជញ្ជក់ហើយជញ្ជក់ទៀត ព្រោះជាប់ចិត្តនឹងរសផ្អែម នៅពេលពិស

ពុលបញ្ចេញសកម្មភាពពេលណា ទើបដឹងថា៖ ឱហ្ន៎! សេចក្តីទុក្ខលំបាកយ៉ាងដូច្នេះទេតើហ្ន៎! ។

មនុស្សលោក ពេលជួបជុំបងប្អូនកូនចៅផៅសន្តានញាតិមិត្តគ្រួសារមាតាបិតា បានសម្រេចសមស្របតាមសេចក្តីប្រាថ្នា ក្នុងយប់មួយថ្ងៃមួយ គេតែងឮសម្លេងសើចក្អាកក្អាយសប្បាយហ៊ោរ តែមិនបានយូរប៉ុន្មាន ការធ្លាប់សើចហ៊ោរផ្លាស់ប្តូរមកជាយំអណ្តឺតអណ្តក ខ្សឹកខ្សួលអួលណែន ដង្ហោយហៅ ឲ្យអ្នកដទៃជួយរំលែកទុក្ខសោកទៅវិញ ។ ទាំងនេះមិនមែនមកពីការបាត់បង់ខូចខាត វិនាសព្រាត់ប្រាសចាកញាតិ ឬរបស់ជាទីពេញចិត្តទេឬ?

ដោយការបម្រើតណ្ហា និងចំណូលចំណង់របស់ខ្លួន ហ៊ានប្រព្រឹត្តបទល្មើសដូចជា លួចឆក់កេងប្រវ័ញ្ច បោកប្រាសគ្រប់បែបយ៉ាង សាងសេចក្តីទុក្ខទោសដល់ខ្លួនដល់អ្នកផងទាំងពួង ដោយឥតមានកោតញញើត អកុសលលាភិសង្ខារនេះហើយ បានតាក់តែងអបាយភូមិ ជាតិកំណើតរបស់សត្វនរក , ប្រេត , តិរច្ឆានដែលជាភពឋានមានតែសេចក្តីទុក្ខក្តៅក្រហាយ រកសេចក្តីចម្រើនមិនមានសោះឡើយ ទាំងនេះមកអំពីសេចក្តីវង្វេង យល់ខុសព្រោះអវិជ្ជាទិដ្ឋិ ធ្វើឲ្យសប្បាយនឹងបាបកម្មនេះឯង ។

ពួកទេវតាទាំងឡាយ បានកើតក្នុងភូមិឋានដ៏ប្រសើរខ្ពស់ជាជាងឋានមនុស្សក្តី ជាអ្នកបរិបូណ៌ដោយរូបទិព្វ , សម្លេងទិព្វ ,

រសជាតិទិព្វ , ក្លិនទិព្វ , សម្ផស្សទិព្វ មានសេចក្តីសុខដោយកាមគុណ អ្វីៗគ្រាន់តែនឹកចង់បាន ក៏អាចកើតឯង មានឯងតាមសេចក្តីប្រាថ្នា ។ តែពួកទេវតាពុំមានឋានៈស្មើគ្នាទេ ការដែលមានឋានៈមិនស្មើនេះហើយ ទើបឲ្យមានការប្រណាំងប្រជែង ដោយអំណាចអវិជ្ជា ទិដ្ឋិ កាមៈតណ្ហា ។ ទេវតាពួកខ្លះត្រូវវិនាសខ្លួនដោយមានកំហឹងកើតឡើង ទេវតាពួកខ្លះសប្បាយភ្លើតភ្លើនភ្លេចខ្លួននឹងកាមគុណ ភ្លេចសោយអាហារជាហេតុ ធ្វើឲ្យច្យុតចាកភពភូមិឋានទេវតាឈ្មោះ **ខិឌ្ឌាបទោសិកា** វិនាសខ្លួនព្រោះតែល្បែងលេងសើច ។

ចំណែកពពួកព្រហ្ម ដែលបានចំរើនរូបាវចរកុសលឈានបានទៅកើតក្នុងឋានព្រហ្មមានរូបដប់ប្រាំមួយជាន់ អ្នកដែលបានចំរើនអរូបាវចរកុសលឈាន បានទៅកើតក្នុងឋានព្រហ្មឥតរូបបួនជាន់ ពួកព្រហ្មទាំងនោះមានអាយុវែងរាប់ចំនួនជាកប្ប ខុសប្លែកពីគ្នា ។ ពួកព្រហ្មគ្មានការសប្បាយរីករាយ ដោយកាមគុណទេ ហើយក៏គ្មានទោសៈដែរ តែព្រហ្មក្រៅពីសុទ្ធាវាសប្រាំជាន់ចេញ ពួកព្រហ្មដទៃពីនោះ សុទ្ធតែជាអ្នកនៅមានលោភៈ , ទិដ្ឋិ , អវិជ្ជា ជាប់ជំពាក់វង្វេងក្នុងភពភូមិឋាន កំណើតរបស់ខ្លួន ។

ដោយភាពវង្វេងនិងការជាប់ជំពាក់ ធ្វើឲ្យពួកព្រហ្មយល់ខុស ប្រកាន់ខុសថាគ្មានភពឋានណា ឲ្យប្រសើរស្មើនឹងឋានខ្លួន។

ការប្រក់ប៉ាំងហ៊ុមព័ទ្ធភ្និតធ្វើឲ្យងងឹត ទើបពួកព្រហ្មក្តី ទេវតាក្តី មនុស្សក្តី វង្វេងជាប់ជំពាក់ក្នុងភពឋាន ជាតិកំណើតរបស់ខ្លួន មិនអាចសម្លឹងមើលឃើញត្រើយ ជាទីកន្លងបង់សេចក្តីទុក្ខបាន ។

**អវិជ្ជា** ជាក្បាល ជាទីប្រជុំចុះនៃសង្ខារទាំងឡាយ ជាមេដំបូល ជាទីប្រជុំចុះនៃបង្កង់ផ្ទោងផ្លាន ជាគ្រឿងហ៊ុមព័ទ្ធធ្វើឲ្យសត្វលោក ចេញមិនផុតរត់មិនរួច អំពីភពទាំងបី មិនខុសអំពីទ្រុងដែលនាយព្រានធ្វើឡើង ដើម្បីក្រុងឃាំងបក្សាបក្សី ម្រឹគីម្រឹគាចិញ្ចឹមរក្សាបំប៉នអាហារយប់ថ្ងៃ ។ ហ្វូងបក្សាបក្សី តែងត្រេកអរសប្បាយដោយចំណីរបស់នាយព្រាន បំបាត់សេចក្តីស្រេកឃ្លានតែរាល់ថ្ងៃ ឥតបានគិតអំពីក្តីព្រួយភិតភ័យអ្វីឡើយ ។

ដោយបានចំណីឆ្អែដោយសប្បាយ ហ្វូងសត្វទាំងឡាយឥតបានគិតអំពីជីវិតដែលត្រូវជួបប្រទះក្នុងពេលខាងមុខ ថាជាយ៉ាងណាទេ លុះត្រាតែត្រូវពួកព្រានចាប់ក្របួចចង យកទៅសម្លាប់ទើបមានការភិតភ័យតក់ស្លុត រន្ធត់ញាប់ញ័រយ៉ាងក្រៃលែង ។

សត្វលោកក្នុងសង្សារវដ្ត ព្រោះតែមានសេចក្តីរីករាយសប្បាយត្រេកអរជាមួយ **ឥដ្ឋារម្មណ៍** គឺអារម្មណ៍ជាទីពេញចិត្តមានគំនិតគិតអណ្តែតអណ្តូងទៅជារឿយៗ តាមការទាញញាក់របស់អារម្មណ៍នោះៗ ម្តងជា **កាមវិតក្កៈ** ការគិតនឹកភ្នកកវត្ថុជាទីប្រាថ្នា

វត្ថុជាទីស្រឡាញ់ពេញចិត្ត គិតថាខ្លួននឹងត្រូវបានវត្ថុ ដែលខ្លួនប៉ុនប៉ងបំណងទាំងនោះ ក៏ធ្វើឲ្យចិត្តភ្លើតភ្លើនសប្បាយជំពាក់ទៅលើអារម្មណ៍នោះៗ ។

កាលបើមិនបានសម្រេច ទៅតាមចំណង់ចំណូលវិញ ក៏ប្រែក្លាយទៅជាកន្ទក់កន្ទេញ ថ្នាំងថ្នាក់អាក់អន់ស្រពន់ចិត្ត ត្បិតតែ **អនិដ្ឋារម្មណ៍** គឺអារម្មណ៍មិនជាទីពេញចិត្ត មានគំនិតអណ្តែតអណ្តូងទៅជារឿយៗ តាមការទាញញាក់របស់អារម្មណ៍នោះៗ ។

**ព្យាបាទវិតក្កៈ** ការគិតប្រកបដោយគំនិតក្តៅក្រហាយប្រទូស្តខឹង , **វិហឹង្សាវិត្តកៈ** ការគិតប្រកបដោយការបៀតបៀន ក៏កើតមានឡើង ។

ដូច្នេះសត្វលោក មានសេចក្តីរីករាយជាចំណង ជាគ្រឿងចងទុក មានសេចក្តីត្រិះរិះជាគ្រឿងប្រព្រឹត្តទៅជារឿយៗ មាន **ឥដ្ឋារម្មណ៍** និង **អនិដ្ឋារម្មណ៍** ជាចំណីរបស់ចិត្តផ្លាស់ប្តូរគ្នាក្នុងជីវិតប្រចាំថ្ងៃ ទើបធ្វើឲ្យសត្វលោក វង្វេងច្រឡំជាប់ចិត្តស្អិតទៅតែវត្ថុក្នុងកាម ដែលជាទីប្រាថ្នាជាទីពេញចិត្ត បំភ្លេចអស់សេចក្តីទុក្ខដែលលាយឡំផ្សំជាមួយកាមទាំងឡាយនោះ ព្រោះអវិជ្ជាទិដ្ឋិបិទបាំង មិនខុសគ្នាអំពីសត្វបក្សាបក្សី ពេញចិត្តនិងជាប់ចិត្តតែនឹង

រសជាតិចំណី ឥតបានគិតអំពីសេចក្តីស្លាប់ ដែលរំកិលមករកជីវិត គ្រប់ខណៈៗក៏ដូច្នោះដែរ ។

ដោយភាពវង្វេងភ័ន្តច្រឡំ និងការយល់ឃើញខុស ធ្វើឲ្យសត្វធ្លាក់ចូលទៅក្នុងអន្លង់ជ្រោះគឺ **ភព** ហើយក៏នៅតែមានសេចក្តីរីករាយ ដោយឥតខ្វល់ខ្វាយរកកោះគោកជាទីពឹងអាងសោះឡើយ សង្សារវដ្តវែងឆ្ងាយសម្រាប់សត្តា ដោយសារតែមានសេចក្តីរីករាយជាចំណងមានគំនិតគិតត្រិះរិះ ម្តងជាយ៉ាងនេះ ម្តងជាយ៉ាងនោះ ជាទីគោចរ ជាដំណើរត្រាច់ទៅរបស់សព្វសត្វ មានខ្សែតណ្ហាជាគ្រឿងបង្ហូរទៅ ឲ្យធ្លាក់ទៅក្នុងភពបី មើលតែត្រើយខាងអាយ មិនអាចចោលភ្នែកក្រឡេក សម្លឹងមើលឃើញត្រើយខាងនាយបាន ។

ក្នុង **សុត្តន្តបិដក ខុទ្ទកនិកាយ ចុឡនិទ្ទេស ទុតិយភាគ** លេខ ៦៨ ទំព័រ ១៥ ។ **ឧទយមាណព** ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា ៖

**កឹសុ សញ្ញោជនោ លោកោ**
**កឹសុ តស្ស វិចារណំ**
**កិស្សស្ស វិប្បហានេន**
**និព្វានំ ឥតិ វុច្ចតិ ។**

## សត្វលោកមានអ្វីជាគ្រឿងចងទុក
## អ្វីជាគ្រឿងត្រាច់ទៅរបស់សត្វលោក
## ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន ។

ព្រះមានព្រះភាគត្រាស់ថា ៖

**នន្ទិ សញ្ញោ ជនោ លោកោ វិតក្កស្ស វិចារណា**
**តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ**

**សត្វលោកមានសេចក្តីរីករាយជាគ្រឿងចងទុក**
**សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ**
**ដែលលោកពោលថានិព្វាន ព្រោះការលះតណ្ហាបាន ។**

**អវិជ្ជា , តណ្ហា , ទិដ្ឋិ** នៅមានដរាបណា សង្សារវដ្តជាផ្លូវឆ្ងាយនៅមានដរាបនោះ ។ សត្វលោកត្រាច់រង្គាត់តាមផ្លូវឆ្ងាយរមែងជួបប្រទះនូវសេចក្តីទុក្ខសោកច្រើនប្រការ មិនអាចនឹងគេចវេះជៀសឲ្យរួចផុតទៅបាន ទោះបីជាខ្លួនខំស្រឡាញ់ឲ្យតម្លៃទៅលើជីវិត ព្យាយាមរក្សាការពារជីវិតដោយវិធីណាក៏ដោយ ជីវិតនេះបានត្រឹមតែជាជីវិតពុកផុយ ជីវិតតិចតួចវិនាសបាត់បង់ទៅឆាប់រហ័ស ជីវិតជាចំណីនៃមច្ចុរាជ ជាទាសករ ជីវិតត្រូវត្រាច់រង្គាត់ត្រូវហែលឆ្លងកាត់អន្លង់ ជីវិតត្រូវចុះចាញ់សង្គ្រាមនៅក្នុងទីលានប្រយុទ្ធគ្រប់ខណៈទាំងអស់ ។

# អន្លង់បួនប្រការ

## បទកាកគតិ

*ជ្រោះបួនប្រការ ដែលសព្វសត្វា កំពុងហែលឆ្លង*
*មួយគឺ* **កាមៈ** *ជ្រោះជ្រៅកន្លង នាំឲ្យសត្វផង*
*លង់ផុងកាយា ។*

*ពីរគឺជា* **ភព** *សត្វផងងងល់ងប់ ព្រោះតែតណ្ហា*
*ជាទ្រុងឃាំងសត្វ នៅក្នុងសំសារ បិទបាំងនេត្រា*
*មិនឲ្យឃើញត្រើយ។*

*បីគឺ* **ទិដ្ឋិ** *ឃើញខុសអស្មិ ជាជ្រោះជ្រៅហើយ*
*ខុសពីកម្មផល ផ្តល់ទុក្ខឥតស្បើយ គ្មានគ្រូណាឡើយ*
*អាចទូន្មានបាន ។*

*បួន* **អវិជ្ជា** *នាំឲ្យសត្វា វង្វេងគ្រប់ប្រាណ*
*លង់មិនដឹងយល់ ពុំអាចស្គាល់បាន ទៅតាមលំអាន*
*អរិយសច្ចៈ ។*

*ជាអន្លង់ជ្រៅ កួចសត្វលង់នៅ ជួបដោយគ្រោះថ្នាក់*
*ឲ្យស្លុងផុងប្រាណ ប្រានចូលអន្លាក់ មច្ចុរាជចងឆ្នាក់*
*ត្របាក់ជានុយ ។*

ដោយ ឧបាសក **ម៉ិញ សាវ៉ាន**

# ការស្រឡាញ់ខ្លួន ត្រូវធ្វើដូចម្ដេច?

ការស្រឡាញ់ខ្លួនស្ងួនជីវិត ត្រឹមតែគិតការពារ ថែរក្សា ទំនុកបម្រុងព្យាយាមរកទ្រព្យសម្បត្តិចំណេះវិជ្ជា លាភ យស សុខ សរសើរ អំណាចតំណែងនាទី មកបំប៉នបំពេញចំណូលចំណង់របស់ខ្លួនត្រឹមតែប៉ុណ្ណោះឃើញថាជាការសប្បាយណាស់ទៅហើយ ដោយមិនចាំបាច់គិតខ្វល់អំពល់ចិត្តអ្វី អំពីអ្នកដទៃសោះ ម្ល៉ោះហើយក៏ខំព្យាយាមបម្រើទៅតាមតណ្ហា ការយល់ឃើញរបស់ខ្លួនទោះបីជាកិច្ចការនាទីខ្លួន ត្រូវប៉ះពាល់បៀតបៀនសង្កត់សង្កិនដល់សិទ្ធិសេរីភាពផលប្រយោជន៍ ធ្វើឲ្យអ្នកដទៃទទួលនូវក្ដីទុក្ខពិបាកវេទនាយ៉ាងណា ក៏មិនខ្វីអើពើយកភ្នែកមើល ឬមានចិត្តអាណិតអាសូរ ស្ងួម្បីតែបន្តិចបន្តួចក៏ទេដែរ ។ ទាំងនេះឈ្មោះថាជាអ្នកស្រឡាញ់ខ្លួនស្ងួនជីវិត ពិតដែរឬទេ ? ។

សូមកុំបោះបង់ខ្លួនចោលសោះឡើយ ជីវិតមានតិចណាស់ កាលវេលាទំពារស៊ីអាយុឲ្យអស់ទៅរាល់ៗខណៈ សូមកុំយកជីវិតទៅប្រព្រឹត្តអំពើអាក្រក់លាមក សូមកុំឈ្លក់វង្វេងដោយអំណាចតណ្ហាអវិជ្ជា ។

ជីវិតមនុស្សបានមកដោយកម្រពេកណាស់ បានមកដោយ

បុណ្យចាស់ដែលខំបំពេញមកពីអតីតជាតិ ជីវិតបច្ចុប្បន្នដែលឋិតនៅបាន ឈ្មោះថាកំពុងទទួលទានអាហារចាស់ (បុណ្យចាស់) ដូច្នេះសូមកុំយកជីវិតនេះ ទៅបម្រើប្រើប្រាស់ក្នុងអំពើបាបកម្មឲ្យសោះ បើពុំនោះសោតទេនឹងឈ្មោះថាជាអ្នកបំផ្លាញខ្លួន បោះបង់ខ្លួនចោលដោយឥតមានស្តាយស្រណោះ ព្រោះតែអំពើបាប អាចប្តូរអត្តភាពពីមនុស្ស ឲ្យធ្លាក់ចុះកាន់អបាយ ។

អបាយជាកន្លែងហាយនៈ មានតែសេចក្តីវិនាស ប្រាសចាកសេចក្តីសុខ ឥតមាននុយគឺកាមគុណ មិនអាចបណ្តុះបុណ្យកុសលបាន មានតែទុក្ខធរមាន និងការស្រេកឃ្លានខ្វះខាតតែប៉ុណ្ណោះ ។

ជីវិតមនុស្សពិតជាមានតម្លៃ ត្រង់ដែលជីវិតមានកម្រៃគឺបុណ្យ បុណ្យជាធនទ្រព្យជាប់មកជាមួយជីវិត អ្នកមានទ្រព្យមិនគប្បីយកទៅបម្រើសេចក្តីសប្បាយ ត្រេកត្រអាលភ្លើតភ្លើន រហូតដល់ភ្លេចស្មារតី អស់គ្មានសល់អ្វីបន្តិចបន្តួចនោះទេ ត្រូវព្យាយាមធ្វើជំនួញ ជួញយកចំណេញបំពេញ សម្រាប់ជាកម្រៃសមតាមពាក្យថា **ជីវិតពិតជាមានតម្លៃ** ។

ជីវិតក្នុងឋានមនុស្ស ជាឋានកណ្តាល ខាងក្រោមពិតជាមានជ្រោះ ងាកទៅខាងខ្ពស់មានឋានទេវតា ទេវតាមនុស្សនរកពិតជានៅជិតជាប់គ្នាបង្កើយ មិនបាននៅឆ្ងាយពីគ្នាសោះឡើយ។

តាមពុទ្ធដីកា ក្នុង **អាទិត្តបរិយាយសូត្ត** ព្រះសាស្ដាសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា លោកគឺភ្នែក , ត្រចៀក , ច្រមុះ , អណ្ដាត , កាយ , ចិត្ត នេះហើយដែលសាងនរក សាងទេវតា ។

ពេលណាលោកទាំងប្រាំមួយនេះ ប្រកបដោយភ្លើងមានកម្ដៅ គឺប្រកបដោយ **រាគគ្គិ , ទោសគ្គិ , មោហគ្គិ** ឋាននរកក៏ប្រាកដមកក្នុងនោះ ។ ពេលណាលោកទាំងប្រាំមួយនេះ រលត់អស់ចំហាយកម្ដៅ ចំហាយត្រជាក់កើតឡើង ពេលនោះឋានទេវតា ក៏កើតឡើងព្រមជាមួយគ្នាដែរ ។

ដូច្នេះត្រូវតែមានស្មារតី យប់ថ្ងៃត្រូវកុំបីធ្វេសប្រហែស បណ្ដោយឲ្យជីវិតនេះរបូតធ្លាក់ទៅកាន់ជ្រោះសោះឡើយ ត្រូវព្យាយាមរកកម្រៃផ្ដល់ឲ្យតម្លៃទៅលើជីវិតពិត គឺខំសន្សំបុណ្យជាធន ទ្រព្យ ជាប់បន្តសម្រាប់ខ្លួនក្នុងការធ្វើដំណើរ ឆ្លងកាត់អន្លង់កាត់ជ្រោះ ទើបឈ្មោះថាជាអ្នកស្រឡាញ់ខ្លួន មិនបានបោះបង់ខ្លួនចោលឡើយ ។



# អត្តាហិ អត្តនោ នាថោ
## ខ្លួនជាទីពឹងរបស់ខ្លួន

ពិតមែនហើយ សូម្បីតែជីវិតនេះនាំមកនូវមារ ជាទាសករ បិតនៅក្នុងរង្វង់សត្រូវ ជាអ្នកដើរផ្លូវឆ្ងាយ ត្រូវហែលឆ្លង ចាញ់សង្គ្រាមយ៉ាងណាក៏ដោយ ក៏ជិវិតនេះត្រូវតែធន់ទ្រាំតស៊ូ ដើម្បីរើបម្រះចេញឲ្យផុត ទោះបីជាត្រូវទទួលទុក្ខទារុណយ៉ាងណាអស់ពេរៈវេលាជាអង្វែង មិនអាចថាបានប្រមាណត្រូវយ៉ាងណាក៏ដោយ ក៏ជីវិតនេះត្រូវតែធន់តស៊ូគ្រប់ដំណាក់កាលយ៉ាងដូច្នេះឯង។

ខ្លួនជាទីពឹងខ្លួន ពាក្យថាខ្លួនបានដល់បញ្ចក្ខ័ន្ធ មានទាំងរូបទាំងនាមជាវិជ្ជមាន បញ្ញត្តិ សម្រាប់សម្គាល់ហៅស្តីនិយាយទៅតាមលោកវោហារការសន្មតិខ្លះ ជាផ្នែកបរមត្ថខ្លះ បើមានតែបរមត្ថ មិនមានបញ្ញត្តិ ជាវិជ្ជមានជាអវិជ្ជមានទេ ក៏គេមិនអាចមានពាក្យសម្តី ប្រាស្រ័យទាក់ទងគ្នាកើតដែរ ។

ដូច្នេះពាក្យថាខ្លួន បានដល់រូបនាមប្រជុំរួមគ្នា មានចលនាប្រព្រឹត្តទៅហៅថាជីវិតនេះឯង ។ ពាក្យថាខ្លួនទីពឹងខ្លួន និយាយឲ្យខ្លីបំបែកសេចក្តីឲ្យងាយយល់បានដល់ បាប បុណ្យ គុណ ទោស ខុសត្រូវអាក្រក់ល្អ ខ្លួនធ្វើគឺខ្លួនជាអ្នកទទួល អ្នកណាធ្វើអ្នកហ្នឹង

ជាអ្នកទទួល ។ ដូចជាអាហារ អ្នកណាបរិភោគអ្នកនោះឆ្អែតនេះជាហេតុផលពិត ត្រង់ថាយកខ្លួនជាទីពឹង ត្រូវព្យាយាមលះបង់សេចក្តីអាក្រក់ចេញ បំពេញសេចក្តីល្អដោយខ្លួនឯង ។ សូម្បីតែបញ្ចេញពាក្យសម្តី ពោលថា ៖ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭកស្មើដោយជីវិត ក៏ពិតមែនហើយ តែបើគ្រាន់តែពោលថា ហើយឥតបានត្រង់ត្រាប់បដិបត្តិតាមឱវាទទេនោះ សង្ឃឹមឲ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជួយតែម្យ៉ាង តើនឹងបានផលដែរឬទេ ? **ព្រះពុទ្ធជួយបានតែមនុស្សមានការ ទេវតាជួយបានតែអ្នកព្យាយាម** ។

ក្បូនជីវិតពិតជាកំពុងអណ្តែត ក្នុងមហាសាគរដ៏ធំធេង ដូច្នេះមានតែម្ចាស់ជីវិតដែលសន្មតថាខ្លួននេះឯង ត្រូវប្រឹងដោលអុំដោយខ្លួនឯងប្រាកដណាស់ ដើម្បីតម្រង់ណែនាំក្បូនជីវិតឲ្យផុតព្យុះសង្ឃរា មានដំណើរត្រង់ទៅតាមទិសដៅពិតប្រាកដ ។

ការលើកតម្កើងឲ្យតម្លៃជីវិតក្តី ការស្រឡាញ់ពេញចិត្តចំពោះជីវិតខ្លួនក្តី បានឈ្មោះថាមិនបណ្តោយខ្លួនឲ្យលុះក្នុងអំពើបាប ការយកខ្លួនជាទីពឹងពំនាក់ បានដល់ការបដិបត្តិតាមគុណធម៌គឺសេចក្តីល្អនេះឯង ។ អ្នកមានគុណធម៌ឈ្មោះថា អ្នកមានខ្លួនជាទីពឹងពំនាក់ អ្នកបដិបត្តិតាមព្រះធម៌ ឈ្មោះថាមានខ្លួនជាទីពឹងរបស់ខ្លួន គុណធម៌ជាក្បូន ជួយសណ្តោងយោងក្បូនជីវិត

ឲ្យឆ្លងផុតពីសមុទ្រទុក្ខទាំងបួនបាន ដូច្នេះជីវិតសូម្បីតែមានរយៈខ្លី ក៏មិនត្រូវភ្លេចស្មារតីក្នុងការសន្សំបំពេញ គុណធម៌ឲ្យកើតមានសម្រាប់ជីវិតនោះឡើយ ។

*ពិសាផ្លែប្រាំ ពិសាររសធម្ម ពិសាសត្យា*
*ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសាររសវា-*
*ចាចេញមធូរ ។*

(សាស្ត្រាច្បាប់ រាជនេតិ ជាព្រះនិពន្ធនៃព្រះរាជសម្ភារ) ។



# គុណធម៌ បួនប្រការ

អន្លង់ទុក្ខមានបួនប្រការ ដែលសត្វាត្រូវហែលឆ្លង ចំណែកធម៌ជាយានសម្រាប់ចម្លងសត្វ ក៏មានបួនប្រការដែរ ៖

**១. សទ្ធា** **៣. វិរិយៈ**

**២. អប្បមាទៈ** **៤.បញ្ញា**

ដោយព្រះមហាករុណាទិគុណរបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គឈ្វេងយល់ឃើញសត្វលោក បានធ្លាក់ចុះក្នុងអន្លង់ ផុងប្រាណមិនងាយហែលឆ្លង ឲ្យកន្លងផុតទៅបាន ទ្រង់មានទឹកព្រះទ័យមេត្តា បានសម្តែងចង្អុលបង្ហាញនាវាធម៌បួនប្រការទុកឲ្យសត្វបានជិះឆ្លងសមុទ្ទទុក្ខ ដោយការបដិបត្តិតាម ។

## ១. គុណធម៌ទី ១ : សទ្ធាយ តរតិ ឱឃំ ឆ្លងអន្លង់បានដោយសទ្ធា

ពាក្យថា **សទ្ធា** ( ជាភាសាបាលី សំស្ក្រឹត ) ប្រែថាជំនឿ សេចក្តីជឿបុណ្យ ជឿបាប ជឿអំពើជាគុណ ជាទោស ខុសត្រូវ ល្អអាក្រក់ គឺជាសទ្ធា **ញាណសម្បយុត្ត** ជំនឿប្រព្រឹត្តទៅមួយអន្លើ ដោយបញ្ញា យល់ហេតុផលត្រឹមត្រូវពិតប្រាកដ ហៅថា សម្មាសទ្ធា ជឿត្រូវ ។ **សទ្ធា** ជឿត្រូវចែកចេញជាបួនយ៉ាង ៖

**១. កម្មសទ្ធា** ជឿកម្ម ;

**២. វិបាកសទ្ធា** ជឿផលរបស់កម្ម ;

**៣. កម្មស្សកតាសទ្ធា** ជឿថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ;

**៤. តថាគតពោធិសទ្ធា** ជឿប្រាជ្ញាការត្រាស់ដឹងរបស់ព្រះមានព្រះភាគ ។

**កម្មសទ្ធា** ជឿកម្ម **កម្ម** ប្រែថាអំពើ ឬការងារ អំពើអាក្រក់ អំពើល្អ កុសលកម្ម អំពើជាកុសល , អកុសលកម្ម អំពើជាអកុសល , បុញ្ញកម្ម អំពើជាបុណ្យ ឬការងារជាបុណ្យ , បាបកម្ម អំពើជាបាប ឬការងារជាបាប ។

ពាក្យថាជឿកម្ម បានដល់ចិត្តជឿស៊ប់ទៅលើកម្មទាំងពីរផ្នែក ទាំងខាងអាក្រក់ទាំងខាងល្អ ថាពិតជាមានប្រាកដមែន ។ អំពើអាក្រក់បានដល់ទុច្ចរិត គឺការប្រព្រឹត្តអាក្រក់តាមទ្វារទាំងបីមាន ៖ **កាយទ្វារ , វចីទ្វារ , មនោទ្វារ** ។

❖ **កាយទ្វារមានបី ៖**

១. ការសម្លាប់សត្វ បំបាត់ជីវិត;

២. លួចឆក់ឆ្មក់កេងប្រវ័ញ្ច បោកប្រាសបន្លំបំបាត់ ទ្រព្យសម្បត្តិអ្នកដទៃ ដោយចំពោះមុខក្ដី ដោយកំបាំងមុខក្ដី ;

៣. ការប្រព្រឹត្តខុសក្នុងកាម ទៅលើប្រពន្ធកូនប្ដីអ្នកដទៃ ;

ការប្រព្រឹត្តទាំងបីយ៉ាង ដូចបានពោលមកហើយនេះ ចាត់ថាជាអំពើអាក្រក់ អកុសល បាបតាមកាយទ្វារ ។

### ❖ វចីទ្វារមានបួន ៖

១. ពោលពាក្យកុហក បោកប្រាសខុសពីសេចក្ដីពិត ;

២. ពោលពាក្យញុះញង់ ពាំពាក្យខាងនេះទៅប្រាប់អ្នកនោះ ដោយមានបំណងចង់ឲ្យអ្នកដទៃបែកបាក់ ឈ្លោះប្រកែកស្អប់គ្នា ;

៣. និយាយពាក្យចាក់ដោត ពាក្យគ្រោតគ្រាត គំហក កំហែងបន្ទុះបង្អាប់ ធ្វើឲ្យអ្នកដទៃមានការឈឺចុកចាប់ ថ្នាំងថ្នាក់អាក់អន់ស្រពន់ចិត្ត ;

៤. ពោលពាក្យរោយរាយ ប៉ប៉ាច់ប៉ប៉ោចឥតប្រយោជន៍ ឥតខ្លឹមសារ ជាតិរច្ឆានកថាប្រាសចាកធម៌វិន័យ ។

ការប្រព្រឹត្តទាំងបួនយ៉ាង ដូចបានពោលមកហើយនេះ ចាត់ថាជាអំពើអាក្រក់ អកុសល បាបតាមវចីទ្វារ ។

### ❖ មនោទ្វារមានបី ៖

១. ចិត្តសម្លឹង រំពៃចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកជារបស់ខ្លួន ;

២. ចិត្តគិតព្យាបាទ ប្រទូស្តធ្វើឲ្យអ្នកដទៃដល់នូវក្ដីវិនាស ឬទទួលនូវសេចក្ដីទុក្ខ ដោយប្រការណាៗ ;

៣. ចិត្តយល់ឃើញខុសប្រាសចាកហេតុផល ប្រាសចាកបុណ្យបាប គុណ ទោស អាក្រក់ ល្អ ទាំងនេះចាត់ថាជាអំពើអាក្រក់ អកុសល បាប តាមមនោទ្វារ ។

អំពើល្អជាកុសលកម្ម ឬជាបុញ្ញកម្ម បានដល់**សុចរិត**បី គឺការប្រព្រឹត្តល្អតាមទ្វារ **កាយ , វាចា , ចិត្ត ៖**

❖ **កាយសុចរិត** ការប្រព្រឹត្តល្អតាមទ្វារកាយមានបី ៖

១. ការវៀរចាកការសម្លាប់សត្វ បំបាត់ជីវិតអ្នកដទៃ ;

២. ការមិនកាន់យកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយឬដោយវាចា ;

៣. ការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ;

❖ **វចីសុចរិត** ការប្រព្រឹត្តល្អតាមទ្វារវាចាមានបួន ៖

១. វៀរចាកការនិយាយកុហក ;

២. វៀរចាកការនិយាយញុះញង់ ;

៣.វៀរចាកការនិយាយចាក់ដោតឲ្យគេមានការឈឺចុកចាប់

៤. វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ។

❖ **មនោសុចរិត** មានបី ៖

១. មិនសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ មកជារបស់ខ្លួន ;

២. មិនព្យាបាទអ្នកដទៃ ;

៣. យល់ឃើញត្រឹមត្រូវទៅតាមហេតុផលពិត ។

ទាំងបីយ៉ាងនេះចាត់ថាជាមនោសុចរិតគឺ ការប្រព្រឹត្តល្អតាមផ្លូវចិត្ត ។

ការងារនៅក្នុងលោកនេះ ទោះបីជាមានច្រើនដោយប្រការផ្សេងៗ រាប់មិនអស់យ៉ាងណា ក៏បំព្រួញឲ្យខ្លីទៅតាមន័យព្រះពុទ្ធសាសនាមានត្រឹមតែពីរយ៉ាងគឺ ៖ អាក្រក់និងល្អនេះឯង ដូចបានសម្តែងពោលរៀបរាប់មកហើយ ។

ទ្រឹស្តីព្រះពុទ្ធសាសនា បានពោលបញ្ជាក់ប្រាកដច្បាស់អំពីកម្មនិងផលរបស់កម្ម កម្មអាក្រក់និងកម្មល្អ ដូចជាពណ៌សនិងខ្មៅផ្សេងដោយឡែកពីគ្នា ។ អំពើអាក្រក់ដូចជាវត្ថុកខ្វក់ មិនស្អាតដែលគួរឲ្យខ្ពើមរអើម កុំថាឡើយចំពោះមនុស្សល្អជាអ្នកខ្ពើមរអើមចំពោះអំពើអាក្រក់នោះ សូម្បីតែអ្នកដែលធ្វើអំពើអាក្រក់ទាំងឡាយ ដោយអកុសលមូលចិត្តណាមួយ ដូចជាធ្វើចោរកម្មជាដើម ត្រូវរាជការចាប់ចង ស្រាប់តែមានគេទៅស្រែកជេរចង្អុលមុខតិះដៀលថា ជាចោរអាក្រក់យ៉ាងនេះយ៉ាងនោះ បុគ្គលដែលជាចោរប្រាកដជាមិនត្រេកអរទេ មុខជាមានការអៀនខ្មាស និងការខឹងសម្បារយ៉ាងខ្លាំង ។

ប៉ុន្តែផ្ទុយទៅវិញ បើសិនជាមានអ្នកដែលមិនដឹង មិន

ដែលស្គាល់ថាបុគ្គលនោះជាចោរទេ ស្រាប់តែគេមកពោលសរសើរថា លោកជាមនុស្សល្អ មានគុណធម៌ យ៉ាងនេះយ៉ាងនោះ បុគ្គលជាចោរប្រាកដជាមានចិត្តត្រេកអររីករាយ សប្បាយជាមិនខាន ។ ទាំងនេះអាចបញ្ជាក់បានថា សេចក្តីល្អជាគុណជាតិដែលសត្វលោកតែងប៉ងប្រាថ្នា ។

**១. សទ្ធា** ដែលថាជឿកម្ម បានន័យថា ជឿថាកម្មអាក្រក់ប្រាកដជា " **អគុណ** " មិនជាទីពេញចិត្តនៃសត្វទាំងឡាយ ជាអំពើដែលគួរលះបង់ អំពើល្អជាគុណគឺជាទីពេញចិត្ត គួរត្រេកអរគួរសប្បាយ ដែលសត្វទាំងឡាយគប្បីបំពេញឲ្យកើតមាន ។

**២. វិបាកសទ្ធា** ជឿផលរបស់កម្ម បានន័យថាកម្មទោះបីជាខាងអាក្រក់ក្តី ល្អក្តី ដែលបុគ្គលបានធ្វើហើយ ប្រាកដជាបានទទួលផល ទៅតាមចំណែកនៃកម្មនោះ ។

សមដូចព្រះពុទ្ធភាសិត បានសម្តែងបញ្ជាក់យ៉ាងនេះថា ៖

**យាទិសំ វបតេ ពីជំ**
**តាទិសំ លភតេ ផលំ**
**កល្យាណការី កល្យាណំ**
**បាបការី ច បាបកំ ។**

**បុគ្គលព្រោះសាបព្ធជយ៉ាងណា រមែងបានផលយ៉ាងនោះ**
**អ្នកធ្វើហេតុល្អ តែងបានទទួលផលល្អ**

**អ្នកធ្វើហេតុអាក្រក់ តែងបានទទួលផលអាក្រក់ ។**

ពុទ្ធភាសិតនេះ ព្រះអង្គបានសម្តែងបញ្ជាក់អំពីហេតុ និងផល ។ កសិករសាបព្រោះបណ្តុះដាំពូជយ៉ាងណា រមែងបានទទួលផ្លែផ្កាមកជាយ៉ាងនោះ កម្មសឲ្យផលជាស កម្មខ្មៅឲ្យផលជាខ្មៅ អ្នកធ្វើបុណ្យបានទទួលផលគឺ សេចក្តីត្រេកអររីករាយពេញចិត្ត ឆ្អែតចិត្ត ។ អ្នកធ្វើបាបបានទទួលផល ជាទុក្ខទោសថ្នាំងថ្នាក់អាក់អន់ស្រពន់ចិត្ត ។ ការមានជំនឿទៅលើផលរបស់កម្មយ៉ាងនេះ ចាត់ថាជា **វិបាកសទ្ធា** ។

**៣. កម្មស្សកតាសទ្ធា** ជឿថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ។ សត្វទាំងពួងក្នុងសង្សារវដ្តនេះ សុទ្ធតែមានកម្មជាពូជ មានកម្មជាកំណើត មានកម្មជាទីពឹងរឭក សត្វលោកធ្វើនូវកម្មណា ជាកុសលកម្មក្តី ជាអកុសលកម្មក្តី កម្មនោះហើយជាទីពឹងអាស្រ័យ ជាមរតក ជាពូជឲ្យកំណើតដល់សត្វទាំងឡាយនោះ ។

➢ **កម្មទុកដូចជាស្រមោលអន្ទោលតាមប្រាណ ឬទុកដូចជាស្នាមគំនូសរបស់ត្រា និងតួត្រា ។ ក្នុងលោកនេះ គ្មានកម្លាំងដទៃ ណាឲ្យខ្លាំងស្មើកម្លាំងកម្មសោះឡើយ ។**

# នត្ថិ កម្មំ សមំ ពលំ
# កម្លាំងស្មើដោយកម្មមិនមាន

សត្វលោកឋិតនៅក្រោមអំណាចនៃកម្ម ព្រោះតែការកសាងកម្មផ្សេងដោយឡែកពីគ្នាដូច្នេះហើយ ទើបសត្វលោកកើតមកមិនដូចគ្នា ទាំងភពភូមិឋាន រូបរាងកាយ ចំណង់ចំណូលរបស់ចិត្ត កុំថាឡើយដល់ទៅពួកសត្វដែលកើតមកមានមាតាបិតាមេបាខុសគ្នា សូម្បីតែសត្វកើតចេញមកពីផ្ទៃតែមួយ ក៏នៅតែមិនដូចគ្នាទេ ។

ដូច្នេះបញ្ជាក់បានថា មាតាបិតាមេបា ពុំមែនជាអ្នកផ្តល់កំណើតឲ្យកូនប្រុសស្រីទាំងអស់នោះទេ ។ ជលាពុជៈកំណើត កំណើតកើតបានដោយសារការផ្សំធាតុមានមាតាបិតា ធាតុមេបា និងមានកម្មធាតុជាបច្ច័យទៀតផង ។

ហេតុដែលនាំឲ្យសត្វចាប់បដិសន្ធិបានមានបីយ៉ាង ៖

១. មាតាមានឧតុរដូវ បានន័យថាមានសុខភាពល្អ មានថ្ងៃខែជាប្រចាំតាមរដូវកាល ;

២. មាតាបិតាបានរួមរស់ជាមួយគ្នា ;

៣. មានសត្វចុះចាប់បដិសន្ធិ ។ ត្រង់ពាក្យថាមានសត្វចុះចាប់បដិសន្ធិនោះ បានដល់កុសលវិបាក អកុសលវិបាក ដែលកើតអំពីកម្មជាបច្ច័យដល់វិបាកបដិសន្ធិ ។ ដូច្នេះហើយទើបសត្វ

លោកកើតមកខុសដោយឡែកពីគ្នា ទាំងរូបរាងកាយ ទាំងចិត្ត គំនិត សូម្បីកើតចេញពីផ្ទៃមាតាតែមួយ មានកូនខ្លះឆ្លាត , ខ្លះ ឆោតល្ងង់ , ខ្លះចិត្តល្អ , ខ្លះចិត្តអាក្រក់ តើមាតាបិតាចង់ឲ្យកូនមាន សភាពខុសគ្នាដូច្នេះឬ ? តាមពិតគ្រប់តែមាតាបិតា តែងមានចិត្ត ប្រាថ្នាឲ្យកូនទាំងអស់ បានប្រកបដោយកាយសម្បទា ចិត្ត សម្បទាល្អបរិបូណ៌ស្មើៗគ្នា តែក៏មិនអាចសម្រេចតាមចិត្តដែល ប្រាថ្នាបាន ។

ដូច្នេះមាតាបិតាពុំមែនជាពុម្ព ឬជាត្រា ផលិតបង្កើតកូន ឲ្យបានដូចចិត្តប្រាថ្នាហួសពីអំណាចនៃកម្ម ដែលសត្វលោកបាន សាងមកនោះទេ ។ មាតាបិតាទុកដូចជាជម្រក ឬជាម្លប់ដ៏ត្រជាក់ ជាទីស្នាក់ជ្រកកោនអាស្រ័យនៅ នៃកូនប្រុសស្រីដែលធ្វើដំណើរ មកអំពីទីដទៃៗពីគ្នា ហើយឃើញម្លប់ដែលអាចចូលជ្រកជាមួយ គ្នាបាន ក៏ចូលជ្រកទៅ ។ ពាក្យថាមកអំពីទីដទៃៗបានន័យថា មកពីកម្មផ្សេងៗគ្នានោះឯង ។

**កម្ម** បានបែងចែកភពភូមិឋាន កំណើតសត្វលោក ឲ្យខ្ពស់ ទាបអាក្រក់ល្អ ប្រកបដោយសុខ ដោយទុក្ខទៅតាមចំណែកដែល សត្វលោកបានសាងសន្សំមក ជំនឿស៊ប់មាំថាសត្វលោក មាន កម្មជារបស់ខ្លួនមិនអាចផុតអំពីកម្មបានយ៉ាងនេះ ចាត់ថាជា **កម្មស្សកតាសទ្ធា** ។

**៤. តថាគតពោធិសទ្ធា** ការជឿ បញ្ញាគឺការត្រាស់ដឹងរបស់ព្រះសាស្តាសម្មាសម្ពុទ្ធ ព្រះប្រាជ្ញាញាណរបស់ព្រះពុទ្ធ ជាអនន្តញាណ ជាព្រះញាណមិនមានទីបំផុតមិនអាចរាប់បាន ជាសព្វញ្ញុតញាណ ជាប្រាជ្ញាដឹងយល់ឃើញសព្វឥតមានសល់ចន្លោះទើសទាក់ត្រង់កន្លែងណា ។

ព្រះប្រាជ្ញាញាណ ព្រះអង្គបានមកដោយការអប់រំ បន្ទុំបារមីធម៌ទាំងដប់ប្រការរហូតគ្រប់ធួន តាមចំនួនបួនអសង្ខេយ្យនិងមួយសែនកប្ប ក្នុងពេលដែលព្រះអង្គបានពត់ភ្នែនពែនព្រះបាទក្រោមដើមពោធិព្រឹក្ស ទ្រង់ចម្រើនអនាបាណស្សតិ ញុំាងចិត្តព្រះអង្គឲ្យស្ងប់ជាអប្បនាសមាធិហើយ ទើបចូលកាន់បឋមឈាន , ទុតិយឈាន , តតិយឈាន , ចតុត្ថឈាន ។

**ក្នុងបឋមយាម** នៃរាត្រី ព្រះអង្គបានសម្រេចនូវ **បុព្វេនិវា - សានុស្សតិញាណ** គឺព្រះញាណដែលអាចរំលឹកឃើញជាតិបានព្រះញាណនេះ ព្រះអង្គអាចរំឭកឃើញនូវជាតិរបស់ព្រះអង្គ តាំងពីមួយជាតិរហូតដល់កប្ប សំវដ្តកប្ប សំវដ្តវិវដ្តកប្ប ព្រះអង្គធ្លាប់កើតជាមនុស្ស , ជាសត្វមានអត្តភាព , ជាតិត្រកូលបែបណា , ជាទេវតា , ជាព្រហ្ម , ជានរក , ប្រេត , តិរច្ឆាន , អសុរកាយ , ទទួលសុខទុក្ខទារុណកម្មយ៉ាងណាព្រះអង្គរំឭកឃើញអស់ ឥតមានចន្លោះត្រង់កន្លែងណា ។

ឋានដែលព្រះអង្គមិនដែលទៅកើត មានតែសុទ្ធាវាស ព្រហ្មប្រាំជាន់ ព្រោះជាឋានរបស់ព្រះអរិយបុគ្គល ថ្នាក់អនាគាមី ដែលបានទៅកើតឋាននោះហើយ មិនវិលត្រឡប់ទៅកើតឋានដទៃទៀតទេ គឺបរិនិព្វានក្នុងឋាននោះតែម្តង ។

ព្រះញាណទីមួយនេះ ព្រះអង្គពុំមែនរំឭកឃើញ ត្រឹមតែជាតិព្រះអង្គប៉ុណ្ណោះទេ សូម្បីតែកំណើតសត្វទាំងឡាយធ្លាប់កើតនៅក្នុងទីណា មានជាតិត្រកូលបែបណា មានអត្តភាពជាអ្វីស្លាប់ពីនោះហើយ ទៅកើតក្នុងទីណា មកពីទីណា ទើបមកកើតក្នុងទីនេះជាដើម ។

**ក្នុងមជ្ឈិមយាម** ព្រះអង្គបានសម្រេច **ចុតូបបាតញ្ញាណ** ជាព្រះញាណទីពីរ អាចធ្វើឲ្យព្រះអង្គទតឃើញ ដោយទិព្វចក្ខុនូវសត្វទាំងឡាយដែល បដិសន្ធិហើយក្តី , កំពុងបដិសន្ធិក្តី , បដិសន្ធិក្នុងកាលខាងមុខក្តី ដោយអំណាចកម្ម សត្វលោកបានថោកទាបខ្ពង់ខ្ពស់ សុខទុក្ខដោយប្រការយ៉ាងណា សុទ្ធតែដោយអានុភាពរបស់កម្ម វិចិត្រតាក់តែង ។

**ក្នុងបច្ឆិមយាម** នៃរាត្រី ព្រះអង្គបានសម្រេចនូវព្រះញាណទីបី ហៅថា **អាសវក្ខយញ្ញាណ** ជាព្រះញាណដ៏ក្រៃលែង ក្នុងការឆ្លុះបញ្ចាំងឃើញប្រាកដពិតថា នេះជាសេចក្តីទុក្ខពិត , នេះជាហេតុបណ្តាលឲ្យកើតសេចក្តីទុក្ខពិត , នេះជាសេចក្តីរំលត់ទុក្ខពិត , នេះ

ជាបដិបទាទៅកាន់សេចក្តីរំលត់ទុក្ខដោយពិត ។

ព្រះអង្គឈ្វេងយល់ស្គាល់ប្រាកដថា ធម៌ប៉ុណ្ណេះជាអាសវៈ នេះជាហេតុនាំឲ្យកើតអាសវៈ[១] នេះជាសេចក្តីរំលត់អាសវៈដូច្នេះ ជាដើម យ៉ាងនេះហៅថាអាសវក្ខយញ្ញាណមានព្រះនាមថា **ពុទ្ធៈ** ព្រោះព្រះអង្គបានត្រាស់ដឹងច្បាស់ ដោយព្រះប្រាជ្ញាញាណដ៏បរិ - សុទ្ធស្អាត គឺវិបស្សនានោះឯង ។

វិបស្សនាញាណ ជាតួបញ្ញាឆ្លុះបញ្ចាំង បំភ្លឺឲ្យឃើញ ប្រាកដពិតនូវនាមនិងរូប ដែលលុះដោយអំណាច នៃព្រះត្រៃ លក្ខណ៍មាន ៖ **អនិច្ចំ , ទុក្ខំ , អនត្តា** បញ្ញាបានពិចារណាឈ្វេង យល់នូវព្រះត្រៃលក្ខណ៍ថា ៖ **នាម** និង **រូប** មិនទៀងទាត់បិតបេរ ចីរកាលយូរលង់ តែងដឹកជញ្ជូនបង្ហូរមកនូវកងទុក្ខមិនមែនជាខ្លួន ប្រាណ មិនលុះតាមបង្គាប់ ជាធម្មជាតិឃាត់មិនបាន ។ ដោយ ការឈ្វេងយល់ព្រះត្រៃលក្ខណ៍នេះ ទើបធ្វើឲ្យព្រះអង្គឃើញនូវធម៌ ពិតគឺ អរិយសច្ចទាំងបួនប្រការ ។

សម្តេចព្រះបរមគ្រូ ព្រះអង្គបានផ្ចាញ់នូវមារាធិរាជព្រម ទាំងសេនាឲ្យបរាជ័យដោយបារមីទាំងដប់ប្រការ ទើបព្រះអង្គទ្រង់

---

(១) កិលេសជាគ្រឿងត្រាំ គឺកិលេសធម៌ដែលត្រាំនៅក្នុងសន្តាន, មាន ៤ យ៉ាងគឺ ១-កាម ហៅថា កាមាសវៈ; ២-ភព ហៅ ភវាសវៈ; ៣-ទិដ្ឋិ ហៅ ទិដ្ឋាសវៈ; ៤- អវិជ្ជា ហៅ អវិជ្ជាសវៈ; (ម. ព. ឱឃ ផង) ។ អាសវក្កិលេស កិលេសជាគ្រឿងត្រាំក្នុងសន្តាន ។

យាងចូលកាន់និរោធសមាបត្តិ [១] ទ្រង់ចេញចាកសមាបត្តិមកវិញ ទើបព្រះអង្គកាន់យកវិបស្សនា ឆ្លុះបញ្ចាំងមើលសង្ខារតាមប្រពៃ-ណីព្រះពុទ្ធអំពីបុរាណឃើញថាជា **អនិច្ចំ , ទុក្ខំ , អនត្តា** ហើយទើបចាក់ធ្លុះអរិយសច្ចទាំងបួនប្រការថា ៖

- **ទុក្ខសច្ចៈ** មានខន្ធប្រាំជាមេទុក្ខ គួរឲ្យខ្លាចទុកដូចជាមេខ្មាំងប្រាំនាក់ តាមពាធាយាយីជាធម្មតា ;
- **សមុទយសច្ចៈ** បានដល់តណ្ហាទាំងបីប្រការ ដូចជាអ្នកបង្ហាញផ្លូវខ្មាំងឲ្យចូលមក ;
- **និរោធសច្ចៈ** គឺព្រះនិព្វាន ជាគ្រឿងបិទស្ទះដំណើរខ្មាំង ;
- **មគ្គសច្ចៈ** គឺអដ្ឋង្គិកមគ្គទាំងប្រាំបីប្រការ ជាឧបាយប្រហារពួកខ្មាំង ។

លុះព្រះអង្គរកឃើញកំណើត នៃសេចក្តីទុក្ខដោយវិបស្សនាយ៉ាងនេះហើយ ទើបទ្រង់លះ **សំយោជនៈ** [២] បីយ៉ាងគឺ ៖

**១. សក្កាយទិដ្ឋិ** ការឃើញថាកាយនេះ ជារបស់ខ្លួន ;

---

(១) និរោធសមាបត្តិ ការចូលឈានដល់ថ្នាក់រម្លត់ឲ្យខ្យល់ដកដង្ហើមចេញចូល តាំងនៅបានអស់កាលកំណត់យ៉ាងយូរត្រឹម ៧ ថ្ងៃ ទើបចេញវិញ...។

(២) សំយោជនៈ ស័ង-យោជៈ នៈ សំ. បា. ( ន. ) (សំយោជន ឬ សញ្ញោជន) កិលេសជាគ្រឿងប្រកបចិត្ត គឺកិលេសរឹងត្អឹងជាគ្រឿងទាក់ទាក់រូបរឹត ដែលអាស្រ័យនៅនឹងចិត្ត... ។

**២. វិចិកិច្ឆា** សេចក្ដីសង្ស័យអំពីជាតិកំណើត គុណព្រះរតនត្រ័យ ;

**៣. សីលព្វត្តបរាមាស** ការបតិបត្តិខុស ដោយសេចក្ដីភ័យខ្លាច ស្ទាបអង្អែលសីលនិងវត្ត ដោយកម្លាំងសោតាបត្តិមគ្គញ្ញាណ លះកាមរាគៈ ព្យាបាទៈ យ៉ាងគ្រោតគ្រាតដោយសកទាគាមិមគ្គ-ញ្ញាណ ។ លះសំយោជនប្រាំគឺ ៖ **រូបរាគៈ , អរូបរាគៈ , មានៈ , ឧទ្ធច្ចៈ , អវិជ្ជា** ដោយអរហត្តមគ្គញ្ញាណ ទើបធ្វើឲ្យសន្តានរបស់ព្រះអង្គបានថ្លាបរិសុទ្ធ ផុតចាកកិលេសតណ្ហា អវិជ្ជាដែលជាកិលេសមារ មិនអាចតាមពាធាយាយីបៀតបៀនព្រះអង្គទៀតបានឡើយ ព្រះពិជិតមារ ព្រះអង្គឈ្នះមារដោយគ្មានសេសសល់ មារទាំងឡាយបាក់បបខ្លបខ្លាច ចាញ់ព្រះអង្គហើយ ។

ព្រះសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានត្រាស់ដឹងក្នុងឆ្នាំរកា ពេញបូរមីខែពិសាខថ្ងៃពុធ ទ្រង់គង់លើរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្ស បន្ទាប់ពីបច្ឆិមយាមនៃរាត្រី ព្រះអង្គបានត្រាស់ដឹងព្រមទាំងផ្ចាញ់មារាធិរាជឲ្យចាលចាញ់ហើយ ព្រះអង្គបានបន្លឺព្រះសូរសីហនាទ ជាបឋមពុទ្ធវចនយ៉ាងនេះថា ៖

**អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**

**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ**

**កាលដែលតថាគត កំពុងស្វែងរកជាងឈើគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាពរបស់តថាគត កាលដែលមិនទាន់បានជួបប្រទះនៅឡើយ តថាគតតែងតែអន្ទោលទៅកាន់ សំសារវដ្តរាប់ជាតិជាអនេកម្ល៉ោះហើយ ជាតិក៏តែងនាំសេចក្តីទុក្ខមក ឲ្យតថាគតរឿយៗឥតស្រាកស្រាន្តឡើយ នៃជាងផ្ទះ ! ឥឡូវតថាគតរកអ្នកឃើញហើយណ៎ា: ពីនេះទៅអ្នកឯងអស់ធ្វើផ្ទះគឺអត្តភាព ឲ្យតថាគតបានទៀតហើយ បង្កង់គឺកិលេសដ៏សេសទាំងឡាយរបស់អ្នកឯង តថាគតកាច់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជា ដែលអ្នកឯងធ្វើរួចហើយនោះ តថាគតក៏បានកំចាត់បង់ហើយ ឥឡូវនេះ ចិត្តរបស់តថាគតបានដល់ព្រះនិព្វាន ដែលប្រាសចាកសង្ខារហើយ តថាគតបានត្រាស់ដឹងនូវអរហត្ត ដែលជាធម៌ក្ស័យតណ្ហាទាំងឡាយហើយ។**

ខ្ញុំបានដកស្រង់យកពុទ្ធដីកា ព្រមទាំងបញ្ញាការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធមកសរសេរបញ្ជាក់ឲ្យឃើញច្បាស់ថា ព្រះប្រាជ្ញាញាណគ្មានសត្វលោកណា ឲ្យបានប្រសើរស្មើព្រះអង្គឡើយ គឺជាការត្រាស់ដឹងយល់ស្គាល់ នូវសភាវធម៌ពិត កំចាត់បង់កិលេសតណ្ហា ជាហេតុនៃសេចក្តីទុក្ខពិត មានដំណើរទៅកាន់ទីរំលត់ទុក្ខពិត ដោយព្រះប្រាជ្ញាញាណរបស់ព្រះអង្គ ។ ដូច្នេះការ

ជឿស៊ប់ពិតប្រាកដមិនងាករេពីបញ្ញាញាណ ដូចរៀបរាប់មកហើយនេះ ទើបចាត់ថាជា តថាគតពោធិសទ្ធា ។

សត្វឆ្លងអន្លង់ទៅបានដោយសទ្ធា សំដៅយកសទ្ធាជាសោភណចេតសិកសម្បយុត្តទៅដោយបញ្ញា ជឿត្រូវត្រង់ចំលើហេតុបួនប្រការ ទើបញ៉ាំងចិត្តឲ្យភ្លឺថ្លា ដូចជាសាជូរគេយកទៅកូរក្នុងទឹកពាងដែលល្អក់ សារជាតិដែលល្អក់តែងធ្លាក់ចុះទៅកាន់បាតពាង សារជាតិដែលថ្លារមែងអណ្តែតឡើងមកខាងលើ ធ្វើឲ្យគេអាចដងទឹកមកទទួលទានបាន យ៉ាងណាមិញ ចិត្តដែលប្រកបដោយសទ្ធាជាញាណសម្បយុត្ត [១] រមែងជាចិត្តថ្លាស្អាត កន្លងបង់មិច្ឆាទិដ្ឋិបាន ។

**មិច្ឆាទិដ្ឋិ** បានដល់ចិត្តយល់ឃើញខុស ចាត់ថាជាអន្លង់ជ្រៅ ព្រោះថាកាលបើចិត្តយល់ខុសឃើញខុស ប្រាកដជាជឿខុស ជឿខុសហើយប្រកាន់តាមខុស បដិបត្តិខុស បានផលមកជាខុស សេចក្តីយល់ខុស ធ្វើឲ្យសត្វលោកមានដំណើរយឺតយូរនៅក្នុងភព

**មិច្ឆាទិដ្ឋិ** ធ្វើឲ្យសត្វលោកវង្វេងងងឹត ចូលចិត្តយកគំនិតទៅគិតក្នុងអ្វីដែលហួសវិស័យ ប្រាសចាកហេតុផល ដឹងមិនដល់

(១) សម្បយុត្ត ស័ម-ប៉ៈយុត បា.; សំ. ( កិ. ឬ គុ. ) (សំប្រយុក្ត ឬ សម្ប្រ--) ប្រកប, ផ្សំ; ដែលប្រកប, ដែលផ្សំហើយ, ដែលលាយច្រឡំ, ដែលរួមចូលគ្នា : ចិត្តសម្បយុត្តដោយអំណរ ។ ញាណសម្បយុត្ត ចិត្តដែលសម្បយុត្តដោយការដឹង, ដោយប្រាជ្ញា ។ សទ្ធាសម្បយុត្ត ចិត្តដែលសម្បយុត្តដោយសទ្ធា ។ល។

យល់មិនអស់ ។

ដូចជាចូលចិត្តគិតអំពីព្រះ បង្កើតទឹកបង្កើតដីបង្កើតសត្វលោក ហើយក៏នាំគ្នាបង្កើតលទ្ធិអង្វរករបន់ស្រន់ សំពះសុំព្រះឲ្យជួយដើម្បីឲ្យបានជាយ៉ាងនេះយ៉ាងនោះ ។ ដោយអំណាចកម្លាចគម្លាន ហ៊ាននាំគ្នាបង្កើតច្បាប់ យកព្រះនាមព្រះមកធ្វើជាទាសករឲ្យជួយតាមចំណូលចំណង់របស់ខ្លួន ។

សេចក្តីមានៈចចេសរឹងត្អឹងក៏មកពីការយល់ខុស ប្រកាន់ខុសជឿខុសប្រាថ្នាខុស ទើបមានការប្រកែក បង្ករជាជម្លោះទាស់ទែង ខ្វែងគំនិតគិតបង្កើតលទ្ធិផ្សេងៗ ទៅតាមការយល់ឃើញតែរៀងខ្លួន ហើយតាំងនាំគ្នាពោលអួតសរសើរ អួតគុណព្រះជាម្ចាស់ឃោសនាប្រមូលឲ្យចូលជាបរិស័ទ មានទាំងខំចែកអំណោយបញ្ចុះបញ្ចូលប្រមែប្រមូលដោយពាក្យសំដី បន្តុះបង្អាប់លទ្ធិដទៃលើកតម្កើងលទ្ធិដែលខ្លួនចុះចូលដោយឥតអៀនខ្មាស ប្រាសចាកហេតុផល ។

ពាក្យស្លោកមួយឃ្លា លោកបានពោលទុកថា ៖

**អ្នកខំប្រឹងអួតព្រោះខ្លួនអន់**
**អ្នកប្រឹងបន់ស្រន់ព្រោះភ័យខ្លាច**
**អ្នកខ្លៅវង្វេងលែងស្គាល់ប្រាជ្ញ**
**អ្នកនោះគេអាចបោកប្រាសបាន ។**

ការមានវិចារណញ្ញាណ ពិចារណាទៅលើកម្មផល មានសេចក្ដីយល់ឃើញត្រូវតាមហេតុផលពិត តម្កល់ចិត្តប្រកបដោយសទ្ធា មានជំនឿចុះស៊ប់រឹងមាំ មិនកម្រើកញាប់ញ័រ មិនងាករេចេញពីកម្ម ផលរបស់កម្ម សត្វមានកម្មជារបស់ខ្លួន ជឿព្រះប្រាជ្ញាការត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ ទាំងនេះធ្វើចិត្តឲ្យមានលំនឹងមានស្មារតីមិនភ័យខ្លាច អាចយកខ្លួនជាទីពឹងរបស់ខ្លួន ជាអ្នកប្រកាន់ខ្ជាប់ខ្ជួន ក្នុងការដោះស្រាយចំពោះហេតុផល ដែលធ្លាក់មកដល់ដោយបញ្ញាយល់ច្បាស់ចូលចិត្តពិតប្រាកដ អាចកន្លងផុតមិច្ឆាទិដ្ឋិ គឺការឃើញខុស ជឿខុស ប្រកាន់ខុសនោះទៅបាន ។

សត្វលោកដែលមានសេចក្ដីញាប់ញ័រ តក់ស្លុតរន្ធត់ភ័យខ្លាចក្រែងនឹងអំពើបាបទាំងឡាយ ក៏ព្រោះមានជំនឿជាក់ថា អំពើបាបជាអំពើអាក្រក់លាមកពិត កាលបើបុគ្គលណាប្រព្រឹត្តហើយនឹងបានឈ្មោះថាជាបុគ្គលអាក្រក់លាមក បានទទួលផលជាទុក្ខជាទោស ជាស្រមោលអន្ទោលតាមប្រាណ មិនបាត់បង់សោះសូន្យឡើយ ។

ចំណែកអំពើបុណ្យជាគុណដ៏ល្អ កាលបើបុគ្គលណាប្រព្រឹត្ត បុគ្គលនោះនឹងបានឈ្មោះថាជាមនុស្សល្អ បានទទួលផលជាសុខ ជាពូជ ជាទ្រព្យជាប់តាមប្រាណ ។ សេចក្ដីអាក្រក់ទាំងមនុស្សទាំងសត្វ តែងស្អប់ខ្ពើមនិន្ទាតិះដៀល ។ សេចក្ដីល្អទាំងមនុស្សទាំងសត្វ រមែងពេញចិត្តពោលសរសើរ ។

មនុស្សតែម្នាក់បើយកស្រោម ឬមុខយក្សមកពាក់លើក្បាលហើយលោតកញ្ឆែង បញ្ចេញសម្លេងស្រែកបែបយក្សប្រាកដជាអ្នកមើលទាំងចាស់ទាំងក្មេង គេសម្គាល់ថាជាយក្ស គឺជាអ្នកកោងកាចមានចិត្តអាក្រក់ ។ តែបើអ្នកនោះ ពាក់ស្រោមទេវតាប្រដាប់កាយគ្រឿងអលង្ការស្អិតស្អាងយ៉ាងប្រណីត ប្រាកដជាអ្នកផងស្រឡាញ់ពេញចិត្ត ពោលសរសើរថាល្អគួរឲ្យចង់គយគន់ ។

ត្រង់ចំណុចនេះ បញ្ជាក់ឲ្យឃើញបានថា មនុស្សតែម្នាក់កាលបើជាអ្នកបៀតបៀន ធ្វើទុក្ខបុកម្នេញសម្លាប់សត្វ បំបាត់ជីវិតមនុស្សដទៃក្តី មានចិត្តមិនល្អប្រព្រឹត្តចោរកម្មបោកប្រាស ក្បត់ចិត្តប្រពន្ធប្តី មានស្រីមានប្រុសខុសប្រពៃណី ពោលពាក្យសម្តីគ្មានខ្លឹមសារកុហកភូតភរ បង្កជម្លោះទាស់ទែងក្លែងបន្លំទ្រព្យសម្បត្តិចិត្តពោរពេញដោយការព្យាបាទ ចងអាឃាតគុំគួន ជាមនុស្សលើកខ្លួនអួតអាងចចេសរឹងរូស ប្រកាន់តាមតែការយល់ឃើញរបស់ខ្លួន ។

បើយ៉ាងនេះ តើគេចាត់មនុស្សប្រភេទនោះថាដូចម្តេច ? គេមុខតែនាំគ្នាស្រែកថា អ្នកនោះជាមនុស្សអាក្រក់ណាស់ ព្រោះអ្វី ? ព្រោះតែសេចក្តីអាក្រក់ បុគ្គលធ្វើអាក្រក់ដូចយកលាមក ប្រឡាក់លើខ្លួនឯង តែងស្អុយជាប់ខ្លួនផង និងជះចំហាយក្លិនស្អុយដល់អ្នកឯទៀតផង ។ ព្រោះផលនៃសេចក្តីអាក្រក់ ធ្វើឲ្យកើតក្តី

ទុក្ខក្តៅក្រហាយខ្វល់ខ្វាយដល់ខ្លួននិងអ្នកដទៃ ធ្វើឲ្យគេខ្ពើមរអើម ខ្លាចរអា និងមានការនិន្ទាដោយប្រការផ្សេងៗ ធ្វើឲ្យមានការថ្នាំង ថ្នាក់អាក់អន់ក្តៅក្រហាយចិត្ត ត្បិតតែអំពើអាក្រក់នោះ ។

ប៉ុន្តែមនុស្សដដែលនោះ គាត់ជាមនុស្សប្រព្រឹត្តល្អ មាន មេត្តាធម៌ចេះអាណិតអាសូរ ជួយស្រោចស្រង់ជីវិតមនុស្សសត្វឲ្យ រួចផុតចាកវិបត្តិភ័យ មានសច្ចៈធម៌សន្តោសត្រេកអរទៀងត្រង់ មិនប៉ះពាល់បៀតបៀន ទ្រព្យសម្បត្តិប្រពន្ធកូនប្តីអ្នកដទៃ ជា អ្នកពោលពាក្យសម្តីមានន័យខ្លឹមសារប្រកបដោយគុណប្រយោជន៍ សម្រាប់ខ្លួនសម្រាប់អ្នកដទៃ ។ បើយ៉ាងនេះអ្នកផងទាំងពួង គេ ប្រាកដជាចូលចិត្ត ពេញចិត្ត ឲ្យតម្លៃទៅលើមនុស្សដដែលនោះ ថាជាមនុស្សល្អព្រោះមានគុណធម៌ ។ គុណធម៌រមែងផ្តល់ផល ត្រជាក់ ដល់អ្នកប្រព្រឹត្តដូចជាក្លិនក្រអូប ដែលជិតជាប់ជិតខ្លួន រមែងបញ្ចេញចំហាយក្រអូបដល់ខ្លួនផង ដល់អ្នកដទៃផង ។ មនុស្សគ្រប់រូបតែងស្រឡាញ់ពេញចិត្ត គុណធម៌គឺសេចក្តីល្អ ស្អប់ ខ្ពើមសេចក្តីអាក្រក់ ទោះបីជាខ្លួនធ្វើអាក្រក់ក៏ដោយ បើមានគេជេរ តិះដៀលស្តីឲ្យ ក៏មិនពេញចិត្តដែរ ។

សេចក្តីអធិប្បាយមកនេះ បញ្ជាក់អំពីហេតុផលឲ្យបាន យល់កាន់តែច្បាស់ថា អំពើអាក្រក់និងអំពើល្អ អាចធ្វើមនុស្សម្នាក់ ឲ្យប្រែភេទទៅជាយក្ស និងទៅជាទេវតាបាន ។ ភ្លើងរមែងមាន ចំហាយក្តៅ អ្នកពាល់ត្រូវភ្លើងរមែងរលាក និងទទួលការឈឺផ្សា

ក្តៅ អ្នកមានកម្តៅត្រូវការទឹក ទឹកតែងផ្តល់ធាតុត្រជាក់ក្នុងពេល មនុស្សសត្វត្រូវការផឹកងូតយ៉ាងណា ពាក្យថាកម្មផល ក៏រមែង ផ្តល់ឲ្យសុភវិនិច្ឆ័យ ឃើញនឹងភ្នែកកើតចំពោះមុខដោយពិតដោយ មិនចាំបាច់យកគំនិតទៅគិត ហេតុការណ៍អាថ៌កំបាំងអ្វី ដូចជា ព្រហ្ម ព្រះបង្កើតមេឃដីមនុស្សសត្វ លើកយកមកអាងយ៉ាងនេះ យ៉ាងនោះ លើកកម្ពស់ ដាក់ទំនាប ឲ្យកំហុស តម្រូវ បន្ទុះបង្អាប់ កម្លាចគម្លាន មានធ្វើកម្មវិធីផ្សេងៗ ដូចជាបួងសួងអង្វរករបន់ ស្រន់សុំសុខសួស្តី ធ្វើស្លាធម៌បាយសី ភ័យខ្លាច ក្រាបសំពះខ្លាច ព្រះជាម្ចាស់ដាក់ទោស ឬក៏មានការសូត្រពោលសរសើរ សេចក្តី អស្ចារ្យឫទ្ធិចេស្តារបស់ព្រះ សុំឲ្យព្រះជួយឲ្យបានជាយ៉ាងនេះ យ៉ាងនោះ ពេលបានដូចបំណងក៏សប្បាយរីករាយ ពេលមិន បានដូចបំណងក៏ខកខូចតូចចិត្ត ។

អ្វីដែលប្រាសចាកភាពពិត មិនអាចឋិតនៅបានយូរ សេច ក្តីអស្ចារ្យទោះបីមានបែបណា ក៏មិនអាចកន្លងផុតអំពីច្បាប់ធម្ម-ជាតិបាន គឺកើតមានហើយក៏វិនាសទៅវិញជាធម្មតា មិនអាចការ ពារបាន ។ តាំងពីបុរាណសម័យ រហូតមកដល់បច្ចុប្បន្នសម័យ ព្រហ្មព្រះក៏ត្រូវតែរលត់រលាយជីវិតប្រាណ ដែលអាចសល់នៅ បានត្រឹមតែជីវប្រវត្តិ គុណធម៌និងអគុណធម៌ ជាតំណទុកឲ្យបច្ឆា-ជនអ្នកប្រកបដោយប្រាជ្ញាពិចារណារកសេចក្តីពិត ។

សទ្ធាជាសោភណចេតសិក កើតឡើងជាមួយចិត្ត ធ្វើចិត្ត

ឲ្យថ្លាបរិសុទ្ធស្អាត គឺមានសេចក្ដីជ្រះថ្លាជាលក្ខណៈ មានសេចក្ដីជឿស្មុះទៅខាងមុខ មានកិរិយាស្ទាបស្ទង់មើលហេតុផល ហើយទើបមានជំនឿ ដែលជាហេតុធ្វើឲ្យកន្លងឲ្យឆ្លងផុតអំពីទិដ្ឋិ ការយល់ឃើញខុសប្រកាន់ខុសនោះទៅបាន ។

ពាក្យថា **សោភណ** បានដល់សភាវៈថ្លាស្អាត បរិសុទ្ធ ។ ពាក្យថា ចេតសិក បានដល់សភាវធម៌កើតរលត់ជាមួយចិត្ត ដូច្នេះ កាមាវចរសោភណៈចិត្ត ២៤ ដួង , រូបាវចរសោភណៈ ១៥ ដួង , អរូបាវចរសោភណៈ ១២ ដួង , លោកុត្តរចិត្ត ៨ ដួង សុទ្ធតែមានសទ្ធា ជាសោភណចេតសិកកើតរួមជានិច្ច ទើបជាកម្លាំងក្នុងការបំពេញកុសល ជាកាមាវចរកុសល , រូបាវចរកុសល , អរូបាវចរកុ - សល , លោកុត្តរកុសល ឲ្យសម្រេចទៅបាន ។

**សទ្ធា** ជាខាងដើមជាពូជបណ្ដុះបង្ហូរ នាំមកនូវកុសលឲ្យកើតកើនចម្រើនឡើងបានតាមលំដាប់ អ្នកមានសទ្ធានឹងត្រូវបានអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ព្រះអង្គអនុគ្រោះ ចូលទៅជិតទទួលទេយ្យទានមុនគេ ដូចជារឿងនាង **ថូនទាសី** ស្រីកំសត់ ដែលបានប្រគេនទឹកតែមួយក្អម ដោយកម្លាំងសទ្ធាជ្រះថ្លាចំពោះព្រះសាស្ដាសម្មាសម្ពុទ្ធ ធ្វើឲ្យនាងរួចចាកសេចក្ដីទុក្ខទោស ក្នុងឋានមនុស្សបាន ។

# រឿង នាងថូនទាសី

ក្នុងពុទ្ធកាល ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ស្តេចយាងទៅដែនកោសលជាមួយនឹងភិក្ខុសង្ឃប្រាំរយអង្គ ទ្រង់យាងចូលទៅសម្រាកព្រះកាយក្នុង **ថូនគ្រាម** ដើម្បីកំចាត់បង់នូវមិច្ឆាទិដ្ឋិរបស់ពួកព្រាហ្មណ៍ ក្នុងថូនគ្រាមនោះ ។

ពួកព្រាហ្មណ៍ទាំងឡាយបានឮដំណឹងថា ព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ស្តេចយាងនិមន្តមកដល់ត្រើយស្ទឹងខាងនាយ បម្រុងនឹងឆ្លងចូលទៅក្នុងថូនគ្រាមហើយ ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យទាំងឡាយ បានប្រកាសប្រាប់ដល់ព្រាហ្មណ៍ជាបរិស័ទថា ៖

*" យើងទាំងអស់គ្នា ! មិនគប្បីគួរសមរាប់រកឲ្យវត្ថុអ្វីដល់សមណគោតមឡើយ " ។*

*" ម្យ៉ាងទៀតយើងទាំងអស់គ្នា ត្រូវអូសទូកឡើងកំពង់ឲ្យអស់ ហើយរុះស្ពានចោលចេញ ទាំងសាលាសំណាក់ក៏ត្រូវរុះស្បូវរើនាបឲ្យអស់ បើអ្នកណាមួយទៅគួរសម ឲ្យវត្ថុអ្វីដល់សមណគោតមនិងភិក្ខុទាំងឡាយ ត្រូវធ្វើទោសអ្នកនោះដល់ជីវិត " ។*

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបវិប្បការៈ[១]របស់ព្រាហ្មណ៍ដូច្នោះ

(១) វិប្បការ វិប-ប៉ៈការ៉ៈ បា. ឬ សំ. ( ន. ) សេចក្តីមើលងាយ, ការមាក់ងាយ មាក់ថោក; ការធ្វើឲ្យគេប្រទះអន្តរាយ, ការធ្វើឲ្យគេបានសេចក្តីទុក្ខពិបាក; សេចក្តីព្យាបាទ; វិប្រការ

ហើយ ក៏នាំភិក្ខុសង្ឃទាំងប្រាំរយហោះឰដ៏អាកាស ឆ្លងស្ទឹងទៅចុះត្រង់កណ្តាលស្រុកនោះ ទ្រង់និមន្តទៅគង់ក្រោមម្លប់ឈើមួយដើមក្បែរអណ្តូងទឹក ។

សម័យនោះ មានទាសីម្នាក់ ជាខ្ញុំបម្រើត្រកូលព្រាហ្មណ៍មួយក្នុងចូនគ្រាមនោះ កំពុងកណ្តៀតក្អមទៅដងទឹកអណ្តូង បានឃើញព្រះមានព្រះភាគ ក៏មានចិត្តជ្រះថ្លាកើតឡើង ។ នាងគិតថា ៖ "*សម័យនេះក្តៅណាស់ ព្រះសម្ពុទ្ធនិងព្រះសង្ឃទាំងអស់អង្គប្រហែលជាស្រេកទឹកខ្លាំង បានមកគង់ក្នុងទីនេះ អញត្រូវតែដងទឹកមួយក្អមយកទៅប្រគេនទើបគួរ ។ ប៉ុន្តែព្រាហ្មណ៍ព្រឹទ្ធាចារ្យបានដាក់អាជ្ញាថា បើអ្នកណាទៅគួរសម យកវត្ថុអ្វីៗ ទៅប្រគេនដល់សមណគោតមនិងព្រះសង្ឃនេះ ត្រូវមានទោសដល់ជីវិត* " ។

នាងគិតដូច្នេះហើយ ក៏ដើរហួសទៅដងទឹក ។ លុះត្រឡប់មកវិញសទ្ធាក៏កើតខ្លាំងឡើងៗទើបគិតថា ៖ "*ណ្ហើយចុះអញបានជួបនឹងស្រែបុណ្យ ដ៏ប្រសើរយ៉ាងនេះហើយគួរតែធ្វើទានកុំខានទោះបីគេសម្លាប់ឬដាក់អាជ្ញាក៏តាមចុះ* " ។

នាងក៏កណ្តៀតក្អមចូលទៅក្នុងកណ្តាលចំណោមភិក្ខុសង្ឃយកទឹកមួយក្អមទៅប្រគេន ព្រះសម្ពុទ្ធ ។ ទ្រង់ទទួលដោយព្រះហស្តទាំងពីរ ថ្លែងអាការៈឲ្យនាងដឹងថា ព្រះអង្គត្រូវការទឹកនោះណាស់ ទ្រង់ចាក់ទឹកនោះលប់ព្រះភក្ត្រ ហើយឆាន់ក្នុងទីចំពោះមុខរបស់នាង ។ ដោយអំណាចឫទ្ធិរបស់ព្រះអង្គ ទឹកក្នុងក្អមនៅ

ពេញដដែល ទើបឲ្យក្អមទឹកនោះ ទៅភិក្ខុសង្ឃប្រាំរយឆាន់ទៀត ទឹកក្អមក៏នៅតែពេញដដែល ។ នាង **ចូនទាសី** បានឃើញចម្លែកអស្ចារ្យដូច្នេះហើយ សេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ក៏កាន់កើតមានចម្រើនឡើងៗ ។

កាលភិក្ខុសង្ឃទាំងប្រាំរយអង្គ ឆាន់ឆ្អែតស្កប់ស្កល់ហើយ ព្រះសម្ពុទ្ធទ្រង់ប្រទានក្អមទឹកនោះដល់នាងចូនទាសីវិញ ។ នាងបានទទួលក្អមហើយ ក៏ថ្វាយបង្គំលាព្រះមានព្រះភាគទៅគេហ-ដ្ឋានរបស់នាងវិញ ។ ជាលំដាប់នោះពួកព្រាហ្មណ៍ទាំងឡាយ ក៏ចាប់នាងវាយតប់ បណ្ដើរយកនាងទៅឲ្យព្រាហ្មណ៍ជាចៅហ្វាយនាយ ៗ ក៏បានវាយនាងថែមទៀតរហូតដល់នាងស្លាប់ក្នុងពេលនោះទៅ ។ ចំណែកខាងព្រះមានព្រះភាគ កាលបើនាងចូនទាសីចេញទៅបាត់ហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទ ប្រើឲ្យយកបាត្រព្រះអង្គទៅដងទឹកអណ្ដូង ព្រះអានន្ទមិនហ៊ានទៅដង ព្រោះខ្លាចព្រាហ្មណ៍វាយសម្លាប់ ។ ទ្រង់ប្រើគម្រប់បីដងព្រះអានន្ទមិនហ៊ានប្រកែក ទើបកាន់យកបាត្រនិមន្តទៅអណ្ដូងទឹក គ្រាន់តែទៅដល់មាត់អណ្ដូង ទឹកក៏បាញ់ចេញពីអណ្ដូង ជោរជន់រាចទៅលើប្រថពីលិចភូមិស្រុកចូនគ្រាមនោះមួយរំពេច ប៉ុន្តែត្រង់កន្លែងដែលព្រះសម្ពុទ្ធនិងព្រះសង្ឃគង់នោះឥតមានទឹកលិចឡើយ ។

ពួកព្រាហ្មណ៍ទាំងឡាយ ឃើញហេតុអស្ចារ្យដូច្នោះហើយ ភិតភ័យខ្លាំងណាស់ ក៏នាំគ្នារត់ចូលទៅសូមទោសព្រះសម្ពុទ្ធថ្វាយ

ខ្លួនជាឧបាសកឧបាសិកា យកព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត ទឹកក៏បាត់អស់រលីងក្នុងខណៈនោះទៅ ។

ឯនាងចូនទាសី ដែលព្រាហ្មណ៍វាយសម្លាប់នោះ បានទៅកើតក្នុងឋានត្រៃត្រិង្ស មានរូបល្អឥតឧបមា មានរស្មីចែងចាំងចេញពីកាយ ផ្សាយទៅក្នុងទិសទាំងពួង មានស្រីទេពអប្សរមួយពាន់ ចោមរោមជាបរិវារ ស្ថិតនៅក្នុងវិមានមាសមានសណ្ឋានដូចជាទូកកឹង ប្រតិស្ឋាននៅលើទឹកទិព្វ ក្នុងមហាស្រះបោក្ខរណីមួយលើមាត់ស្រះមានដើមកប្បព្រឹក្សដុះព័ទ្ធជុំវិញ ក្នុងស្រះនោះមានដើមឈូកដុះព្រោងព្រាត បញ្ចេញផ្កាផ្លែផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប ។ ឈូកនោះមានផ្កាប្រាំពណ៌ ខ្លះដើមជាមាសស្លឹកជាកែវមណី ផ្កាជាប្រាក់ផ្លែជាត្បូងទទឹម ខ្លះដើមជាត្បូងទទឹមស្លឹកជាប្រាក់ផ្កាជាកែវមណី ផ្លែជាមាសដុះព័ទ្ធព័ន្ធវិមានប្រាសាទ ។ ក្នុងពេលនោះ នាងគិតពិចារណាអតីតជាតិរបស់នាង ក៏បានដឹងសព្វគ្រប់ថា ៖ " *ឱ ! អញដែលបានមកកើតជាទេពធីតាបរិបូណ៌ដោយទិព្វសម្បត្តិដូច្នេះ ដោយសារតែទឹកមួយក្អម ដែលអញបានប្រគេនព្រះសម្ពុទ្ធក្នុងស្រុកចូនគ្រាម ឥឡូវនេះព្រះសម្ពុទ្ធគង់នៅក្នុងទីនោះ ពុំទាន់និមន្តទៅណានៅឡើយ ដូច្នេះគួរតែទៅបំពេញសម្បត្តិរបស់អញ ឲ្យវិសេសជាងនេះទៅទៀត* " ។ គិតដូច្នេះហើយ ក៏ចុះមកភ្លាម វិមានប្រាសាទក៏អណ្តែតមកប្រតិស្ឋាន លើផែនដីក្នុងចំពោះព្រះភក្ត្រព្រះសម្ពុទ្ធ ។

នាងទេពធីតាបាននាំបរិវារទាំងមួយពាន់ ចេញពីវិមានប្រាសាទ ចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធបរមគ្រូ ។ ពេលនោះពួកព្រាហ្មណ៍ទាំងឡាយ ដែលកំពុងអង្គុយគាល់ព្រះមានព្រះភាគ ក៏ផ្អើលឈ្ងួតរនឹកស្ញើចក្នុងចិត្តឥតឧបមា ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរនាងទេពធីតា ដើម្បីឲ្យពួកព្រាហ្មណ៍ទាំងអស់ បានដឹងក្នុងពេលនោះថា ៖

*" ម្នាលទេពធីតា ! អ្នកបរិបូណ៌ដោយទិព្វសិរី មានពន្លឺចែងចាំងជានិច្ច តើនាងមកអំពីទីណា , បានធ្វើបុណ្យអ្វី ក្នុងជាតិមុន ?"*

នាងទេពធីតាក្រាបទូលព្រះមាន ព្រះភាគដូច្នេះ ៖

*" បពិត្រព្រះមានព្រះភាគ ! ខ្ញុំព្រះអង្គមកពីស្ថានត្រៃត្រិង្ស កាលពីម្សិលមិញ ខ្ញុំព្រះអង្គនៅក្នុងស្រុកចូនគ្រាមនេះ បានដងទឹកមួយក្អមប្រគេនព្រះអង្គ លុះត្រឡប់ទៅផ្ទះវិញ ត្រូវពួកព្រាហ្មណ៍ទាំងឡាយ ដែលអង្គុយជុំវិញនេះ នាំគ្នាចាប់វាយខ្ញុំព្រះអង្គបណ្តើរទៅឲ្យព្រាហ្មណ៍ជាចៅហ្វាយរបស់ខ្ញុំព្រះអង្គ ៗបានវាយថែមទៀតដរាបដល់ស្លាប់ "* ។

បន្ទាប់មកនាងក៏បានថ្លែងរៀបរាប់ អំពីទិព្វសម្បត្តិរបស់នាង ក្នុងស្ថានសួគ៌ដោយសព្វគ្រប់ លុះចប់ហើយ ព្រះសម្ពុទ្ធបរមគ្រូទ្រង់សម្តែងនូវធម្មកថា ពន្យល់អំពីអរិយសច្ចធម៌ បួនប្រការ នាងទេពធីតាក៏បានសម្រេចដល់សោតាបត្តិផល ក្នុងពេលនោះទើបថ្វាយបង្គំលាព្រះមានព្រះភាគ ទៅស្ថានត្រៃត្រិង្សវិញ ។

ពួកព្រាហ្មណ៍ក្នុងចូនគ្រាម ក៏បានយល់ជាក់ច្បាស់ នូវលទ្ធិពុទ្ធសាសនាក្នុងពេលនោះ ។

សេចក្ដីក្នុងនិទាននេះ បានបញ្ជាក់ឲ្យឃើញច្បាស់ថា **ចូនទាសី** ធីតាសុខចិត្តលះបង់ជីវិត ដោយឥតកោតញញើត ដោយមានសទ្ធាជ្រះថ្លាជាកុសលញាណសម្បយុត្តិ ទើបប្រគេនទឹកមួយក្អមដល់ព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទាំងឡាយ ខុសផ្ទុយពីពួកព្រាហ្មណ៍ទាំងអស់នោះ ព្យាយាមប្រទូស្តជាមួយព្រះសម្ពុទ្ធព្រមទាំងភិក្ខុសង្ឃ ដោយចិត្តជា **មិច្ឆាទិដ្ឋិ** ។ ដូច្នេះ**សទ្ធា** ជាពូជបណ្ដុះកុសលផង ជាធមិសម្រាប់ឆ្លងអន្លង់គឺទិដ្ឋិ ការយល់ឃើញខុស ប្រកាន់ខុស បដិបត្តិខុសផង ។

## ២. គុណធម៌ទី ២ : អប្បមា ទេន អណ្ណវំ ឆ្លងសមុទ្របានដោយ សេចក្ដីមិនប្រមាទ

ពាក្យថា **អប្បមាទៈ** ( ជាភាសាបាលី ឬសំស្ក្រឹត ) ប្រែជាភាសាខ្មែរមានន័យថា សេចក្ដីមិនធ្វេស , មិនប្រហែស ឬមិនធ្វេសប្រហែស , ការមិនធ្វេសស្មារតី , ការប្រុងប្រយ័ត្នជានិច្ច , ការប្រុងមិនឲ្យភ្លាំងភ្លាត់ , ការប្រយ័ត្នមិនធ្វើអំពើអាក្រក់ , ការមានស្មារតីមិនភ្លាំងភ្លេច ។

**អប្បមាទៈ** ជាធម៌ចម្បងជាងធម៌ទាំងពួង ជាមាតានៃសេចក្តីសុខ ជាឫសគល់នៃកុសលធម៌ទាំងពួង ជាទីតាំងនៃកុសលធម៌ និងជាកំពូលជាទីប្រជុំចុះនៃកុសលធម៌ទាំងឡាយទាំងពួង ។

បណ្តាស្នាមជើងនៃសត្វទាំងឡាយ មានស្នាមជើងនៃសត្វដំរី ដែលធំជាងសត្វដទៃ ដានជើងនៃសត្វទាំងអស់នោះ រមែងប្រជុំចុះនៃដានជើងដំរី យ៉ាងណាមិញ កុសលធម៌ទាំងឡាយក៏ប្រជុំចុះក្នុងសេចក្តីមិនប្រមាទ មិនធ្វេសប្រហែសក៏យ៉ាងនោះដែរ។

កិច្ចការគ្រប់យ៉ាង ទាំងខាងផ្លូវលោក ផ្លូវធម៌ ដែលអាចប្រព្រឹត្តទៅបានល្អ រហូតសម្រេចជាគុណជាប្រយោជន៍បាន លុះណាតែជាអ្នកមានស្មារតីប្រុងប្រយ័ត្ន មិនស្រវឹង មិនវង្វេង មិនបណ្តោយឲ្យកាលវេលាកន្លងទៅ ជាអ្នកមិនបណ្តោយចិត្ត ឲ្យងឹតស្រវឹងដោយហេតុបីយ៉ាងគឺ ៖

**១. យោព្វនមទោ** ស្រវឹងវ័យ ;

**២. អរោគមទោ** ស្រវឹងថាខ្លួនមិនមានរោគ ;

**៣. ជាតិមទោ** ស្រវឹងក្នុងជាតិនៃខ្លួនថា ជាអ្នកមានជាតិខ្ពង់ខ្ពស់ មានសក្តិយសច្រើន ។

សេចក្តីឈ្លក់វង្វេងភ្លេចស្មារតី យប់ថ្ងៃបណ្តោយចិត្តឲ្យគិតថាខ្លួននៅក្មេង មានអាយុកំពុងពេញសប្បាយ ទៅតាមចលនាការបត់បែនរបស់លោកិយនិយម ជាប់ជំពាក់នឹងរូបរាងកាយ ដោយ

គិតថាខ្លួនមានសុខភាពល្អ មិនមានរោគាព្យាធិបៀតបៀន ជាអ្នកបានរៀនចេះដឹងច្រើន មានជាតិត្រកូលខ្ពស់ មានយសសម្បត្តិច្រើន បណ្តោយខ្លួនទៅជាអ្នករង្វេងជ្រប់ងុបងល់ ប្រមាទភ្លេចស្មារតី យប់ថ្ងៃបណ្តោយកាយ វាចា ចិត្ត ឲ្យបិតត្រាំនៅដោយវត្ថុកាម កិលេសកាម អ្នកនោះឈ្មោះថា ជាអ្នកប្រមាទខាតបង់គុណប្រយោជន៍សម្រាប់ខ្លួន ។

ពាក្យថា **អណ្ណវៈ** ប្រែថា សមុទ្រ ។ ជីវិតសត្វលោកត្រូវហែលឆ្លងភពទាំងបី ឬហៅថា **សង្សារវដ្ត** ទុកដូចជាសមុទ្រ ដែលសត្វលោកមិនងាយហែល អំពីត្រើយខាងអាយឆ្ពោះទៅត្រើយខាងនាយ ឲ្យបានដល់ឡើយ ។ ដូច្នេះសត្វណា ជាអ្នកប្រមាទភ្លាំងភ្លេចស្មារតី មានសេចក្តីជាប់ជំពាក់ដោយចំណីកាមគុណបណ្តោយចិត្តឲ្យប្រព្រឹត្តតាមខ្សែញាក់តណ្ហា បានឈ្មោះថាជាអ្នកនៅស្លាប់ កើតក្នុងភពរកទីបញ្ចប់គ្មាន ។

## បមាទោ មច្ចុនោ បទំ
## សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ។

ដើម្បីឲ្យបានកន្លង ឬឆ្លងឲ្យផុតពីសេចក្តីទុក្ខ សត្វលោកត្រូវសម្លឹងឃើញរឿយៗ នូវទុក្ខទោសទាំងអស់ ដែលកើតមានមកអំពីភព ហើយមានសេចក្តីតក់ស្លុតរន្ធត់ភ័យ មានសេចក្តីនឿយណាយ ព្យាយាមរកច្រកចេញឲ្យផុតរត់ឲ្យរួច ដោយការមិន

ប្រមាទ មានស្មារតីប្រុងប្រយ័ត្ន មិនធ្វេសប្រហែសបណ្តោយឲ្យកាលវេលាកន្លងទៅឥតប្រយោជន៍ ជាអ្នកព្យាយាមលះការជាប់ជំពាក់ រូបរាងកាយ , ជីវិតវ័យ , ទ្រព្យសម្បត្តិ មានសតិរឭកជានិច្ចនូវកាលវេលា គ្រប់ខណៈដែលបានកន្លងទៅ សុទ្ធតែបានទំពារស៊ីនាំយកនូវអាយុជីវិតរបស់សត្វទាំងឡាយ ព្រមទាំងទ្រព្យរបស់ឥតមានលើកលស់ស្រណោះអាណិត សត្វណាមួយឡើយ ។

សេចក្តីមិនធ្វេសប្រហែស ព្យាយាមលះសេចក្តីអាក្រក់ទាំងឡាយ តាមទ្វារកាយ វាចា ចិត្ត បំពេញសេចក្តីល្អ ឈរលើស្មារតីជាអ្នកឃើញភ័យក្នុងសង្សារវដ្ត មិនបណ្តោតបណ្តោយឲ្យអកុសលធម៌ចូលមកគ្របសង្កត់ចិត្តបាន ទាំងនេះឈ្មោះថាជាអ្នកភ្ញាក់រឭកមិនលង់លក់ ជាអ្នកព្យាយាមរើបម្រះចេញចាក អំពីសេចក្តីស្លាប់ ដែលតាមឃាយីជីវិតសត្វលោក ។

## **អប្បមាទោ អមតំបទំ**
## **សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ ។**

ពាក្យថាមិនស្លាប់បានន័យថា មិនសូន្យចាកកុសលធម៌គុណធម៌ មិនសូន្យចាកការព្យាយាម មិនលើកលះចាកការបតិបត្តិមិនប្រហែសបណ្តោតបណ្តោយ ឲ្យអកុសលធម៌ទាំងពួងកើតឡើងបាន មានស្មារតីរារាំងបិទបាំងប្រុងប្រយ័ត្នជានិច្ច មានស្មារតីក្នុងការលះបង់ កំចាត់បាបចាស់ដែលធ្លាប់មានមក ចេញឲ្យអស់មិន

ឲ្យមានសេសសល់ មិនមានការធ្វេសប្រហែសក្នុងកិច្ចនាទីបំពេញកុសលធម៌ឲ្យកើតមាន ព្រមទាំងរក្សាការពារមិនឲ្យ កុសលធម៌គុណធម៌សាបសូន្យបាត់បង់ទៅវិញបាន ។

អ្នកមានស្មារតីយប់ថ្ងៃមិនប្រមាទ ឈ្មោះថាមិនខាតបង់កាលវេលា ការងារដែលគេធ្វើដោយការប្រុងប្រយ័ត្ន រមែងមិនភ្លាំងភ្លាត់ខុស កុសលធម៌ទាំងអស់មាន ៖ **កាមាវចរកុសល , រូបា - វចរកុសល , អរូបាវចរកុសល** និង **លោកុត្តរកុសល** តែងប្រជុំចុះក្នុងសេចក្ដីមិនប្រមាទ ។

ឱវាទរបស់ព្រះសក្យមុនី ព្រះអង្គទ្រង់ត្រាស់សម្ដែងប្រោសសត្វលោក ទោះបីជាមានច្រើនប្រការយ៉ាងណា ក៏ព្រះអង្គទ្រង់ត្រាស់បំព្រួញនៅត្រឹមតែ **អប្បមាទធម៌** នេះឯង ដែលជាបណ្ដាំចុងក្រោយ ជាពុទ្ធវចនៈចុងក្រោយបង្អស់ ឬហៅថា **បច្ឆិមវាចា** ក្នុងពេលដែលព្រះអង្គជិតនឹងរំលត់ខន្ធ យាងចូលកាន់ព្រះនិព្វានទ្រង់មានព្រះពុទ្ធតម្រាស់យ៉ាងនេះថា ៖

**ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា**
**អប្បមាទេន សម្បាទេថាតិ ។**

**ម្នាលភិក្ខុទាំងឡាយ ! ណ្ហើយចុះ , ឥឡូវនេះតថាគត**
**ប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ**

## មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំង កិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។

នេះជាបណ្តាំចុងក្រោយ ដោយទឹកព្រះទ័យដ៏ប្រកបដោយមហាករុណាទិគុណដល់សត្វលោក ទោះបីជាព្រះអង្គទ្រង់មានព្រះកាយពល ថមថយល្ហិតល្ហៃយ៉ាងណាក៏ព្រះអង្គព្យាយាមទូន្មានសត្វលោកកុំឲ្យប្រមាទ ភ្លាំងភ្លេចស្មារតី កុំឲ្យស្រវឹងវង្វេងនឹងជីវិតវ័យ ។ អាយុជីវិតចេះតែតិចទៅអស់ទៅតាមកាលវេលា ដូចជាខ្សែទឹកហូរទៅហើយមិនត្រឡប់វិញ ត្រូវយកជីវិតនេះទៅបម្រើក្នុងគុណប្រយោជន៍ គឺកាលបើជីវិតរស់នៅ ត្រូវខំបំពេញកិច្ចការ ជាប្រយោជន៍ទាំងបីមាន ៖ ប្រយោជន៍បច្ចុប្បន្ន , ប្រយោជន៍បរលោក និងបរមត្ថប្រយោជន៍គឺព្រះនិព្វាន ដែលមិនមានភពកំណើត នាំឲ្យកើតសេចក្តីទុក្ខទៀត ដោយអប្បមាទធម៌ ។

## ៣. គុណធម៌ទីបី: វិរិយេន ទុក្ខមច្ចេតិ ឆ្លងអន្លង់ទុក្ខបាន ព្រោះសេចក្តីព្យាយាម

សេចក្តីព្យាយាម បានដល់សេចក្តីខំប្រឹងប្រែង , ការប្រឹងប្រែង , ដំណើរខ្មីឃ្មាត , សង្វាត , ធ្វើការដោយព្យាយាម , ធ្វើការដោយឧស្សាហ៍យកចិត្តទុកដាក់ ។

ពាក្យថាអន្លង់ទុក្ខ បានដល់សេចក្តីទុក្ខដែលកើតអំពីកាម

មានវត្ថុកាម កិលេសកាមជាដើម ។ សេចក្តីទុក្ខដែលកើតឡើង បានដោយ មានចិត្តជាប់ជំពាក់ ប្រកាន់ស្អិតញៀនញ៉ាម ទៅតាម ប្រភេទនៃវត្ថុនិងអារម្មណ៍ ជាចំណីជានុយរបស់កាមគុណ ដូចខ្ញុំបាទបានសរសេរបញ្ជាក់រួចមកហើយ ។

ដូច្នេះដើម្បីលះបង់ សេចក្តីទុក្ខដែលកើតអំពីកាម ត្រូវព្យាយាមលះបង់វៀរចាកកាម ដោយការពិចារណាឲ្យឃើញទោសរបស់កាមទាំងឡាយ ឲ្យឃើញថាមិនគួរប្រាថ្នា មានសេចក្តីត្រេកអរតិច ដូចជារាងឆ្អឹង គ្រាន់តែផ្សំផ្គុំរៀបចំជាគម្រោងឲ្យមានឡើងតែប៉ុណ្ណោះ ។ ដូចជាដុំសាច់ ដែលលាបស្រឡាបដោយឈាមមានពណ៌ក្រហម ជារបស់សាធារណៈ សម្រាប់ហ្វូងសត្វក្អែកត្មាត ជញ្ជែងដណ្តើមគ្នាតែប៉ុណ្ណោះ ។ ដូចជាគប់ស្មៅ ដែលដុតដោយភ្លើង ហើយបុគ្គលកាន់ដើរច្រាសខ្យល់ រមែងត្រូវផ្កាភ្លើងរសាត់ពោយរាយ រលោកលើខ្លួន ។ ដូចរណ្តៅរងើកភ្លើង ដោយកិរិយាក្តៅពោលរាលខ្លាំង មានចំហាយជះកំដៅខ្លាំង ។ ដូចជាការយល់សប្តិ៍ ដោយសេចក្តីថា មានកិរិយាតាំងឡើងផ្តេសផ្តាស មិនប្រាកដប្រជា ក្នុងពេលនិទ្រាលក់សុបិនឃើញយ៉ាងនេះយ៉ាងនោះ ហាក់ដូចជាពិតប្រាកដណាស់ ដល់ភ្ញាក់ក្រោកឡើងគ្មានអ្វីបន្តិចបន្តួចឡើយ ។ ដូចជារបស់ខ្ចីគេ គ្រាន់តែជារបស់ប្រព្រឹត្តទៅបានម្តងម្កាលប៉ុណ្ណោះ ។ ដូចឈើមានផ្លែ ដោយកិរិយាបាក់ខ្ទេចខ្ទីពោយរុះជ្រុះស្លឹក បាក់មែកដោយការបេះដោយទំពក់ គប់គ្រវែង

ចោលដោយដំបង ។ ដូចកាំបិតនិងជ្រុញ ដោយសេចក្តីថា មានស្នាមសឹកដាច់រេចរឹល ប្រឡាក់ដោយឈាម កំទេចសាច់រំអិល ។ ដូចមុខលំពែងស្រួច ដោយការចាក់ទម្លុះ ធ្វើឲ្យឈឺចុកចាប់ ។ ដូចជាក្បាលពស់វែក ដោយសេចក្តីថា ប្រកបដោយភ័យចំពោះមុខ ។ ដូចគំនរភ្លើង ដោយសេចក្តីថា ក្តៅរោលរាលក្រហល់ក្រហាយ ដោយភ្នក់ភ្លើងធំ ។

សត្វលោកកាលបើមិនឃើញទោសក្នុងកាមទេ ក៏រមែងសប្បាយរីករាយ វង្វេងភ្លេចស្មារតី ដូចហ្វូងត្រីសប្បាយនឹងឃើញនុយ ឬដូចសត្វជ្រូកសប្បាយព្រោះចំណី ដែលម្ចាស់បំប៉នឲ្យទាំងយប់ថ្ងៃ ដើម្បីឲ្យជ្រូកធាត់ធំនឹងសម្លាប់យកសាច់ ឬគ្រាន់តែលក់យកកម្រៃផលប៉ុណ្ណោះ ។ ជីវិតសត្វលោករស់នៅ ត្រេកត្រអាលរីករាយស្រើបស្រាល ដោយអំណាចកាមគុណ រស់នៅដោយការធន់ទ្រាំនឹងកម្លាច គម្លាន កង្វះ ចំណង់ចំណូល សេចក្តីទុក្ខសោកដល់កម្រឹតណា ក៏សុខចិត្តធន់ទ្រាំដោយភាពវង្វេង ដោយទ័លច្រក ។

ក្នុងអនុបុព្វីកថា ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្តែងអំពីទាន សីល អានិសង្សទានសីល បន្ទាប់មកព្រះអង្គទ្រង់ត្រាស់សម្តែង អំពីឋានសួគ៌បង្ហាញសត្វលោកឲ្យឃើញយល់ស្គាល់ដឹងប្រឹងបំពេញទានសីល ដើម្បីឲ្យបានទៅកើតក្នុងឋានសួគ៌បរិបូណ៌

ដោយសម្បត្តិទិព្វ និងពោរពេញដោយកាមគុណ ជាចំណីដែលសត្វលោកតែងប្រាថ្នា ។

បន្ទាប់មកទៀតទើបព្រះអង្គទ្រង់ត្រាស់សម្ដែងបំភ្លឺ បញ្ជាក់ឲ្យសត្វលោកយល់ច្បាស់ អំពីទោសរបស់កាមគុណ ដែលមានទម្ងន់គ្របសង្កត់ ធ្វើឲ្យសត្វលោកមានដំណើរវងវឹតវង្វេង មិនអាចរកទិសចេញឲ្យផុតរត់ឲ្យរួច អំពីអន្ទាក់មច្ចុមារបាន ។ ដូច្នេះដើម្បីដាស់ស្មារតីសត្វលោក ដែលកំពុងតែងោកងក់លង់លក់ក្នុងភពពោរពេញដោយនុយ គឺកាមនេះ ព្រះអង្គទ្រង់បានត្រាស់សម្ដែងអរិយសច្ចធម៌ បង្ហាញអំពីសេចក្ដីទុក្ខ ដែលជាផល កើតចេញមកអំពីហេតុ គឺកាមតណ្ហានេះឯង ទ្រង់សម្ដែងអំពីមគ្គ ជាផ្លូវប្រតិបត្តិដើម្បីកំចាត់បង់តណ្ហា និងជាផ្លូវធ្វើដំណើរទៅកាន់ទីរំលត់ទុក្ខ ។

ការរើបម្រះឲ្យផុតពីអន្លង់កាមទៅបាន ត្រូវតែព្យាយាមពិចារណា ឲ្យឃើញទោសរបស់កាម ដែលមានច្រើនប្រការហើយព្យាយាមលះបង់ ការជាប់ជំពាក់ហ្មងហ្មងសោកស្ដាយ នឿយណាយធុញទ្រាន់ ខិតខំចម្រើនអនុស្សតិដប់ប្រការមាន ៖

**១. ពុទ្ធានុស្សតិ** រំឭកគុណព្រះពុទ្ធ ;
**២. ធម្មានុស្សតិ** រំឭកគុណព្រះធម៌ ;
**៣. សង្ឃានុស្សតិ** រំឭកគុណព្រះសង្ឃ ;
**៤. សីលានុស្សតិ** រំឭកគុណសីល ;

**៥. ចាគានុស្សតិ** រំឭកគុណដល់ទានដែលបានបរិច្ចាគហើយ ;

**៦. ទេវតានុស្សតិ** រំឭកដល់គុណធម៌ដែលកើតជាទេវតា ;

**៧. ឧបសមានុស្សតិ** រំឭកគុណព្រះនិព្វាន ;

**៨. អនាបានុស្សតិ** រំឭកខ្យល់ដង្ហើមចេញចូល ;

**៩. មរណានុស្សតិ** រំឭកដល់សេចក្តីស្លាប់ដែលមានដល់ខ្លួន ;

**១០. កាយគតានុស្សតិ** រំឭកទូទៅក្នុងកាយឲ្យឃើញថាជា របស់មិនស្អាតគួរខ្ពើម ។

ការព្យាយាមចម្រើន **អនុស្សតិ** ទាំងដប់ប្រការឲ្យញយៗរឿយៗ រមែងធ្វើឲ្យចិត្តកើតសេចក្តីជ្រះថ្លាផង ឲ្យកើតសង្វេគផង ឲ្យកើតការនឿយណាយខ្ពើមរអើមចំពោះរាងកាយ ដែលពោរពេញដោយសាកសព ជាទីជម្រកនៃសត្វដង្កូវ ជាលំនៅនៃរោគគ្រប់ជំពូក ជាប្រភពនាំមកនូវសេចក្តីទុក្ខច្រើនប្រការ ។ សេចក្តីពិចារណាឃើញច្បាស់ ទុក្ខទោសដែលកើតអំពីកាម មានការសង្វេគតក់ស្លុតភ័យខ្លាច ទើបអាចមានសេចក្តីព្យាយាម ធ្វើឲ្យកន្លងផុតពីអន្លង់គឺកាមនេះទៅបាន ។

## ៤. គុណធម៌ទីបួន: បញ្ញាយ បរិសុជ្ឈតិ

## បុគ្គលបរិសុទ្ធបានដោយបញ្ញា

ពាក្យថា **បញ្ញា** ( ជាភាសាបាលី ) ប្រែជាភាសាខ្មែរបាន ន័យថា ការយល់ដឹង , ការពិចារណា , ការពិចារណាសព្វ , ការពិចារណាធម៌ , ការកំណត់ , ការកំណត់មាំមួន , ការគិត , ការពិនិត្យ , ការត្រិះរិះ ។ ពាក្យថា **បុគ្គលបរិសុទ្ធបាន** បានដល់បុគ្គលដែលអាចបរិសុទ្ធ ផុតចាកភាពវង្វេងងងឹតល្ងង់គឺអវិជ្ជា ។ ជាគ្រឿងខ្ទប់រាំងហ៊ុមគ្រប បង្រួមផ្កាប់បិទបាំង មិនឲ្យឃើញសេចក្ដីពិត គឺអរិយសច្ចធម៌ ។ បុគ្គលអាចឆ្លងអន្លង់អវិជ្ជាបាន ដោយសារមានបញ្ញា , បញ្ញាជាគ្រឿងដឹងនូវការអស់ទុក្ខដោយប្រពៃ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ , នេះជាហេតុនាំឲ្យទុក្ខកើត , ដឹងច្បាស់តាមពិតថា នេះជាទីរំលត់ទុក្ខ , ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីប្រតិបត្តិ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

បញ្ញាចាត់ថាជាសោភណៈចេតសិក កើតឡើងជាមួយចិត្ត ធ្វើចិត្តឲ្យបរិសុទ្ធស្អាតថ្លា គួរដល់ការបំពេញកងការកុសលទាំងពួងបាន បញ្ញាជាគ្រឿងទំលាយបង់នូវកងកិលេសទាំងឡាយ ជាគ្រឿងដឹកនាំឲ្យចំគោលដៅ បុគ្គលអ្នកមានសទ្ធាមានការព្យាយាមជាចាំបាច់ណាស់ ត្រូវមានបញ្ញាជាជំនួយក្នុងការបំភ្លឺផ្លូវឆ្ពោះទៅកាន់គោលដៅមិនខុស ។ បញ្ញាអាភាៈ ប្រាជ្ញាជាពន្លឺ ជារស្មីចែងចាំង កំចាត់បង់នូវភាពងងឹត គឺអវិជ្ជាឲ្យអស់ទៅបាន បញ្ញាជា

អាវុធដ៏មុតថ្លា អាចកាប់ផ្ដាច់បំបាក់បង់មារសត្រូវ ពោលគឺ កិលេសាសវៈ ដែលជាសេនាមច្ចុមារឲ្យអស់ដោយពុំមានសេសសល់ ។

*នេះជាកំណាព្យរបស់លោក **ឱម ណារត្រី** ( សាស្ត្រាចារ្យភាសាខ្មែរ ) ៖

ប្រាជ្ញាអាវុធប្រសើរពិត អាចជួយគូរគិតការពារគ្រប់
មានទុក្ខទោសភ័យទាំងថ្ងៃយប់ ប្រាជ្ញាប្រារព្ធឲ្យសុខសាន្ត ៗ

ប្រាជ្ញាអាចឆ្លុះបំភ្លឺឲ្យយល់ស្គាល់ ច្បាស់ពិតប្រាកដហេតុផលជាអាក្រក់ឬល្អ , ធម៌សធម៌ខ្មៅ , ខុសត្រូវ , គុណទោស , ប្រយោជន៍ឬមិនជាប្រយោជន៍ នឹងជាគុណជាតិធ្វើឲ្យបានសម្រេចនូវ លោកិយកុសល និងលោកុត្តរកុសល បានតាមប្រាជ្ញានៃការព្យាយាមនោះៗ ។

ដូច្នេះត្រូវខំសន្សំបំពេញបង្កើនប្រាជ្ញា ឲ្យកើតមានឡើងជាលំដាប់ដោយហេតុបីប្រការគឺ ៖ **១. សុតមយបញ្ញា , ២. ចិន្តាមយបញ្ញា , ៣. ភាវនាមយបញ្ញា ។**

ធម៌ទាំងបីប្រការនេះហើយ ជាផ្ទាលបណ្ដុះបញ្ញា :

**១. សុតមយបញ្ញា** ប្រាជ្ញាកើតបានដោយការស្ដាប់បានសេចក្ដីថាជាចំណេះដឹងគ្រប់យ៉ាង ដែលអាចចេះដឹង យល់ស្គាល់ទៅបាន លុះត្រាណាតែព្យាយាមតាំងចិត្តស្ដាប់ ហាត់

អានរៀនសរសេរ កំណត់កត់ចាំទន្ទេញ ស្តាប់ម្តងហើយបើមិនចាំ ព្យាយាមស្តាប់ម្តងទៀត ស្តាប់ឲ្យរឿយៗ ។ ការស្តាប់តែម្យ៉ាង ពុំអាចធ្វើឲ្យបញ្ញាចងចាំបានដោយងាយៗ នោះទេ ដូច្នេះហើយ បានជាការសិក្សានៅក្នុងសាលា ឬទីណាៗក៏ដោយគេត្រូវមាន ឧបករណ៍ ដូចជាសៀវភៅខ្មៅដៃដើម្បីកត់ត្រាសរសេរទុក គឺត្រូវ ព្យាយាមស្តាប់ដោយយកចិត្តទុកដាក់ កាលបើមិនចាំត្រង់ចំណុច សំខាន់ ត្រូវស្តាប់ហើយស្តាប់ទៀត ឆ្លៀតឱកាសរៀនអានសូត្រ ទន្ទេញ សរសេរទុកផ្ទៀងផ្ទាត់ សាកសួរបួរយោបល់អំពីលោកអ្នក ប្រាជ្ញពហុស្សូត ស្តាប់សេចក្តីអធិប្បាយពន្យល់ ចង្អុលបង្ហាញពី លោក រហូតបានចេះចាំ ទាំងនេះទើបឈ្មោះថាការស្តាប់ ដែល ហៅថាធ្វើឲ្យកើតបញ្ញាអំពីការស្តាប់ ។ បើគ្រាន់តែអង្គុយស្តាប់ព្រះ ធម៌ទេសនា ទៅតាមទម្លាប់ ឬក៏ចាក់បើកវិទ្យុម៉ាញ៉េស្តាប់ព្រះធម៌ អំពីសំណាក់លោកអ្នកប្រាជ្ញណាម្នាក់ ដោយគ្រាន់តែពោលពាក្យ សរសើរ ជាប់ចិត្តចំពោះសម្លេងលោកពីរោះ លោកទេសន៍ក្បោះ-ក្បាយ បរិយាយបានល្អត្រឹមតែប៉ុណ្ណោះ ទោះបីជាស្តាប់ដល់កំរិត ណាក៏មិនទាន់បានឈ្មោះថា ធ្វើឲ្យកើតបញ្ញាដែរ ។

ការព្យាយាមស្តាប់ដោយមិនមានការចងចាំ នៅខ្វះការដឹង យល់យ៉ាងនេះ មិនទាន់ឈ្មោះថាជា **សុតមយបញ្ញា** នៅឡើយទេ ឈ្មោះថា ជាអ្នកកំពុងបណ្តុះឧបនិស្ស័យក្នុងការស្តាប់ឲ្យកើតមាន រឿយៗ ចំណែកអ្នកស្តាប់ដោយយកចិត្តទុកដាក់ រហូតដល់រៀន

អានសូត្រទន្ទេញ ឲ្យបានចេះចាំដឹង យល់ទាំងនេះឈ្មោះថា **សុតមយបញ្ញា** ។

**២. ចិន្តាមយបញ្ញា** បានដល់បញ្ញាកើតឡើង ដោយការត្រិះរិះពិចារណា រកហេតុផលឲ្យបានដឹងយល់ ច្បាស់ប្រាកដពិតដែលជាពន្លឺ បញ្ចាំងចេញមកពីផ្នត់គំនិតដោយឥតសង្ស័យ មិនមានការស្រពេចស្រពិលនៅក្នុងចិត្ត ។ ពិតមែនហើយរឿងរ៉ាវហេតុការណ៍ដែលមាននៅក្នុងលោកនេះ សុទ្ធតែជាហេតុការណ៍មានជម្រៅបង្កប់នៅដោយអាថ៌កំបាំង ធ្វើឲ្យមនុស្សដែលជាបុថុជ្ជនមានសេចក្តីសង្ស័យស្រពេចស្រពិលមិនអស់មិនហើយ ។

ដូច្នេះបញ្ញាកើតបានត្រឹមពីការស្តាប់ ការឮដឹងឃើញនៅមិនទាន់ជាគ្រប់គ្រាន់ទេ សូម្បីតែការស្តាប់ដល់ថ្នាក់សិក្សាសូត្ររៀន ហាត់អានទន្ទេញចាំហើយក៏ដោយ ក៏ត្រូវពឹងលើគំនិតគិតពិចារណា ត្រិះរិះរកហេតុផល ឲ្យបានយល់ចូលចិត្តដែរ បើពុំនោះសោតទេនឹងធ្វើការយល់ដឹងខុស ប្រកាន់តាមខុស បតិបត្តិខុសមិនខាន ។

មិនថាក្នុងពុទ្ធសម័យ ឬសម័យបច្ចុប្បន្ននេះទេ អ្នកដែលចេះចាំទន្ទេញអានរៀនស្តាប់ អំពីសំណាក់គ្រូណាហើយក្តី គោរពធ្វើវត្តបតិបត្តិតាមទ្រឹស្តី ប្រពៃណីទំនៀមទម្លាប់ ជាប់ជាតំណតពីចាស់ទុំបរមបុរាណក្តី ក៏យល់ចូលចិត្តប្រកាន់តាមទ្រឹស្តីនោះៗ

មានខុសមានត្រូវដែលតម្រូវ ឲ្យប្រកាន់ជាប់ស្អិតក្នុងផ្នត់គំនិត មិនព្រមលះបង់នៅទោសកំហុសនោះសោះឡើយ ។ ទាំងនេះមកពីការដឹងយល់ មានកម្រឹតត្រឹមតែការស្តាប់ប៉ុណ្ណោះ ទើបធ្វើឲ្យមានការបតិបត្តិខុស ផ្ទុយអំពីហេតុផលនៃជីវិត ។ ដូចជាការបែងចែកវណ្ណៈ ធ្វើឲ្យមនុស្សមានមានៈលើកកំពស់ខ្លួន មើលងាយវាយបន្ទោកអ្នកដទៃ បង្កើតជារឿងវិវាទទាស់ទែងខ្វែងគំនិត មានចិត្តញែកបែកចេញពីគ្នា ។ មានទ្រឹស្តីច្រើនណាស់ក្នុងពុទ្ធកាលដែលពួកព្រាហ្មណ៍ បានបង្កើតដោយខ្វះវិចារណញ្ញាណ មានការសម្លាប់សត្វ ចាប់ក្មេងប្រុសស្រីជំទង់ យកទៅបូជាភ្លើងដើម្បីបំពេញបំប៉នមហិច្ឆតារបស់ខ្លួន ទាំងនេះជាអំពើធ្វើតៗគ្នា ដោយការចេះចាំស្តាប់ពីហ្មតពីគ្រូ ប្រកាន់ខ្ជាប់ជាទម្លាប់ប្រពៃណី ដោយខ្វះស្មារតីពិចារណារកហេតុរកផលពិត ។

ការយល់ចូលចិត្តទៅតាមលទ្ធិច្រើនរាប់មិនអស់ ដូចលទ្ធិអង្វរករបន់ស្រន់សុំជំនួយក្តី លទ្ធិថាមនុស្សខ្ពស់ជាងតិរច្ឆាន សត្វតិរច្ឆានទាំងអស់ជាទាសៈរបស់មនុស្ស ៗ អាចកាប់សម្លាប់សត្វជាចំណីតាមសេចក្តីប្រាថ្នា ការកាប់សម្លាប់បំបាត់ជីវិតគ្នា គ្មានទោសពៃរ៍អ្វីទេ ព្រោះមានព្រះជាអ្នកធានាទទួលទោសជំនួស សុខទុក្ខដែលសត្វលោកបានមក ដោយសារមានព្រះជាអ្នកប្រទានរួចទៅហើយ ។

ការបានស្តាប់ចេះចាំតាមលទ្ធិនីមួយៗ បានត្រឹមតែការចេះចាំទន្ទេញសូត្រ និងធ្វើទៅតាមការស្តាប់ឮដឹងឃើញ បើធ្វើទៅចំលើខុសក៏រមែងទទួលទោស ទៅតាមកំហុសនោះៗ ព្រោះគុណទោសជាច្បាប់ធម្មជាតិ ម្យ៉ាងវិញទៀតបើទង្វើនោះបានត្រឹមតែខុសមិនដល់ថ្នាក់ទទួលទោសទេ ក៏គង់ខកខូចតូចចិត្តដ្បិតមិនបាន គុណប្រយោជន៍តាមសេចក្តីប្រាថ្នា និងជាហេតុធ្វើឲ្យខាតបង់ពេលវេលាទៀតផង ។

ដូច្នេះ **ចិន្តាមយបញ្ញា** បានដល់ការស្តាប់ចេះចាំហើយ ដឹងឮឃើញហើយយកមកត្រិះរិះពិចារណា តាំងចិត្តប្រើគំនិត ស្រាវជ្រាវរករកហេតុផល ឲ្យបានដឹងយល់ទៅតាមសេចក្តីពិត ដែលហួរចេញពីផ្នត់គំនិត មានចិត្តប្រកាន់ទៅតាមហេតុផល ឬកម្មផល ( ពាក្យថា ហេតុផលឬកម្មផល ) មានទាំងផ្នែកខាងគុណនិងទោសខុសត្រូវអាក្រក់ល្អជាគូគ្នា ទោះបីជាមនុស្សសត្វ មានច្រើនប្រភេទផ្សេងដោយឡែកពីគ្នាយ៉ាងណាក៏ដោយ ក៏មិនអាចគេចរួចអំពីហេតុផល ឬកម្មផលនេះទេ ។

សត្វលោកស្រឡាញ់ជីវិតពិតដូចគ្នា ស្រឡាញ់សេចក្តីសុខខ្ពើមសេចក្តីទុក្ខ សត្វលោកត្រូវការអាហារ កាលបើសេចក្តីស្រេកឃ្លានកើតមានហើយ គេត្រូវការបរិភោគអាហារ ៗ ជាហេតុកំចាត់បង់សេចក្តីស្រេកឃ្លានជាផល ។ សូមប្រើគំនិតពិចារណាដឹង

យល់ស្គាល់នូវអ្វី ទៅតាមសភាវពិត គឺហេតុផល ។ សូមកុំប្រើចម្ងល់ទៅលើហេតុការណ៍អ្វីដែលខុស ឬដែលហួសវិស័យ សូមកុំចូលចិត្តយកគំនិត ទៅគិតពិចារណាអ្វីដែលដឹងមិនដល់ឆ្ងល់មិនអស់នាំឲ្យខាតពេលវេលា ។ ឧទាហរណ៍ដូចមនុស្សពីរនាក់ បានស្រុះស្រួលបបួលគ្នាទៅជីកត្បូង លុះប្រឹងជីកកាយរណ្ដៅរហូតទៅឃើញត្បូង មនុស្សម្នាក់មានចិត្តសង្ស័យ គិតពិចារណាមិនដាច់ស្រេចក្នុងគំនិតថា ៖ ត្បូងនេះកើតចេញពីយ៉ាងណា ដីនេះធ្វើឲ្យត្បូងកើតចេញដូចម្ដេចហ្ន៎ !។ ឯមនុស្សម្នាក់ទៀតគ្រាន់តែក្រឡេកឃើញត្បូង យល់ស្គាល់ថាជាត្បូង ឥតបង្អង់រុញរា ព្យាយាមកើបស្រវារដាក់ថង់ងើបចេញពីរណ្ដៅយ៉ាងរហ័ស ។ ន័យនេះបញ្ជាក់ឲ្យបានយល់ច្បាស់ថា ការប្រើគំនិតគិតពីហេតុការណ៍មានមកចំពោះមុខ ជាកិច្ចប្រសើរជាជាងដែលយកគំនិតទៅគិត អំពីហេតុអ្វីដែលជាអតីហេតុ គឺហេតុដែលកន្លងទៅហើយ និងអ្វីជាអនាគតហេតុ គឺហេតុដែលមិនទាន់មានមកដល់ ។ ការប្រើគំនិតត្រិះរិះពិចារណា ឲ្យកើតប្រាជ្ញាយល់ច្បាស់ ចូលចិត្តអំពីហេតុផលពិតដែលកំពុងកើតមានចំពោះមុខ ទើបចាត់ថាជាបញ្ញាកើតឡើងអំពីការគិត ។

**៣. ភាវនាមយបញ្ញា** ប្រាជ្ញាកើតឡើងបានដោយការចម្រើន ប្រាជ្ញានេះជាប្រាជ្ញាជាន់ខ្ពស់ហួសពី **សុតមយបញ្ញា** និង **ចិន្តាមយបញ្ញា** ការស្ដាប់ការត្រិះរិះពិចារណា នាំឲ្យកើតប្រាជ្ញាបាន

ជាស្រទាប់ខាងក្រៅមិនបានចូលទៅដល់ជម្រៅ ខាងក្នុងនៅឡើយទេ ។ ព្រោះបញ្ញាទាំងពីរនេះ នៅមិនទាន់មានកម្ពស់ឲ្យចាក់ធ្លុះពីសភាវៈធម៌ពិត ដែលហូរចេញអំពីផ្នត់គំនិតខ្លួននោះទេ ទើបត្រូវមាន **ភាវនាមយបញ្ញា** មួយទៀត ដើម្បីបញ្ជាំងឲ្យដល់ជម្រៅ និងធ្លុះបំភ្លឺនូវអ្វីៗ ដែលជាអាថ៌កំបាំងមិនធ្លាប់បានយល់ស្គាល់ ឲ្យយល់ស្គាល់ដែលហូរចេញ ពីផ្នត់គំនិតខ្លួនពិតៗ ។ **សុតមយបញ្ញា** ប្រៀបបានជាអ្នកចោលភ្នែក ក្រឡេកឃើញភោជនដែលគេដាក់នៅក្នុងភាជន៍ គ្រាន់តែបានស្ញើចសរសើរ ដោយការវិចិត្ររៀបចំភោជននោះ មានពណ៌ខៀវក្រហមលឿងស គួរឲ្យចង់បរិភោគប៉ុណ្ណោះ ។ **ចិន្តាមយបញ្ញា** ប្រៀបដូចជាអ្នកបានចូលទៅជិតភោជនាហារ ដែលគេរៀបចំចាត់ចែងដាក់ក្នុងភាជន៍ មានកម្ដៅហុយផ្សែងបញ្ចេញក្លិនឲ្យបានដឹងថានេះជាក្លិននៃម្ហូបនេះ នេះជាក្លិននៃម្ហូបនោះជាដើម តែឥតបានបរិភោគ ។

ចំណែកឯ **ភាវនាមយបញ្ញា** ទើបចាត់ថាជាអ្នកបានឃើញភោជនផង បានដឹងក្លិននិងបានបរិភោគ ដឹងយល់ស្គាល់រសជាតិភោជន ថាឆ្ងាញ់ឬមិនឆ្ងាញ់ដោយខ្លួនឯងទៀតផង ។

ប្រាជ្ញាកើតឡើងអំពីការស្ដាប់ក្ដី កើតឡើងពីការត្រិះរិះពិចារណាក្ដី អាចធ្វើឲ្យបានគុណប្រយោជន៍ជាលោកិយបាន មិនអាចធ្វើឲ្យសម្រេចគុណប្រយោជន៍ ជាលោកុត្តរៈបានឡើយ មានតែភាវនាមយបញ្ញាទើបធ្វើឲ្យសម្រេចគុណប្រយោជន៍ជាលោកុត្តរៈ

ព្រោះជាថ្នាក់បញ្ញាដែលកើតឡើងបាន ដោយការហ្វឹកហ្វឺនហាត់ហៅថា **វិបស្សនាភាវនា** ជាវិជ្ជាជាន់ខ្ពស់ផ្នែកពុទ្ធសាសនា អាចកំចាត់បង់នូវ **អវិជ្ជា** ឲ្យអស់បាន ។ ព្រះអរិយបុគ្គលទាំងពួងលោកបានកន្លងភាពជាបុថុជ្ជន ទៅកាន់អរិយជន បានឆ្លងភាពពីអរិយជនថ្នាក់សេក្ខៈ ទៅកាន់ថ្នាក់អសេក្ខៈជាព្រះអរហន្តបាន ក៏ព្រោះតែមានវិបស្សនាភាវនា គឺការចម្រើនបញ្ញាឲ្យកើតការយល់ដឹងឃើញច្បាស់ នូវសង្ខារធម៌ដែលកើតអំពីហេតុបច្ច័យមានការកើតរលត់ទៅគ្រប់ខណៈ មានការប្រែប្រួលផ្លាស់ប្តូរទៅ តាមប្រក្រតីធម្មតា ដែលគ្មានសត្វលោកណា មានអំណាចឃាត់ឃាំងរាំងរាបាមឃាត់បានឡើយ ។

បើមានសំណួរថា ៖ " *បញ្ញាកើតឡើងអំពីការស្តាប់មិនអាចធ្វើឲ្យសម្រេចលោកុត្តរកុសលបាន ចុះមានពួកសាវករបស់ព្រះសម្ពុទ្ធជាច្រើន គ្រាន់តែតាំងចិត្តស្តាប់ព្រះធម៌ទេសនា ពីសំណាក់ព្រះសាស្តាសម្មាសម្ពុទ្ធ បានសម្រេចជាព្រះអរហន្ត ជាព្រះអរហន្តីមិនខុសទៅហើយឬ ?* " ។

ចម្លើយ ៖ " *មិនខុសទេ , ការស្តាប់ព្រះធម៌ ធ្វើឲ្យបានសម្រេចជាលោកុត្តរកុសលនោះ ក៏ព្រោះតែមាន **ភាវនាមយបញ្ញា** ចាស់ក្លា បានសម្រេចបំពេញមកជាអសង្ខេយជាតិ ចំណែក **សុតមយបញ្ញា** និង **ចិន្តាមយបញ្ញា** ជាហេតុ ជាបច្ច័យ ដល់*

***ភាវនាមយបញ្ញា*** *។ ដូចជាផ្លែឈើកើតចេញបាន ក៏ដោយមានផ្កាឈើ ផ្លែតូចបានទៅជាផ្លែធំ ពីសភាពខ្ចីទៅកាន់ចាស់ស្រគាលទុំគួរដល់ការបរិភោគបាន យ៉ាងណាមិញ បញ្ញាទាំងបីប្រការនេះក៏មានបច្ច័យប្រាស្រ័យ ទំនុកបំរុងគ្នា យ៉ាងនោះឯង ” ។*

ជីវិតសត្វលោក ដែលត្រាច់រង្គាត់ក្នុងសង្សារវដ្តនេះ តែងប្រព្រឹត្តទៅក្រោមអំណាច **អវិជ្ជា** បច្ច័យតាក់តែងឲ្យមានជីវិតឡើងគឺ **អវិជ្ជា ។** ជាខាងដើមបង្កើតឲ្យមានសេចក្តីទុក្ខ ហើយហ៊ុមព័ទ្ធបិទបាំងរាំងស្ទះសត្វលោក ឲ្យងងឹតឥតពន្លឺ ងប់ងល់មិនយល់ដឹងស្គាល់ សេចក្តីទុក្ខនោះទៀតផង មានតែ **ភាវនាមយបញ្ញា** នេះ ជាគុណជាតិធ្វើឲ្យសត្វលោកបានបរិសុទ្ធ ផុតចាកកិលេសជាគ្រឿងសៅហ្មង និងអាចឆ្លងចាកភាពងងឹតគឺ **អវិជ្ជា** នេះបាន ។



# សេចក្ដីបញ្ជាក់

**អន្លង់** ទាំងបួនមាន ៖

- **កាម** ចំណង់ , ចង់ , ជាប់ ;
- **ភព** ទី , កើត , ទីអាស្រ័យ ;
- **ទិដ្ឋិ** ការយល់ឃើញ , ការប្រកាន់តាមការយល់ឃើញ;
- **អវិជ្ជា** មិនចេះ , មិនដឹង , វង្វេងមិនស្គាល់ធម៌ ។

ទាំងបួនប្រការនេះ ចាត់ថាជាអន្លង់ជ្រៅ ព្រោះសត្វលោកមិនងាយហែលឆ្លងកន្លងឲ្យផុតទៅបានទេ ។ **ភព** ជាកន្លែងជាភូមិឋាន ឲ្យសត្វលោកបានសម្រាកសម្រាន្ត អាស្រ័យនៅ ។ **អវិជ្ជា** តណ្ហាជាមេជាង បានរចនាវិចិត្រតាក់តែងស្អិតស្អាង សាងអត្តភាពសត្វលោក ព្រមទាំងភូមិឋានឲ្យមានប្រការប្លែកៗ ពីគ្នាទៅតាមកុសលាភិសង្ខារខ្លះ , អកុសលាភិសង្ខារខ្លះ , អនេញ្ជាភិ - សង្ខារខ្លះ ។ **តណ្ហា** សេចក្ដីប្រាថ្នាបានបញ្ជោចិត្តសត្តា ឲ្យស្ទុះទៅជារឿយៗ សត្វណាដែលកើតនៅក្នុងទុគតិភូមិ ឬសត្វណាដែលមានទុក្ខ ក៏ប្រាថ្នាសូមឲ្យបានរួចផុតចាកសេចក្ដីទុក្ខ សូមឲ្យបានសេចក្ដីសុខ សត្វដែលកើតក្នុងឋានមនុស្ស តែងប្រាថ្នាសម្លឹងប្រឹងរកសេចក្ដីសុខ ឲ្យបានខ្ពស់ប្រសើរថែមទៀត ទាំងមនុស្សទេវតាពោរពេញដោយសេចក្ដីប្រាថ្នា ព្រមទាំង **កាម** ជាចំណីទាក់ទាញ

ចិត្តឲ្យរីករាយសប្បាយ លាយឡំផ្សំដោយសេចក្តីទុក្ខ **ទិដ្ឋិអវិជ្ជា** សេចក្តីយល់ឃើញខុស វង្វេងប្រកាន់តាមខុស ធ្វើឲ្យសត្វលោកជាប់ចិត្តស្អិតប្រកាន់ទៅតែផ្លូវម្ខាង គឺការរីករាយសប្បាយភ្លើតភ្លើនស្រើបស្រាល ឥតបាននឹកគិតដល់សេចក្តីទុក្ខ ដែលបង្កប់មកជាមួយនឹងសេចក្តីសប្បាយនោះទេ ។ ទិដ្ឋិធ្វើឲ្យប្រកាន់ជាប់ចិត្តដោយភាពងងឹត សំអាងទៅលើភូមិឋានជាតិកំណើត សក្តិអំណាចលើកតម្កើងខ្លួន ជាប់ចិត្តប្រកាន់ស្អិតក្នុងភពជាតិនៃខ្លួន មិនអាចងាកចេញឲ្យរួចផុត សូម្បីតែបានកើតដល់កំណើតព្រហ្មហើយ ក៏នៅតែជាប់ជំពាក់ចូលក្នុងអន្ទាក់អវិជ្ជា មិនអាចគេចឲ្យផុតបានដែរ ពីព្រោះ ភព , ជាតិ , កាមៈ , តណ្ហា ជានុយជាចំណីប្រលោមលួងលោម ឲ្យសត្វលោកត្រេកអររីករាយ ។ អវិជ្ជាទិដ្ឋិ ធ្វើឲ្យសត្វលោកវង្វេង ប្រកាន់ជាប់ជំពាក់មើលឃើញ ត្រឹមតែភពឋានជាតិកំណើតរបស់ខ្លួន ដោយការធន់ទ្រាំក្រសោបឱបយក សេចក្តីសុខដែលលាយឡំផ្សំដោយសេចក្តីទុក្ខ បង្កប់មកជាមួយនឹងជីវិតនេះ ដូចជាទឹកឃ្មុំដែលគេបន្លំលាយដោយថ្នាំពិស ដែលមានទាំងជាតិផ្អែមនិងជាតិពិសនៅជាមួយគ្នា ។

ព្រោះតែការស្រេកឃ្លាននិងចំណង់ ព្រមទាំងភាពវង្វេងមិនដឹង សត្វលោកបរិភោគទឹកឃ្មុំយ៉ាងសប្បាយ ឥតមានខ្វល់អំពីជាតិពុលអ្វីឡើយ យ៉ាងណាមិញ សត្តាកាលបើធ្វើនូវអំពើលាមកអាក្រក់ហើយ ក៏សប្បាយរីករាយនឹងអំពើអាក្រក់នោះ ។ ដោយ

សេចក្តីងងឹតល្ងង់ ដោយការប្រកាន់ទៅតាមការយល់ឃើញខុស មាន មានះឥតព្រមទទួលយល់សម្គាល់ទៅតាមហេតុផលពិត ធ្វើឲ្យជីវិតវិលវល់អន្ទោលទៅមករកផ្លូវចេញមិនផុតរត់មិនរួចអំពីភព។

សត្វលោកនៅត្រើយខាងអាយ មិនអាចសម្លឹងមើលឃើញទៅត្រើយខាងនាយបាន ដូចជាបុគ្គលដែលមានភ្នែកខ្វាក់ រមែងមិនអាចយល់ស្គាល់ពន្លឺថាជាយ៉ាងណាបាន ។ ដូច្នេះសូមព្យាយាមចេញពីទីងងឹត ឆ្ពោះទៅរកទីភ្លឺដោយការបតិបត្តិ ទៅតាមគោលធម៌ទាំងបួនប្រការមាន ៖ **សទ្ធា , វិរិយៈ , អប្បមាទ , បញ្ញា** ជាធម្មនាវាសម្រាប់ចម្លងសត្វលោក ឲ្យបានឆ្លងផុតអន្លង់ទាំងបួនដែលពោរពេញដោយសេចក្តីទុក្ខច្រើនប្រការ ។

សត្វលោកកាលបើគ្មានធម៌បួនប្រការនេះទេ រមែងដេកត្រាំលិចអណ្តែត ប្រកបដោយសេចក្តីវង្វេងងងឹត ពិតជាពុំអាចរកទិស ចេញទៅឲ្យផុតបានទេ ដូចជាបុគ្គលគ្មានការជឿបាបបុណ្យគុណទោស មានការយល់ឃើញខុសអំពីហេតុផល មិនព្រមទទួលស្គាល់ទៅតាមហេតុផលពិត ដោយគំនិតប្រកាន់តាមការយល់ចូលចិត្តខុស ជាអ្នកបង់បោះសេចក្តីព្យាយាម ប្រហែសធ្វេសភ្លាំងភ្លេចស្មារតី ប្រកបដោយសេចក្តីល្ងង់វង្វេង បុគ្គលពួកនេះពុំមែនគ្រាន់តែជាអ្នកពុំអាចបំពេញបុណ្យកុសលអ្វីកើតទេ ថែមទាំងឲ្យគេហ៊ានប្រព្រឹត្តអំពើបាប ប្រកបដោយចេតនាចិត្តឥតកោត

ញញើតទៀតផង ។ មិនចាំបាច់និយាយដល់ ភពខាងនាយឬភពថ្មីអ្វីទៀតនោះទេ គេអាចទទួលស្គាល់យល់ទៅតាមហេតុផលពិតដោយឥតប្រកែកបាន ដូចជានៅក្នុងគ្រួសារមួយ បើប្តីប្រពន្ធកូនមិនចុះសម្រុងគ្នា ដោយមានចិត្តមិនស្មោះត្រង់ ដូចជាប្តីក្បត់ចិត្តប្រពន្ធទៅលបលួចមានស្រីថ្មី , ប្រពន្ធប្រព្រឹត្តអបាយមុខ លេងល្បែងភ្នាល់ស៊ីសងធ្វើឲ្យខូចទ្រព្យសម្បត្តិ , ពោលពាក្យកុហកបោកប្រាសប្តី , កូនប្រុសស្រីឥតស្តាប់ដំបូន្មានឪពុកម្តាយ គិតតែពីការសប្បាយ , ចាយវាយឥតគិត , សេពគប់មិត្តពាលាអាវាសែ ។

ទាំងនេះសួរថាតើជាអំពើអាក្រក់ ឬជាអំពើល្អ ?

ចម្លើយមុខជានាំគ្នាឆ្លើយថា ជាអំពើអាក្រក់ហើយ ។ បើហេតុការណ៍អាក្រក់ហើយ ផលក៏ជាអាក្រក់ហើយដែរ ! ព្រោះធ្វើឲ្យក្តៅក្រហាយ ឈ្លោះទាស់ទែងលែងទុកចិត្តគ្នា បង្កើតជាពៀរវេរាផ្សេងៗ ។ បុគ្គលមិនស្គាល់មិនយល់ មិនជឿកម្មផលនៃបាបរមែងធ្វើនូវអំពើបាបដោយឥតកោតញញើត ដូចជាបុគ្គលមិនស្គាល់ថ្នាំពិស តែងផឹកថ្នាំពិសដោយចិត្តរីករាយ នៅទីបំផុតក៏បានទទួលផល គឺពុលនោះឯង ។

តាមពិតបាបបុណ្យគុណទោស ហេតុផលអាក្រក់ល្អកម្មសកម្មខ្មៅ មិនពិបាកយល់ទេគ្រាន់តែគេមិនទទួលស្គាល់ មិនព្រមយល់ចូលចិត្តទៅតាមសេចក្តីពិតប៉ុណ្ណោះ ព្រោះមានអវិជ្ជានិងទិដ្ឋិ

បិទបាំង មានជំនឿនិងការប្រកាន់យកខាងខុសទៅវិញ ។

ដូច្នេះដើម្បីឆ្លងឲ្យផុតអំពីភាពវង្វេង និងការយល់ឃើញខុស ប្រកាន់តាមខុស ត្រូវព្យាយាមបណ្តុះសទ្ធាព្រមទាំងបញ្ញាឲ្យចម្រើនមានជាលំដាប់ **សម្មាសទ្ធា** ការជឿចំត្រង់ទៅតាមហេតុផល យល់ច្បាស់អំពីបាបបុណ្យគុណទោស ពិតប្រាកដក្នុងចិត្ត រមែងកំចាត់បង់ការយល់ឃើញខុសឲ្យអស់ចេញ សេចក្តីព្យាយាមបំពេញកងការកុសល ក៏នឹងកើតមានឡើងជាលំដាប់ ។

ពាក្យថា **បុណ្យ , កុសល , គុណធម៌** គឺសេចក្តីល្អនេះហើយដែលសត្វលោកតែងប្រាថ្នា មានសេចក្តីត្រូវការជាចាំបាច់ ដូចជាការមិនបៀតបៀនធ្វើទុក្ខទោសដល់គ្នា មានទឹកចិត្តស្មោះត្រង់ ប្រកបដោយមេត្តាករុណាដល់គ្នា មានវាចាគួរជាទីស្រឡាញ់ពេញចិត្ត ពោលពាក្យដាស់តឿនក្រើនរំលឹកគ្នា ដោយវាចាជាគុណប្រយោជន៍ ចេះជួយរំលែកសេចក្តីទុក្ខ ចែកសេចក្តីសុខដល់គ្នា ទាំងនេះហើយហៅថាសេចក្តីល្អ គុណធម៌ ជាហេតុនាំមកនូវផល គឺសេចក្តីសុខមនោរម្យ ក្នុងសង្គមគ្រួសាររហូតដល់សង្គមលោក ។

លោកិយកុសលក្តី លោកុត្តរកុសលក្តី ដែលអាចកើតឡើងបាន ត្រូវមានសទ្ធាជាខាងដើម ជាពូជជាកម្លាំង ។ អ្នកបំពេញទានមាន សីល ចម្រើនភាវនា ជឿគុណព្រះរតនត្រ័យ

គោរពប្រតិបត្តិតាមឱវាទ របស់ព្រះសាស្ដាសម្មាសម្ពុទ្ធ ក៏ព្រោះមានសទ្ធាជាហេតុ ។ សទ្ធាតាំងមាំតាំងស៊ប់ប្រាកដហើយ សេចក្ដីព្យាយាមក៏កើតមានជាកម្លាំង កំចាត់ខ្មាំងគឺ **កាម** មិនឲ្យជំពាក់នៅក្នុងភពទាំងបី ដោយពឹងលើស្មារតី មិនធ្វេសប្រហែសមិនភ្លេចភ្លាំង មិនងងឹតវង្វេងព្រោះមានបញ្ញាជាពន្លឺ បំភ្លឺឲ្យមើលឃើញគោលដៅ បដិបត្តិត្រូវទៅតាមទិសនិងជាអាវុធកំចាត់បង់សត្រូវពោលគឺ **កិលេស** ។ មាន **កាមតណ្ហា , ទិដ្ឋិ , អវិជ្ជាភព** ដែលជាសត្រូវស្ទះផ្លូវ ធ្វើឲ្យដំណើរជីវិតប្រព្រឹត្តទៅ យឺតយូរនៅក្នុងភពទៀតផង ។

ធម៌ទាំងបួនប្រការគឺ ៖ **សទ្ធា , វិរិយៈ , អប្បមាទ , បញ្ញា** ជាគុណធម៌ដ៏ប្រសើរ ដែលមានចែងសម្ដែងក្នុង **ពោធិបក្ខិយធម៌ ៣៧** ប្រការមាន ៖ **សតិប្បដ្ឋានបួន , សម្មប្បធានបួន , ឥទ្ធិបាទបួន , ឥន្ទ្រិយប្រាំ , ពលៈប្រាំ , ពោជ្ឈង្គៈប្រាំពីរ , មគ្គមានអង្គប្រាំបី ។**

ដែលពោលថា **ពោធិបក្ខិយធម៌** នោះ ព្រោះជាធម៌ខាងផ្នែកត្រាស់ដឹង ដែលព្រះសម្ពុទ្ធបរមគ្រូ ព្រះអង្គបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ គឺព្រះប្រាជ្ញាជាគ្រឿងត្រាស់ដឹងព្រះអង្គឯងដោយប្រពៃនោះ គឺព្រះអង្គបានត្រាស់ដឹងនូវធម៌ទាំង ៣៧ ប្រការនេះឯង ដែលជាតួអនុត្តរសម្មាសម្ពោធិញ្ញាណ ជាអនសុតធម៌ ជាធម៌ដែលព្រះអង្គមិនធ្លាប់បានឮ បានស្ដាប់មកពី

ដើមឡើយ ស្រាប់តែប្រាកដឡើងដល់ព្រះអង្គជាគ្រាដំបូង ។ ធម៌ទាំង ៣៧ ប្រការនេះហើយ ដែលធ្វើព្រះអង្គបានទៅជាព្រះសម្មាសម្ពុទ្ធពិតប្រាកដ ។

ដូច្នេះធម៌ទាំងបួនប្រការមាន ៖ **សទ្ធា , វិរិយៈ , អប្បមាទ , បញ្ញា** ក៏មាននៅក្នុង **ពោធិបក្ខិយធម៌** នេះដែរ ។ **អប្បមាទ** មិនធ្វេសប្រហែសមានស្មារតីជានិច្ច ជាតួសតិចាត់ចូលក្នុង **សតិប្បដ្ឋានបួន** មានកាយានុបស្សនាសតិបដ្ឋានជាដើម ។ **វិរិយៈ** សេចក្តីព្យាយាម ចាត់ចូលក្នុង **បធានបួន** មានបហានបធាន ព្យាយាមលះអំពើបាបមិនឲ្យកើតមានជាដើមចាត់ចូលក្នុង **ឥទ្ធិបាទធម៌** មានវិរិយិទ្ធិបាទ ព្យាយាមញុំាងប្រយោជន៍ឲ្យសម្រេចជាដើម ។ **សទ្ធា , វិរិយៈ , សតិ , បញ្ញា** ប្រព្រឹត្តទៅព្រមជាមួយគ្នា ចាត់ចូលក្នុង **ឥន្ទ្រិយប្រាំ** ធម៌មានសភាពជាធំ ជាប្រធានក្នុងការ ញុំាងកុសលធម៌ដទៃ ឲ្យកើតឡើងបាន ចាត់ចូលក្នុង **ពលៈប្រាំ** ធម៌ជាកម្លាំងក្នុងការជម្រុញបង្កើន កុសលធម៌ទាំងឡាយទាំងពួង ដែលមិនទាន់កើតឲ្យកើតឡើងបាន និងឲ្យមានដំណើរប្រព្រឹត្តទៅជានិរន្តរ៍ផង ។ នៅក្នុង **ពោជ្ឈង្គៈ** និង **អរិយមគ្គ** ក៏មាន សតិ , វិរិយៈ , បញ្ញា ប្រកបរួមជាមួយដែរ ។

ដើម្បីចម្លងជីវិតឲ្យបានរួចផុត អំពីសមុទ្រទុក្ខដ៏សែនលំបាកនេះ លុះណាតែមានបញ្ញា ពិចារណាឲ្យឃើញអំពីសេចក្តីទុក្ខ

ដែលជាសភាវធម៌មានមកជាមួយជីវិតផង ។ ពិចារណាឃើញ សេចក្តីទុក្ខដែលកើតពី **កាមតណ្ហា** គឺសេចក្តីប្រាថ្នា , ចំណង់ , ការ ជាប់ជំពាក់ , កង្វះខាត , កម្ហាច , គម្លាន មានជាបញ្ហាមិនចេះចប់ ផង ។ យកពន្លឺ គឺបញ្ញាឆ្លុះបញ្ចាំងឲ្យឃើញទោសរបស់អវិជ្ជាទិដ្ឋិ មិនវង្វេងងប់ងល់ត្រេកត្រអាល នឹងភពដែលពោរពេញដោយ វត្ថុ កាម , កិលេសកាម ជាចំណី ជានុយបោកបញ្ឆោត លួងលោម បន្លំភ្នែកដែលមានទាំងសម្រែកសើចសប្បាយ ព្រមទាំងសំណោក សោកសៅ ក្តៅក្រហាយពុំមានទីបំផុត ។ **សទ្ធិន្ទ្រិយ , វិរិយិន្ទ្រិយ** សទ្ធាជាធំ សទ្ធាចាស់ក្លា ជាជំនួយដល់បញ្ញាក្នុងការបំបាក់បង់ អវិជ្ជាទិដ្ឋិ ។ **វិរិយៈ** សេចក្តីព្យាយាមជាធំ ជាប្រធានក្នុងការកំចាត់ បង់កាមតណ្ហា ជាអន្ទាក់ជាចំណងរបស់មច្ចុមារ ។ **សតិ** ការមិន ភ្លាំងភ្លាត់ភ្លេចស្មារតី មិនធ្វេសប្រហែស សម្លឹងឃើញទុក្ខទោស ក្នុងភព គួរឲ្យតក់ស្លុតភ័យខ្លាចមិនអាចសម្ងំនៅ រិះរកផ្លូវគេចឲ្យ ផុតរត់ចេញឲ្យរួច ដោយសេចក្តីមិនប្រមាទ ។

គុណធម៌ទាំងបួនប្រការនេះ **ជាពលៈធម៌ , ជាសហជាតធម៌** រួមចូលគ្នាជាកម្លាំងញ៉ាំងការបតិបត្តិកម្ចាត់ជម្រុះចោល អកុសល កិលេស មិនឲ្យចាក់ស្រេះ ហ៊ុមព័ទ្ធបិទបាំងចិត្តបាន ជាកម្លាំងរុញ ច្រានការបតិបត្តិ ឲ្យរឹងរិតតែខ្លាំងក្លាក្នុងការបំពេញគុណធម៌ ដើម្បី ចម្លងក្បួនជីវិតឲ្យមានដំណើរ ជាលំដាប់ក្នុងការចេញចាកភព ។

ក្នុងស្មារតីមិនភ្លាំងភ្លេច មិនធ្វេសប្រហែស ។

ព្រះសាស្ដាសម្មាសម្ពុទ្ធបរមគ្រូនៃយើង កាលនៅជាព្រះបរមពោធិសត្វ កំពុងបំពេញបារមីធម៌ ដើម្បីឲ្យបានសម្រេចសម្មាសម្ពោធិញ្ញាណ ព្រះអង្គតែងមានសេចក្ដីតក់ស្លុតរន្ធត់ភ័យអំពីសេចក្ដីទុក្ខទោស ដែលកើតមានព្រោះការជាប់ជំពាក់ ដោយវត្ថុកាម និងកិលេសកាម ។ ព្រះអង្គព្យាយាមរត់គេចចេញ ដោយព្រះបញ្ញាពិចារណាឃើញនូវកាម ថាជានុយ ជាចំណីសម្រាប់ល្បួងលោមចិត្តសត្វលោកឲ្យវង្វេង ឲ្យងងឹតធ្លាក់ចូលក្នុងអន្ទាក់របស់មារដែលមាន ៖ **ជរា, ព្យាធិ , មរណៈ** តាមយាយីបៀតបៀនទាំងយប់ថ្ងៃ មានភពទាំងបីជាទ្រុងឃាំងបិទបាំងទុក ធ្វើឲ្យសត្វលោកសម្លឹងទៅខាងមុខមិនបានឆ្ងាយ បានសុខសប្បាយលាយឡំដោយសេចក្ដីទុក្ខ ព្រោះអំណាច កុសលាអកុសលកម្ម ផ្លាស់ប្ដូរជាប្រចាំមិនចេះចប់ ។

អាស្រ័យហេតុនេះ ទើបព្រះអង្គព្យាយាមលះបង់ ដោយការតាំងចិត្តអំណត់ធន់តស៊ូយកជំនះនឹងឧបសគ្គ គ្រប់បែបយ៉ាង ដើម្បីសាងអត្តភាព[១]របស់ព្រះអង្គឲ្យរួចផុតចាកអន្ទាក់ចំណង ជាគ្រឿងចងឆ្នាក់ទាំងឡាយនោះ។ ដើម្បីបញ្ជាក់សេចក្ដីឲ្យបានច្បាស់

---

(១) អត្តភាព : ភាវៈរបស់ខ្លួន; ខ្លួនទាំងមូល; ធម្មតារបស់ខ្លួន; និស្ស័យនៃខ្លួន; អាត្មាភាព ។

ក្នុងការលះចេញចាកកាម ខ្ញុំព្រះករុណា ខ្ញុំបាទសូមលើកយកជីវប្បវត្តិ ព្រះបរមពោធិសត្វ កាលព្រះអង្គទ្រង់យោនយកកំណើតជា **តេមិយៈ** មានសម្ដែងក្នុង **សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសមភាគ** ( លេខ ៦២ ) មកសរសេរដោយសង្ខេប ដើម្បីបានពិចារណាពីដំណើរជីវិត ដែលប្រព្រឹត្តទៅក្នុងសង្សារវដ្ត ដូចតទៅនេះ ។



# តេមិយជាតក

កាលដែលព្រះបរមសាស្តាសម្មាសម្ពុទ្ធ នៅជាព្រះបរមពោធិសត្វ បានយោនយកកំណើតជាព្រះរាជបុត្ររបស់ព្រះបាទ **កាសិកៈ** ទ្រង់ព្រះនាម **តេមិយៈ** ។ កាលប្រសូតមកនៅជាព្រះរាជកុមារ ទ្រង់រំឭកជាតិបាន ។ ព្រះមហាសត្វ បានរំឭកឃើញជាតិរបស់ព្រះអង្គ កាលពីដើមធ្លាប់បានកើតជាព្រះរាជាមួយអង្គសោយរាជ្យក្នុងនគរនេះឯង បានត្រឹមតែម្ភៃឆ្នាំ ដោយអំពើបាបកម្មលុះសោយទីវង្គតទៅ បានធ្លាក់ទៅសោយទុក្ខក្នុងឋាននរកអស់ប្រាំបីម៉ឺនឆ្នាំ ។ ថ្ងៃមួយព្រះរាជបិតា ដាក់រាជកុមារឲ្យអង្គុយលើព្រះឧរុ ហើយទ្រង់វិនិច្ឆ័យក្តីថា ៖

" *អ្នកទាំងឡាយចូរសម្លាប់ចោរម្នាក់នេះ ! ចូរចងចោរម្នាក់នេះ ហើយយកទឹកក្បុងមកប្រឡាក់ រួចយកទៅដោតដោយឈើស្រួច* " ។

ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ ។

ព្រះមហាសត្វ គ្រាន់តែស្តាប់វាចាដ៏អាក្រក់របស់ព្រះបិតាដូច្នេះ មានការភ័យរន្ធត់តក់ស្លុតញាប់ញ័រក្នុងព្រះចិន្តាគិតថា ៖

" *អាត្មាអញធំពេញវ័យកាលណា រាជសម្បត្តិនេះនឹងធ្លាក់មកលើអាត្មាអញ ម្ល៉ោះហើយការធ្វើនូវអំពើបាបទាំងឡាយនឹង*

*មានដល់អាត្មាអញ ផលនៃបាបនឹងនាំឲ្យធ្លាក់ទៅសោយទុក្ខក្នុងនរកទៀត ពុំអាចគេចរួចឡើយ "* ។

ព្រះរាជកុមារមានព្រះរាជតម្រិះដូច្នេះហើយ ទ្រង់មានព្រះទ័យក្តុកក្តួលខ្លាំងណាស់ ។ កាលនោះ មានទេវតាពោលទូលព្រះអង្គថា ៖

*" អ្នកកុំប្រកាសភាពជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួងដឹងថាជាមនុស្សល្ងង់ ជនទាំងអស់ចូរមើលងាយចុះ សេចក្តីចម្រើននឹងមានដល់អ្នកដោយវិធីយ៉ាងនេះ " ។*

ព្រះមហាសត្វទ្រង់ត្រាស់ថា ៖

*" បពិត្រទេវតា ! អ្នកនិយាយពាក្យណានឹងខ្ញុំ ៗ នឹងតាមពាក្យរបស់អ្នកនោះ ។ បពិត្រទេវតា ! អ្នកឈ្មោះថាប្រាថ្នានូវសេចក្តីចម្រើនដល់ខ្ញុំ ។ បពិត្រទេវតា ! អ្នកឈ្មោះថាប្រាថ្នាប្រយោជន៍ដល់ខ្ញុំ " ។*

ក្រោយពីបានស្តាប់ពាក្យទេវតា ព្រះមហាសត្វទ្រង់មិនពោលស្តីមានអាការៈដូចជាមនុស្សគ ថ្លង់ ខ្វិន មិនកម្រើកដៃជើងរហូតដល់ធំពេញវ័យ ព្រះរាជបិតារកវិធីពិសោធន៍ដោយប្រការផ្សេងៗ ក៏មិនស្តីមិននិយាយ ។ ព្រះមាតាបិតាជឿជាក់ថា ព្រះរាជកុមារជាមនុស្សគ ថ្លង់ ខ្វិន ពិការពិតប្រាកដមែន ។

ព្រះបាទ **កាសិកៈ** មានព្រះទ័យថ្នាំងថ្នាក់អាក់អន់ពន់ពេក ក៏បញ្ជាឲ្យនាយសារថីបរព្រះរាជរថ យកព្រះរាជកុមារទៅធ្វើគុត

ដោយឲ្យជីករណ្ដៅកប់ទាំងរស់ ។ ប៉ុន្តែមុននឹងយកទៅធ្វើគុត បានអភិសេកព្រះរាជកុមារ ឲ្យគ្រងរាជ្យប្រាំពីរថ្ងៃ បន្ទាប់មកទើបឲ្យនាយសារថីនាំចេញទៅ ។

លុះទៅដល់ក្នុងព្រៃ នាយសារថីឈប់រថហើយ ទើបប្រញាប់ទៅជីករណ្ដៅ ដើម្បីកប់ព្រះរាជកុមារទាំងរស់ តាមបញ្ជាព្រះរាជបិតា ដោយប្រកាន់ថាព្រះរាជបុត្រជាមនុស្សចង្រៃឧត្បាត ។

ក្នុងពេលនាយសារថីកំពុងជីករណ្ដៅ ព្រះមហាសត្វបានក្រោកចេញអំពីរថហើយ ទើបស្រែកសួរទៅកាន់នាយសារថីថា ៖

*" នែ៎នាយសារថី ! អ្នកប្រញាប់ប្រញាល់ជីករណ្ដៅ តើព្រោះហេតុអ្វី ម្នាលសម្លាញ់ ! អ្នកដែលខ្ញុំសួរហើយចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្ដៅ ?" ។*

នាយសារថីពោលតប ព្រះមហាសត្វថា ៖

*" ព្រះរាជបុត្រកើតមកហើយ គផង , ខ្វិនផង , ដូចជាឥតចិត្ត ឯខ្ញុំនោះព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកចូរជីកកប់កូនអញក្នុងព្រៃចុះ !" ។*

ព្រះមហាសត្វទ្រង់ពោលតបទៅកាន់នាយសារថីវិញថា ៖

*" ខ្ញុំមិនថ្លង់ , មិនគ , មិនខ្វិន , មិនមែនវិកលវិការទេ ។ នែ៎នាយសារថី ! បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ ។ អ្នកចូរមើលភ្លៅនិងដើមដៃខ្ញុំ ទាំងចូរស្ដាប់សម្ដីខ្ញុំ នែ៎នាយសារថី ! បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ " ។*

នាយសារថីក៏សួរទៅកាន់ព្រះមហាសត្វវិញថា ៖

*" អ្នកជា ទេវតា , ជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ , អ្នកជាអ្វី , ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបាន ដោយប្រការដូចម្តេច ? " ។*

ព្រះមហាសត្វទ្រង់ពោលតបទៅកាន់នាយសារថីវិញថា ៖

*" ខ្ញុំមិនមែនជាទេវតា , មិនមែនជាគន្ធព្វ , មិនមែនជាបុរិន្ទទសក្កទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្តៅ បុគ្គលនោះ គឺខ្ញុំជាកូនរបស់ព្រះបាទកាសិកៈ អ្នករស់នៅដោយស្រួលព្រោះអាស្រ័យនូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ ។ នែ៎នាយសារថី ! បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ ។ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះជាអ្នកទ្រុស្តមិត្រ ជាមនុស្សលាមក ។ នែ៎នាយសារថី ! ព្រះរាជាទុកដូចជាដើមឈើ ខ្លួនខ្ញុំក៏ទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចជាបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើដូច្នេះ ។ នែ៎នាយសារថី ! បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌" ។*

នាយសារថី ក្រោយពីបានស្តាប់ព្រះសូរសៀង ដ៏សែនពីរោះរបស់ព្រះមហាសត្វ ដែលបានទូន្មានប្រកបដោយអត្ថន័យមានខ្លឹមសារពីរោះក្បោះក្បាយ ក៏មានសេចក្តីរីករាយសប្បាយក្នុងចិត្តគិតថា ៖ *" បើអញនាំព្រះរាជបុត្រត្រឡប់ចូលទៅកាន់នគរវិញ ប្រាកដជាបានរង្វាន់ច្រើនមិនខាន "* ។ គិតដូច្នេះហើយទើបពោល

ទៅកាន់ព្រះមហាសត្វថា ៖

*" បពិត្រព្រះរាជបុត្រ ! សូមទ្រង់ស្ដេចមក ទូលបង្គំជាខ្ញុំនឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះ សេចក្ដីចម្រើននឹងមានដល់ទ្រង់ ៗ នឹងធ្វើអ្វីក្នុងព្រៃ" ។*

ព្រះមហាសត្វក៏ពោលទៅកាន់នាយសារថីថា ៖

*" នែ៎នាយសារថី ! រាជសម្បត្តិណាដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ឬដោយជនជាញាតិ ឬក៏ដោយទ្រព្យទេ" ។*

*" ខ្ញុំដែលព្រះបិតាមាតា អ្នកដែន អ្នកនិគម និងពួករាជកុមារទាំងពួង បានលះបង់ចោលហើយ ផ្ទះរបស់ខ្លួនខ្ញុំមិនមានទេ ខ្ញុំដែលព្រះមាតាបានអនុញ្ញាតឲ្យទទួលរាជ្យប្រាំពីរថ្ងៃហើយ ខ្ញុំដែលព្រះបិតាលះចោលស្រឡះហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ ។ សេចក្ដីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ (អស់ ១៦ ឆ្នាំ) ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែ៎នាយសារថី ! អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយនឹងមានភ័យអំពីណា !" ។*

នាយសារថី ក្រោយពីបានស្ដាប់ព្រះសូរសីហនាទ ដ៏ពីរោះក្បោះក្បាយរបស់ព្រះមហាសត្វហើយ ទើបក្រាបបង្គំទូលសូម

សាងផ្នួសនៅក្នុងព្រៃនោះដែរ ។ តែព្រះមហាសត្វបានប្រាប់ឲ្យត្រឡប់មកកាន់នគរ យករថទៅប្រគល់ថ្វាយដល់ព្រះបិតា ព្រមទាំងទូលដំណឹងសព្វគ្រប់ប្រការ ថ្វាយព្រះមាតាបិតាឲ្យបានជ្រាបហើយសូមឲ្យត្រឡប់មកវិញ ។

នាយសារថី បានទូលបញ្ជាក់ព្រះមហាសត្វថា ៖

" *សេចក្ដីចម្រើនចូរមានដល់ទ្រង់ ពាក្យណាដែលទ្រង់បានថ្លែងហើយ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើតាមពាក្យនោះ ទ្រង់ដែលទូលព្រះបង្គំអង្វរហើយ គួរធ្វើតាមពាក្យទូលព្រះបង្គំជាខ្ញុំនោះផង ។ សូមទ្រង់ស្ដេចគង់នៅក្នុងទីនេះ ដរាបដល់ទូលព្រះបង្គំជាខ្ញុំនាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ទតឃើញហើយ សមជាមានព្រះរាជហឫទ័យត្រេកអររីករាយ* " ។

ព្រះមហាសត្វក៏ពោលទៅកាន់នាយសារថីថា ៖

" *នែ៎នាយសារថី ! អ្នកនិយាយពាក្យណានឹងខ្ញុំៗ នឹងធ្វើតាមពាក្យរបស់អ្នកនោះ ។ ឯខ្ញុំក៏មានបំណងដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្ដេចយាងមកក្នុងទីនេះដែរ* " ។

" *ម្នាលសម្លាញ់ ! អ្នកទៅហើយ ចូរមកវិញ ចូរត្រឡប់ទៅសិនចុះ អ្នកប្រាប់នូវសេចក្ដីសុខដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយ គប្បីក្រាបទូលនូវការថ្វាយបង្គំចំពោះព្រះមាតាបិតា* " ។

នាយសារថី ចាប់ព្រះបាទានៃព្រះមហាសត្វនោះ ហើយក៏ធ្វើប្រទក្សិណព្រះមហាសត្វរួចឡើងជិះរថ បរចូលទៅកាន់រាជ

ទ្វារ យកដំណឹងទៅទូលថ្វាយព្រះមាតាបិតា , ទ្រង់បានជ្រាបសព្វសេចក្តី មានព្រះរាជហឫទ័យរំភើបត្រេកអរឥតឧបមា ។

ព្រះបាទកាសិកៈ បានទ្រង់ជ្រាបថា ព្រះរាជបុត្រមានព្រះកាយសមសួន បរិបូណ៌ដោយសម្បទាគ្រប់យ៉ាង ទាំងមានព្រះវាចាពីរោះក្បោះក្បាយដូច្នេះ ព្រះរាជាឥតមានរារង់បង្អង់ឲ្យខាតវេលាឡើយ បានបញ្ជាឲ្យពួកទាហាន សេនាអាមាត្រ នាយសារថី ពួកមន្ត្រីស្រីស្នំរាជកុមារ និងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ មានពួកហ្មដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង ចូរប្រញាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង ។

បន្ទាប់ពីការចាត់ចែងរៀបរាជរថ ទឹមដោយសេះមានកម្លាំងមានល្បឿនសន្ទុះលឿន ទាំងពលដំរីពលថ្មើរជើង ពួកសេនាទាហាន មន្ត្រីស្រីស្នំ ប្រដាប់ដោយគ្រឿងអលង្ការ តាក់តែងកាយាយ៉ាងប្រណីតរួចស្រេចហើយ ព្រះរាជាបានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្តេចយាងទៅ **តេមិយកុមារ** នៅក្នុងទីណាក៏យាងទៅក្នុងទីនោះយ៉ាងឆាប់ ។

**តេមិយៈ** ទតឃើញព្រះបិតានោះ កំពុងស្តេចយាងមកហាក់ដូចជារុងរឿងដោយតេជៈ ដែលពួកអាមាត្រអ្នកកាន់ព្រះខាន់ហែហមហើយ ។ ទើបត្រាស់សួរព្រះបិតាថា ៖

*"បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ ? បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះអាពាធទេឬ ? រាជកញ្ញាទាំង*

*អស់ជាព្រះមាតារបស់ខ្ញុំ មិនមានរោគទេឬ ?"* ។

ព្រះវរបិតាមានព្រះរាជបន្ទូលតបថា ៖

" *នែ៎កូន ! ខ្ញុំសុខសប្បាយទេ ខ្ញុំមិនមានជម្ងឺតម្កាត់ទេ រាជកញ្ញាទាំងអស់ជាមាតារបស់អ្នក មិនមានរោគទេ "* ។

រួចហើយព្រះមហាសត្វក៏ពោលទៀតថា ៖

" *បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ ? សុរាមិនពេញព្រះទ័យរបស់ព្រះអង្គទេឬ ? ព្រះទ័យរបស់ព្រះអង្គត្រេកអរ ក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទាន ដែរឬទេ ?"* ។

ព្រះវរបិតាមានព្រះបន្ទូលទៅកាន់ព្រះមហាសត្វវិញ ៖

" *នែ៎កូន ! ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀតសុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំតែងត្រេកអរ ក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទាន "* ។

ក្រោយពីបានសំណេះសំណាល សួរសុខទុក្ខជាច្រើនប្រការរវាង ព្រះវរបិតានិងព្រះរាជបុត្រមក ព្រះមហាសត្វក៏មានព្រះបន្ទូលទៅកាន់ព្រះវរបិតាថា ៖

" *បពិត្រមហារាជ ! ព្រះអង្គយាងមកល្អហើយ មួយទៀតព្រះអង្គស្ដេចយាងមកមិនមែនអាក្រក់ទេ រាជបុរស ! ចូររៀបចំបល្ល័ង្ក ជាទីគង់របស់ព្រះរាជា "* ។

" *ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតាំងហើយ សូមព្រះអង្គយកទឹកអំពីទីនេះលាងព្រះបាទារបស់ព្រះអង្គចុះ !"* ។

" *បពិត្រព្រះរាជា ! ស្លឹកនោះដែលអាត្មាភាពចំអិនហើយ ជារបស់មិនមានរសប្រៃ ។ បពិត្រមហារាជ សូមព្រះអង្គស្ដេចសោយចុះ ព្រះអង្គទើបស្ដេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព* " ។

ព្រះវរបិតា មានបន្ទូលតបទៅ ព្រះមហាសត្វវិញថា ៖

" *ខ្ញុំមិនបរិភោគស្លឹកនោះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ៗ បរិភោគតែបាយនៃស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត* " ។

" *សេចក្ដីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញលោកនៅស្ងាត់តែម្នាក់ឯង កាលលោកបរិភោគភោជនបែបនេះ សម្បុរនៅតែស្រស់ថ្លាដោយហេតុដូចម្ដេច ?* " ។

ព្រះមហាសត្វទូលតបព្រះវរបិតាដូច្នេះថា ៖

" *បពិត្រព្រះរាជា ! អាត្មាភាព ម្នាក់ឯងសឹងលើកម្រាលស្លឹកដែលតាំងទុកហើយ ។ បពិត្រព្រះរាជា ! វណ្ណៈរបស់អាត្មាភាពស្រស់ថ្លា ដោយដំណេករបស់ម្នាក់ឯងនោះ ។ ពួកអ្នករក្សាព្រះរាជាដែលសៀតព្រះខាន់ មិនប្រាកដដល់អាត្មាភាពទេ ។ បពិត្រព្រះរាជា ! វណ្ណៈរបស់អាត្មាភាពស្រស់ថ្លាដោយដំណេកម្នាក់ឯងនោះ ។ អាត្មាភាព មិនតាមសោក និងអារម្មណ៍ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលលើកឡើងចំពោះមុខ ហេតុ*

*នោះបានជាវណ្ណៈរបស់អាត្មាភាពរមែងស្រស់ថ្លា ។ ជនពាលទាំងឡាយតែងរីងស្ងួត ព្រោះសេចក្តីប្រាថ្នាអារម្មណ៍ ដែលមិនទាន់មកដល់ ព្រោះសេចក្តីតាមសោកស្តាយអារម្មណ៍ដែលកន្លងទៅហើយនេះ ដូចជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃដូច្នោះ ” ។*

ព្រះវរបិតាក៏មានព្រះបន្ទូលទៅព្រះរាជបុត្រវិញថា ៖

*" នែ៎កូន ! ខ្ញុំនឹងឲ្យនូវពលដំរី , ពលរថ , ពលសេះ , ពលថ្មើរជើង , ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយជាទីត្រេកអរដល់អ្នក ។ មួយវិញទៀត ខ្ញុំឲ្យនូវស្រីស្នំ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក , នែ៎កូន ! ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង ។ ស្ត្រីរបាំ ជាអ្នកឈ្លាសក្នុងការរាំនិងច្រៀង បានសិក្សា ( ក្នុងកិច្ចស្ត្រី ) ញុំាងអ្នកឲ្យត្រេកអរក្នុងកាម ។ អ្នកនឹងធ្វើអ្វីក្នុងព្រៃ ខ្ញុំនឹងនាំយករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក ៗ ចូរញុំាងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះ ហើយសឹមបួសក្នុងកាលជាខាងក្រោយ ។ អ្នកនៅក្មេងកម្លោះប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ ” ។*

ព្រះមហាសត្វមានបន្ទូលថា ៖

*" បុគ្គលនៅកម្លោះគប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នក*

*ប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅកម្លោះ នេះពួកឥសីទាំងឡាយសរសើរហើយ ។ បុគ្គលនៅកម្លោះគប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅកម្លោះ អាត្មាភាព នឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាព មិនត្រូវការដោយរាជ្យទេ ។ បពិត្រព្រះមាតានិងបិតា អាត្មាភាព ឃើញនរជននៅក្មេង ទើបនឹងចេះនិយាយ ជាកូនជាទីស្រឡាញ់ ដែលមាតាបិតាបានដោយលំបាក មិនទាន់ចាស់គ្រាំគ្រាហើយស្លាប់ ។ អាត្មាភាព ឃើញនាងកុមារីមានសម្បុរដូចមាស ដែលមច្ចុរាជ ចាប់ដកក្បាលជីវិតហើយ ដូចជាដកនូវទំពាំងឫស្សីដ៏ខ្ចី ។ នរជនទាំងឡាយ ឬនាងនារីទាំងឡាយ សូម្បីនៅក្មេងក៏តែងស្លាប់ តើសត្វណាគប្បីទុកចិត្តក្នុងជីវិតនោះថា អាត្មាអញនៅក្មេងដូច្នេះ អាយុនៃកុមារណាមានប្រមាណតិច ដោយការកន្លងទៅនៃយប់និងថ្ងៃ ភាពនៃខ្លួនជាកុមារក្នុងវ័យនោះ នឹងធ្វើដូចម្តេចកើត ដូចទីមានទឹកតិចរបស់ត្រីទាំងឡាយ ។ សត្វលោក ត្រូវសត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរិតជានិច្ចផង កាលយប់និងថ្ងៃទាំងឡាយ មិនកន្លងទៅទទេ តើព្រះអង្គនឹងអភិសេកអាត្មាភាពក្នុងរាជ្យដូចម្តេច ?" ។*

ព្រះរាជាទ្រង់មានចម្ងល់ក៏ទូលសួរព្រះមហាសត្វ ៖

*"សត្វលោកនេះ ត្រូវសត្រូវអ្វីបៀតបៀនផង ត្រូវសត្រូវអ្វីរួបរិតផង ធម្មជាតិដូចម្តេចមិនកន្លងទៅទទេ ខ្ញុំសួរហើយ ចូរអ្នកប្រាប់នូវដំណើរនោះ ?" ។*

ព្រះមហាសត្វក៏មានព្រះបន្ទូលតទៅទៀតថា ៖

" *សត្វលោកត្រូវមច្ចុបៀតបៀនផង ត្រូវជរារួបរឹតផង រាត្រីទាំងឡាយរមែងមិនកន្លងទៅទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ* " ។

" *កាលតម្បាញដែលបុគ្គលត្បាញរបស់ណាៗ ដែលបុគ្គលនឹងត្បាញ របស់ដែលត្រូវត្បាញ ( នោះៗ ) ជារបស់នៅសល់តិចយ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញ កាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅមិនត្រឡប់វិញយ៉ាងនោះដែរ ។ ផ្លូវទឹកដ៏ពេញ គប្បីបន្សាត់ទៅនូវដើមឈើទាំងឡាយដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ត្រូវជរានិងមរណៈ បន្សាត់ទៅក៏យ៉ាងនោះដែរ* " ។

ព្រះវរបិតា ៖

" *នែ៎កូន ! ខ្ញុំនឹងឲ្យឃ្លាំងជង្រុក , វាហនៈ , ពល និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក ។ អ្នកដែលក្រុមនៃរាជកញ្ញា មានចំណែកដ៏ល្អចោមរោមហើយ មានពួកនៃខ្ញុំស្ត្រីបែហាមហើយ ចូរសោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ* " ។

ព្រះមហាសត្វ ៖

" *ប្រយោជន៍អ្វីដោយទ្រព្យដល់អាត្មាភាព ព្រោះទ្រព្យតែង*

*អស់ទៅ ប្រយោជន៍អ្វីដោយភរិយា ព្រោះភរិយាក៏គង់ស្លាប់ ប្រយោជន៍អ្វីដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្ដីត្រេកអរអ្វី, ការលេងសើចអ្វី , ការរីករាយអ្វី , ការស្វែងរកទ្រព្យអ្វី , អាត្មាភាពត្រូវការអ្វីដោយកូននិងប្រពន្ធ ” ។*

*" បពិត្រព្រះរាជា ! អាត្មាភាពផុតស្រឡះចាកចំណងហើយ អាត្មាភាពដឹងច្បាស់នេះថា ៖ មច្ចុមិនធ្វេសប្រហែសចំពោះអញឡើយ អាត្មាភាពនោះ ត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្ដីត្រេកអរដូចម្ដេច ការស្វែងរកទ្រព្យដូចម្ដេចទៀត ។ ផ្លែឈើទុំទាំងឡាយ តែងមានការភិតភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយកើតមកហើយ តែងមានភ័យអំពីសេចក្ដីស្លាប់ ជានិច្ចយ៉ាងនោះដែរ ” ។*

*" ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក ។ សេចក្ដីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណាគប្បីដឹងថាសេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក ដ្បិតការបណ្ដោះបណ្ដែអំពីសេចក្ដីស្លាប់ ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ ។ ពួកចោរទាំងឡាយ តែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា ! សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះបាទទ័យទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ ” ។*

កាលបើបានពិចារណា ទៅតាមដំណើរប្រវត្តិជីវិត របស់ព្រះបរមពោធិសត្វយ៉ាងនេះហើយ បញ្ជាក់ឲ្យបានយល់ច្បាស់ថា ជីវិតសត្តាក្នុងសង្សារវដ្តនេះ ប្រកបដោយបញ្ហានាំនូវសេចក្តីទុក្ខច្រើនប្រការ រស់នៅក្នុងរង្វង់សត្រូវ ពោលគឺ **ខន្ធមារ , កិលេស-មារ , មច្ចុមារ** តាមបៀតបៀនយាយីទាំងយប់ថ្ងៃ ធ្វើឲ្យសត្វលោកស្លុតភ័យ ស្ទុះរត់ទៅមកនៅក្នុងអន្លង់ភព មិនអាចនឹងរកផ្លូវចេញឲ្យរួចទៅបាន ។

ដើម្បីរត់ឆ្លងកន្លងឲ្យផុតពីអន្លង់ ត្រូវមានចិត្តសង្វេគតក់ស្លុតភ័យ សម្លឹងឃើញទុក្ខទោសនៃជីវិតដែលកំពុងប្រព្រឹត្តទៅនៅក្នុងសង្សារវដ្តនេះ ព្យាយាមលះបង់ផ្តាច់ផ្តិល ចំណង ចំណីនុយ កាមគុណ រត់ចេញអំពីទីងងឹតពោលគឺ **មិច្ឆាទិដ្ឋិ** ទៅរកពន្លឺគឺ **ការបណ្តុះសទ្ធា** ជឿជាក់ពិតប្រាកដចំពោះកម្មផល តម្កល់ស្មារតីយប់ថ្ងៃព្យាយាម បិទបាំងរាំងមិនឲ្យបាបអកុសល កើតមានក្នុងសន្តាន ព្យាយាមលះបាបចាស់ដែលកើតមានមកហើយឲ្យអស់ទៅបន្តិចម្តងៗ ព្យាយាមបំពេញកុសលឲ្យកើតមានជាលំដាប់ តាំងចិត្តរក្សាកុសលដែលកើតមានហើយ មិនឲ្យសាបសូន្យបាត់បង់ទៅវិញ បំពេញបង្កើនបញ្ញាជាអាវុធ សម្រាប់កាប់ឆ្ការ **អវិជ្ជា** ឲ្យអស់ទៅ ធ្វើដំណើរចេញពីត្រើយខាងអាយ ឆ្ពោះទៅកាន់ត្រើយខាងនាយចំទិសដៅ ដោយមានពន្លឺគឺ **បញ្ញា** ញ៉ាំងជីវិត

ឲ្យប្រព្រឹត្តទៅតាមដំណើរ **ពោធិបក្ខិយធម៌** ជាធម៌របស់ព្រះសាស្ដាសម្មាសម្ពុទ្ធ ដែលជាមាគ៌ាដ៏បរិសុទ្ធទាំងប្រាំបីប្រការ ហៅថា **អរិយមគ្គ** ជាផ្លូវដ៏ប្រសើរ **សម្មាមគ្គ** ជាផ្លូវត្រឹមត្រូវ ជាគូបដិបក្ខនឹង **មិច្ឆាមគ្គ** ផ្លូវវៀច , ផ្លូវខុស , មិនត្រឹមត្រូវ **មជ្ឈិមាបដិ-បទា** ការបដិបត្តិតាមមាគ៌ាកណ្ដាល ដែលនៅក្នុងចន្លោះ **អត្តកិលមថានុយោគ** ការបដិបត្តិតឹងហួសហេតុពេក ធ្វើបាបខ្លួនឯងឥតបានប្រយោជន៍ ដូចជាខ្សែទ្រចាប៉ី ដែលរឹតតឹងពេកនាំឲ្យដាច់ **កាមសុខល្លិកានុយោគ** ការបដិបត្តិធូរពេក ដោយការរស់នៅច្របូកច្របល់ជាប់ជំពាក់ជាមួយ វត្ថុកាមនិងកិលេសកាម ដូចជាខ្សែទ្រចាប៉ី ធូរពេកនាំឲ្យមានសម្លេងមិនពីរោះ ឬដូចជាដើមឈើនៅស្រស់ កាលបើបុរសត្រូវការភ្លើង មិនអាចយកមកសង្កួតឲ្យចេញជាភ្លើងបានឡើយ ។

ការបដិបត្តិតាមហេតុទាំងពីរប្រការនេះ ព្រះសក្យមុនីព្រះអង្គបានសាកល្បងពិសោធរួចមកហើយ ឃើញថាគ្មានផល នាំឲ្យមានការនឿយហត់ឥតប្រយោជន៍ ទើបព្រះអង្គបានរកមាគ៌ាថ្មីមួយ ឃើញថាជាមាគ៌ាកណ្ដាល ហៅថា **អដ្ឋង្គិកមគ្គ** ជាផ្លូវប្រកបដោយអង្គប្រាំបីប្រការមាន ៖

**១. សម្មាទិដ្ឋិ** ការយល់ត្រូវ ;

**២. សម្មាសង្កប្ប** គំនិតត្រិះរិះត្រូវ ;

**៣. សម្មាវាចា** សម្ដីនិយាយត្រូវ ;
**៤. សម្មាកម្មន្ត** ការងារត្រូវ ;
**៥. សម្មាអាជីវៈ** ចិញ្ចឹមជីវិតត្រូវ ;
**៦. សម្មាវាយាមៈ** ព្យាយាមត្រូវ ;
**៧. សម្មាសតិ** រឭកត្រូវ ;
**៨. សម្មាសមាធិ** តំកល់ចិត្តត្រូវ ។

**មគ្គ** ប្រកបដោយអង្គប្រាំបីប្រការនេះ ការយល់ឃើញត្រូវជាតួបញ្ញា ការត្រិះរិះពិចារណាត្រូវជាតួបញ្ញា ចាត់ថាជាខាងដើមនៃផ្លូវ សម្រាប់ដើរឲ្យត្រង់ទិសដៅ ទៅដល់ឃើញនូវអរិយសច្ចធម៌ ជាធម៌ពិតប្រាកដកំណត់ឆ្លុះបញ្ចាំង អំពីសភាពជីវិតឋិតនៅដោយហេតុបច្ច័យ ។

**ជីវិត** ពិតជាប្រកបដោយហេតុបច្ច័យ ដែលប្រកបដោយសេចក្ដីទុក្ខជាអនេកប្រការ មិនមានទីបញ្ចប់ ដូច្នេះមានតែម្ចាស់ជីវិត គឺខ្លួនយើងម្នាក់ៗ ជាសម្មតិវោហារ ជាអវិជ្ជមានបញ្ញត្តិត្រូវព្យាយាមខំរចនាច្នៃ ចម្លងក្បួនជីវិតឲ្យប្រព្រឹត្តទៅមុខជាលំដាប់ ធ្វើដំណើរចេញពីត្រើយខាងអាយ ឆ្ពោះទៅកាន់ត្រើយខាងនាយ ដោយសេចក្ដីព្យាយាម មានស្មារតីមិនធ្វេសប្រហែស ។

ពិតមែនហើយជីវិតបច្ចុប្បន្ន ទោះបីជាម្ចាស់ជីវិតដឹងយល់

ទទួលស្គាល់ថា ជាខន្ធមារនាំមកនូវសេចក្តីសុខបន្តិចលាយដោយសេចក្តីទុក្ខ ឬក៏មិនព្រមយល់ទទួលស្គាល់ថា ជាសភាពដូច្នោះក៏ដោយ ក៏ជីវិតបច្ចុប្បន្ននេះ ទុកដូចជាក្បូនចាស់ ដែលម្ចាស់ជីវិតកំពុងជិះ កំពុងតែប្រកៀកប្រកើយនៅជាមួយគ្នា ទោះបីជាម្ចាស់មិនពេញចិត្តក្តី ឬពេញចិត្តគិតឲ្យតម្លៃលើកកម្ពស់យ៉ាងណាក៏ដោយ ក៏ក្បូនជីវិតនេះចេះតែគ្រាំគ្រាទ្រុឌទ្រោមទៅតាមកាលវេលា បើយ៉ាងនេះ កាលក្បូនជីវិតមិនទាន់បែកធ្លាយនៅឡើយ សូមកុំបណ្តោយឲ្យជីវិតនេះ ឋិតនៅក្នុងសភាពងងឹតឲ្យសោះគឺ **មិច្ឆាទិដ្ឋិ** សេចក្តីយល់ខុសអំពីហេតុផល ។ តម្កល់ជីវិតឲ្យឋិតនៅក្នុងពន្លឺគឺ **បញ្ញា** មានស្មារតីព្យាយាមបណ្តុះពូជគឺ **សទ្ធា** ចម្លងក្បូនជីវិតឲ្យប្រព្រឹត្តទៅតាម មគ្គប្រកបទៅដោយអង្គប្រាំបីប្រការ ។ ជីវិតចាស់មាននៅ ត្រូវធ្វើជំនួញជួញយក **គុណធម៌** ។ ពេលក្បូនជីវិតចាស់បែកធ្លាយ រលត់រលាយទៅឥតមានសល់នៅអ្វី សូម្បីតែបន្តិចបន្តួចឡើយ មានតែ **គុណធម៌** នេះហើយ ដែលជាសំណៅសំណាម បន្សល់ពីជីវិតចាស់ ជាកម្មបច្ច័យតាក់តែងសាងជីវិតថ្មី ដែលហៅថា **វិបាកបដិសន្ធិ** ប្រៀបដូចក្បូនចាស់បាក់បែកប្រើការលែងកើត គេត្រូវសាងក្បូនថ្មីដើម្បីឲ្យបានឆ្លងទៅមុខ ឲ្យបានមួយដំណាក់កាល ៗ គឺមួយជាតិ ៗ មិនប្រមាទបណ្តោយស្មារតី ឲ្យឃ្លាតចេញពី **គុណធម៌** ។

**គុណធម៌** គឺសេចក្ដីល្អនេះហើយ ជាកម្លាំងរុញច្រានក្បូនជីវិត ឲ្យរំកិលចេញពីត្រើយខាងអាយឆ្ពោះ ទៅកាន់ត្រើយខាងនាយ ។ ដូច្នេះត្រូវព្យាយាមរត់គេចពីទីងងឹត ចេញទៅរកទីភ្លឺ គឺលះចោលអំពើអាក្រក់ បំពេញសេចក្ដីល្អ ។ សូមកុំរត់ចេញពីពន្លឺទៅកាន់ទីងងឹតវិញឡើយ គឺកុំលះសេចក្ដីល្អ ( **គុណធម៌** ) ចោល ទៅប្រព្រឹត្តអំពើបាប ។ ចូរចេញអំពីទីភ្លឺ ឆ្ពោះទៅកាន់ទីភ្លឺ ដោយយកជីវិតបច្ចុប្បន្ននេះ ទៅបម្រើ **គុណធម៌** គឺធ្វើសេចក្ដីល្អគ្រប់ពេលវេលា ព្រោះថា **ជីវិត** នេះមានតម្លៃ បានមកដោយអំណាចនៃបុណ្យកុសល ។ ដូច្នេះត្រូវព្យាយាមបំពេញបុណ្យកុសលជារឿយ ៗ ដើម្បីតម្កល់ទុកសម្រាប់ **ជីវិត** ឲ្យបានគ្រប់ ៗ ជាតិ កុំបីឃ្លាតក្លាយជាបការៈដទៃឡើយ ! ។

**ជីវិតកថា** ការពោលរៀបរាប់អំពីជីវិត សម្មតា សន្មតិថា ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

**ដោ**យវិរិយៈភាព គឺសេចក្ដីព្យាយាម រៀបរៀង សរសេរ ចាត់ចែង វាយពុម្ពជាអក្ខរៈ ព្យញ្ជនៈខេមរភាសា និងដោយចេតនាចិត្តជ្រះថ្លា នៃយើងខ្ញុំព្រះករុណាទាំងឡាយ ក្នុងការខ្វល់ខ្វាយបំពេញធម្មទាន សូមព្រះករុណាម្ចាស់គ្រប់ព្រះអង្គ ព្រមទាំងលោក-អ្នកអានទាំងអស់ បានប្រកបដោយបញ្ញាស្មារតីភ្លឺស្វាង

សន្សំបុណ្យកុសល សម្រេចមគ្គផលដល់ទីបំផុតទុក្ខ សមតាមសេចក្តីប្រាថ្នាទៅហោង ៕៚

# នាវាព្រះធម៌

*នាវាបួនប្រការ ផ្ទុកសត្តាឆ្ពោះដល់ត្រើយ*
*កុំស្មៀមឃើតយូរឡើយ ត្រៀមឲ្យហើយទាំងយប់ថ្ងៃ។*
*ទីមួយមាន* **សទ្ធា** *តាំងចិត្តានិងស្មារតី*
*មិនជឿទៅលើអ្វី ក្រៅឲ្យឃ្លាតចាកកម្មផល ។*
*ទីពីរមាន* **វិរិយៈ** *ព្យាយាមជាក់ពិតបានដល់*
*លះកាមញ៉ាំងកុសល តម្កល់ទុកឥតឲ្យខ្វះ ។*
*ទីបី* **អប្បមាទ** *ខំសង្វាតឆាប់រហ័ស*
*តាំងពីក្មេងដល់ចាស់ ព្យាយាមណាស់សម្អាតចិត្ត។*
*ទីបួនគឺ* **បញ្ញា** *យល់ហេតុការណ៍មិនងងឹត*
*ដឹងស្គាល់សភាពពិត ញ៉ាំងជីវិតបរិសុទ្ធ ។*
*នាវាបួនប្រការ ផ្ទុកសត្តាឆ្លងសមុទ្រ*
*អន្លង់ជ្រៅប្រាកដ រំលែងភ័យស្លុតផុតទុក្ខា ៕*

ដោយ ឧបាសក **ម៉ិញ សាវ៉ាន**

# សមាសភាពចូលរួម

១. ឧបាសិកា សិម ចាន់ធូរ៉ា

២. លោក ទ៉ាត សុគន្ធ

៣. លោក ទ៉ាត ភារា ( ទីទី )

៤. លោក ទ៉ាត ម៉ូលីវណ្ណ

៥. កញ្ញា ទ៉ាត ទារីយ៉ា



# ឯកសារពិគ្រោះ

១. **វចនានុក្រមខ្មែរ** ( ២០០៨ ) ស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ ;

២. បិដក **អភិធម្មបិដក គម្ពីរវិភង្គ បឋមភាគ** លេខ ៨០ ;

៣. **គម្ពីរព្រះអភិធម្ម** ;

៤. **ជរាសុត្តនិទ្ទេសទី ៦** (បិដក **ខុទ្ទកនិកាយ មហានិទ្ទេស បឋមភាគ** លេខ ៦៨) ;

៥. **ប្រជុំនិទានជាតក** ;

៦. បិដក **សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសមភាគ** លេខ ៦២ ;

៧. បិដក **សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ** លេខ ៦៣ ;

៨. បិដក **សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស បឋមភាគ** លេខ ៦៧ ;

៩. បិដក **សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស ទុតិយភាគ** លេខ ៦៨ ;

១០. **អាទិត្តបរិយាយសូត្ត** ។

# នាមពុទ្ធបរិស័ទ

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យ
## ដើម្បីបោះពុម្ពសៀវភៅជាធម្មទាន ៖

| | | | |
|---|---|---|---|
| . ព្រះភិក្ខុ | **ធឹង ធីម** | . អ្នកស្រី | **សិម ចាន់ធូរ៉ា** |
| . ព្រះភិក្ខុ | **ហ៊ុន ឃួយ** | . យុវជន | **សិម រតនា** |
| . ព្រះភិក្ខុ | **កែវ សម៉ននឈាង** | . លោក | **តាយ យ៉ន** |
| . ព្រះភិក្ខុ | **ប៉ាង សែន** | . លោក | **សិម វី** |
| . ពុទ្ធបរិស័ទ | **វង្ស តក្របូរីយ៍** | . អ្នកស្រី | **សិម ចាន់នី** |
| . ឧបាសិកា | **ឡុត យឿម** | . អ្នកស្រី | **សិម ចិន្តា** |
| . ឧបាសិកា | **តែ ឆឹងអ៊ី** | . លោក | **ខៃ ឃុនហៃ** |
| . លោកយាយ | **ចាន ផាន់** | . អ្នកស្រី | **សិម ចាន់ធូរ៉ាណា** |
| . លោកយាយ | **ដាន យុតហ្គួ** | . យុវជន | **សិម រីឆា** |
| . លោកយាយ | **ត្វូ ស៊ីវលន់** | . លោក | **សិម សុមេរ៉ា** |
| . លោកតា | **ម៉ុញ្ញ មឿន** | . អ្នកស្រី | **ជា ពិសី** |
| . លោកយាយ | **ស៊ុត គិមមាន** | . កុមារា | **សិម ប៊ីលី** |
| . លោក | **សិម សារឿន** | . កុមារា | **សិម លីណូ** |
| . អ្នកស្រី | **ចាន់ ដារី** | . អ្នកស្រី | **សិម ទេវី** |
| . លោក | **ពេជ្រ សារឿម** | . អ្នកស្រី | **ស៊ុំ យ៉ាង** |
| . អ្នកស្រី | **សិម ចាន់ដារ៉ា** | . អ្នកស្រី | **ឈាង វ៉ាន់នី** |
| . លោក | **សិម សទ្ធា** | . លោក | **ជួប បុរីវុទ្ធ** |
| . អ្នកស្រី | **ពេជ្រ រីលីន** | . អ្នកស្រី | **សួស ចាន់សីម៉ា** |

| | | | | | |
|---|---|---|---|---|---|
| . លោក | មួង សុធា | | . អ្នកស្រី | លី សុភី | |
| . អ្នកស្រី | ម៉ែត ផាន់នី | | . លោក | ភិច នូភាន | |
| . អ្នកស្រី | តាយ ភិរម្យ | | . អ្នកស្រី | សេម ស៊ីភាធូក | |
| . យុវនារី | តាយ តាវី | | . លោក | អៀម រឿន | |
| . លោក | លី ទីមុត | | . អ្នកស្រី | ភី រិម | |
| . អ្នកស្រី | សិម ចាន់ណារី | | . អ្នកស្រី | ផាត់ សាវឡា | |
| . លោក | សួស ប៉ុណ្ណាវុធ | | . លោក | ផាត់ សុភឡិត | |
| . អ្នកស្រី | សិម វិច្ឆិកា | | . អ្នកស្រី | ឆៃ សុភិន | |
| . កុមារា | សិម ឡេអូ | | . លោក | សក្តិ ផល្លា | |
| . កុមារា | សិម ប៊ីលីយ៉ាម | | . អ្នកស្រី | ចាន់ សុម៉ាលី | |
| . លោក | ចៅ សុខ | | . យុវជន | ផល្លា ពិសិដ្ឋ | |
| . អ្នកស្រី | ឈឹម សុនី | | . លោក | យន់ សាវុធ | |
| . លោក | ទូច សាន | | . អ្នកស្រី | ឈាម នី | |
| . អ្នកស្រី | ស៊ុយ សាម៉ុន | | . អ្នកស្រី | ហ៊ុន ហ៊ាង | |
| . លោក | នុន ស្បៃ | | . លោក | ពិន ឃឹមខុន | |
| . អ្នកស្រី | នុន ណាន់ថា | | . លោក | ហេង ចាន់ថា | |
| . លោក | លី សាម៉ន | | . អ្នកស្រី | ប្រេង ហូច | |
| . អ្នកស្រី | ញឹក ស្រីភាព | | . អ្នកស្រី | អ៊ុំ តឿន | |
| . លោក | អ៊ួង ហ៊ាង | | . លោក | ឃុំ ម៉ែន | |
| . អ្នកស្រី | វ៉ែន យិម | | . អ្នកស្រី | គ្លឹម ហ៊ុត | |
| . លោក | លី គាង | | . លោក | ឃុំ មាន | |
| . អ្នកស្រី | អ៊ុក គិមហ៊ាង | | . អ្នកស្រី | សួន ស៊ីសុវណ្ណា | |
| . លោក | នូ ស៊ីយឿន | | . លោក | ខួន សុវណ្ណា | |

| | | | |
|---|---|---|---|
| . អ្នកស្រី | **ឃុំ ហែម** | . លោក | **ទិម សៀប** |
| . លោក | **ត្វូ ម៉េងហុង** | . អ្នកស្រី | **អ៊ឹម វ៉ាន** |
| . អ្នកស្រី | **ឱក គិមហ៊ាង** | . អ្នកស្រី | **ទូច ជីវសេង** |
| . យុវជន | **ត្វូ គិតឡាយ** | . អ្នកស្រី | **លិម មួយគិច** |
| . លោក | **ហួត គិមគាវ** | . អ្នកស្រី | **ហាន គិម** |
| . អ្នកស្រី | **គិវ ស៊ីនួន** | . លោក | **គិម ដេត** |
| . លោក | **ឱប ច័ន្ទា** | . អ្នកស្រី | **គិម ហាន** |
| . អ្នកស្រី | **លៀម សុភាព** | . យុវជន | **ប្រាក់ ចាន់តារ៉ា** |
| . លោក | **សេក សារុន** | . យុវនារី | **ប្រាក់ ចាន់ដារី** |
| . អ្នកស្រី | **ម៉ៀច ស៊ីថុល** | . អ្នកស្រី | **វ៉ាន់ ហាន** |
| . លោក | **នូ សារឿន** | . អ្នកស្រី | **គិន សា** |
| . លោក | **ជួន កែវ** | . លោក | **គិន ឈាង** |
| . អ្នកស្រី | **ហាច់ សំអឿន** | . លោក | **កង កុសល** |
| . លោក | **អែម ណាវី** | . អ្នកស្រី | **មួយ** |
| . អ្នកស្រី | **អាត សំណាង** | . លោក | **ម៉ុញ វ៉ាន់ថា** |
| . លោក | **អ៊ុំ ហំ** | . អ្នកស្រី | **ជីវ សុផាន់នី** |
| . អ្នកស្រី | **ទិម ណាវី** | . លោក | **ទីន រតនៈ** |
| . លោក | **ឌី ស៊ុនហេង** | . អ្នកស្រី | **កេង សោភា** |
| . អ្នកស្រី | **អាង ពៅ** | . អ្នកស្រី | **ម៉ៀច វណ្ណា** |
| . លោក | **ឌិន ចាន់ដារ៉ា** | . លោក | **វ៉ាត តារា(ទីទី)** |
| . អ្នកស្រី | **សេង វ៉ាន់នី** | . លោក | **វ៉ាត ម៉ូលីវណ្ណា** |
| . លោក | **ខួន សារុន** | . កញ្ញា | **វ៉ាត ធារីយ៉ា** |
| . អ្នកស្រី | **ហួ ចាន់ណា** | . ឧបាសិកា | **ជា ស្រីយុទ្ធថូ** |

| | |
|---|---|
| . ឧបាសក **អ៊ូ សុផុន** | . អ្នកស្រី **សូហ៊ី** |
| . ឧបាសិកា **អ៊ូ សុខន** | . ឧបាសក **ខាយ ម៉ុនគីម** |
| . ឧបាសក **ផាន សុផុន** | . ឧបាសិកា **ស សុខឆេង** |
| . ឧបាសិកា **ឈឿង យ៉ាវ** | . យុវជន **វាលសុន សខាយ** |
| . លោក **ផាន សុផៃរតនៈ** | . ឧបាសក **ម៉ម លន់** |
| . លោកស្រី **ផាន ម៉ារីសុរិយា** | . ឧបាសិកា **ផ្លែង ជឿន** |
| . ឧបាសក **ខាំផាន់ ម៉ាលីថៃ** | . ឧបាសក **អ៊ឹម សាម៉ៃ** |
| . ឧបាសិកា **ម៉ា ថងអន** | . ឧបាសិកា **ភូវ នឿន** |
| . ឧបាសិកា **ទេព ឆុង** | . ឧបាសក **ផល់ ផាន់** |
| . ឧបាសិកា **អ៊ាប គិមជា** | . ឧបាសិកា **យូ ហ៊ី** |
| . ឧបាសិកា **ស៊ុយ ជាមួយ** | . កញ្ញា **ផល់ សុខឌី** |
| . ឧបាសិកា **អ៊ុង ឆាយហ៊ុន** | . លោក **ជីវ សុខាល័យ** |
| . លោក **មាស ឧត្តរោ** | . អ្នកស្រី **លៀម ស៊ីណាត** |
| . អ្នកស្រី **ឌិន ចន្ថា** | . លោក **ថង ប៉ៃ** |
| . ឧបាសិកា **តែ ឆឹងលាត** | . អ្នកស្រី **សាលួន ស៊ីសុវណ្ណា** |
| . ឧបាសក **អ៊ឹម កុសល** | . លោក **យូ ផាន់ឡេន** |
| . លោក **ថាវរី** | . អ្នកស្រី **សិម លក្ខិណា** |
| . យុវជន **ភូ គិតលី** | . អ្នកស្រី **យឹម ច័ន្ទឌី** |
| . យុវជន **ភូ គិតអាឡិចសង់ទ្រឹះ** | . លោក **សួន ច័ន្ទវេហា** |
| . កញ្ញា **ភូ សុនដារីស** | . លោក **ម៉ុនច័ន្ទ ហ្វ្រេដេរីក** |
| . លោក **ចៅ ទ៉ាន់** | . លោក **ម៉ុនច័ន្ទ ស្ទីវិន** |
| . អ្នកស្រី **គុយ ឃួង** | . ឧបាសិកា **ជា នាង** |

. លោក **គិម ទិបុល**
. លោក **ខ្វាន់ ប៊ុណ្ណា**
. អ្នកស្រី **គិម សិរីសោភា**
. ឧបាសក **ប៉ែន សារឿន**
. ឧបាសិកា **ឡាំ ឈួម**
. អ្នកស្រី **ស៊ុំ សោភ័ណ្ឌ**
. លោក **ឡាំ ស្ទីស**

*សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅនេះ

បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ

និងបានឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួង

កុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនា** !!!

# រក្ខេយ្យ អត្តនោ សាធុំ
# លវណំ លោណតំ យថា

## ត្រូវរក្សាសេចក្ដីល្អ របស់ខ្លួនទុក
## ដូចជាអំបិល តែងរក្សានូវរសជាតិប្រៃ





## ពាក្យកាព្យ

ត្រូវខំសន្សំសេចក្ដីល្អ ជាពូជបន្តសំរាប់ជីវិត
ព្យាយាមបដិបត្តិព្រះធម៌ពិត នោះទើបជីវិតមានតម្លៃ ។
ដូចជាអំបិលតែងរក្សា រាល់ពេលវេលារសជាតិប្រៃ
នៅក្នុងសម្លទោះយប់ថ្ងៃ រសប្រៃមិនសាបសូន្យសោះឡើយ ។

**សម្រាប់ជាធម្មទាន**